# ព្រះនាងកំពូលសាំញ៉ាំ

បង្រ្គាបពួកក្បត់ក៏រលំណាស់ទៅហើយ នៅមកខាតពេលបង្រ្គាបប្រពន្ធកំពូលឆ្លាសទៀត
តែចង់ប្រើកម្លាំងក៏មិនបាន ខ្លាចក្បាលរបុតពីស្មា
ព្រោះនាងជាប្អូនស្រីបណ្ដូលចិត្តរបស់ព្រះអង្គម្ចាស់ ប្រកាន់ថាខ្លួនឯងស្អាតគឺត្រូវតែក្រទើ
ព្រឹកក្រទើ ថ្ងៃក្រទើ ល្ងាចក្រទើ រឿងច្រើនសាំញ៉ាំរញ៉ាំរញ៉ូវលេខមួយ កាបូបត្រូវតែម៉ាកល្បី
ម្ហូបអាហារការហូបចុកត្រូវតែជាថ្លៃដៃចុងភៅលំដាប់លោក ស្វាមីត្រូវត្រឡប់មកផ្ទះទៀងពេល
និងត្រូវតែឈប់ដើរលេងផឹកស្រា ជក់បារី។
"រ៉ៃមសៀ...បងសម្លាញ់"
"កើតអី ប្រាប់ម៉ោមើល"
ខ្លារិហ្សា យំអណ្ដឹតអណ្ដក លើកដៃយឺតៗ ទើបត្រូវ រ៉ៃមសៀ ស្រវាចាប់
ពិនិត្យមើលថានាងមានរបួសត្រង់ណាដែរទេ អាចមានសត្វល្អិតទិច ឬខាំនាងក៏ថាបាន។
"ក្រចក...រហែក"
"ថាម៉េច ?"
"ប្រាប់ថាក្រចករហែក មិនឮទេអី ម៉ុតនេះទើបតែធ្វើថ្មីៗ កាលពីម្សិល
អង្គុយធ្វើចុកខ្នងចុកចង្កេះ ទម្រាំតែរួច មើលចុះ អស់ស្អាតរលីង"
"ក្រចករហែក មិនមែនប្ដីស្លាប់ទេ ស្រែកឡូឡាធ្វើអី ថ្លង់"
"ប្ដីស្លាប់ យំធ្វើអី គេមានតែសើច"
"ខ្លារិហ្សា!"
"មិនបាច់គ្រហឹម ជាពិសេសប្ដីចិត្តអាក្រក់មានឈ្មោះ រ៉ៃមសៀ សមតែស្លាប់"
"បើបងស្លាប់ បានអ្នកណារកលុយចិញ្ចឹមអូន"
"ទុកមរតកឲ្យច្រើនៗម៉ោ"
"ទុកឲ្យច្រើន គង់តែបំផ្លាញអស់ក្នុងពេលបីខែទេ"
"ចិញ្ចឹមប្រពន្ធប៉ុណ្ណឹង យំពីរអ្វី ប្រពន្ធម្នាក់ចិញ្ចឹមមិនរស់ អន់!"




Ls_558


Come to join us
www.facebook.com/yuveakvey
Tel:010687767


ឈុត ធ្លាក់អន្លង់ស្នេហ៍


រក្សាសិទ្ធិ ហាមថតចំលងគ្រប់រូបភាព


ព្រះនាងកំពូលសាំញ៉ាំ

S@rikA




Scanned by CamScanner

# ១

## លោភភៃនាស

រ៉េមសៀ ដាវ៉ៃហ៊ីណេស កំពុងមានកំហឹង តែប្រឹងគ្រប់គ្រងវា ខណៈនោះ កំមានសំឡេងគ្រហឹមបន្លឺចេញពីបបូរមាត់ក្រាស់បែបបុរសដែរ។ រូបរាងមាំមួន សម្បុរស្រគាំ កំពុងញ័រទទ្រើត តែគេត្រូវគ្រប់គ្រងវា យ៉ាងហោចណាស់គឺ ទាល់តែចូលទៅដល់បន្ទប់ទទួលភ្ញៀវផ្ទាល់ព្រះអង្គ...ព្រះអង្គម្ចាស់ ខាឡូម៉ាន់ ម៉ាលខៃសេនតេ ម្ចាស់បញ្ហា ដែលធ្វើឲ្យភ្លើងទោសៈរបស់គេឆាបឆេះប្រាសាទ ត្រៃភ្រៃយ។

រ៉េមសៀ ទើបធ្វើដំណើរមកពីក្រុង សេនដីវីក មានភាពវឹកវរកើតឡើង នៅទីនោះ ដោយសាក់ខាវៀ មិនទាន់មានឈ្មោះជាប្រទេសមានសុខសន្តិភាពទេ ព្រោះនយោបាយផ្ទៃក្នុងប្រទេសនៅតែក្តៅគគុក។

សាក់ខាវៀ ជាប្រទេសដែលទើបតែមានសេរីភាពពីក្រុមអំណាចចាស់ ដែលគ្រប់គ្រងប្រទេសដោយភាពរាជានិយម តាបសង្កត់ជិះជាន់ប្រជាជននៅក្រោមអំណាច ធ្វើឲ្យកំហឹងផ្ទុះពីប្រជាជនគ្រប់ស្រទាប់វណ្ណៈ។ រាជវង្សានុវង្ស សម្ព័ន្ធមិត្ត ដែលសហការគ្នាជាសម្ងាត់ នៅក្រោមការដឹកនាំរបស់ ខាឡូម៉ាន់ ម៉ាលខៃសេនតេ សម្ងំសន្សំកងកម្លាំង រឹបអូសសន្សឹមៗយកអំណាចពីអ្នកគ្រប់គ្រងប្រទេសដែលស្អាបនាខ្លួនឯង ដោយមិនស្របច្បាប់រហូតដល់អាចចូលទៅកៀកប្រមុខប្រទេស ដែលវង្វេងវង្វាន់នឹងអំណាចនិងសោយសុខលើគំនរមាសប្រាក់ដែលប្លន់ពីរាជវង្ស ម៉ាលខៃសេនតេ។

ឧត្តមសេនីយដ៏និតម្នាក់ក្នុងចំណោមជំនិតរបស់ ខាឡូម៉ាន់ ដែលគោរពហាក់ដូចបងប្រុសបង្កើតគឺ រ៉េមសៀ ដាវ៉ៃហ៊ីណេស។

ហ៊ឺ! គេជួយ ខាឡូម៉ាន់ រឹបអូសអំណាចមកឲ្យរាជវង្ស ម៉ាលខៃសេនតេវិញ គាំទ្រឲ្យ ខាឡូម៉ាន់ ឡើងធ្វើជាប្រមុខនៃ សាក់ខាវៀ ក្រៅពីនេះគេក៏រវល់ឡើងវៃលក្បួងនឹងក្រុមដែលប្រឆាំងនឹងអំណាចរបស់ ខាឡូម៉ាន់ ហើយមិនមែនមានតែគេម្នាក់ សម្ព័ន្ធមិត្តក៏មានតួនាទីជួយបង្ក្រាប ប៉ុន្តែ ខាឡូម៉ាន់ អាចគិតថាការមានពេលទ្មេចភ្នែកមួយថ្ងៃពីរបីម៉ោងរបស់គេ វានៅច្រើនពេក ទើបបោះបញ្ហាមកដាក់លើស្មារបស់គេទៀត ដែលបញ្ហាមួយនេះជាបញ្ហាធំបំផុតនៅក្នុងជីវិតរបស់គេ។

បុរសមានឧក្រអាញ ធ្វើមុខក្រមូវ សាច់ដុំធំៗឡើងរឹងកំព្រឹស។ ទោះពាក់អាវយឺត តែបិទបាំងភាពមាំមួយមិនជិត ហើយបើមិនមែនជា រ៉េមសៀ ដាវ៉ៃហ៊ីណេស ការពាក់អាវយឺត ខោសាច់ក្រណាត់ក្រាស់ ស្បែកជើងប៉ូតស្បែក និងសភាពស្រមេកស្រមកបែបនេះ នឹងត្រូវឃាត់ខ្លួនតាំងពីនៅមុខទ្វារប្រាសាទវីដូសា ម្ល៉េះ ប៉ុន្តែ រ៉េមសៀ ជាបុគ្គលពិសេស សូម្បីតែទាហានសាក់ខាវៀទូទាំងប្រទេស ក៏គោរពនិងស្តាប់បញ្ជាគេបន្ទាប់ពី ខាឡូម៉ាន់ ឬ ព្រះអង្គម្ចាស់ខាឡូម៉ាន់ ម៉ាលខៃសេនតេ ប្រមុខនៃសាក់ខាវៀ ដែរ។



"អម្ចាស់...អម្ចាស់..."

វែមសៀ ដើរតាមអ្នកបម្រើចូលទៅក្នុងបន្ទប់ទទួលភ្ញៀវពិសេស។

ខាឡូម៉ាន់ បក់ដៃឲ្យអ្នកបម្រើឲ្យចេញពីបន្ទប់ មិនចាំបាច់មានការរាយការណ៍ជាមុនឲ្យខាតពេលវេលា ពេលគេដឹងពីគោលបំណងនៃការមកទីនេះរបស់ វែមសៀ កែវភ្នែកពណ៌ខៀវសចាស់របស់បុរសខែងវែងសមជាអ្នកចម្បាំងនៃ សាក់ខាវៀ មានអណ្ដាតភ្លើង តែក៏ព្រមឱនក្បាលដាក់ ខាឡូម៉ាន់ ដើម្បីបង្ហាញពីការគោរព។

ទោះខឹងកម្រិតណា ខាឡូម៉ាន់ ជាបុគ្គលដែលគេត្រូវគោរព មិនមែនដោយតួនាទី វែមសៀ ប្រគល់ភាពស្មោះត្រង់ភក្ដីឲ្យ ខាឡូម៉ាន់។ គេជាមនុស្សចិត្តដាច់ និងម៉ឺងម៉ាត់ តែបើបានប្រគល់ឲ្យហើយ លំបាកណាស់ដែលគេទាមទារយកវិញ។

ភាពស្មោះត្រង់ភក្ដី ក៏ជារឿងមួយទៀត តែពេលនេះកណ្ដាប់ដៃរបស់គេកំពុងតែចង់ដាល់មុខរបស់ ខាឡូម៉ាន់ ក៏ជារឿងមួយទៀតដូចគ្នា។

ខាឡូម៉ាន់ ងារដៃទៅរកកៅអីប្រណិតនៅក្នុងបន្ទប់ទទួលភ្ញៀវ ចំណង់ចំណូលចិត្តរបស់រតីតអ្នកគ្រប់គ្រងជារឿងដែល ខាឡូម៉ាន់ ត្រូវការកែប្រែ។

វាប្រណិតក៏ពិតមែន តែបែរជាគ្មានរសនិយមដោយតម្លៃថ្លៃ តែរញ៉េរញ៉ៃទើសទែង។ ខាឡូម៉ាន់ កែប្រែប្រាសាទវើងសាបន្តិចម្ដងៗ ព្រោះមានរឿងចាំបាច់ជាងការកែប្រែប្រាសាទទៅទៀតគឺសេដ្ឋកិច្ចប្រទេសជាតិ ដែលពាក់ព័ន្ធនឹងជីវិតរបស់ប្រជាជន។

"សុខសប្បាយទេ វែមសៀ ?"



"ត្រូវសុខសប្បាយ ?" វែមសៀ ត្បុកសួរដោយភាពតំរោះតំរើយ។

ខាឡូម៉ាន់ មិនបាននៅក្នុងបន្ទប់ទទួលភ្ញៀវម្នាក់ឯង នៅមានបុរសម្នាក់ទៀត និងស្នាមញញឹមនៅតែមមាត់របស់អាម្នាក់នោះក៏ព្រោះទោសៈរបស់គេដែរ។

"មួម៉ៅ ម៉ោពីណា ឯកឧត្ដម"

"សីតីរ៉ាស ច្បាស់ហើយថាឯងមិនដឹងមូលហេតុ"

"ខ្ញុំឬហ៊ានមើលចិត្តឯងឲ្យធ្លុះ"

**សីតីរ៉ាស វើឡានិមៀ** មានអាយុតិចជាង វែមសៀ បីឆ្នាំ តែពួកគេរាប់អានគ្នាជាមិត្តរួមឧត្ដមគតិ និងមិត្តរួមសមរភូមិ។ សីតីរ៉ាស ជាអ្នកចម្បាំងដូច វែមសៀ ទោះបុគ្គលិកលក្ខណៈបែបបុរសព្រោះខ្ជិររបស់គេ ដូចមនុស្សរស់នៅស្រណុកសុខស្រួលឡូយឆាយរាល់ថ្ងៃ តែសមត្ថភាពនិងបញ្ញាស្មារតីមុតដូចមុខដាវមុខកាំបិត។

សីតីរ៉ាស ជាបុរសដែលមានភាពឆ្លៀវឆ្លាតនិងឈ្លាសវៃ សុំត្រឹមបក្សពួករបស់ខ្លួនបានផលប្រយោជន៍ គេនឹងមិនខ្វល់ទេថាវាមានមនុស្សធម៌ ឬអមនុស្សធម៌។ ច្បាប់របស់ សីតីរ៉ាស មានត្រឹមតែមិនធ្វើបាបកូនក្មេង ស្ត្រី និងចាស់ជរា ហើយចាស់ជរាគឺត្រូវតែមានច្បាប់ពិសេសថា ជាចាស់ជរាទន់ជ្រាយ បើជាចាស់ជរា តែកាចសាហាវ គេក៏មិនទុក ក្រៅពីនេះគេគ្មានបម្រាមអ្វីទាំងអស់នៅក្នុងការយកឈ្នះបក្សប្រឆាំង។



"សាកមើលធ្លុះទៅ"



Scanned by CamScanner

រ៉េមសៀ ខាំធ្មេញនិយាយដាក់ ស៊ីតីរ៉ាស ដោយមិនព្រមអង្គុយលើកៅអី មានចេតនាឈរចំទែង និងមើលទៅ ខាឡូម៉ាន់ ដែលនៅតែធ្វើមុខស្លូត។

"ឯងម៉ោអរគុណអម្ចាស់"

ស៊ីតីរ៉ាស ឃើញ រ៉េមសៀ ខាំថ្គាមណែន ហើយក៏អត់គិតមិនបានថា អាចខាំបែកថ្គាមក៏ថាបានព្រោះអំណាចទោសៈ។

"ខាឡូម៉ាន់ យើងត្រូវចរចាគ្នា"

"អញ្ជើញ រ៉េមសៀ"

ពេល ខាឡូម៉ាន់ អនុញ្ញាត រ៉េមសៀ ក៏ប្រសព្វភ្នែកជាមួយ ហើយដក ដង្ហើមធំ ដើរទៅដាក់បង្គុយលើកៅអី។

"ខ្ញុំទទួលបានបញ្ជាបន្ទាន់"

"បញ្ជាមិនពិស្ដារ"

ទោសៈរបស់ រ៉េមសៀ ក្ដៅគគុក ដែល ខាឡូម៉ាន់ ដឹងច្បាស់។ គេមិន ពេញចិត្តនឹងរឿងនេះជាខ្លាំង ហើយគេត្រូវការប្រឆាំង មិនព្រមធ្វើតាមបញ្ជា។

"អារអម្ចាស់! ខ្ញុំមានគុណសម្បត្តិ ឬ គុណវិបត្តិ ហេតុអីខ្ញុំត្រូវទទួល ព្រះនាងមេបញ្ជាជាប្រពន្ធ នេះឲ្យរង្វាន់ ឬដាក់ទោស!"

បញ្ជាបន្ទាន់របស់ ខាឡូម៉ាន់ គឺការឲ្យរង្វាន់ជាការតបស្នងគុណសម្បត្តិ របស់ រ៉េមសៀ បន្ទាប់ពីហត់នឿយ ប្រកៀកស្មានឹង ខាឡូម៉ាន់ តែវត់នោះទេ! អារអម្ចាស់យោរយៅនោះមិនត្រូវការឲ្យគេសុខសប្បាយ មានតែឲ្យហត់នឿយ លើសដើម ដោយការប្រគល់រង្វាន់ឲ្យគេជាប្អូនស្រីម្ដាយទីទៃ...ព្រះនាង **ការ៉ុន**



ខ្លារីហ្សា ចាង ម៉ាលខៃសេនតេ។

ស្រីស្អាត ឈ្មោះវែងវាស់ម៉ែត្រ ដែល រ៉េមសៀ មិនចង់យកចិត្តចងចាំ ក្រៅពីចាំនាងក្នុងនាម ខ្លារីហ្សា ម៉ាលខៃសេនតេ។

ព្រះនាងក្រទើម្នាក់នោះ ជាមនុស្សស្រី ដែលគេមិនស្រឡាញ់ចូលចិត្ត ព្រោះស្រីកំណាន់ទាំងអម្បាលម៉ានរបស់គេ ត្រូវតែសុភាពរាបសារ តែបើមិន សុភាពមែនទែន ក៏ត្រូវធ្វើពុតដែរ ហាមព្រហើនមកវាយស្មើគេដាច់ខាត ប៉ុន្តែ ព្រះនាង ខ្លារីហ្សា មិនស្រដៀងនឹងមនុស្សស្រីដូចរៀបរាប់។ នាងផ្ទើងផ្ទៃ មាន អំនួត ទំនើងផុតលេខ។ រឿងតែមួយគត់ដែលគេអាចទទួលយកបានគឺ សម្រស់ ដែលមាននាងជាម្ចាស់ ព្រះអនុជត្រីរបស់ ខាឡូម៉ាន់ ស្អាតគ្មានអ្វីឲ្យទាស់ ស្អាតគ្មានគូប្រៀប ប៉ុន្តែពេលនិយាយពីចរិតឆ្មាសឆ្មើមរបស់នាង គេគ្មានចិត្ត បេតិនាងអីមួយម៉ាត់។

"សុភាពបន្តិច រ៉េមសៀ នោះអម្ចាស់" ស៊ីតីរ៉ាស ដាស់តឿន។

រ៉េមសៀ ងាកទៅសម្លឹងអ្នកដាស់តឿន ហើយមើលទៅម្ចាស់ប្រាសាទ ដែលទោះជាព្រះអង្គម្ចាស់ ឬទេវតា ពេលនេះគេលែងខ្វល់ហើយ។

"ប្រហារខ្ញុំ ខ្ញុំសុខចិត្តងាប់!"

គេមានការងារច្រើនណាស់ ខាឡូម៉ាន់ ដឹងច្បាស់ ហើយដែលគេធ្វើការ ហត់នឿយសឹងតែក្អួតឈាម ដើម្បីភាពរឹងមាំនៃអំណាចរបស់ ខាឡូម៉ាន់។

"ប្រហារឯង ហើយម្នាក់ណារៀបការនឹង ខ្លារីហ្សា"

"ស៊ុត!" គេជញ្ជក់មាត់។ ព្រះនាងកំពូលសម្រស់នោះប្រហែលគ្មាន





Scanned by CamScanner

បុរសណាហ៊ានចូលស្ដីដណ្ដឹងយកធ្វើជាភរិយា ទើបព្រះអង្គម្ចាស់ យកមកញាត់ញៀតឲ្យគេ។

"ព្រះនាងមេបញ្ញា នោះគ្មានអ្នកណាយកមែនទេ"

"នេះជាការសួនាំពីសុភាពនារី ដែលគ្រោតគ្រាតណាស់"

"បិទមាត់ សិតិរ៉ាស! មិនអីចឹង ខ្ញុំនឹងញ៉ុកមាត់ឯងដោយកណ្ដាប់ដៃរបស់ខ្ញុំ"

សិតិរ៉ាស មិនគិតថា រ៉ែមសៀ និយាយលេង អារម្មណ៍របស់អាម្សៀនេះកំពុងពុះ និងការបានដាល់ដោយកណ្ដាប់ដៃអាចជាការកម្សាយអារម្មណ៍របស់ រ៉ែមសៀ ដែលគេសុំបាយៗ។

"ខ្លារិហ្សា ស្អាតនិងគួរឲ្យស្រឡាញ់ណាស់"

"បានហើយ! ឈប់និយាយពាក្យដែលធ្វើឲ្យខ្ញុំចង់ក្អួតទៅ ខ្លារិហ្សាស្អាត ខ្ញុំព្រមទទួល តែគួរឲ្យស្រឡាញ់នេះមិនមែនទេ ចរិតរបស់នាង មិនមែនថាខ្ញុំមិនដឹង ប្អូនស្រីរបស់ឯងជាបិសាចនោះឯង រកមនុស្សបង្ក្រាបមិនបានអីចេះចុះ ខាឡូម៉ាន់ ឯងចង់បានខ្ញុំជាប្អូនថ្លៃ រៀបការដើម្បីពង្រឹងអំណាចបារមីស្អីក៏តាមតែឯងទៅ ខ្ញុំអូខេ តែសុំជាប្អូនស្រីផ្សេងបានទេ មិនយកនាងហ្នឹង"

"ខ្ញុំចេញបញ្ជានិងបោះត្រារួចរាល់ហើយ ឯងក៏ដឹង រ៉ែមសៀ ថាវាមិនអាចកែប្រែអីបានទេ"

ម្ដងទៀតហើយដែល រ៉ែមសៀ ប្រើពាក្យដោយមិនក្រែងចិត្ត គេជាអ្នកមានគុណរបស់ ខាឡូម៉ាន់ បើមិនច្រើនក៏មិនតិចដែរ ព្រោះគេជាកម្លាំងសំខាន់



ដែលធ្វើឲ្យព្រះអង្គម្ចាស់បានគ្រប់គ្រងអំណាចប្រទេស សាក់ខាវៀ ហើយនេះគឺជារង្វាន់អីចឹងឬ សុខចិត្តឲ្យ ខាឡូម៉ាន់ អូសគេទៅកាត់ក្បាលប្រកាសនៅមុខរាជធានី វាល្អជាងការប្រើវិធីបែបនេះដាក់ទណ្ឌកម្មគេ។

"ហេតុអីខ្ញុំមិនស្លាប់ពេលច្បាំងរឹបអូសអំណាច ហ៎ា!"

"រ៉ែមសៀ សាក់ខាវៀ ស្ថិតនៅក្នុងស្ថានការណ៍ដែលត្រូវកែប្រែច្រើនទៀត ភាពតានតឹងដែលកើតឡើងគួរបានបន្ធូរបន្ថយខ្លះដោយពិធីរីករាយ"

"ពិធីមង្គលការរបស់ខ្ញុំ ?"

"ជារឿងគួរឲ្យរីករាយ"

"សួរខ្ញុំហើយនៅ"

"ខ្ញុំដឹងថាឯងត្រូវតែពេញចិត្តធ្វើដើម្បី សាក់ខាវៀ"

"ទ្រីស្ដិស្ដីហ៎ា! ម៉េចក៏ឯងមិនរៀបខ្លួនឯង ខាឡូម៉ាន់"

"រ៉ែមសៀ កូនក្រមុំរបស់ខ្ញុំ នឹងក្លាយជាផ្នែកមួយនៃអំណាចគ្រប់គ្រងរបស់ សាក់ខាវៀ ក្នុងស្ថានការណ៍បែបនេះ ខ្ញុំរើសអ្នកណាបាន"

"ហ៊ឺ!" រ៉ែមសៀ គ្រហឹមនៅដើម.ក ក្នុងស្ថានការណ៍បែបនេះរើសអ្នកណាបានអីចឹងឬ គេមើលឃើញម្នាក់សក្តិសម តែ ខាឡូម៉ាន់ មានចេតនាមើលមិនឃើញ។

"ការរៀបការរបស់ឯងជាមួយ ខ្លារិហ្សា ជារឿងសំខាន់ណាស់ វាជាការប្រកាសថាឯងនៅតែស្មោះត្រង់ចំពោះខ្ញុំ ហើយភាពស្មោះត្រង់នេះនៅតែគង់វង្សយូរអង្វែង ព្រោះយើងមានទំនាក់ទំនងគ្នាកាន់តែស្អិតល្មួត តាមរយៈចំណង



រវាងឯងនិង ខ្លារិហ្សា ប្រជាជនត្រូវការទំនុកចិត្ត"

"បើយើងបែកខ្ញែកគ្នា យើងមិនចាំបាច់ច្បាំងប្រកៀកស្មាគ្នាប្រជុយស្លាប់រស់ជាមួយគ្នាដែរ ខាឡូម៉ាន់"

"តែប្រជាជនមិនដឹងរឿងនេះ"

"ហេតុអីជា ខ្លារិហ្សា ?"

"នាងជាប្អូនស្រីដែលស្អាតជាងគេ សម្រស់របស់នាងលេចធ្លោ គ្មានគូប្រៀប"

"ថែមទាំងមានចរិតអន់គ្មានគូប្រៀបដែរ" វៃមសៀ ត្បកលឿនដូចព្យុះ។

ព្រោះ ខ្លារិហ្សា ជាប្អូនស្រីដែលកំព្រាទាំងឪពុកទាំងម្តាយ ទើប ខាឡូម៉ាន់ ទំយើជាពិសេស។ ម្តាយជនជាតិអាស៊ីរបស់ ខ្លារិហ្សា ជាស្ត្រីដែលឪពុករបស់ ខាឡូម៉ាន់ មានចិត្តស្រឡាញ់ ដោយកាលនោះឪពុករបស់ ខាឡូម៉ាន់ មានព្រះជាយាចំនួនបួននាក់រួចទៅហើយ។

ទោះប្រាសចាកអំណាច តែសមាជិករាជវង្ស ម៉ាលខៃសេនតេ នៅតែរស់នៅបែបរាជវង្ស សម្បូរទ្រព្យធន ដោយជំនួញនៅបរទេស ទើបការលួចចេញពីប្រទេស សាក់ខាវៀ មិនធ្វើឲ្យពួកគេលំបាក។

ម្តាយរបស់ ខ្លារិហ្សា ជាភរិយាទីប្រាំ ដែលស្រឡាំងកាំងចំពោះការពិតនៃរឿងនេះមែនទែន។ ទោះជាភរិយាដែលឪពុករបស់ ខាឡូម៉ាន់ ស្រឡាញ់ជាងគេក៏ដោយ ប៉ុន្តែស្នេហានោះបានបំផ្លាញនាង។ ចាង ការអុន ទ្រាំនឹងការឈឺចាប់បេះដូងខ្ទេចខ្ទាំ ព្រោះទទួលយកមិនបាននឹងការធ្វើជាភរិយាទីប្រាំរបស់ស្វាមី។



ការអុន ត្រាំត្រា អត់ធ្មត់ បីបាច់ ខ្លារិហ្សា ដល់អាយុប្រាំឆ្នាំក៏ធ្លាក់ខ្លួនឈឺជាអាការៈជំងឺផ្លូវចិត្តរ៉ាំរ៉ៃ ធ្វើឲ្យផ្លូវកាយខ្សោយទើបផ្តាំផ្ញើ ខាឡូម៉ាន់ ដែលកាលនោះជាក្មេងប្រុសម្នាក់។

ការអុន មិនត្រូវការផ្ញើកូនស្រីនឹងឪពុកព្រាន ដោយជឿជាក់ចំពោះ ខាឡូម៉ាន់ ជាងស្វាមី ខាឡូម៉ាន់ បានសន្យានឹងម្តាយតូចទីប្រាំទោះខ្លួនឯងនៅក្មេង តែសន្យាធ្វើឲ្យពូកជានិច្ច និងមានទំនួលខុសត្រូវចំពោះវា ដោយមើលថែ ខ្លារិហ្សា បានល្អ ទំយើប្អូនរហូតដល់ដឹងខ្លួនម្តងទៀត ទេពធីតាតូចក្លាយជាបិសាចសម្រាប់អ្នកដទៃទៅហើយ។

"ខ្លារិហ្សា ក៏មានចំណុចគួរឲ្យស្រឡាញ់ចូលចិត្តដែរ"

"សម្រាប់តែឯង"

"ឯងអាចជាម្នាក់នោះក៏ថាបាន"

"ឈប់និយាយទៅ ខាឡូម៉ាន់ ឯងត្រូវការអ្នកមើលថែប្អូនស្រីបិសាចរបស់ឯង ហើយឯងក៏ឆ្លៀតឱកាសញាត់ញៀត ខ្លារិហ្សា ឲ្យខ្ញុំ"

"ឯងគិតអវិជ្ជមានពេកហើយ វៃមសៀ ខ្ញុំរើស ខ្លារិហ្សា ឲ្យឯង ព្រោះឯងជាបុគ្គលដែលសក្តិសមជាងគេ"

"ខ្ញុំត្រូវតែបានសេរីភាពក្នុងការគ្រប់គ្រង ខ្លារិហ្សា"

វៃមសៀ មកទីនេះដោយអារម្មណ៍ដូចទឹកក្តៅពុះ ដោយមិនខ្វល់ពីរឿងគ្រាបញ្ហា តែពេលទោសៈរាងរសាយ ទើបមើលឃើញច្បាស់ថាបញ្ហារបស់ ខាឡូម៉ាន់ មិនអាចកែប្រែបាន ក្រៅពីនេះអំណាចដែលទើបផ្លាស់ប្តូរ មិនអាចឲ្យ





Scanned by CamScanner

ខាឡូម៉ាន់ បង្ហាញពីភាពមិនច្បាស់លាស់ឲ្យឃើញជាដាច់ខាត។

ទោះត្រូវខិនក្បាលទទួលយកបញ្ហារបស់ ខាឡូម៉ាន់ តែគេត្រូវដាក់សំណើឲ្យម្ចាស់បញ្ហាដូចគ្នា។ ប្អូនស្រីកំណាចរបស់ ខាឡូម៉ាន់ គេត្រូវតែមានអំណាចគ្រប់គ្រងត្រួតត្រាពេញដៃ ព្រោះគេនឹងឈឺក្បាល ផ្ទុះខួរមិនខាន បើ ខាឡូម៉ាន់ នៅតែកាន់ជើងប្អូនស្រី។

"មានន័យដល់ ?"

"អំណាចគ្រប់គ្រងត្រួតត្រា ខ្លារិហ្សា ត្រូវស្ថិតនៅលើខ្ញុំ ឯងមិនត្រូវលូកដៃមកចេះដឹងបញ្ហាក្នុងគ្រួសាររបស់ខ្ញុំ"

"ចុះបើនាងត្រូវការជំនួយ ?"

"ឯងដឹងច្បាស់ ខាឡូម៉ាន់ ថាខ្ញុំត្រូវការអី ហើយឯងត្រូវធ្វើខ្លួនយ៉ាងណាខ្ញុំព្រមរៀបការ តែខ្ញុំមិនប្រណីប្អូនស្រីឯងទេ បើនាងធ្វើខ្លួនសាញ៉ាំ"

"ខ្លារិហ្សា ជាប្អូនស្រីគួរឲ្យអាណិត"

"ក្នុងភ្នែកឯងប៉ុណ្ណោះ"

"ខ្ញុំដែរ"

"បិទមាត់ ស៊ីតឺរ៉ាស!" មាត់ជាអ្នកនេះ តែកែវភ្នែកសម្លឹងអ្នកនោះ។

ព្រះអង្គម្ចាស់ដឹងច្បាស់ថា រ៉ែមសៀ ព្រមថយមួយជំហាន ទើបទ្រង់មានជម្រើសតែមួយគត់ គឺព្រមថយមួយជំហានដែរ។

"ឯងបានសិទ្ធិនោះ រ៉ែមសៀ"

"ឯងដឹង ខាឡូម៉ាន់ ខ្ញុំមិនមែនមនុស្សចិត្តល្អ ហើយប្អូនស្រីឯងដឹងតែ



លំបាក បើនាងធ្វើខ្លួនមានបញ្ហា"

"ជួនកាលឯងរាចធុញស្រីក្បាលទន់"

"ខ្ញុំសុំយោបល់ពីឯងពីអង្កាល់ ស៊ីតឺរ៉ាស"

"ខ្ញុំចង់និយាយក៏និយាយ រ៉ែមសៀ ឯងនៅជាមួយមនុស្សស្រីដែលធ្វើខ្លួនជាទន្សាយ ទាំងដែលការពិតស្រីៗរបស់ឯងស្ទើរតែទាំងអស់មានចរិតដូចពស់វែក អ្នកដែលថាស្លូតក៏ស្លូតរកលេខដាក់គ្មាន គ្មានគំនិតយោបល់ គ្មានស្មារតី គ្មានព្រលឹងព្រលះ ពួកនាងធ្វើតួនាទីនៅលើគ្រែ ដេកនៅក្រោមរាងកាយរបស់ឯង ព្រមឲ្យឯងត្រួតត្រា តែឯងមានអារម្មណ៍ពុះកញ្ជ្រោលនឹងរសជាតិលើគ្រែបែបនោះទេ ?"

"ខ្ញុំមិនចាំបាច់ផ្សព្វផ្សាយរឿងលើគ្រែឲ្យឯងស្តាប់ ស៊ីតឺរ៉ាស"

"ឯងធ្វើការហត់នឿយ ឯងត្រូវតែបានទទួលថាមពលដែល ខ្លារិហ្សា នឹងធ្វើឲ្យឯងមានរបស់នោះ"

"ឯងយកនាងទៅចិញ្ចឹមជំនួសខ្ញុំទេ ស៊ីតឺរ៉ាស"

"ខ្លារិហ្សា មិនចូលចិត្ត វេសល័យប្រេន ទីនោះអាប់អួនិងស្ងាត់ជ្រងំ"

ស៊ីតឺរ៉ាស ញាក់ស្មា។ ខ្លារិហ្សា មុខជាស្រែកបែកវេសល័យប្រេន មិនខាន បើត្រូវទៅនៅទីនោះជាមួយគេ ដែលសំខាន់ គេស្រឡាញ់ចូលចិត្តនាងដូចប្អូនស្រី ទោះនាងស្អាតទាក់ភ្នែកយ៉ាងណាក៏គេគ្មានអារម្មណ៍ស្នេហាលើនាងដែរ។ សម្រាប់គេ មនុស្សស្រីដែលអាណិតស្រឡាញ់នឹងបញ្ឈប់អារម្មណ៍នៅត្រឹមប៉ុណ្ណឹង ចំណែកមនុស្សស្រីដែលត្រូវការនៅលើគ្រែ នឹងមានអារម្មណ៍



ឲ្យមួយបែបទៀត។ គេច្បាស់លាស់ជានិច្ចចំពោះការបែងចែកប្រភេទអារម្មណ៍របស់ខ្លួន។

រ៉ែមសៀ គ្រហឹមក្នុងចិត្ត តែទទួលបានការអភ័យទោស ទោះប្រើពាក្យអសុរោះបែបណាក៏ព្រះអង្គម្ចាស់ ចិត្តទូលាយចំពោះជំនិតដ៏ស្មោះត្រង់របស់ទ្រង់ជានិច្ច។

"វាសមតែស្ងាត់ជ្រងំ ទីនោះមានតែខ្មោច"

"នៅជាមួយខ្មោចវាស្ងាត់ចឹង មិនថាពេលថ្ងៃឬយប់ វាដេកតែក្នុងផ្នូរមិនទាន់មានសាកសពណាងើបម៉ោបង្កបញ្ហាឲ្យខ្ញុំបានមួយទេ ងាប់ហើយគឺងាប់តែម្តង"

"ឈប់ធ្វើមុខមាត់អាគតចិត្តដាក់ខ្ញុំទៅ ស៊ីគីរ៉ាស"

"រ៉ែមសៀ អាគតចិត្តស្អី វាជាផ្នែកសប្លារបស់ខ្ញុំតើ"

"ឯងសមតែត្រូវកប់ចោលនៅវេសល័យ៍ប្រេន សមហើយដែលឯងត្រូវនៅទីនោះ ស៊ីគីរ៉ាស"

ស៊ីគីរ៉ាស សើច មិនខឹង រ៉ែមសៀ ដែលនិយាយដូចដាក់ទំនាយឲ្យស្លាប់ដោយប្រយោល។ ជីវិតរបស់គេឆ្លងកាត់ការស្លាប់រស់រួចមកហើយ ទើបការស្លាប់វាមិនគួរឲ្យខ្លាច។ គេដូច រ៉ែមសៀ និងមហាមិត្តរបស់គេ ដែលចងសម្ព័ន្ធភ្ជាប់ទាមទារយកប្រទេស សាក់ខាវៀ មកវិញ បើខ្លាចស្លាប់គឺមុខជាមិនបានចូលរួមបំពេញភារកិច្ចនេះជាមួយគ្នាទេ។

"សរុបទៅយើងចប់ការចរចាគ្នា ?"



ពេល រ៉ែមសៀ ដកភ្នែកពី ស៊ីគីរ៉ាស មើលមក ខាឡុម៉ាន់ ក៏ឆ្លៀតឱកាសសរុបលទ្ធផលនៃការចរចា ដែល រ៉ែមសៀ មិនអាចធ្វើអ្វីបានក្រៅពីងក់ក្បាល។

"ខ្ញុំមិនចង់ចប់ តែក៏ត្រូវចប់ លទ្ធផលនៃការចរចាលើកនេះ ខ្ញុំមិនពេញចិត្តទាល់តែសោះ"

"តែខ្ញុំដឹងថាឯងមានទំនួលខុសត្រូវ ព្រមទទួលយកលទ្ធផលនៃការចរចានេះ"

"បើខ្ញុំមិនសូវមានទំនួលខុសត្រូវប្រហែលល្អ"

"ឯងមិនមែនមនុស្សបែបហ្នឹងទេ រ៉ែមសៀ"

ខាឡុម៉ាន់ និយាយដាក់បុគ្គលដែលខ្លួនគោរពដូចបងប្រុស ក្រៅពីនេះក៏ជាមិត្តរួមឧត្តមគតិ អាចហៅថា ទាំងជាមិត្តភក្តិផង ជាបងប្រុសផង។

"ស្អែកខ្ញុំនឹងប្រកាសដំណឹងភ្ជាប់ពាក្យ"

"មង្គលការរៀបចំពេលណា ?"

"បើឯងមិនថាអី គឺប្រហែលពីរខែក្រោយ"

"ខ្ញុំរវល់ណាស់ ខាឡុម៉ាន់ គ្មានពេលត្រៀមពិធីស្អីទេ"

"ខ្ញុំនឹងចាត់ការឲ្យទាំងអស់"

ខាឡុម៉ាន់ នឹងរៀបចំគ្រប់យ៉ាងឲ្យសមឋានៈរបស់ ខ្លារីហ្សា ប្អូនស្រីរបស់គេនឹងរៀបការជាមួយ រ៉ែមសៀ ឲ្យសមកិត្តិយស។ ក្រុងសេនដីរីក

"ឯងចង់ធ្វើអីក៏អញ្ជើញ ខ្ញុំសុំទៅ សេនដីរីក ហើយ នៅទីនោះមានពួកខូតិច ឲ្យខ្ញុំចាត់ការទៀត មានម្នាក់ដែលខ្ញុំចាក់ក្បាលពោះវានឹងកាំបិតខ្លីដើម្បី



ឈ្លេចយកចិទ្ធន័យ មិនដឹងវាងាប់ហើយនៅ ខ្ញុំសុំទៅសិនហើយ អម្ចាស់ មានភារកិច្ចពាក់ព័ន្ធនឹងស្ថិរភាពរបស់ទ្រង់ដែលខ្ញុំត្រូវចាត់ការបន្ទាន់"

វែមសៀ ក្ដាប់ដៃផ្ទឹបនឹងពោះ ឱនគំនាប់ដើម្បីបង្ហាញពីការគោរពចំពោះ ខាឡម៉ាន់ ហើយបែរខ្នងដើរចេញពីបន្ទប់ទទួលភ្ញៀវ។

សីតិភ័ស រស់សំណើចតិចៗនឹងមិត្តភក្តិ។ វែមសៀ សម្រុកចូលមកដូចព្យុះ ឡូឡាករឿងពីរបីម៉ាត់ក៏ប្រើសម្ដីអសុរោះ តែចុងក្រោយក៏បញ្ចប់ដោយការផ្ដល់កិត្តិយសឲ្យ ខាឡម៉ាន់។ ភាពស្មោះត្រង់ភក្ដីរបស់ វែមសៀ គ្មានអ្វីឲ្យសង្ស័យ តែ ខាឡម៉ាន់ ត្រូវការឲ្យមានភាពយូរអង្វែង មិនត្រូវការឲ្យមានរឿងប្ដោះប្ដោយនាពេលអនាគតទើបធ្វើបែបនេះ។

"ព្រះនាង"

"គេប្រមាថខ្ញុំ"

ការ៉ិន មករកបងប្រុស។ ទោះអ្នកនៅជុំវិញខ្លួនហៅនាងថា ខ្លារិហ្សា តែនាងចូលចិត្តឈ្មោះ ការ៉ិន ជាង ព្រោះជាឈ្មោះដែលធ្វើឲ្យនឹកដល់ម្ដាយ ចំណែកឈ្មោះ ខ្លារិហ្សា បងប្រុសជាអ្នកដាក់ឲ្យ បើសិនឪពុកជាអ្នកដាក់ឲ្យវិញ នាងនឹងមិនព្រមប្រើទេ។

នាងត្រូវបានអនុញ្ញាតជាពិសេសពីបងប្រុស អាចចេញចូលប្រាសាទវើដូសា ដោយគ្មានការរាំង ឬត្រូវរាយការណ៍ដល់ម្ចាស់ប្រាសាទឲ្យដឹងជាមុន។ អ្នកបម្រើផ្ទាល់ខ្លួនទាំងពីររបស់ព្រះនាងកំពុលសម្រស់ លុតជង្គង់លើកម្រាល



ខ្ទល់ខ្លាយនឹងទោសៈរបស់ម្ចាស់ស្រី។

ទោះព្រះនាងជាប្អូនស្រីសំណព្វចិត្តរបស់ព្រះអង្គម្ចាស់ ខាឡម៉ាន់ តែ វែមសៀ ជាឧត្ដមសេនីយ៍ បុគ្គលសំខាន់ដែលព្រះអង្គម្ចាស់ ទុកចិត្តទុកថ្លើមដល់ថ្នាក់ប្រគល់ក្រុងអាឡិចសានដេ ឲ្យជារង្វាន់ បន្ទាប់ពីរឹបអូសអំណាចបានសម្រេច។ ក្រុងអាឡិចសានដេ ត្រូវបានរៀបចំជាតំបន់ស្វ័យតពិសេស វែមសៀ មានអំណាចគ្រប់យ៉ាង ដោយពុំចាំបាច់ឆ្លងយោបល់ពី ខាឡម៉ាន់។

"ព្រះនាង"

"ថយចេញ"

ពេលត្រូវបញ្ជាបែបនេះ មានឬដែលអ្នកបម្រើហ៊ានបំពាន ទើបនាំគ្នាអូសជង្គង់ថយក្រោយ ចំណែក ការ៉ិន ក៏ស្ទុះទៅរក វែមសៀ ភ្លាម ពេលគេបើកទ្វារចេញ ហើយមនុស្សដូចគេ ប្រមាថនាងមិនគ្រប់ នៅគ្មានមារយាទដាក់បងប្រុសរបស់នាងទៀត។

ការបដិសេធរបស់គេ លាន់ចេញពីក្នុងបន្ទប់ទទួលភ្ញៀវ ព្រោះទ្វារមិនត្រូវបានបិទ ដែលធ្វើឲ្យនាងអាម៉ាស់មុខ ប៉ុណ្ណឹងមិនទាន់គ្រប់ទេ ព្រោះថារាងកាយរបស់នាងញ័រទទ្រើតដោយទោសៈ ដែលគេបន្ទាបតម្លៃនាងដោយគ្នាឲ្យស្ដាប់មែនទែន។ បើគេមិនត្រូវការរៀបការជាមួយនាង ជួយបដិសេធឲ្យល្អជាងនេះមិនបានទេអី។

ប្រហែលគិតថាខ្លួនជាមនុស្សសំណព្វរបស់បងប្រុស ទើបនិយាយស្ដីមិនពីរោះពិសាបែបហ្នឹង ហើយនាងក៏ត្រូវការរឹបអូសយកការសរសើរដែលធ្លាប់





Scanned by CamScanner

មានចំពោះគេមកវិញ។ ភាពជាអ្នកចម្បាំងដ៏ម៉ាំមួនអង់អាច ក្លាហាន សមជាបុរសភេទរបស់គេត្រូវបានសរសើរ ដោយសារការកិច្ចផ្សងជីវិតដើម្បីសាក់ខាង និង ខាឡូម៉ាន់ តែនាងនឹងរឹបអូសយកការសរសើរទាំងនេះវិញ។

ទោសៈធ្វើឲ្យនាងគ្រប់គ្រងស្មារតីមិនបានល្អ ប៉ុន្តែនាងមិនចាំបាច់ប្រើស្មារតីក៏បាន ព្រោះ រ៉េមសៀ ញាត់ញៀតឲ្យនាងជាបិសាច ជាមនុស្សស្រីសាំញ៉ាំ នាងនិងគេធ្លាប់និយាយគ្នាបានម្តងឬអត់ ទោះធ្លាប់ជួបគ្នាបីដង តែបីដងនោះគ្រាន់តែជាការមើលគ្នាដោយគ្មានការរាក់ទាក់។

"រ៉េមសៀ"

ការ៉ិន ចូលទៅដល់ខ្លួនគេ។ បុរសមុខក្រមូវដើរចេញពីបន្ទប់ទទួលភ្ញៀវ បានជួបនឹងមេបញ្ជាដោយស្មានមិនដល់។ ព្រះនាង ការ៉ិន ឬ ខ្លារីហ្វា របស់មនុស្សគ្រប់គ្នា ស្រស់ស្អាតនៅឈុតវែង ព្រលែងស្វា ពណ៌ស្រាសាំប៉ាញ សម្រុងវែងដល់ដី តែផែកវែងដល់ភ្លៅស្រឡូនស្អាត ស្បែដណ្តប់តម្លៃកប់ពពក ដែលនាងកំពុងដណ្តប់នោះ ធ្វើឲ្យរស្មីនៃភាពជាស្ត្រីខ្ពង់ខ្ពស់របស់នាងកាន់តែត្រដឹម។

ការ៉ិន ខ្ពង់ខ្ពស់ដោយវង្សត្រកូល ទោះមានឈាមឪពុកពាក់កណ្តាលតែយ៉ាងណា នាងក៏ជាសមាជិករាជវង្ស ម៉ាលខៃសេនពេ។ សម្រស់ដ៏ស្រស់ស្អាតរបស់ ការុន ត្រូវផ្ទេរឲ្យកូនស្រី ផ្សេងគ្នានឹងភាពសង្ហាមានមន្តស្នេហ៍របស់ឪពុក ទើប ការ៉ិន ស្រស់ស្អាត គ្មានអ្វីឲ្យទាស់បែបនេះ។

បើមិនធ្លាប់ដឹងពីភាពកំណាចរបស់នាង រ៉េមសៀ មុខជាមើលនាងភ្លឹក



ទៅហើយ។

ការ៉ិន ចូលទៅដល់ខ្លួនរបស់ រ៉េមសៀ លឿនដូចព្យុះ ហើយប្រឈមមុខនឹងគេ ដោយមុខស្រស់ស្អាត មើលភ្លឹកនោះឡើងក្រមូវ តែយ៉ាងណាក៏នៅតែស្អាតចាក់ដោតអារម្មណ៍ ដៃទាំងពីរលើករុញដើមទ្រូងហាប់ណែនសុទ្ធតែសាច់ដុំ តែម្ចាស់ទ្រូងមិនរង្គោះរង្គើអីបន្តិច បន្ទាប់មកក៏ក្តាប់ដៃតក់ទ្រូង ដែលវាធ្វើឲ្យនាងកាន់តែខឹងព្រោះគេរឹងមាំពេកហើយ ឲ្យបាតដៃរបស់នាងឡើងក្រហម។

រ៉េមសៀ បានទទួលការស្វាគមន៍ពីនាងដោយស្មានមិនដល់ តែជាការស្វាគមន៍ដែលគ្មានមារយាទ។

"មនុស្សព្រហើន!"

*គេឬព្រហើន?*

*ចុះអ្នកដែលកំពុងទះតប់គេនេះគួរហៅថាអ្វី?*

រ៉េមសៀ ចាប់ដៃដ៏ស្រឡូនទាំងពីរក្រសោបដោយដៃម្ខាង ហើយច្របាច់រាងខ្លាំងបន្តិចពេលនាងប្រឹងរលាស់។ គេមិនប្រើកម្លាំងច្រើនពេកទេ ព្រោះរាងកាយរបស់នាងតូចស្តើងពេកហើយ ពេលប្រៀបធៀបនឹងគេ បើមិនបញ្ចូលដើមទ្រូងណែនក្បុំដែលវាសឹងតែប្រាល់ចេញពីអាវ ខណៈដែលអ្វីផ្សេងទៀតនៅលើដងខ្លួនតូចច្រឡឹងនេះគឺតូចទាំងអស់ ហើយបើជាមនុស្សប្រុសដូចគ្នាមុខជាត្រូវគេច្របាច់ដោយកម្លាំងបាយ ដែលមានច្រើនជាងទៅហើយ។

"លែង"

"នេះជាការទទួលភ្ញៀវ?"



"លោកមិនមែនភ្ញៀវរបស់ខ្ញុំ!"

អ្នកបម្រើចាប់ដៃគ្នា ខ្លួនញ័រចំប្រប់ដោយការភ័យខ្លាច ការដែល ការ៉ិន គ្មានមារយាទដាក់ រ៉ែមសៀ ក៏ជាកំហុសរបស់ពួកនាងដែលបំពេញតួនាទីក្នុងការមើលថែព្រះនាងមិនបានល្អ ប៉ុន្តែជាតម្រូវការរបស់ព្រះនាង អ្នកបម្រើមានអំណាចរាំងបានដែរឬ។

"ឈប់ឡូឡា!"

រ៉ែមសៀ កំពុងមួម៉ៅព្រោះរឿងរបស់នាងជាមូលហេតុ ហើយនាងក៏លេចមុខមកឲ្យគេកាន់តែពុះ ព្រោះគេប្រញាប់ទៅចាត់ការធុរៈរបស់គេឲ្យរួចរាល់ នាងបែរជាមករាំងផ្លូវឲ្យកាន់តែយឺតយ៉ាវ។

"ខ្ញុំចង់ឡូឡា"

"នាងត្រូវតែឈប់!

"ខ្ញុំមិនឈប់"

ការ៉ិន មិនស្ដាប់បញ្ជា ហើយប្រឹងរើបម្រះទៀត ទើបចាប់ដៃរបស់នាងកាន់តែណែន។ ព្រះនាងមេបញ្ជាកំពុងចង់សាកជាមួយគេ ហើយគេក៏ចង់ចាត់ការមនុស្សចំនើងឲ្យទក់សាច់ដែរ ជាការដាក់ទោស។

"ចាំទុក! រ៉ែមសៀ ដាវ៉ៃហិណេស ខ្ញុំមិនព្រមរៀបការជាមួយលោក"

នាងសម្លក់គេថ្មៃ និងប្រកាសខ្លាំងៗដែល រ៉ែមសៀ យល់ដោយគិតថា នាងបានឮការសន្ទនាដែលកើតឡើងក្នុងបន្ទប់ទទួលភ្ញៀវ។

"ខ្លារិហ្សា"



"បងប្រុស ជួយផង បញ្ជាឲ្យមនុស្សព្រហើននេះលែងខ្ញុំ បងប្រុស"

សំឡេងឡូឡាដែលលាន់ចូលមកក្នុងបន្ទប់ទទួលភ្ញៀវ ធ្វើឲ្យ ខាឡូម៉ាន់ និង សិតិរ៉ាស នាំគ្នាចេញមកមើល។

ការ៉ិន សុំឲ្យបងប្រុសជួយ តែ រ៉ែមសៀ ដែលចាប់នាងជាប់មិនព្រមលែង សម្លឹងមើលមក ខាឡូម៉ាន់ មើលមកដោយខ្សែភ្នែកដែលរានមិនផ្អះ។

"រ៉ែមសៀ"

"អម្ចាស់ ទ្រង់សន្យានឹងទូលបង្គំហើយ"

ព្រោះមានអ្នកបម្រើរបស់ ការ៉ិន នៅម្តុំនេះដែរ ទើប រ៉ែមសៀ និយាយដាក់ ខាឡូម៉ាន់ ដោយការគោរព ដោយបញ្ជាក់ដល់ពាក្យសន្យា។

'អំណាចគ្រប់គ្រងត្រួតត្រា ខ្លារិហ្សា ត្រូវស្ថិតនៅលើខ្ញុំ ឯងមិនត្រូវលូកដៃមកចេះដឹងបញ្ហាក្នុងគ្រួសាររបស់ខ្ញុំ'

"ខ្ញុំដឹង រ៉ែមសៀ ខ្ញុំសន្យា តែឯង និង ខ្លារិហ្សា មិនទាន់រៀបការទេ"

"ទ្រង់ប្រថាប់ត្រាក្នុងបញ្ជាហើយ ដូច្នោះហើយបញ្ជានោះចាត់ទុកថាពេញលក្ខណៈហើយ"

"ទោះអីចឹងក៏ដោយ ខ្លារិហ្សា អាចរងរបួស ជួយលែងដៃនាងសិនទៅ"

"ខ្ញុំចាប់តែដៃនាងប៉ុណ្ណោះ"

រ៉ែមសៀ រសាយដៃ តែពេល ការ៉ិន ស្ទុះទៅរកបងប្រុស ទើបគេស្រវាឱបចង្កេះនាង ទាញឲ្យមកឈរបៀតរាងកាយអ្នកចម្បាំង។ កដៃរបស់នាងតូចមែននោះឯង កម្លាំងដែលគេប្រើតែបន្តិចសោះ តែធ្វើឲ្យកដៃនោះក្រហម។





Scanned by CamScanner

"ថយចេញ!"

"ព្រះអង្គម្ចាស់ ខាឡូម៉ាន់ ឲ្យអំណាចគ្រប់គ្រងនាងម៉ោខ្ញុំ អ៊ីចឹងហើយគួរធ្វើខ្លួនឲ្យបានល្អ ខ្លារិហ្សា"

"ខ្ញុំមិនស្ដាប់សម្ដីលោក"

"សាកមើលទៅថានាងស្ដាប់ ឬមិនស្ដាប់ មារយាទនៅក្នុងការទទួលអនាគតប្ដីរបស់នាង អន់ណាស់ តែថ្ងៃនេះខ្ញុំមានការរវល់ អ៊ីចឹងមិនប្រកាន់នាងពីរឿងនេះទេ"

ការ៉ិន ខ្ទីបបបូរមាត់ និងបាញ់ខ្សែភ្នែកឆ្មាសដាក់ វ៉ែមសៀ ពេលនោះឯងដែលគេសង្កេតឃើញថាបបូរមាត់របស់នាងក្រពុំ និងឲ្យអារម្មណ៍ប្រាជ្ញាប្លែកប្រហែលមកពីនាងស្អាតខ្លាំងនោះឯង។

រួកកំលោះទាញខ្សែភ្នែកមកប្រសព្វនឹងនាងវិញ បន្ទាប់មកក៏ឱនមកថើបមាត់របស់នាង ដើម្បីបង្ហាញអំណាច ហើយទុកឲ្យឈររឹងខ្លួនស្លុកដោយអារម្មណ៍ញាប់ញ័រ ដោយខ្លួនឯង ដើរញាប់ជើងស្មេចេញទៅបាត់។



# ២

## ឈឺចិត្តឆ្អិតទ្រូង

"ខ្លារិហ្សា"

ខាឡូម៉ាន់ មានតួនាទីលួងលោមប្អូនស្រីសំណព្វចិត្ត។ ការថើបពី វ៉ែមសៀ មិនមែនជាការបង្ហាញអារម្មណ៍ស្នេហាចំពោះ ការ៉ិន តែជាការបង្ហាញពីអំណាច។ វ៉ែមសៀ ត្រូវការបង្ហាញឲ្យ ការ៉ិន ដឹងថាគេមានអំណាចចំពោះនាងចំណែកលទ្ធផលដែលទទួលបានគឺ វ៉ែមសៀ ចាកចេញទៅដោយកំហឹង ឯការ៉ិន ក៏ក្ដៅក្រហាយ។

នាងសម្លឹងចំកែវភ្នែករបស់បងប្រុស ព្រមឲ្យគេឱប។ នាងទទួលពាក្យបងប្រុស ព្រមរៀបការនឹង វ៉ែមសៀ ដោយអាពាហ៍ពិពាហ៍នយោបាយ ដែលខាឡូម៉ាន់ ប្រាប់នាង។ នាងព្រមលះបង់ខ្លួនឯង តែ វ៉ែមសៀ បែរជាធ្វើដាក់នាងយ៉ាងអសីលធម៌។

"គេឈ្លើយណាស់" នាងនិយាយបានតែប៉ុណ្ណឹង ក៏អួលណែនដើមទ្រូងដោយកំហឹង និងក្រៅពីអារម្មណ៍នេះហើយ នៅមានភាពរស់សង្ស័យដែរ ព្រោះ វ៉ែមសៀ គួរមានភាពជាសុភាពបុរស តែគេបែរជាគ្មានរបស់នោះ។

"វ៉ែមសៀ កំពុងស្រ្តេស គេមានភារកិច្ចធំណាស់"



"បងប្រុសក៏មានភារកិច្ចធំដែរ"

ជាការពិតដែល វែមសៀ មានភារកិច្ចធំ តែនោះមិនមែនជាហេតុផលដែលគេសមនឹងទទួលបានការអភ័យពីអាកប្បកិរិយាព្រហើន កោងកាចរបស់គេ ក្រៅពីនេះគេមិនភ្ញាក់រឭកចំពោះទង្វើរបស់ខ្លួនទៀត ពេលដែលបើបមាត់នាងហើយ ក៏ដើរចេញទៅដោយកំហឹង។

*មនុស្សព្រហើន!*

បើស្អប់ខ្ពើមនាង គឺគ្មានសិទ្ធិប៉ះពាល់នាង តែនេះស្អី! សម្ដីរបស់គេប្រមាថមើលងាយនាង ហើយទង្វើក៏ប្រមាថ មិនឲ្យកិត្តិយសនាងទៀត។

"ការគ្រប់គ្រងអារម្មណ៍របស់មនុស្សយើង មានភាពខុសគ្នា"

"សិតិភ័ស ក៏មានការងារច្រើនដែរតើ"

កាអ៊ិន ងាកទៅមើល សិតិភ័ស ដែលប្រៀបដូចបងប្រុសរបស់នាងម្នាក់ទៀត ព្រោះគេ ជាអ្នកតាមការពារសុវត្ថិភាពរបស់ព្រះអង្គម្ចាស់ ខាឡូម៉ាន់។

"ព្រោះបងជាមនុស្សល្អហ្នឹងអី"

សិតិភ័ស យកល្អដាក់ខ្លួន តែរឿងអាក្រក់ក៏មិនបានបោះបោល គ្រាន់តែបើកផ្លូវឲ្យ កាអ៊ិន បោះវាឲ្យ វែមសៀ ឫសរឹងរូសប៉ុណ្ណោះ។

"វែមសៀ ជាមនុស្សមិនល្អ"

"ខ្លាំហ្វា ប្អូនក៏ពឹងដូចបងដឹង វែមសៀ ស្មោះត្រង់ភក្ដីចំពោះរាជវង្សម៉ាលខៃសេនតេ"

"គេមានចរិតមិនល្អ"



កាអ៊ិន នៅតែប្រកាន់យកតាមជំនឿរបស់ខ្លួន។ វែមសៀ ជាមនុស្សក្បាលរឹង ប្រងេងប្រងាង ក្លាហាន មិនខ្លាចអ្នកណា ចំណែក កាអ៊ិន ក៏ក្បាលរឹង និងទំនើងណាស់ដែរ ការប៉ះគ្នារបស់ពីរនាក់នេះគួរឲ្យចាប់អារម្មណ៍ ត្រង់ថានរណានឹងហត់នឿយមុន។

"ខ្ញុំមិនចង់រៀបការជាមួយគេទេបងប្រុស"

"នោះជាគំនិតរបស់ វែមសៀ នៅពេលនេះ"

"អនាគតក៏មិនខុសគ្នា"

"ស្ថិតនៅលើប្អូន"

"ខ្ញុំឬ?"

"បើប្អូនត្រូវការយកឈ្នះ វែមសៀ គឺធ្វើឲ្យគេមានចិត្តស្នេហាចំពោះប្អូន"

កាអ៊ិន យល់ពីសម្ដីរបស់ ខាឡូម៉ាន់។ បងប្រុសដឹងខ្ពង់ខ្ពស់បោះត្រាលើបញ្ជា ដែលត្រូវចែកចាយតាមស្ថាប័ននានាដែលពាក់ព័ន្ធ ដើម្បីប្រកាសឲ្យប្រជាជនដឹង។ ទោះទំនើង តែនាងដឹងថារឿងណាស់ខាន់ខ្លាំង ឬមិនសូវសំខាន់ នាងមានហេតុផល និង ចេះបែងចែកចំពោះរឿងខ្លះ។

នាងមិនអាចបញ្ឈប់ពីមង្គលការបាន តែដែលប្រកាសដាក់មុខ វែមសៀ បែបនោះ ព្រោះខឹងខ្លាំងពេក ហើយម្យ៉ាងទៀតការបញ្ឈប់មង្គលការ នឹងធ្វើឲ្យប៉ះពាល់ដល់បងប្រុស ទោះ ខាឡូម៉ាន់ ស្រឡាញ់នាង ព្រមធ្វើតាមចិត្តនាងបញ្ឈប់ពិធីមង្គលការឲ្យក៏ដោយ បើនាងនៅតែប្រកែកថាមិនព្រម។



សាក់ខារៀ មិនទាន់ជាប្រទេសមានសុខសន្តិភាព ស្ថិរភាពពិតប្រាកដ

ខាឡូម៉ាន់ ត្រូវធ្វើឲ្យប្រជាជនភាគច្រើនទុកចិត្ត តែបើពិធីមង្គលការត្រូវបញ្ឈប់ បងប្រុសនឹងត្រូវប្រមាថថារឿងតូចតាចសោះក៏ធ្វើមិនកើត។

"មនុស្សប្រុសតែងតែចុះចាញ់អំណាចស្នេហា"

សឺតិរ៉ាស ញញឹមញញែម។ រ៉ែមសៀ ជាមនុស្សឆ្លាតនឹងអំណាច ចំណែក ការ៉ុន ក៏ចូលចិត្តយកឈ្នះ បើមានវិធីយកឈ្នះ រ៉ែមសៀ បាន មានឬដែល ការ៉ុន មិនចាប់អារម្មណ៍។ គេលាក់ល្បិចកលនៅក្នុងខ្សែភ្នែក តែមាត់មាន ស្នាមញញឹម ពេលឃើញការចាប់អារម្មណ៍នៅក្នុងពន្លឺភ្នែករបស់ ការ៉ុន។

"មនុស្សបែបហ្នឹង ខ្ញុំមិនស្នេហា គេជាដាច់ខាត"

"ព្រះនាង ខ្លារិហ្សា ទ្រង់មិនចាំបាច់ស្នេហា រ៉ែមសៀ ទេ សុំត្រឹមទ្រង់ធ្វើឲ្យ គេស្នេហាទ្រង់ឲ្យបាន ទ្រង់នឹងមានអំណាចលើគេ អំណាចលើ រ៉ែមសៀ ដាវ៉ៃហ៊ីណោស"

"បងកំពុងញុះញង់ខ្ញុំ សឺតិរ៉ាស"

សឺតិរ៉ាស ញញឹមពព្រាយ ឱនគំនាប់បន្តិចដាក់ព្រះនាង។ ការ៉ុន ជា មនុស្សស្រីស្អាតមែនទែន និងក្រៅពីសម្រស់ហើយ នាងក៏មានភាពឆ្លៀវឆ្លាតគួរ ឲ្យស្ងើចសរសើរ អីចឹងហើយ ទើបគេមិនហ៊ានយកខ្លួនឯងមកស្នើជូននាងទេ ព្រោះគេជាមនុស្សគ្មានសមត្ថភាព ប៉ុន្តែភាពឆ្លៀវឆ្លាតរបស់ព្រះនាង គួបដោយ ភាពល្ងង់ល្ងើ ដែលមានកម្រិតស្មើគ្នា ជាបញ្ហាដែលគេទប់ទល់មិនឈ្នះ ទើបគេ សុំអាណិតស្រឡាញ់នាងក្នុងឋានៈជាបងប្រុសប៉ុណ្ណឹងទៅបានហើយ។

"ខ្ញុំមិនចង់ឲ្យមនុស្សបែបហ្នឹងមានអារម្មណ៍ស្នេហាខ្ញុំទេ" ការ៉ុន បញ្ជាក់



ព្រោះខឹងមិនទាន់បាត់ ហើយកំហឹងនេះនឹងនៅតែមានជាបន្តបន្ទាប់ទាល់តែ នាងមានជ័យជម្នះលើ រ៉ែមសៀ ដាវ៉ៃហ៊ីណោស។

**ទោះប្រកាសក្លែងៗ ថាមិនចាប់អារម្មណ៍ ដាវ៉ៃហ៊ីណោស ប៉ុន្តែនាងនៅ តែនឹកដល់សម្ដីរបស់បងប្រុស និង សឺតិរ៉ាស។**

*អំណាចលើ រ៉ែមសៀ ដាវ៉ៃហ៊ីណោស!*

ការ៉ុន រលាស់ប្រយោគនេះចេញពីគំនិតមិនបាន ព្រោះវាមានជាតិផ្អែម និងទាក់ទាញចិត្តមែនទែន ពេលនឹកដល់ការមានអំណាចលើបុរសរឹងរូសម្នាក់ នោះ។ រ៉ែមសៀ ជាន់ឈ្លី ទំនុកចិត្ត ចំពោះខ្លួនឯងរបស់នាង គេបដិសេធនាង យ៉ាងព្រហើន ធ្វើឲ្យនាងស្លឹកមុខនឹងពាក្យបដិសេធនោះ។

រ៉ែមសៀ មើលនាងដូចរបស់គ្មានតម្លៃ ដល់ថ្នាក់សុំ ខាឡូម៉ាន់ រៀបការ នឹងអ្នកណាក៏បានដែលមិនមែនជានាង។ នៅក្នុងទ្រូងរបស់នាងក្ដៅភាយៗ ដោយកំហឹងនិងការអាម៉ាស់ ដូច្នោះហើយបើនាងមានអំណាចលើគេ នាងនឹង ជាន់ឈ្លីអារម្មណ៍របស់គេវិញ។

រ៉ែមសៀ មិនមែនជាបុរសដែលនាងត្រូវការ។ នាងកំពុងខឹង គ្រប់រឿង ដែលពាក់ព័ន្ធនឹងគេ វាប៉ះពាល់ផ្លូវចិត្តរបស់នាង ហើយមុខក្រម្ងរនោះក៏ធ្វើឲ្យ អ្នកបម្រើភ័យខ្លាច ទោះឈរចាំបម្រើម្ចាស់ស្រីពីចម្ងាយក៏ដោយ។

"ខ្ញុំនឹងស្អប់គេ" ការ៉ុន ងាកទៅប្រាប់មនុស្សជំនិតទាំងពីរ។

ស៊ីឡា និង ហ្វ៊ីរ៉ា ធ្វើបានត្រឹមទទួលស្ដាប់ ព្រោះបុគ្គលដែលម្ចាស់ស្រី





Scanned by CamScanner

និយាយប្រាប់គឺឧត្តមសេនីយ វែមសៀ ដាវ៉ៃហ៊ីណេស ពួកនាងម្ដេចហ៊ាន ស្ដីបន្ទោស ឬ និយាយដើមទៅ ហើយបើនិយាយ មានអ្នកឮ ពួកនាងមិនត្រូវទទួលទោសធ្ងន់ទៅហើយ។

"ខ្ញុំនឹងស្ដាប់គេមិនខាន"

"ព្រះនាង ជាមនុស្សស្រី គឺត្រូវតែស្រឡាញ់ និងគោរពស្វាមី"

"ហ៊ឺ! មនុស្សបែបហ្នឹងគួរឲ្យគោរពត្រង់ណា ស៊ីឡា ដូចគេសមតែត្រូវវ៉ៃនឹងដំបង វ៉ៃៗ វ៉ៃឲ្យខ្លាំងៗ"

"ទ្រង់ធ្វើបែបហ្នឹងមិនបានទេ"

ស៊ីឡា ខិតទៅជិតព្រះនាងកំពូលសម្រស់ ដាក់បង្អុយចុះលើកម្រាលហើយចាប់ដៃម្ចាស់ស្រី។ ការធ្វើឲ្យឧត្តមសេនិយ វែមសៀ ឈ្លក់វង្វេង តែងតែល្អជាងរឹងទទឹង ព្រោះ វែមសៀ មានអំណាចលើបុរសទាំងឡាយនៅ សាក់ខាវៀព្រោម ខាឡូម៉ាន់ តែម្នាក់ប៉ុណ្ណោះ ដូច្នេះហើយបើត្រូវប៉ះគ្នាក្រែងថាព្រះនាងរបស់នាង ត្រូវចាញ់រាបដូចកន្ទេល។ ព្រះនាងស្អប់ភាពបរាជ័យ ហើយការប៉ះវែមសៀមិនមែនជាជម្រើសល្អទេម្យ៉ាងទៀតវែមសៀមានស្រីកំណាន់ពេញឃ្លាំងអីចឹងហើយ ស៊ីឡា ត្រូវការឲ្យម្ចាស់ស្រីរបស់ខ្លួន ក្លាយជាទីមួយក្នុងចិត្តលោកឧត្តមសេនិយ។

"ខ្ញុំនឹងគោរពគេ ទាល់តែគេធ្វើខ្លួនគួរឲ្យគោរព ហើយខ្ញុំព្រមទទួលគេដោយចិត្តប៉ុណ្ណោះ ខ្ញុំមិនបង្ខំចិត្ត ឱនក្បាលដាក់គេទាំងដែលចិត្តខ្ញុំហៅគេជាប្រុសឆ្កួត"



"ព្រះនាង និយាយពីលោកឧត្តមសេនីយ បែបហ្នឹងមិនបានទេ"

"ខ្ញុំនឹងនិយាយ អូខេ ស៊ីឡា ខ្ញុំត្រូវផ្ដោចការចងចាំរបស់នាងឬអត់ នាងជាមនុស្សរបស់ខ្ញុំ"

"ឱ! ព្រះនាង ខ្ញុំម្ចាស់ជាខ្ញុំបម្រើរបស់ទ្រង់ ស្មោះត្រង់ មិនកែប្រែមួយជីវិត ខ្ញុំម្ចាស់ចង់ឲ្យទ្រង់មានសេចក្ដីសុខ"

"សេចក្ដីសុខរបស់ខ្ញុំក្លាយជាសេចក្ដីទុក្ខទៅហើយ ខ្ញុំប្រហែលត្រូវទុក្ខធំជាបណាដែលត្រូវរៀបការជាមួយ វែមសៀ ដាវ៉ៃហ៊ីណេស"

"ព្រះនាង"

"បើព្យាយាមនិយាយដើម្បីឲ្យខ្ញុំមើលគេនៅក្នុងផ្លូវល្អ អីចឹងឈប់ទៅ វាមិនកើតជាប្រយោជន៍អីទេ មនុស្សម្នាក់នោះធ្វើឲ្យខ្ញុំខ្មាសគេ គេនិយាយពីខ្ញុំនៅចំពោះមុខបងប្រុស និងបង សីតីភ័ស ដោយមិនឲ្យកិត្តិយស គេស្គាល់ខ្ញុំប៉ុណាទៅ ទើបហ៊ាននិយាយស្ដីគ្រោតគ្រាតបែបនោះដាក់ខ្ញុំ"

"ព្រះនាងត្រូវយកឈ្នះចិត្តលោកឧត្តមសេនីយ ដោយទង្វើល្អទៅ"

"អត់! ពេលគេមើលខ្ញុំអាក្រក់ ខ្ញុំនឹងធ្វើជាមនុស្សអាក្រក់ ដើម្បីគេជាពិសេស"

វែមសៀ មើលនាងនៅក្នុងផ្លូវអាក្រក់ ហើយនាងត្រូវព្យាយាមធ្វើខ្លួនឲ្យល្អដើម្បីយកឈ្នះចិត្តនាងអីចឹងឬ ហ៊ឺះ! គ្មានផ្លូវទេ! ក្នុងពេលដែលគេគិតថានាងអាក្រក់ នាងនឹងធ្វើជាស្រីបិសាច គួរគេឲ្យខឹងទាល់តែផ្ទុះ បើមិនជឿ ចាំតែមើលទៅ។



"ព្រះនាង តើទ្រង់មិនចង់យកឈ្នះចិត្តលោកឧត្តមសេនីយដោយស្នេហាទេឬ?"

"មនុស្សបែបហ្នឹងមិនសមទទួលបានស្នេហា"

ទោះនិយាយបែបនេះ តែការមានវិធីសាគួរយកឈ្នះ រ៉ែមសៀ ក៏ជារឿងល្អ។ នាងគួរត្រៀមខ្លួនឲ្យរួចរាល់ ព្រោះដឹងថាការយកឈ្នះដោយស្នេហា គឺត្រូវស្និទ្ធស្នាលនឹង រ៉ែមសៀ ប៉ុន្តែត្រូវធ្វើយ៉ាងណា?

"ស៊ីឡា តើការយកឈ្នះដោយស្នេហាត្រូវធ្វើយ៉ាងណា?"

"ត្រូវទៅជួប អ្នកនាង សានេនេ"

"អីចឹងចាំសិនទៅ"

ទោះចង់យកឈ្នះគេស្ទើរដាច់ខ្យល់ តែព្រះនាងជិខ្ពង់ខ្ពស់នៅតែធ្វើឡូយដោយការដើបដើរទៅឈរនៅមាត់បង្អួច ប៉ុន្តែពេលមើលសួនផ្កាខាងក្រៅសូម្បីដើមឈើ ដើមស្មៅ ក៏មានមុខរបស់ រ៉ែមសៀ ឲ្យឃើញ នោះហើយដែលធ្វើឲ្យនាងលើកដៃប៉ះបបូរមាត់ខ្លួនឯងដោយអារម្មណ៍ហោះហើរ។ មនុស្សក្អេងក្អាង ច្រងេងច្រងាងនោះប្លន់យកស្នាមថើបដំបូងរបស់នាងយ៉ាងព្រហើន។ បបូរមាត់របស់គេសង្កត់លើបបូរមាត់របស់នាងខ្លាំងៗ ហាក់ដូចគេជាម្ចាស់បបូរមាត់របស់នាង ហើយបបូរមាត់របស់គេក្តៅណាស់ ព្រោះពេលសង្កត់លើបបូរមាត់នាងហើយ ដកចេញភ្លាមៗ ក៏អារម្មណ៍ក្តៅនោះនៅតែជិតដាម។

"យើងនឹងបានឃើញគ្នា រ៉ែមសៀ"

នាងនិងគេ នឹងបានឃើញគ្នា ទោះរៀបការក្លាយជាភរិយារបស់គេក៏ដោយ



តែនាងនឹងរឹងទទឹងដាក់គេ នាងមិនព្រមចុះញ៉មគេលុះក្រោមអំណាចរបស់គេ គេត្រូវតែទទួលបានមេរៀនធំពីការប្រមាថកិត្តិយសនាង។ ស្អាយអារម្មណ៍ដែលខំសរសើរគេ អ្នកក្លាហានដែលហ៊ានពលីជីវិតដើម្បីបងប្រុសរបស់នាង។

"ខ្ញុំនឹងស្អប់លោក"

ព្រះនាងកំពូលសម្រស់នៅតែគិតដល់ រ៉ែមសៀ ដោយអារម្មណ៍ឈឺចៀបក្នុងទ្រូង។ វាចាទាំងនោះបង្ហាញពីការស្អប់និងខ្ពើមរអើម។ ក្នុងពេលដែលគេមិនត្រូវការនាង នាងនឹងមិនត្រូវការគេដូចគ្នា។

**ភាពខែងរែងរបស់ រ៉ែមសៀ ភកប់នៅក្នុងរាងកាយ ចិត្តវិញ្ញាណសូម្បីតែ** ពេលនៅជាមួយមនុស្សស្រីនៅលើគ្រែ។ ស្រីកំណាន់ គេនឹងថើបពួកនាង ពេលដែលចង់ថើបប៉ុណ្ណោះ ដែលវាកើតឡើងតិចណាស់ ព្រោះសម្រាប់គេ ការថើបមាត់ គឺជាទំនាក់ទំនងដែលស្និទ្ធស្នាលពេក ម្យ៉ាងទៀតបើមិនចង់ថើបគេនឹងមិនបង្ខំចិត្តធ្វើ។

តម្រូវការផ្នែករាងកាយរបស់គេ ជារឿងល្វែងក្រោម មិនមែនល្វែងលើ ទោះមិនបាច់ថើប ក៏គេអាចប្រើម្រាមដៃនិងមាត់ ដាស់រាងកាយរបស់ពួកនាងបាន។

"លោក...ម្ចាស់"

ស្រីកំណាន់ដែលគេចាំបានថា ទើបតែយកនាងមកកាលពីខែមុន ជូរ



ហៅគេ។ ពេលនេះនាងដេកផ្កាប់មុខនៅលើគ្រែ បង្អួតភាពសិចស៊ី ដែលបុរស

ប្រាជ្ញា រីអនត្រគាកមករកដើម្បីទទូលយកភាពក្ដៅគគុកពី រ៉េមសៀ។

តេមិនចូលចិត្តមនុស្សស្រីឱបក្រសោប តែខណៈនោះគេបដិសេធតម្រូវការតាមធម្មជាតិរបស់មនុស្សប្រុសមិនបាន ទើបតែងតែធ្វើសង្គ្រាមតណ្ហាជាមួយស្រីរបស់គេដោយឲ្យពួកនាងបែរខ្នងដាក់។

"លោកម្ចាស់"

ស្រីកំណាន់ជូរដូចក្រាបឈើ ព្រោះភ្លើងតណ្ហារបស់គេក្ដៅគគុកនិងពុះកញ្ជ្រោល ប៉ុន្តែដឹងច្បាស់ថាមិនអាចបំបាំងប្រាជ្ញាអ្វីពីបុរសល្អម្នាក់នេះបាន។ រ៉េមសៀ ផ្តល់ការមើលថែបានល្អ និងដរាបណាដែលនាងរស់នៅក្រោមច្បាប់របស់គេ ទោះគេចាប់អារម្មណ៍ស្រីផ្សេង ក៏នាងត្រូវបានគេមើលថែបន្ត។

មិនធ្លាប់មានស្រីណាបានធ្វើជាម្ចាស់របស់ រ៉េមសៀ គេមិនអនុញ្ញាតឲ្យស្រីណាធ្វើបែបនោះ ប៉ុន្តែមិនមែនមិនធ្លាប់មានអ្នកណាព្រហើន។ ស្រីកំណាន់ដែលគិតថាខ្លួនឯងមានឥទ្ធិពលចំពោះគេ បង្ហាញអំណាច ធ្វើដូចខ្លួនជាភរិយា លទ្ធផលទទួលនោះ គឺនាងត្រូវកម្ចាត់ចេញពីជីវិតរបស់គេភ្លាមៗ។

គេគ្មានចិត្តឲ្យស្រីណាទាំងអស់ តួនាទីរបស់ពួកនាងគឺធ្វើខ្លួនជាវត្ថុបម្រើលើគ្រែរបស់គេ ដែលពួកនាងយល់ព្រមធ្វើ គឺដើម្បីការសប្បាយរបស់ខ្លួនឯង ហើយអ្វីដែលពួកនាងបំបាំងដូចគ្នា គឺបេះដូងរបស់ រ៉េមសៀ។

មានស្ត្រីដែលចង់សាកនិងបេះដូងរឹងកំព្រឹសរបស់ រ៉េមសៀ លើសពីប្រាំនាក់ លទ្ធផលគឺដូចគ្នាទាំងអស់ ហើយពេលនេះពួកនាងក៏មិនបានរស់នៅក្នុងប្រាសាទក្រេវីក្រយ សូម្បីតែនាងក៏ដូចគ្នា នាងត្រូវដឹងថា ខ្លួនឯងនៅក្នុងឋានៈ



ហាមមានមហិច្ឆតា។ ហាមគិតធំហួសមាឌ ព្រោះ រ៉េមសៀ រៀបចំនាងនិងស្រីកំណាន់ឯទៀតនៅក្នុងឋានៈច្បាស់លាស់ហើយ។

នៅក្នុងប្រាសាទក្រេវីក្រយ មានកន្លែងស្នាក់នៅសម្រាប់ស្រីកំណាន់ពួកនាងនៅជាមួយគ្នានៅក្នុងបរិវេណធំទូលាយ និងត្រូវតុបតែងស្អាត មានបន្ទប់ផ្ទាល់ខ្លួន និងអ្នកបម្រើផ្ទាល់ខ្លួន។

"លោកម្ចាស់"

សំឡេងញ័រនោះ ធ្វើបានត្រឹមហៅគេប៉ុណ្ណោះ ដៃទាំងពីរខ្ទាំពូក ដោយចិត្តពុះកញ្ជ្រោល នៅលើគ្រែធំទូលាយក្នុងបន្ទប់ដែលគេយកធ្វើជាបន្ទប់បន្ធូរអារម្មណ៍ ដោយបន្ទប់នេះស្ថិតនៅក្នុងបរិវេណកន្លែងស្នាក់នៅរបស់ស្រីកំណាន់ហើយគេនឹងមកទីនេះពេលត្រូវការបន្ធូរអារម្មណ៍។

ស្ត្រីដែលត្រូវជ្រើសរើសឲ្យនៅក្នុងបន្ទប់នេះ នឹងត្រូវកំណត់ទីតាំង និងបែងចែកច្បាស់លាស់ ថាពួកនាងមានសិទ្ធិនៅក្នុងកន្លែងនេះតែប៉ុណ្ណោះ។ រ៉េមសៀ មិនអនុញ្ញាតឲ្យស្រីកំណាន់ចេញមកក្រៅកន្លែងដែលគ្រប់គ្រង ចំណែកស្ត្រីដែលត្រូវការសេរីភាព គឺត្រូវរាយការណ៍ឲ្យដល់អ្នកមើលការខុសត្រូវទីនេះ ហើយពួកនាងនឹងត្រូវដោះលែង ពេល រ៉េមសៀ មានបញ្ហា។

ពេលនេះ គេកំពុងរាយវេទមន្តទៅលើស្រីនៅក្រោមរាងកាយ និងផ្តល់សេចក្តីសុខឲ្យខ្លួនឯង។ រាងកាយទាក់ទាញរបស់នាងកន្ទ្រាក់ម្តងហើយម្តងទៀត តែកម្លាំងពលំរបស់គេមិនថមថយ គេនៅតែធ្វើសកម្មភាពគ្រប់គ្រងនាងដោយភាពក្តៅគគុក។



កែវភ្នែករបស់គេឆាបឆេះដោយភ្លើងប្រាថ្នា តែវាមានត្រឹមភាពក្តៅគគុកដែលត្រូវការ ការដោះលែងប៉ុណ្ណោះ ទើបធ្វើឲ្យភ្នែកមួយគូនេះគួរឲ្យខ្លាច ស្រី នៅក្រោមរាងកាយ ស្រែកដោយសេចក្តីសុខរបស់រាងកាយដែលហោះហើរទៅរកភាពរញ្ជួយ។

"លោកម្ចាស់ ទ្រាំ...មិនបាន...ទេ" នាងហត់នឿយខ្លាំងណាស់។

រ៉េមសៀ ដាក់ដៃលើខ្នងដែលរលោង ហើយត្រលែងត្រគាកទៅរកល្បឿនដូចព្យុះ សំឡេងថ្ងូរតិមាយា ព្រោះនាងមិនត្រូវការឲ្យគេឈប់ តែត្រូវការឲ្យគេធ្វើដាក់រាងកាយរបស់នាងជាបន្តបន្ទាប់។

សំឡេងថ្ងូចថ្ងូរនោះឮខ្លាំងទៅខ្លាំងទៅៗ គេកំពុងតែធ្វើឲ្យពិភពរបស់នាងរញ្ជួយដោយការប្រាថ្នា។ គេជាបុរសប៉ិនប្រសប់ណាស់ តាំងពីនាងធ្លាប់ជួប។

រ៉េមសៀ មិនចូលចិត្តស្រីក្រមុំបរិសុទ្ធ ស្រីកំណាន់របស់គេត្រូវតែមិនមែនជាស្រីព្រហ្មចារី ព្រោះគេមិនត្រូវការបង្រៀនក្បាច់ក្បួនអីដល់ពួកនាង គេគ្មានពេលវេលាគ្រប់គ្រាន់ទើបត្រូវការតែស្ត្រីដែលមានជំនាញនិងទទួលយកតម្រូវការក្តៅគគុករបស់គេបានដោយគ្មានដែនកំណត់ ដូច្នោះហើយស្ត្រីព្រហ្មចារី ក្លាយជាបន្ទុកដែលគេត្រូវថយឲ្យឆ្ងាយ។

ក្លិនចារី សាយភាយនៅក្នុងបន្ទប់ធ្វើការរបស់ រ៉េមសៀ ដោយស្ថានភាពនៅក្នុងនេះគ្មានរបៀប សណ្តាប់ធ្នាប់ ឯកសារ ផែនទី និងរបស់របរតាំងបាច់រាយប៉ាយ ញើរញ៉ៃ ហើយបន្ទប់នេះជាកន្លែងហាមប្រាម។



អ្នកបម្រើដែលអាចចេញចូលបន្ទប់នេះបានមានតែ ចច ដែលជាមនុស្សជំនិតប៉ុណ្ណោះ។ គេមានតំណែងជាប្រធានអ្នកបម្រើក្នុងប្រាសាទត្រេវ៉ៃព្រយ និងជាមនុស្សដែលមានសិទ្ធិចូលមកបោសសម្អាតបន្ទប់ធ្វើការនេះ តែមិនថា ចច ធ្វើអីបន្ទប់នេះក៏ដោយ របស់របរគ្រប់យ៉ាងនៅក្នុងត្រូវដាក់នៅកន្លែងដើម។

គំនរឯកសារដែលគួរហៅថាគំនរសំរាមនោះ បើបាត់តែមួយសន្លឹក រ៉េមសៀ នឹងដឹងភ្លាម។ ទោះជាមនុស្សដែលចៅហ្វាយទុកចិត្តក៏ដោយ ចច នៅតែអនុវត្តតួនាទីរបស់ខ្លួនដោយការប្រុងប្រយ័ត្ន។

ពេលនេះ រ៉េមសៀ កំពុងមួម៉ៅ តែកំរើយមុខ ចង្អុលទៅតុមូលនៅកៀនជញ្ជាំង ដើម្បីឲ្យ ចច ដាក់ថាសភេសជ្ជៈនៅលើនោះ។

"លោកម្ចាស់ យកអីបន្ថែមទេ?"

"មិនយក ចេញទៅ"

"បាទ"

ការរួមត្រេជាមួយស្រីកំណាន់ចុងក្រោយ មិនធ្វើឲ្យ រ៉េមសៀ បាត់មួម៉ៅ។ គេមានការងារជ្រែកដៃត្រូវធ្វើ មានបញ្ហាចលាចលនៅក្នុងប្រទេស សាក់ខារៀ ដែលត្រូវចាត់ការ ដោយគេជាកម្លាំងសំខាន់ តែព្រះអង្គម្ចាស់ ខាឡូម៉ាន់ នៅបោះបន្ទុកធំមកលើស្មារបស់គេទៀត។

*ព្រះនាង ខ្លារិហ្សា ម៉ាលខៃសេនតេ!*

អ្នកកំលោះ លើកដៃប៉ះបបូរមាត់ បបូរមាត់ក្តៅរបស់គេសង្កត់លើបបូរមាត់ក្រពុំស្អាត គឺដើម្បីប្រកាសអំណាចរបស់គេ គេថើបលឿន ថើបខ្លាំង តែរសនៃ



ការប៉ះពាល់បែរជាច្បាស់ចែស។ បបូរមាត់របស់នាងទន់ណាស់ ទន់បែបដែលមាត់របស់ស្ត្រីគ្រប់រូបដែលគេធ្លាប់ថើប ពៀបគ្នាមិនបាន។

សម្រស់របស់នាងនឹងធ្វើឲ្យគេពេញចិត្តជាងនេះ បើវាមកជាមួយនឹងចរិតទន់ភ្លន់ ស្តាប់បង្គាប់ តែព្រះនាងកំពូលសម្រស់គ្មានចរិតដែលគេពេញចិត្ត។ ចរិតរបស់នាងឬ? គឺនាងហ៊ានស្រែកដាក់មុខគេដោយសម្តីដែលគ្មានការក្រែងរអែងចិត្តនោះឯង។

'ចាំទុក វ៉ែមសៀ ដាវ៉ៃហ៊ីណោស ខ្ញុំមិនព្រមរៀបការជាមួយលោក'

ហ៊ឺ! វ៉ែមសៀ ដាវ៉ៃហ៊ីណោស ម្នាក់នេះក៏មិនចង់រៀបការនឹងព្រះនាងមេបញ្ហាដែរ តែគេគ្មានជម្រើសដូចតែនាងដែរទៀតហ្នឹង ព្រោះបញ្ហារបស់ខាឡូម៉ាន់ មិនអាចចៀសបាន ហើយគេក៏ស្មោះត្រង់ចំពោះបុរសម្នាក់នោះដោយមិនអាចរំលងរួសដាក់បាន។

"ឈឺក្បាលណាស់"

គេទើបតែត្រឡប់មកពីក្រុងសេនដីរីក ព្រោះមានភារកិច្ចនៅទីនោះ និងមានបញ្ហាជាច្រើនទៀតត្រូវចាត់ការ។ ទោះសម្ព័ន្ធមិត្តដែលជួយផ្តល់អំណាចចាស់និងគាំទ្រព្រះអង្គម្ចាស់ ខាឡូម៉ាន់ នៅតែជួយធ្វើការយ៉ាងសស្រាក់សស្រាំ ហើយភារកិច្ចរបស់ពួកគេនៅតែជាភារកិច្ចធំ និងត្រូវតែចាត់ការជាបន្ទាន់។

"នាងនឹងបង្កបញ្ហាអ្វីខ្លះក៏មិនដឹង"

វ៉ែមសៀ ជឿជាក់ថា កាអ៊ិន ត្រូវតែជាបញ្ហា ព្រោះនាងជាប្អូនស្រីដែលខាឡូម៉ាន់ស្រឡាញ់ជាងគេ ទទួលបានការយកចិត្តទុកដាក់ ទើបមិនចេះប្រកប



ពាក្យថា ឃ្លើសចិត្ត ហើយលទ្ធផលនៃការទំយើប្អូនស្រីហួសហេតុរបស់ព្រះអង្គម្ចាស់ ក៏ធ្វើឲ្យនាងត្រូវតែបានដូចចិត្តគ្រប់រឿង។

អ្នកកំលោះដើបចេញពីកៅអីវែល ដើរទៅដាក់បង្អួយលើសាឡុងចាក់កាហ្វេខ្មៅពីថូថ្មដាក់ពែង ហើយលើកផឹក។ កាហ្វេខ្មៅរបស់គេ ជាកាហ្វេខ្មៅដែលមិនដាក់អ្វីទាំងអស់ ក្រៅពីទឹកក្តៅ ព្រោះគេមិនចូលចិត្តភេសជ្ជៈផ្អែមៗ រួមទាំងធ្វើខ្លួនផ្អែមល្ហែមដែរ។

គេមិនមែនជាមនុស្សប្រុសដែលធ្វើដាក់មនុស្សស្រីដល់ម្ល៉ឹង គេនឹងមិនលួងខ្លៅជាលើកទីពីរដាច់ខាត រឿងចង្រៃបែបនោះត្រូវតែមិនកើតឡើងទៀតដូច្នោះហើយ ទើបគេត្រូវមានបញ្ញាស្មារតីចំពោះគ្រប់រឿង ជាពិសេសរឿងមនុស្សស្រី។

វ៉ែមសៀ កំណត់ព្រំដែនរបស់គេចំពោះមនុស្សស្រីនៅក្រោមអំណាចច្បាស់លាស់។ គេពេញចិត្ត តែមិនស្នេហា ការពេញចិត្តរបស់គេគឺតម្រូវការផ្នែករាងកាយ ចំណែកស្នេហាជាអារម្មណ៍ផ្លូវចិត្ត ដែលវាមិនធ្លាប់កើតមាន ព្រោះគេគ្រប់គ្រងខ្លួនឯងបានល្អណាស់ចំពោះរឿងនេះ។ មនុស្សស្រីជាភេទដែលអាចប្តូរចិត្តបានងាយៗ ពួកនាងរារែក ទាមទារ និងគួរឲ្យធុញទ្រាន់។

"ខាឡូម៉ាន់ ឯងអាចស្តាយក្រោយដែលបញ្ជូនប្អូនស្រីមកឲ្យខ្ញុំមើលថែ"

រសជាតិល្វីងជាប់អណ្តាតរបស់កាហ្វេ ហូរយឺតៗពីបំពង់កចូលទៅក្នុងរាងកាយរបស់វ៉ែមសៀហើយអត់គិតមិនបានថាត្រូវមើលថែនាងយ៉ាងណាទើបសក្តិសម ព្រោះថានាងជាប្អូនស្រីព្រះអង្គម្ចាស់។ ការទទួលខុសត្រូវជីវិតមនុស្ស





Scanned by CamScanner

ស្រីណាម្នាក់ជារឿងធំ ស្រីកំណាន់គេគ្រាន់តែឲ្យរបស់របរនិងផ្តល់ភាពងាយស្រួល តែភរិយាត្រូវមានភាពសំខាន់មួយលំដាប់ទៀត។

ចិញ្ចើមក្រាស់ជ្រួញចូលគ្នា គ្រាន់តែនឹកដល់ការមានភរិយានៅក្បែរកាយ ភាពតានតឹងក៏កើតមាន និងដកដង្ហើមធំ។

"ហាយនះច្បាស់ណាស់"

វ៉ែមសៀ ស្រួសខ្លាំង ត្រូវចាក់កាហ្វេផឹកមួយកែវទៀត។ គេត្រូវបញ្ចុះបញ្ចូល ការ៉ុន ឲ្យនាងព្រមទទួលឋានៈភរិយារបស់គេដោយមិនចាំបាច់ឲ្យអ្នកណាទៀតទេ។ គេមិនត្រូវការមានស្នេហា ព្រោះស្នេហាធ្វើឲ្យគេទន់ជ្រាយ។

"ខាឡូម៉ាន់ ឯងកំពុងធ្វើឲ្យខ្ញុំឆ្កួត"

វ៉ែមសៀ ទាំថ្ពាមណែន និងធ្វើបានត្រឹមរអ៊ូរទាំដល់ ខាឡូម៉ាន់។ ក្នុងស្ថានការណ៍ពិត គេត្រូវត្រៀមខ្លួន ដើម្បីរៀបការជាមួយព្រះនាងមេបញ្ហា។ នាងជាបញ្ហាសម្រាប់គេ គេជឿថា ការ៉ុន មិនព្រមឲ្យជីវិតរបស់គេស្ងប់សុខនោះទេ ព្រោះនាងបានឮគេបដិសេធនាង ហើយនាងក៏មិនពេញចិត្តខ្លាំងដែរ។

"ពេល្ហិយ!"

គេរុកពែងកាហ្វេនឹងចានទ្រ ដែលវាវ៉ៃតែបែក សំណាងដែលសាច់កែវក្រាស់និងមាំល្អ ទើបអាចរក្សារូបរាងដើមបាននិងគិតថា នាងចង់មានអារម្មណ៍យ៉ាងណាក៏ស្រេចតែនាង ព្រោះគេនឹងបង្ខំចិត្តទទួលយកនាងជាភរិយា។

*ត្រូវយកឈ្នះគេដោយស្នេហា!*



ការ៉ុន មិនចង់ចាប់អារម្មណ៍ មិនចង់ផ្តោតសំខាន់ បើឲ្យទាក់ទាញ វ៉ែមសៀ នាងសុខចិត្តលោតជ្រោះវាងាយជាង ហើយមុខនាងក៏ក្រមូវ ព្រោះការគិតដល់ វ៉ែមសៀ ធ្វើឲ្យនាងអស់អារម្មណ៍រីករាយ។ សេចក្តីសុខរបស់នាងឬ វាហោះហើរទៅបាត់តាំងពីបានឮគេនិយាយពីនាងម្ល៉េះ នាងជាបិសាចនៅក្នុងភ្នែករបស់គេ បែបហ្នឹងពួកគេនឹងរស់នៅបែបស្វាមីភរិយាយ៉ាងណាទៅ។

"ផឹកកាកាវស៊ិន ការ៉ុន"

ចាស្ទីន ដាក់ពែងកាកាវក្តៅនៅលើតុ។ នាងជាមិត្តជិតស្និទ្ធរបស់ ការ៉ុន មានឱកាសបានការងារនឹងន ព្រោះ ការ៉ុន ជួយផ្តាំផ្ញើឲ្យ។

នាងជាកូនកាត់ ម្តាយជាជនជាតិកូរ៉េខាងត្បូង ឪពុកជាកូនកាត់កូរ៉េខាងត្បូង-អ៊ីតាលី។ នាងនិង ការ៉ុន ស្គាល់គ្នានៅសាលារៀនប្រចាំនៅអង់គ្លេស ហើយរាប់អានគ្នាតាំងពីពេលនោះមក និងបន្ថែមភាពស្និទ្ធស្នាលជារៀយៗ។ ទោះចរិតរបស់ពួកនាងខុសគ្នា តែក្លាយជាធាតុផ្សំដែលលាយចូលគ្នាបានល្អ ម្នាក់ត្រជាក់ ម្នាក់ក្តៅ ម្នាក់ទឹក ម្នាក់ទៀតជាភ្លើង ម្នាក់រហ័សរហួន ម្នាក់ទៀតយឺតយ៉ាវ។

ចាស្ទីន រៀនចប់ និងធ្វើការនៅក្រុមហ៊ុនដែលរាជវង្ស ម៉ាលខៃសេនគេជាម្ចាស់។ នាងត្រូវជ្រើសរើសឲ្យមកធ្វើការនៅសាក់ខារៀ ដែលនាងក៏យល់ព្រម ព្រោះ ការ៉ុន ចង់ឲ្យមិត្តភក្តិមកនៅជិត។

នាងជាក្មេងកំព្រា ឪពុកម្តាយមានគ្រោះថ្នាក់តាំងពីនាងនៅតូច ហើយអ្នកមើលថែនាង គឺលោកយាយ។ គ្រួសាររបស់ឪពុកជាអ្នកមាន ទើបនាងមាន



ជីវិតស្រណុកសុខស្រួល មិនចាំបាច់ប្រឹងប្រែងត្រដាបត្រដួស លោកយាយក៏រៀបចំផែនការជីវិតឲ្យចៅរាល់ ដើម្បីឲ្យនាងមានគ្រប់យ៉ាងដូចគេឯងនៅក្នុងសង្គម និងអាចមើលថែខ្លួនឯងបាន។

លោកយាយដ៏ល្អរបស់នាង ចែកឋានបន្ទាប់ពីនាងរៀនចប់បានមួយឆ្នាំ។ ទោះសោកសង្រេងយ៉ាងណា តែការចាកចេញទៅរបស់គាត់ ព្រោះជរារាងកាយរុះរោយទៅតាមពេលវេលា ហើយអ្នកដែលនៅក្បែរនាងពេលវេលាសោកសៅនោះគ្មានអ្នកណាក្រៅពី ការ៉ិន ទើបនាងមិនរារែក មិនគិតច្រើនពេលមិត្តភក្តិបបួលមករស់នៅ សាក់ខាវៀ ជាមួយ។

ពេលមិត្តសម្លាញ់យល់ព្រម ការ៉ិន ក៏ដំណើរការបន្ត។ ចាស្មីន មានឈ្មោះជាបុគ្គលិករបស់ក្រុមហ៊ុនដែលត្រូវផ្ទេរមកប្រទេស សាក់ខាវៀ ដោយការងារនៅទីនេះ គឺមើលការខុសត្រូវរូបភាពរបស់សមាជិករាជវង្ស ម៉ាលខៃសេនតេ ដែលក្នុងនាទីនេះមានសមាជិកច្រើន ដោយ ចាស្មីន ជាប្រធានក្រុម។ តាំងពីសម្លៀកបំពាក់ ស្បែកជើង ឬ គ្រឿងតុបតែងលម្អ នាងត្រូវជ្រើសរើសសម្រិតសម្រាំង ឬ ច្នៃម៉ូត កាត់ដេរដើម្បីភាពសក្តិសម។

នាងមានកូនចៅនៅក្រោមការបង្គាប់បញ្ជាជាងសាមសិបនាក់ ជាអ្នកជំនាញតាមផ្នែកផ្សេងៗ ពាក់ព័ន្ធនឹងគ្រឿងតែងកាយ គ្រឿងលម្អ។ នាងអភិវឌ្ឍខ្លួនឯង និងច្នៃប្រឌិតជានិច្ច ដើម្បីមិនឲ្យមានពាក្យសម្ដីថានាងមានខ្នងហើយតាំងពីមកធ្វើការនៅ សាក់ខាវៀ នាងរវល់ការងារណាស់ ឯសមត្ថភាពរបស់នាង គ្មានអ្វីឲ្យទាស់ ហើយបើទោះជាមានអ្នករិះគន់ ក៏គ្មានអ្នកណាហ៊ាន



និយាយ ព្រោះបញ្ហាតែងតាំងនាងឲ្យទទួលខុសត្រូវការងារនេះគឺមកពីព្រះអង្គម្ចាស់ ខាឡូម៉ាន់។

"គេនិយាយពីខ្ញុំអាក្រក់ណាស់"

"នោះមកពីគេមិនទាន់ស្គាល់ឯង"

ចាស្មីន ដាក់បង្អួយលើកៅអីមួយទៀត ហើយស្រវាចាប់ដៃរបស់ព្រះនាងលួងលោមដោយស្នាមញញឹមដ៏ស្រទន់។

"នោះកាន់តែយ៉ាប់ហើយ គេមិនគួរកាត់ក្ដីខ្ញុំ ព្រោះគេមិនស្គាល់ខ្ញុំ"

"ហើយឯងកំពុងតែធ្វើឲ្យគេបានស្គាល់ជាតុពិត ដែលគួរឲ្យស្រឡាញ់របស់ឯង"

"ក្នុងពេលដែលគេគិតថាខ្ញុំជាបិសាច ខ្ញុំនឹងធ្វើជាបិសាចឲ្យគេវៃមុខ"

ចាស្មីន នៅតែញញឹម។ រ៉េមសៀ ដាវ៉ៃហ៊ីណេស ជាបុរសដែលទទួលបានការសរសើរពីស្ត្រីទូទាំងប្រទេសសាក់ខាវៀននៅក្នុងលំដាប់ជួរមុខ ហើយបើមានបុរសណាមានភាពលេចធ្លោជាង ម្នាក់នោះគឺ ខាឡូម៉ាន់។

ព្រះអង្គម្ចាស់ជាប្រមុខប្រទេសនិងនៅលីវ តើស្ត្រីណាហ៊ានរៀបខ្លួនឯងនឹងទ្រង់ ដែលសូម្បី រ៉េមសៀ ក៏ខ្ពស់ហួសឈោង។ មន្តស្នេហ៍បែបព្រៃផ្សៃរបស់គេរញ្ជួយចិត្តសម្រាប់ស្ត្រី។ ការ៉ិន ជាប់ចិត្តនឹងភាពស្មោះត្រង់ដែល រ៉េមសៀ មានចំពោះព្រះអង្គម្ចាស់ ប៉ុន្តែពេលនេះការជាប់ចិត្តនោះរុះរោយទៅហើយ។

"ការ៉ិន កុំយកអារម្មណ៍មកសម្រេចចិត្ត"

"មនុស្សបែបហ្នឹងសមតែបានការវាយបកយ៉ាងសាហាវ ខ្ញុំធ្លាប់គិតថាខ្ញុំ



នឹងព្យាយាមឱបក្រសោបទំនាក់ទំនងនោះ ខ្ញុំដឹងថាខ្លួនឯងមានសិទ្ធិរើសមិនច្រើន ពេលយើងកើតក្នុងខ្សែរាជវង្ស គឺត្រូវតែមានការលះបង់"

"ឯងមានបេះដូងប្រពៃណាស់ ការ៉ុន"

"អនាគតស្វាមីខ្ញុំ ហៅខ្ញុំថាព្រះនាងមេបញ្ជា"

"តែគេនឹងដឹងថាគេគិតខុសពេលបានរួមរស់នឹងឯង"

"គេត្រូវតែក្អួតឈាម ព្រោះគេគិតត្រូវទៅវិញទេ"

ចាស្មីន ប្រចាច់ដៃមិត្តសម្លាញ់តិចៗ។ ការ៉ុន កំពុងខឹង ហើយកំហឹងនេះក៏ត្រូវកម្ចាយដាក់ រីមសៀ ប៉ុន្តែនាងចង់ឲ្យមិត្តភក្តិក្លាយជាស្ត្រីដែលមានសុភមង្គលនឹងជីវិតគូ ដែលការវាយបក រីមសៀ បែបនោះ នឹងធ្វើឲ្យព្រះនាងកើតទុក្ខជាងកើតសុខ។

"ឯងមិនជឿថាខ្ញុំធ្វើបែនឬ ចាស្មីន ?"

ការ៉ុន ជាស្ត្រីទំនើង តែមិនមែនជាគ្មានហេតុផល។ មិត្តភក្តិរបស់នាងក៏មានចំណុចគួរឲ្យស្រឡាញ់ដែរ តែគួរឲ្យស្ដាយដែល រីមសៀ និងមិនបានមើលឃើញចំណុចនោះ ទាល់តែព្រះនាងឈប់ងរ។

"ខ្ញុំជឿឯង ផឹកកាកាវសិន បើត្រជាក់នឹងមិនឆ្ងាញ់"

ដើម្បីមិនឲ្យមិត្តភក្តិកាន់តែតានតឹង ទើប ចាស្មីន ជួយឱបក្រសោបស្ថានភាពផ្លូវចិត្តនោះ។

ទោះធ្វើតាមសម្ដីមិត្តភក្តិ ដោយការលើកពែងកាកាវផឹកក៏ពិតមែន តែក្នុងចិត្តរបស់ព្រះនាង នៅតែមានឈ្មោះរបស់ រីមសៀ តាមអុកឡុក។



# ៣

## សង្គ្រាមទឹកមាត់

ការ៉ុន ចង់តែស្រែកដាក់មុខ រីមសៀ។ ពួកនាងមានតារាងពេលវេលាត្រូវណាត់ជួបគ្នា តែគិតថាគេប្រហែលមិនចង់ជួបនាង ចំណែកនាងមិនចង់ជួបគេដូចគ្នា។

នាងពាក់រ៉ូបវែង ពណ៌ផ្កាប៉ៃសរបស់វាស៊ីនឹងស្បែកផូរផង់ឲ្យស្មើកាន់តែភ្លឺថ្លា។ ស្បែកសពណ៌ផ្កាឈូក គួរឲ្យស្ងាបអង្អែល ទាញចូលភ្នែករបស់ រីមសៀ។ រ៉ូបឥតដៃនោះធ្វើឲ្យនាងមើលឃើញស្មារបស់នាងជាតូចយ៉ាងណា។

ខណៈដែលនាងមើលរំលងទោសៈដែលពួកគេមានចំពោះគ្នា តែងខ្លួនដើម្បីជួបគេជាការផ្ដល់កិត្តិយស តែ រីមសៀ បែរជាព្រងើយកន្តើយនឹងធ្វើបែបនោះ។

*មនុស្សឆ្កួត!*

ការ៉ុន ផ្ដាសាអ្នកកំលោះនៅក្នុងចិត្ត។ រីមសៀ ស្ថិតនៅក្នុងឋានៈដែលសមនឹងពាក្យប្រឡាក់ប្រឡូស តែគេជាមនុស្សធំហើយមិនមែនកូនក្មេងទៀតទេ គួរដឹងថាគេត្រូវងូតទឹក និងផ្លាស់ប្ដូរសម្លៀកបំពាក់មុនពេលមកជួបនាងនៅទីនេះ មកដំណាក់របស់ព្រះនាង ការ៉ុន ដែលបើកទ្វារស្វាគមន៍គេតាមបញ្ជា



របស់ព្រះអង្គម្ចាស់ ខាឡូម៉ាន់។

"រ៉េបសៀ ដាវ៉ៃហ៊ាំណោស!"

រ៉េមសៀ ខិនតំនាប់អ្នកដែលគ្រហឹមហៅឈ្មោះរបស់គេ។

ការពិតគេគ្មានចេតនាគ្មានមារយាទ តែព្រោះមានបញ្ហាមុនពេលធ្វើដំណើរ ធ្វើឲ្យយឺតយ៉ាវ ទើបត្រូវប្រញាប់ប្រញាល់មក ហើយបើឲ្យផ្លាស់សម្លៀកបំពាក់សិន គឺត្រូវចំណាយពេលប្រហែលមួយម៉ោងទៀត ដែលគេមិនធ្វើព្រោះគេជាមនុស្សទៀងពេល ទើបនៅលើដងខ្លួននាពេលនេះ ជាអាវយឺតខោទាហានរបស់ប្រទេសសាក់ខារៀ។ អាវយឺតប្រឡាក់ គេដឹងច្បាស់ ព្រោះប៉ុកនឹងធូលីដោយសារការបង្កប់ខ្លួនទៅសង្កេតការណ៍នៅទីតាំងលាក់ខ្លួនរបស់ពួកខ្មាំងមួយក្រុម។

គេទើបតែចេញពីបរិវេណគ្រោះថ្នាក់ ដើម្បីធ្វើដំណើរមកជួបព្រះនាងការ៉ុន។ ទោះធ្វើដំណើរដោយឧទ្ធម្ភាគចក្រ តែមកទាន់ពេលណាត់ទាំងប្រផុតប្រផើយ ហើយទឹកមុខរបស់នាង បញ្ជាក់ឲ្យដឹងច្បាស់ថា កំពុងខឹងខ្លាំង។

មិនត្រឹមតែមុខមាត់ទេ ស្នាតូចស្ទើងហួសហេតុនោះក៏ញ័រទទ្រើតដែរ ដែលមិនមែនខ្លាចគេ តែកំពុងខឹងគេ។

រ៉េមសៀ ប្រសព្វភ្នែកនឹងព្រះនាង ហើយញាក់ស្នាបន្តិច។ នាងគួរមានស្មារតីគិតឲ្យបានល្អថា គេអាចមានការសំខាន់ដែលធ្វើឲ្យត្រូវមកទីនេះដោយស្ថានភាពបែបនេះ តែនាងបែរជាជ្រើសរើសខឹងគេ មើលគេដោយទោសៈ។

ក្រៅពីមិនសុំអធិប្បាយហើយ គេគ្មានតួនាទីអ្វីត្រូវយកចិត្តយកថ្លើមនាងដែរ។ គេរអាចិត្តនឹងអាកប្បកិរិយារបស់នាងទាំងដែលទើបមានឱកាសបាននៅជិតគ្នា នោះមកពីគុណវិបត្តិរបស់នាងវាខ្ចាតចូលត្រចៀករបស់គេញឹកញាប់នោះឯង។

"ខ្ញុំត្រូវអញ្ជើញលោកចូលក្នុងដំណាក់ឬអត់?"

គេតែងខ្លួនបែបនេះ នាងគួរតែបណ្ដេញគេចេញពីដំណាក់ទើបត្រូវ។ រ៉េមសៀ ប្រើពាក្យសម្ដីប្រមាថនាងហើយនៅប្រើអាកប្បកិរិយាមិនផ្ដល់កិត្តិយសដាក់ទៀត។

"គឺត្រូវតែបែបហ្នឹង"

គេតប ទាំងតំរោះតំរ៉ើយ។ គេហត់នឿយនិងត្រូវបញ្ជាឲ្យមកទីនេះ ទាំងដឹងថារកការសប្បាយចិត្តពីដំណាក់របស់ព្រះនាងមេបញ្ហាមិនបាន តែពេលត្រូវប្រឈមនឹងកាយវិការក្រទិក្រទើ ងើយលើកើងទ្រូងរបស់នាងហើយ វាធ្វើឲ្យគេកាន់តែធុញទ្រាន់និងម្ហូម៉ៅ។

គេមកទីនេះដើម្បីអង្គុយមើលមនុស្សស្រីគ្មានប្រយោជន៍ម្នាក់ ពើងទ្រូងដាក់ដើម្បីអ្វី។ គេមានការត្រូវធ្វើ ការងារសំខាន់ពាក់ព័ន្ធនឹងការការពារប្រទេសសាក់ខារៀ មិនឲ្យធ្លាក់ទៅក្នុងដៃរបស់ពួកដែលគ្មានសិទ្ធិទៀត តែព្យាយាមធ្វើឲ្យខ្លួនឯងមានសិទ្ធិ។ គេត្រូវលបចូលទៅទីនោះទៀត ដើម្បីសង្កេតការណ៍ និងផ្ដាច់ជីវិតរបស់ពួកវាម្ដងមួយៗ ហើយបើនរណាធ្វើខ្លួនមានប្រយោជន៍ ផ្ដល់ទិន្នន័យឲ្យគេ គេនឹងទុកជីវិតឲ្យសិន។

រ៉េមសៀ កំពុងគិតដល់ការកម្ចាត់សត្រូវ ទើបកែវភ្នែករបស់គេទៅជារឹង





Scanned by CamScanner

កំព្រឹស ដូចអាកប្បកិរិយាដែលបង្ហាញឲ្យឃើញដែលធ្វើឲ្យ ការ៉ុន ញ័រខ្លួនកាន់តែខ្លាំងដោយទោសៈ។ បើសិនមិនបានទទួលបញ្ជាពីបងប្រុស នាងនឹងដេញ រ៉ែមសៀ ចេញពីបន្ទប់ទៅហើយ ព្រោះជាគេមិនពេញចិត្តមកទីនេះ ថែមទាំងធ្វើឫកឈ្លើយដាក់នាងទៀត។

"អញ្ជើញ តែសុំឲ្យលោកដឹងថា ខ្ញុំបង្ខំចិត្ត"

"ដូចគ្នា"

នាងសម្លក់សម្លឹងគេ ហើយធ្វើឆើយ បង្វិលខ្លួនដើរតន្ត្រំជើងនាំមុខចូលទៅក្នុងបន្ទប់ទទួលភ្ញៀវ ទើប រ៉ែមសៀ តាមមើលពីក្រោយ។ ការ៉ុន ជាស្រីស្អាត មិនថាខាងមុខ ឬ ខាងក្រោយ ក៏ស្អាតទាក់ទាញភ្នែក សក់រៀបទឹករលកនោះដូចវាវួញបែបនោះតាមធម្មជាតិ។

គេដឹងថាវាត្រូវរៀបចំឲ្យមានម៉ូតបែបនោះទម្លាក់ខ្លួនរសាយដូចទឹករលកពេញខ្នង តែគេមិនដឹងថាមនុស្សស្រីមានវិធីមើលថែវារបៀបណា។ រាងកាយរបស់នាងទាក់ទាញ ឈុតដែលនាងពាក់ ព្រលែងស្មាក៏ពិតមែន តែមិនបានមើលទៅសិចស៊ីអាក្រក់មើល ហើយរូបរាងរបស់នាងកាន់តែលេចធ្លោពេលដែលនាងធ្វើសកម្មភាព។

ក្រពាករបស់នាងមូលភ្លំ តូចង វាមានទំហំដែលគេមានអារម្មណ៍ថាវាសមសួននិងរាងកាយរបស់នាង។ ការ៉ុន ជាស្រីស្អាត ហើយបើចរិតរបស់នាងដូចមុខមាត់ប្រហែលជាល្អ និងបើសួរនាំគេមួយម៉ាត់ គេក៏ឆ្លើយពីរោះដាក់។

គេត្រូវនាំខ្លួនឯងមក ដោយស្ថានភាពរាងកាយបែបនេះ ព្រោះគេមាន



ការងារសំខាន់ ទើបមិនអាចផ្លាស់ខោអាវទាន់។ គេបានត្រឡប់ទៅប្រាសាទក្រវ៉ៃក្រយ រយៈពេលមួយសប្តាហ៍ហើយ តែគេមានផ្ទះសម្រាប់ស្នាក់អាស្រ័យនៅគ្រប់ទីក្រុងក្នុងប្រទេសសាក់ខារៀ។ គេនឹងត្រឡប់ទៅផ្ទះខ្លួនឯងសិនបើមានពេលគ្រប់គ្រាន់។

នាងមិនសួរនាំ ហើយខឹងគេ មើលមកគេជាមនុស្សគ្មានមារយាទ ដូច្នេះហើយគេនឹងបណ្តោយឲ្យនាងខឹង ខ្ជិលចំណាយពេលអធិប្បាយ។

"ព្រះនាង អញ្ជើញលោកឧត្តមសេនីយ រ៉ែមសៀ អង្គុយទៅ ព្រះម៉ែ"

ស៊ីឡា ខ្សឹបខ្សៀវប្រាប់ តែព្រះនាងមិនយកត្រចៀកស្តាប់។ នាងប្រសព្វភ្នែកនឹង រ៉ែមសៀ ផ្ទាញ់ផ្ទាលគេ ប្រកាសសង្គ្រាមតាមរយៈខ្សែភ្នែក។

អ្នកកំលោះធុញទ្រាន់មនុស្សស្រីមានចរិតបែបនេះមែនទែន មិនរង់ចាំឲ្យនាងអញ្ជើញ គេអញ្ជើញខ្លួនឯងហើយលើកដៃមើលនាឡិកា។

"បើលោកមានការរវល់..."

"ខ្ញុំត្រូវនៅទីនេះតាមការកំណត់ បើខ្ញុំជ្រើសរើសបាន ខ្ញុំមិនមកទីនេះតាំងពីដំបូង ព្រះនាង"

រ៉ែមសៀ ឆ្លើយតបទៅវិញ មុនពេលព្រះនាងនិយាយចប់។ នាងចង់បណ្តេញគេ ជាសិទ្ធិរបស់នាង តែគេចេញពីទីនេះមិនបាន ទាល់តែគ្រប់ការកំណត់ចំនួនពីរម៉ោង ព្រោះនេះគឺជាការនៅជិតដើម្បីសិក្សាពីគ្នា តែមិនដឹងថាបានសិក្សា ឬបានខាំគ្នាដោយពាក្យសម្តី។

"បើប្រញាប់ខ្លាំង ទៅវិញទៅ"





Scanned by CamScanner

ស៊ីឡា និង ហ្វីរ៉ា បើកភ្នែកធំៗដោយការភ្ញាក់ផ្អើល និងទៅជាទន់ជង្គង់។ ព្រះនាងនិយាយបែបនេះ បើសិន រ៉េមសៀ ខឹង តើនឹងមានអ្វីកើតឡើង។

"ព្រះនាងនិយាយបែបនេះដាក់លោកឧត្តមសេនីយមិនបានទេ"

"ហេតុអីនិយាយមិនបាន ទីនេះជាដំណាក់របស់ខ្ញុំ ខ្ញុំចង់និយាយអីក៏បាន"

រ៉េមសៀ ដកដង្ហើមធំ។ គេមិនពេញចិត្ត គេធុញថប់ គេមិនត្រូវការនៅទីនេះ។ នោះជាកាសាផ្លូវកាយគេដែល ការ៉ុន មើលដឹង។

"ព្រះនាង"

"ឈប់ហៅខ្ញុំទៅ ចេញឲ្យអស់ទៅ ឆុញ!"

ភាគតិចណាស់ដែល ការ៉ុន ស្រែកគំហកដាក់អ្នកបម្រើ តែម្តងនេះនាងគ្រប់គ្រងខ្លួនឯងមិនបានពេលមនុស្សរបស់ខ្លួនចូលដៃចូលជើងខាង រ៉េមសៀ។

ស៊ីឡា និង ហ្វីរ៉ា ត្រូវធ្វើតាមបញ្ជាម្ចាស់ស្រី រួមទាំងអ្នកបម្រើដែលទើបតែលើកគេសជ្ជៈមកដាក់លើតុដែរ ដែលស្ទុះស្ទាចេញពីបន្ទប់ ព្រោះភ័យខ្លាចនឹងការស្រែកឡូឡាបស់ព្រះនាង។

"អង្គុយចុះ ខ្លារីហ្សា"

រ៉េមសៀ ចេញបញ្ជាដោយសម្លីកាច ព្រោះមនុស្សស្រីដែលធ្វើខ្លួនឯងធំហួសហេតុ គ្មានខួរក្បាល ឆេវឆាវ ជាមនុស្សស្រីដែលគេមិនធ្លាប់មានអារម្មណ៍បេតី តែគេបែរជាមកជួបគ្រប់យ៉ាងដែលមិនប្រាថ្នានៅក្នុងខ្លួនរបស់អនាគតភរិយា។



"លោកបញ្ជាខ្ញុំ ?"

"ឬត្រូវឲ្យចាប់អង្គុយ!"

រ៉េមសៀ ងើបឈរ កាយវិការរបស់គេអង់អាច ទើបនាងត្រូវអនុវត្តតាម គឺមើលដៃរបស់គេចុះ ធំជាងជើងរបស់នាងទៅទៀត ហើយបើគេវាត់វាមកលើខ្លួននាង នាងអាចសន្លប់បាន តែទោះធ្វើតាមក៏ចរិតក្រទើនៅតែយកមកប្រើ។

"ខ្ញុំមិនស្តាប់បង្គាប់លោក តែខ្ញុំចុកជើង"

នាងដើរបកក្រោយទៅដាក់បង្គុយលើសាឡុង ដែលវានៅទល់មុខសាឡុងដែលគេអង្គុយ ហើយលើកជើងគងអន្ទាក់ខ្លា ដែលធ្វើឲ្យគេមើលឃើញថារ៉ូបនោះផែកសិងតែផិតដល់គល់ភ្លៅស្រឡូន។

នាងក្រមុំផ្ទៀងខ្លួនបន្តិច ព្យាយាមបិទបាំងសាច់ពីខ្សែភ្នែករបស់ រ៉េមសៀ ដែលការពិតទៅនាងគួរតែប្តូរឥរិយាបថនៃការអង្គុយ តែដោយសារមិនត្រូវការអាម៉ាស់មុខ ទើបអត់ធ្មត់អង្គុយបែបហ្នឹងបន្ត ខណៈដែល រ៉េមសៀ បែរទៅមើលក្រៅបង្អួច ព្រោះការមើលដើមឈើដើមព្រៃ វាធ្វើឲ្យស្រួលភ្នែកជាងមើលមុខក្រមុំរបស់អនាគតភរិយា។

ការ៉ុន អង្គុយរឹងខ្លួន ឈឺសាច់ដុំ គិតថាត្រូវចំណាយពេលម៉ាស្សាខ្លួនរាប់ម៉ោងទៀត បន្ទាប់ពី រ៉េមសៀ ត្រឡប់ទៅវិញ។ ដោយសារតែគេ ដែលធ្វើឲ្យនាងត្រូវអង្គុយប្រទេចផ្កាសាគេនៅក្នុងចិត្តបែបនេះ និងភ្លេចការណែនាំរបស់



ចាស៊ីន ឲ្យឈឺង។ ការធ្វើខ្លួនជាមនុស្សធំនៅចំពោះមុខ វែមសៀ គឺជាអ្វីដែលនាងមិនស្គាល់ នាងមិនដឹង ព្រោះពេលនេះកំពុងតែធ្វើខ្លួនជាក្មេងស្រីងរង៉ក់នៅចំពោះមុខគេ។

វែមសៀ ជាបុរសសំណាងល្អ ដែលទទួលបានកិត្តិយស តែគេគិតថាខ្លួនឯងសំណាងអាក្រក់បំផុត ដែលត្រូវមកប្រឈមនឹងនាង និងមិនបិទបាំងភាពនឿយណាយរបស់ខ្លួន។ ហេតុផលនៃការរៀបការជាហេតុផលនយោបាយគ្មានទំនាក់ទំនងផ្លូវចិត្តមកពាក់ព័ន្ធ។ នាងមិនសង្ឃឹមថា ឲ្យគេស្រឡាញ់នាង ព្រោះនាងក៏មិនបានមានអារម្មណ៍បែបនោះចំពោះគេ នាងសង្ឃឹមត្រឹមការផ្តល់កិត្តិយសឲ្យគ្នា តែ វែមសៀ មិនបានប្រគល់វាឲ្យនាង។

*មនុស្សចង្រៃ!*

នាងជេរប្រទេចគេនៅក្នុងចិត្ត ពេញចិត្តនឹងការបានកម្ចាយកំហឹងដែលមានចំពោះគេ ទោះជាកម្ចាយនៅក្នុងចិត្តក៏ដោយ ព្រោះពាក្យទាំងនេះមិនអាចនិយាយឲ្យឮបាន។ នាងត្រូវទំយើកំពិតមែន តែមិនត្រូវបានអនុញ្ញាតឲ្យប្រើពាក្យអសុរោះ។

"ព្រះនាងដល់វេលាសោយក្រយាល្ងាចហើយ ព្រះម៉ែអញ្ជើញលោកឧត្តមសេនីយទៅបន្ទប់ទទួលទានអាហារ"

ហ្វ៊ីវ៉ា មានតួនាទីលុតជង្គង់ដើរមកឈប់ក្បែរសាឡុងរាយការណ៍ប្រាប់ម្ចាស់ស្រីដោយការគោរព ទើប ការ៉ុន ដៀងមើលបុរសមុខកាច។

"លោកឧត្តមសេនីយ មិនឃ្លានទេ" នាងឆ្លៀតឱកាសឆ្លើយជំនួស។



លោកឧត្តមសេនីយ ដកដង្ហើមធំ ដោយការម៉ូម៉ៅនឹងការធ្វើខ្លួនដូចកូនក្មេងមិនចេះធំ ចរិតនិងអាយុមិនដើរទន្ទឹមគ្នារបស់អនាគតភរិយា។ បែបនេះត្រូវតែចាប់ទៅអប់រំ ហើយបើនាងមិនស្តាប់បង្គាប់ គេនឹងដាក់ទោសឲ្យណាណី។

"ចៃដន្យអីខ្ញុំឃ្លាន"

ពេលឃើញគេងើបឈរ នាងក៏ចងចិញ្ចើម ថយទៅបៀតនឹងសាឡុងដោយការប្រុងប្រយ័ត្ន ពេលគេដើរមករក។

*ឬថាគេខឹង ទើបចង់ចាប់នាងបោះទៅក្រៅដំណាក់!*

នាងក្រមុំមើលគេ ដោយការភ័យខ្លាច ដោយមិនដឹងខ្លួនហើយងាកទៅរកអ្នកបម្រើ តែ ហ្វ៊ីវ៉ា ដើរចេញពីបន្ទប់ទៅហើយដោយដឹងតួនាទី។

ចាំទុក!

ការ៉ុន ស្រែកនៅក្នុងចិត្ត។ នាងខឹងចិត្តណាស់ ដែលអ្នកបម្រើរបស់នាងខ្លាច វែមសៀ ជាងខ្លាចនាងទៅទៀត។

"អាំ!"

នាងស្រែកចាច ពេលគេលោមុខមកជិត តែគេមិនបានធ្វើបាបរាងកាយរបស់នាង គេគ្រាន់តែដាក់ចាតដៃមកឲ្យប៉ុណ្ណោះ។

"មនុស្សឆ្កួត! លស់ព្រលឹងអស់"

នាងនិយាយដោយសំឡេងកូរៗ ដោយការងរង៉ក់ដាក់ដោយភ្លេចឲ្យឈឺងទៅថា ត្រូវរក្សាគម្លាត ត្រូវធ្វើខ្លួនក្រអឺតក្រទមដាក់គេ។

វែមសៀ លើកចិញ្ចើមមើលមក ហាក់ដូចត្រូវការផ្ទាញ់ផ្ទាលថា នាង



ហ៊ានដាក់ដៃលើបាតដៃរបស់គេឬអត់។

"ខ្ញុំត្រូវការទៅបន្ទប់ទទួលទានអាហារ"

"ឃ្លានឲ្យស្លាប់ទៅ"

ព្រះនាងធ្វើមាត់អេចអូច រ៉ែមសៀ មិនបានឮ តែគេអាចសន្និដ្ឋានបានថាគ្មានអ្វីក្រៅពីពាក្យមិនល្អ ព្រោះនាងបានប្រកាសខ្លួនជាសត្រូវនឹងគេច្បាស់ទៅហើយ។ ត្រឹមគិតថាត្រូវធ្វើសង្គ្រាមនឹងនាងនៅក្នុងស្ថានភាពគូស្វាមីភរិយា ក៏ធ្វើឲ្យគេធុញទ្រាន់ទៅហើយ។ គេធ្វើសង្គ្រាមនឹងពួកក្បត់ក៏រវល់ស៊ីងស្លាប់ទៅហើយ នៅមកធ្វើសង្គ្រាមនឹងប្រពន្ធក្បាលរឹងទៀត ឱ! ជីវិត។

*រំលល់យក់!*

អ្នកកំលោះដេរនៅក្នុងចិត្ត។ គេមានភារកិច្ចរឹតខ្លួន គេរីករាយនឹងចិញ្ចឹមផ្គត់ផ្គង់ស្រីកំណាន់ឲ្យរស់ស្រណុកសុខស្រួល ប៉ុន្តែការមានភរិយាម្នាក់នឹងធ្វើឲ្យគេវិលក្បាលហើយ ការ៉ិន ក៏ខុសពីប្រពន្ធនៅក្នុងឧត្តមគតិរបស់គេដែរ។ ប្រពន្ធនៅក្នុងឧត្តមគតិរបស់គេត្រូវតែសុភាពរាបសារ ស្តាប់បង្គាប់បញ្ជាឆ្វេងៗ ស្តាំៗ មិនមាត់ក មិនតវ៉ា តួនាទីនៅលើគ្រែក៏មិនខ្វះខាត ព្រោះគេជាមនុស្សប្រុសដែលមានតម្រូវការធម្មជាតិខ្ពស់ណាស់ រឿងលើគ្រែគឺជាវិធីកម្សាយភាពតានតឹងរឿងការងារ។ គេមិនចាំបាច់មានវាកល់ថ្ងៃ តែបើស្ត្រេសខ្លាំង ពេលដល់វេលាកម្សាយ គេនឹងបំផុះវាដោយការរួមរ័កនឹងស្រីកំណាន់ ដោយមិនខ្វល់ពីអ្វីផ្សេង។

គេមានកម្លាំងច្រើន តែមើលរាងកាយរបស់ ការ៉ិន ចុះ តូចតែមួយ រាងស្ដើង ដៃជើងតូចដូចដងវែក ទោះសមសួន តែវាតូចពេកហើយ អាចបាក់ជាពីរ



ក៏ថាបាន បើគេក្រសោបចង្កេះរបស់នាង ហើយគ្រប់គ្រងដោយអារម្មណ៍ប្រាថ្នាដ៏ខ្លាំងក្លា។

ក្រៅពីមុខស្អាត និងដើមទ្រូងទ្រលុកទ្រលន់ដែលគួរតែជាអវយវៈតែមួយគត់នៅលើខ្លួនរបស់នាងដែលវាពេញដៃពេញជើងបាន គេរកមើលមិនទាន់ឃើញអ្វីផ្សេងទេ ជាពិសេសអត្តចរិត។ គេខ្លាំង នាងក្តៅ គេរឹងរូស នាងទំនើង គេមិនចូលចិត្តល្បួង នាងចូលចិត្តងរង៉ក់ ថែមទាំងរខ្លាំងទៀត ព្រោះពេលនេះកំពុងអង្គុយធ្វើមុខក្រមូវ តែគេមិនចំណាយពេលលួងទេ ព្រោះបើបានលួងម្តងហើយ មុខជាត្រូវលួងទៀត ហើយគេក៏មិនចេះលួងមនុស្សស្រីដែរ បើចេញបញ្ជាគេជំនាញជាង។

អ្នកកំលោះសម្លឹងមុខនាង នាងក៏សម្លឹងគេវិញ។ ភ្នែករបស់នាងស្អាតតែជះពន្លឺផ្លេកៗដូចស្រីឆ្មាស តែពេលគេមិនព្រមព្រិចភ្នែក មិនព្រមដកខ្សែភ្នែកចេញ ថ្ពាល់សរលោងក៏ក្រហមបន្តិចម្តងៗ។ នាងដឹងច្បាស់ ការសម្លឹងមុខគេយូរនឹងធ្វើឲ្យនាងអៀន តែនាងមើលរំលងអារម្មណ៍នោះដោយការយកទោសៈមកបិទបាំង។

"អញ្ជើញ ខ្លារីហ្សា"

គេជាមនុស្សគ្មានមារយាទ តែសំឡេងកាចនោះបែរជាធ្វើឲ្យនាងព្រមដាក់ដៃលើបាតដៃធំក្រាស់។

គិតថានាងមិនហ៊ានឲ្យគេចាប់ដៃឬយ៉ាងម៉េច មនុស្សដូច ខ្លារីហ្សា មិនខ្លាចអ្នកណាគេ ជាពិសេសមនុស្សដូច រ៉ែមសៀ ដាវ៉ែហ៊ីណេស!





Scanned by CamScanner

"ឃ្លានខ្លាំងឬ?" នាងតំហឹកសួរ។

"បើមិនចង់និយាយស្ដីឲ្យល្អ បិទមាត់ល្អជាង ខ្លាឃ្មុំហ្វា"

"នេះលោក!"

នាងក្រមុំឆ្ងល់ចុងច្រមុះ។ គេត្រូវការឲ្យនាងនិយាយល្អ ចុះគេមានចង់និយាយល្អដាក់នាងខ្លះទេឬអី និងចាប់ផ្ដើមពីការធ្វើមុខឲ្យល្អពេលជួបគ្នា។

"ប្រាប់ខ្លួនឯងទៅ"

ការិន ឈប់ដើរ និងរលាស់ដៃគេចេញ ដែលគេក៏ព្រមឲ្យរលាស់ និងព្រមព្រលែងកដៃរបស់នាង តែបែរជាស្រវាចាប់ដើមដៃ ទាញនាងឲ្យជ្រប់មករក។

"អ៊ូ! ឈឺ!"

នាងងើយមើលមុខគេដោយខ្សែភ្នែកឆ្មាសឆ្មើម ភ្លាប់ដៃគក់ដើមទ្រូងធំទូលាយ ដែលធ្វើឲ្យម្ចាស់ទ្រូងមួម៉ៅលែងចង់អត់ធ្មត់។

"មនុស្សចង្រៃ!"

ដៃម្ខាងដែលមិនត្រូវបានចាប់ ភ្លាប់គក់ទ្រូងហាំមួន ប៉ុន្តែអ្នកដែលឈឺតិនាង ទាស់ត្រង់ នាងមិនព្រមឈប់ ហើយនៅមានសំឡេងច្រែតៗរបស់នាងដែលផ្ទោចទោសៈរបស់គេឲ្យដល់ចំណុចពុះ ប៉ុន្តែគេហិង្សាដាក់នាងមិនបាន ក្បាលរបស់គេអាចរបូតពីស្មា ព្រោះនាងជាប្អូនស្រីសំណព្វចិត្តរបស់ប្រមុខប្រទេស ហើយបើគេស្លាប់ ការិន នឹងមានសេចក្ដីសុខ ដែលគេមិនព្រមឲ្យនាងសោយសុខ ខណៈដែលក្បាលរបស់គេរបូតពីស្មាបាន។



"ឆ្ងាសណាស់"

គេគ្រហឹមដោយសំឡេងរឹងកំព្រឹស ដែលសំឡេងនេះក៏ធ្វើឲ្យ ការិនព្រមបញ្ឈប់សកម្មភាព ព្រោះជាសំឡេងកាច ធ្វើឲ្យនាងស្រឡាំងកាំង ទើបគេផ្ទៀតឱកាសនេះ លើកដៃទាំងពីរក្រសោបថ្ពាល់រលោង ហើយឱនទៅថើបផញ្ចក់បបូរមាត់របស់នាង។

"ហ៊ឺ! អ៊ឹងអុំ!"

នាងបញ្ជាឲ្យគេលែង តែសំឡេងដែលរបូតចេញមកពីមាត់បែរជាស្ដាប់មិនយល់ ព្រោះត្រូវបបូរមាត់ក្ដៅរបស់គេបឺតផញ្ចក់។ នាងងាកមុខចេញ គេក៏អូសបបូរមាត់តាម ហើយនាងក៏អស់ឱកាសនឹងងាកមុខគេចទៅណាទៀត ពេលគេច្របាច់មុខ ឲ្យនាងនៅស្ងៀម។

មាត់របស់គេឈ្លានពាននាង នាងក៏បើកមាត់ ព្រោះត្រូវគេសង្កត់ទាល់តែឈឺ ហើយនៅមានពុកមាត់ពុកចង្ការរបស់គេទៀត ធ្វើឲ្យស្បែកមុខរបស់នាងរមាស់អស់ហើយ។

"ហ៊ឺ!"

នាងតវ៉ាដោយសំឡេងក្អួវ ភ្លាប់ដៃគក់ខ្លួនប្រាណហាប់ណែន ដោយសាច់ដុំ ដែលរឹងកំព្រឹសហាក់ដូចដុំថ្ម គក់យ៉ាងណាក៏រង្គោះរង្គើ ហើយគេក៏មិនបានរាសចេញ ព្រោះកម្លាំងរបស់នាងដូចស្រមោច ទើបមាត់របស់គេនៅតែគ្រប់គ្រងមាត់របស់នាង ដៃទាំងពីរនៅតែក្រសោបមុខស្រស់ស្អាត។

ដៃរបស់គេធំណាស់ និងមានកម្លាំងខ្លាំងជាងនាង ទើបនាងធ្វើបានត្រឹម



ថ្ងូចថ្ងូរជាការតវ៉ា និងតក់តេបន្ត តែកាន់តែតក់ នាងកាន់តែខ្សោះកម្លាំងទៅៗ។ រ៉ែមសៀ ថើបជញ្ជក់បបូរមាត់របស់នាងដោយបទពិសោធដែលមានច្រើនជាង ហើយការតបតរបស់ព្រះនាងឆ្មាស ក៏ធ្វើឲ្យគេបានដឹងពីភាពមិនដឹងខ្យល់អីរបស់នាង។

គេសង្កត់បបូរមាត់ថ្នមៗ កាត់បន្ថយភាពព្រៃផ្សៃ បន្ថែមភាពរញ្ជួយ។ នាងទន់ជង្គង់ ពេលអណ្តាតក្តៅជ្រែកចូលមកក្នុងប្រអប់មាត់ ដៃដែលក្រសោបមុខស្រស់ស្អាតក៏ដកទៅក្រសោបចង្កេះ។

រ៉ែមសៀ មានការកំណត់ក្នុងការដាក់ទោសព្រះនាងឆ្មាស ហើយវិធីនេះមើលទៅបានលទ្ធផលល្អ ប៉ុន្តែគេបែរជាភ្លើតភ្លើននឹងភាពក្រអូបផ្អែមលាយឡំភាពមិនដឹងខ្យល់អីដែលគេរកឃើញពីបបូរមាត់ស្រីឆ្មាស រាងកាយរបស់នាងទន់ល្មើយនិងក្រអូបប្រហើរ។

ក្លិនក្រអូបប្រហើរនោះស្រោចលើច្រមុះរបស់គេ ព្រោះបបូរមាត់ក្តៅគគុកនៅតែបឺតជញ្ជក់បបូរមាត់ទន់ល្មើយ។ គេថើបនាងថ្នមៗ បន្ទាប់មកក៏បន្ថែមកម្រិតឲ្យកាន់តែក្តៅ ដែលកាន់តែថើប កាន់តែភ្លើតភ្លើននឹងរសក្រអូបដែលគេលួចយកពីបបូរមាត់នាងដោយមិនក្រែងរអែងចិត្ត។

"អឺ..."

សំឡេងថ្ងូចថ្ងូរតិចៗនោះប្រាសចាកកំហឹង រ៉ែមសៀ ឱបរឹតនាងកាន់តែណែន ហើយអង្រួញជើងបន្តិច លើកនាងបី ដោយបបូរមាត់នៅតែស្អិតល្មួតគ្នា តែពេលបានឮសំឡេងក្អកត្រហែម ទើបព្រមដកបបូរមាត់ចេញ។



"អម្ចាស់"

រ៉ែមសៀ ងាកទៅមើលទៅទ្វារ ឃើញព្រះអង្គម្ចាស់ឈរនៅត្រង់នោះ។

ខាឡូម៉ាន់ ចេញបញ្ជាឲ្យអ្នកបម្រើក្នុងដំណាក់របស់ព្រះនាងរាយការណ៍ពេល រ៉ែមសៀ ធ្វើដំណើរមកដល់ ហើយបើឃើញថាមានអីមិនស្រួល ខ្លាចថាពីរនាក់នេះហិង្សាដាក់គ្នាត្រូវរាយការណ៍ជាបន្ទាន់ ដែលគេក៏ស្រូតដំណើរមកទីនេះបន្ទាប់ពីអ្នកបម្រើរាយការណ៍ថា រ៉ែមសៀ មកដល់មួយសន្ទុះ ស្ថានការណ៍ក៏មិនសូវល្អដែរ។

រ៉ែមសៀ ឱនគំនាប់ ធ្វើការគោរពព្រះអង្គម្ចាស់ ដោយក្នុងដៃរបស់គេមានស្រីស្អាតទន់ខ្លួនល្មុក ព្រោះតក់ស្លុត បន្ទាប់ពីត្រូវប្លន់ថើប។

"មើលទៅស្ថានការណ៍មិនអាក្រក់ដូចខ្ញុំគិតទេ"

"ខ្ញុំអាចគ្រប់គ្រងបាន"

បើឲ្យស្ត្រីទន់ជ្រាយម្នាក់មានអំណាចលើខ្លួន តើគេសក្តិសមនឹងធ្វើជាអ្នកចម្បាំងសំខាន់របស់ព្រះអង្គម្ចាស់ ខាឡូម៉ាន់ ទៀតឬ។

"ខ្លារិហ្សា"

"នាងឆ្លើយមិនបាន កំពុងតក់ស្លុត"

ខ្លារិហ្សា បាញ់ខ្សែភ្នែកឆ្មាសឆ្អើមដាក់ តែនាងគ្មានកម្លាំងនិយាយមែននោះឯង អណ្តាតត្រូវបឺតជញ្ជក់ឡើងទន់ល្មុក ទោះការពិតវាមានសភាពដូចដើមក៏ដោយ តែការថើបរបស់ រ៉ែមសៀ ធ្វើឲ្យរាងកាយរបស់នាងស្រាប់ស្រល់ សូម្បីចង់និយាយក៏លំបាក។





Scanned by CamScanner

"ពីងឯង មើលថៃ ខ្លារិហ្សា ផងទៅចុះ"

កុំ!

ខ្លារិហ្សា ចង់ប្រកែកនឹងបងប្រុស នាងមិនចង់ឲ្យ វ៉េមសៀ មើលថៃ តេឬមើលថៃ មានតែផិះជាន់នាង។

"កុំបារម្ភអី អម្ចាស់ ខ្ញុំចាត់ការគ្រប់រឿងបាន"

"អូខេ មើលឃើញហើយ អីចឹងខ្ញុំមិនរំខានទេ អញ្ជើញតាមសម្រួលចុះ"

ព្រះអង្គម្ចាស់ មិននាំខ្លួនឯងមករារាំងភាពស្និទ្ធស្នាលរវាង វ៉េមសៀ និងព្រះនាង ការ៉ុន ក៏បែរខ្នងដើរចេញទៅ ទើប វ៉េមសៀ ឱនមកប្រសព្វនឹងភ្នែកមូលក្លុំបង្ហាញឲ្យឃើញពីការងរង៉ក់របស់អ្នកនៅក្នុងរង្វង់ដៃ។

"ហ៊ឺ!"

នាងហើបមាត់ ក៏ត្រូវគេឱនមកថើបបបូរមាត់ទៅហើយ។ នាងមិនទាន់បានឆ្លាសផង គេមានសិទ្ធិអីមកថើប!

ខួរក្បាលបញ្ជាឲ្យរើបម្រះ តែបបូរមាត់បែរជាបង្ហើបទទួលយកការថើបពីបបូរមាត់ក្តៅៗ នាងគួរតក់គេឲ្យខ្លាំងៗ តែដៃចង្រៃបែរជាលើកទៅឱប.ករឹងមាំ។

"លោក...អុំ!"

ស៊ីឡា រង់ចាំប្រណិប័តន៍ ចៅហ្វាយ តែចៅហ្វាយបច្ចុប្បន្ននិងអនាគតចៅហ្វាយ មិនព្រមទៅបន្ទប់អាហារសោះ ទើបដើរមកមើល ហើយក៏ប្រញាប់លើកដៃបិទមាត់ មិនឲ្យឆ្លោយបញ្ចេញសំឡេងរំខានកំលោះក្រមុំ និងប្រញាប់ប្រញាល់ថយចេញពីបន្ទប់ទទួលភ្ញៀវ។



វ៉េមសៀ បីព្រះនាងទៅបន្ទប់អាហារ ដែលជាសាឡុងវែងដោយគេដាក់បង្អុយលើនោះឲ្យនាងអង្គុយលើភ្លៅ ដែលពេលនោះឯងស្មារតីរបស់ព្រះនាងក៏ត្រឡប់មកវិញទើបនាងប្រឹងរើបម្រះ តែបានមួយសន្ទុះប៉ុណ្ណោះបបូរមាត់ស្ទាត់ជំនាញរបស់គេក៏ពង្វក់ឲ្យស្មារតីរបស់នាងខ្សោះកម្លាំងម្តងទៀត។

"ចាំទុក ខ្លារិហ្សា នាងត្រូវស្តាប់បង្គាប់ខ្ញុំ លុះក្រោមអំណាចខ្ញុំ"

"គ្មានថ្ងៃ"

ទោះត្រូវថើងឡើងអស់កម្លាំង ក៏នាងនៅតែមិនព្រមឲ្យ វ៉េមសៀ មានអំណាចកៀបសង្កត់ នាងនៅតែរឹងទទឹងដាក់គេឲ្យដល់ទីបំផុត។

"អីចឹង ត្រូវស្វែងយល់ជាថ្មីហើយ"

អ្នកកំលោះ គ្រប់គ្រងស្ថានការណ៍នៅក្នុងដៃបានល្អជានិច្ច។ គេចាប់ចង្ការបស់នាងភ្ញើយ ហើយឱនទៅសង្កត់បបូរមាត់នឹងថ្ពាល់ថើបជញ្ជក់ខ្លាំងៗ បន្ទាប់មកក៏គ្រប់គ្រងបបូរមាត់ទន់ល្មើយ។

វ៉េមសៀ ចាកចេញពីដំណាក់របស់ព្រះនាង ការ៉ុន តាមពេលកំណត់ ដោយក្រពះទទេស្អាត មិនបានបន្ថែមអាហារ តែបបូរមាត់ឆ្អែត ព្រោះបានថើបនាងទាល់តែបបូរមាត់ក្រពុំហើមជាំ ក្រហមឆ្អាំង ខណៈដែលភ្នែកស្អាតសម្លក់គេចង់ផ្ទុះគ្រាប់ទៅហើយ ដោយការមិនពេញចិត្ត។

ការ៉ុន ប៉ះសម្តីនឹងគេបាន តែប៉ះកម្លាំងស្នេហារបស់គេមិនបាន។ នាងគ្មានបទពិសោធ ម្ចាស់ស្នាមដំបូងរបស់នាងគឺ វ៉េមសៀ។ នាងចាញ់ភាពស្ទាត់





Scanned by CamScanner

ជំនាញរបស់គេ និងក្រៅពីខឹងគេហើយ នាងនៅពាលខឹងខ្លួនឯងដែលមិនអាចប្រឆាំងនឹងគេបានទៀត។

រាងកាយរបស់នាងកើតអី ត្រឹមធ្លាក់នៅក្នុងរង្វង់ដៃមាំមួនក៏ខ្សោះអស់កម្លាំងពតាំង។ នាងតួរើបម្រះ ដើម្បីសេរីភាព តែការពិតរាងកាយរបស់នាងចូលចិត្តការប៉ះពាល់របស់គេ ត្រេកត្រអាលនឹងការថើបរបស់គេ អស់កម្លាំងនៅក្នុងរង្វង់ដៃរបស់គេ។

"ចាំជួបគ្នាទៀត ព្រះនាង"

"អ្នកណាចង់ជួបទៀត"

នាងបែរខ្លួន ដើរលឿនស្លេវចូលដំណាក់ ដូចខ្លាចគេតាមមកចាប់ខ្លួនទៀត បន្ទាប់ពីចេញមកជូនដំណើរគេតាមមារយាទ ព្រោះខ្លាចថាបើរឿងដែលនាងទុកឡៀវចោល ដោយមិនយកចិត្តទុកដាក់ដឹងដល់ត្រចៀកបងប្រុស នោះនាងនឹងត្រូវហៅទៅស្តីបន្ទោស។

វែមសៀ តាមមើលខ្នងតូចស្តើងរបស់ព្រះនាងឆ្លាសឆ្លើម ហើយលើកដៃប៉ះមាត់។ តាមពិត ការមកទីនេះក៏មិនបានធ្វើឲ្យគេធុញទ្រាន់អីណាស់ណាដែរ វានៅមានភាពត្រេកត្រអាលឲ្យភ្លើតភ្លើនដែរតើ ដែលពេលគេអស់ការអត់ធ្មត់គឺអាចដាក់ទោសនាងបាន ដោយការចាប់ថើប ហើយការថើបដាក់ទោសនោះក៏កាត់បន្ថយកំហឹងបានខ្លះដែរ។

គេបដិសេធការបង្កើនទំនាក់ទំនងនឹងស្រីព្រហ្មចារី ភាពមិនដឹងខ្យល់អីជារឿងដែលគេតែងតែគេចវេះ។ គេមិនត្រូវការខាតពេល ដើម្បីបង្រៀនរឿង



តណ្ហារាគៈនៅលើគ្រែដល់នាង ព្រោះគេត្រូវការសេពសុខរាងកាយប៉ុណ្ណោះ។

បទពិសោធរបស់ពួកនាងត្រូវយកមកបម្រើរាងកាយរបស់គេ តែពេលបានថើបជញ្ជក់បបូរមាត់ក្រពុំនោះហើយ គេបែរជាមានអារម្មណ៍ពេញចិត្តប្លែក ហើយបបូរមាត់ផ្អែមនោះជារបស់គេតែម្នាក់គត់។ ការរ៉ិន មិនចេះថើប ង៉េមង៉ាម គ្មានបទពិសោធ គេគួរតែធុញទ្រាន់ តែបបូរមាត់របស់នាងនិងគេត្រូវទាញរកគ្នាដូចមេដែកប៉ូលខុសគ្នា។

"ឆ្លាសណាស់"

គេនិយាយរអ៊ូៗ ខណៈដែលដើរសំដៅឧទ្យានចក្រផ្ទាល់ខ្លួន។ គេនឹងធ្វើដំណើរទៅក្រុងសេនជីរ៉ក ព្រោះមានភារកិច្ចត្រូវបំពេញនៅទីនោះ ក្រៅពីនេះនៅមានប្រជុំសំខាន់ជាមួយសម្ព័ន្ធមិត្តនៅថ្ងៃស្អែកទៀត ខាឡម៉ាន់ ក៏ត្រូវទៅចូលរួមដែរ។

ពេលឧទ្យានចក្រហើយ គេក៏ងាកទៅមើលដំណាក់របស់ព្រះនាងឆ្លាសម្តងទៀត ឃើញនាងនៅជិតទ្វារ តែពេលប្រសព្វភ្នែកជាមួយគេពីចម្ងាយ នាងក៏ពើងទ្រូងដាក់ ហើយបែរខ្លួន ដើរលឿនស្លេវចូលទៅខាងក្នុង។

"ព្រះនាងឃ្លានទេ ?" ស៊ីឡា សួរជាការយកចិត្តយកថ្លើម ព្រោះព្រះនាងមិនទាន់បានទទួលទានអាហារពេលល្ងាច ទើបបារម្ភពីទ្រង់ តែម្ចាស់ស្រីក៏ពុលសម្រស់បែរជាគ្រវីក្បាលបដិសេធ។

"ខ្ញុំមិនចង់ញ៉ាំ"



"ព្រះនាង បើឃ្លានពេលយប់ គិតយ៉ាងម៉េច?"

"តិពេលនេះមិនទាន់ឃ្លាន ចង់ទៅដើរលេង"

ការ៉ុន មិននឹកចង់អាហារ ហើយក៏ចង់ឱ្យ ស៊ីឡា និង ហ្វីរ៉ា ដែលមិនមកជួយនាងពីការដាក់សម្លាបរបស់ រ៉ែមសៀ ដែរ តែនាងក៏មានហេតុផល។ នាងខឹងមនុស្សរបស់ខ្លួនមិនបាន រ៉ែមសៀ ជាបុរសដែលទទួលបានការគោរពខ្លបខ្លាច និងក្រែងអែងចិត្ត ហើយមានឬដែលអ្នកបម្រើហ៊ានប៉ះពាល់គេ។

"ដើរលេងហើយមកសោយក្រយាវិញ ព្រះម៉ែ"

"បើខ្ញុំឃ្លាន"

"ឱ! ព្រះនាង"

"ក៏បានៗ ដើរលេងហើយនឹងទៅញាំបាយ ពេញចិត្តហើយនៅ ស៊ីឡា ហ្វីរ៉ា?"

ពេលបានឮបែបនេះអ្នកបម្រើទាំងពីរដែលអម្បាញ់មិញខំបញ្ចុះបញ្ចូលម្ចាស់ស្រីចង់បែកពពុះមាត់ក៏នាំគ្នាញញឹម។

"ព្រះម៉ែ" ពួកនាងឆ្លើយដំណាលគ្នា ហើយដើរតាមព្រះនាងទៅសួននៅខាងក្រៅ។

ការ៉ុន ដើរបង្ហើរអារម្មណ៍នៅក្នុងសួន តែមិនបានចាប់អារម្មណ៍ដើមផ្កាដើមព្រៃ តែគំនិតរបស់នាងកំពុងនឹកដល់អ្នកដែលទើបតែចាកចេញទៅ។

*គួរឲ្យខឹងណាស់!*

នាងខឹងសម្បាជាក់គេបានតែប៉ុណ្ណឹងឯងឬ ត្រឹមបបូរមាត់របស់គេដែល



សង្កត់លើបបូរមាត់របស់នាងក៏អាចបញ្ឈប់ភាពឆ្មាសឆ្មើមរបស់នាង។ នាងព្រមចុះញ៉មគេងាយពេកហើយ ដូច្នេះហើយ នាងត្រូវបង្ខំចិត្តគំនិតឲ្យរឹងមាំនិងម៉ឺងម៉ាត់ជាងនេះ ត្រូវតែមិនព្រមទោរទន់តាមការប៉ះពាល់របស់គេទៀត។

"មនុស្សបែបនោះ គួរឲ្យខឹងមែនទែន"

"ព្រះនាងចង់ជាឲ្យអ្នកណា?" ហ្វីរ៉ា សួរខ្សឹបៗដោយការក្រែងអែងចិត្ត ព្រោះសុខៗចៅហ្វាយនិយាយបែបនេះ ទើបនាងមិនបានជាត្រៀមខ្លួន គិតមិនទាន់ថា ព្រះនាងចង់ជាឲ្យអ្នកណា។

"មានអ្នកណាទៀត ក្រៅពីលោកឧត្តមសេនីយ រ៉ែមសៀ របស់ពួកនាង"

"មិនមែនទេ ព្រះម៉ែ"

ស៊ីឡា និង ហ្វីរ៉ា បើកភ្នែកធំៗ ប្រញាប់បដិសេធ។ ពួកនាងជាអ្នកបម្រើមានឬហ៊ានទទួលថាលោកឧត្តមសេនីយ រ៉ែមសៀ ជារបស់ខ្លួន។

ការ៉ុន នៅតែដើរគយគន់ទេសភាពនៅក្នុងសួន ទោះខួរក្បាលចេះតែគិតដល់ រ៉ែមសៀ ដល់ថ្នាក់គួរឲ្យខឹងក៏ដោយ។



## ៤

## មានចេតនា

"បងស្រី"

កាអ៊ិន ក្រដាងដៃឱបប្អូនស្រីរួមឪពុក។ នាងជាកូនស្រីរបស់ភរិយាទីប្រាំ តែជាបងស្រីធំរបស់ប្អូនស្រី ដែលកើតពីភរិយាមុនៗ ចំណែក យែតទ្រីណា ម៉ាលខៃសេនតេ ជាកូនស្រីរបស់ភរិយាទីបួន។

ប្រហែលមកពីឈាម ម៉ាលខៃសេនតេ ដែលមាននៅក្នុងខ្លួនទេដឹង ទោះជាកូនម្ដាយទីទៃ តែកូនប្រុសកូនស្រីរួមឪពុក ស្រឡាញ់គ្នាស្និតល្មួត។

យែតទ្រីណា មកដំណាក់របស់បងស្រី ព្រោះទើបតែដឹងដំណឹងរឿងពិធីមង្គលការជាមួយ រ៉េមសៀ។

"ហេតុអ្វីធ្វើមុខសោកសៅបែបនេះ" ពួកនាងផលថ្ពាល់គ្នា ហើយអង្អែលថ្ពាល់ប្អូនស្រីពៅ។ ទោះនាងជាស្រីឆ្លាស ចូលចិត្តស្រែកឡូឡានៅក្នុងខ្សែភ្នែករបស់ រ៉េមសៀ តែសម្រាប់ប្អូនស្រី នាងចិត្តល្អមានមេត្តាឲ្យជានិច្ច។

"ប្អូនទើបដឹងថាបងស្រីត្រូវរៀបការនឹងលោកឧត្តមសេនីយ រ៉េមសៀ"

ទោះទទួលបានការស្វាគមន៍យ៉ាងកក់ក្ដៅ គឺទឹកមុខរបស់ យែតទ្រីណា នៅតែមិនស្រស់បស់។



"តាមនោះ"

នាងចាប់ដៃប្អូនស្រី នាំទៅអង្គុយលើសាឡុង។ យែតទ្រីណា ធ្លាប់ជួប រ៉េមសៀ ហើយ តែមិនធ្លាប់សន្ទនាគ្នា បុរសម្នាក់នោះសង្ហាក៏ពិតមែន តែគេមើលទៅកាច និងព្រៃផ្សៃគួរឲ្យខ្លាច។

"បងស្រីពេញចិត្តឬអត់ ?" ប្អូនស្រីសួរដោយការព្រួយបារម្ភ។ បើសិនឲ្យនាងរៀបការជាមួយ រ៉េមសៀ នាងមុខជាភ័យខ្លាចដល់សន្លប់មិនខាន។

យែតទ្រីណា ក្រសោបដៃរបស់បងស្រី បងស្រីដែលមានមាឌតូចល្អិតពេលធៀបនឹងបុរសមាឌធំដូច រ៉េមសៀ ដាវ៉ៃហ៊ីណោស ហើយបើសិនគេចាប់ខ្លាំងតែបន្តិច ឆ្អឹងរបស់បងស្រីក៏ពូលសម្រស់អាចរងការប៉ះពាល់បាន។

របបនៃការគ្រប់គ្រងនៅ សាក់ខាវៀ នាពេលនេះមានការបែងចែកវណ្ណៈអ្នកដឹកនាំនិងប្រជាជន ហើយនៅក្នុងវណ្ណៈអ្នកដឹកនាំមានការបែងចែកថ្នាក់អ្នកគ្រប់គ្រង នោះគឺខ្សែរាជវង្ស...រាជវង្ស ម៉ាលខៃសេនតេ ថ្នាក់អ្នកការពារ គឺក្រុមសម្ព័ន្ធមិត្តដែលជាអ្នកចម្បាំងដែលប្រកៀកស្មានឹង ខាឡូម៉ាន់ ទាល់តែផែនការរឹបអូសអំណាចបានសម្រេច។ បុគ្គលនៅក្នុងថ្នាក់អ្នកការពារ មានតួនាទីការពារមើលថែប្រទេស សាក់ខាវៀ ដោយបុគ្គលដែលមានអំណាចធំជាងគេនៅក្នុងថ្នាក់អ្នកការពារគឺ រ៉េមសៀ ដាវ៉ៃហ៊ីណោស។

ថ្នាក់អ្នកគ្រប់គ្រង គឺក្រុមដែលមានតួនាទីគ្រប់គ្រងប្រទេស ដែលទទួលបានការស្នើឈ្មោះពីថ្នាក់អ្នកគ្រប់គ្រងដូចគ្នា និងថ្នាក់អ្នកការពារ មុនពេល ខាឡូម៉ាន់ ធ្វើការជ្រើសរើស ដែលនៅថ្នាក់អ្នកគ្រប់គ្រង អ្នកដែលមានអំណាច



នៅក្នុងការគ្រប់គ្រងធំបំផុតគឺនាយករដ្ឋមន្ត្រី ហើយអ្នកដែលមានអំណាចធំជាងគេនៅ សាក់ខាវៀ គឺ ខាឡូម៉ាន់។

របបគ្រប់គ្រងនាពេលអនាគតអាចមានការកែប្រែ ប៉ុន្តែពេលនេះរបបនេះត្រូវយកមកប្រើដើម្បីគ្រប់គ្រងមើលការខុសត្រូវប្រទេស និងទោះពួកនាងត្រូវចាត់ចូលថ្នាក់គ្រប់គ្រង តែដឹងច្បាស់ថាស្ត្រីនៅក្នុងខ្សែរាជវង្សសំខាន់ និងមានអំណាច ធៀបនឹងថ្នាក់អ្នកការពារមិនបាន។

"មិនថាពេញចិត្តឬអត់ រឿងខ្លះយើងមិនអាចជ្រើសរើសបានទេ យែត"

យែតទ្រីណា មានអារម្មណ៍សោកសៅ ពេលបានឮដូច្នេះ។ ការរៀបការដែលប្រាសចាកស្នេហា បងស្រីដែលនាងស្រឡាញ់គោរពត្រូវរៀបការដើម្បីសេចក្ដីសុខសមូហភាពជាងសេចក្ដីសុខផ្ទាល់ខ្លួន។

"ឱ! បងស្រី"

"មិនអីទេ យែត បងស្រីនឹងមាំនិងធ្វើតាមការសម្រេចចិត្តរបស់បងប្រុស"

"ហេតុអីបងប្រុសសម្រេចចិត្តបែបនេះ"

សម្ដីរបស់ យែតទ្រីណា សុភាព ទន់ភ្លន់ មួយៗដូចបុគ្គលិកលក្ខណៈ ប៉ិនភ័យ ប៉ិនខ្លាច ក្រៅពីនេះក៏មានទំនាក់ទំនងល្អនឹងសមាជិកគ្រួសារដែរ។ បើជារឿងដែលពាក់ព័ន្ធនឹងសមាជិកគ្រួសារ បេះដូងរបស់ យែតទ្រីណា នឹងងាយទទួលបានការប៉ះទង្គិចណាស់ ទាំងដែលធម្មតាចិត្តគំនិតនាងផុយស្រួយណាស់ទៅហើយ។

"ព្រោះតាំងពី ស្ថានការណ៍នៅសាក់ខាវៀមិនទាន់មានស្ថិរភាពទេ ការ



ធ្វើឲ្យគ្រឹះអំណាចមានលំនឹង គឺការប្រកាសចំណងរវាងថ្នាក់អ្នកគ្រប់គ្រងនិងអ្នកការពារ"

"លោកឧត្ដមសេនីយ រែមសៀ គួរឲ្យខ្លាចណាស់"

"បងស្រី មិនខ្លាចគេទេ កុំបារម្ភអី បងស្រីអាចចាត់ការគេបាន"

"ទោះយ៉ាងហ្នឹងក៏ដោយ នៅតែបារម្ភ គ្រីស្ទី ក៏បារម្ភ តែមិនបានមកទីនេះព្រោះមិនសូវស្រួលខ្លួន"

"គ្រីស្ទី កើតអី ?"

"ផ្ដាសាយ"

គ្រីស្ទីណា ម៉ាលខៃសេនតេ ឬ គ្រីស្ទី ប្អូនស្រីម្នាក់ទៀតរបស់ ខាឡូម៉ាន់ ដែលកើតពីភរិយាទីពីររបស់ឪពុក ចំណែកភរិយាទីបីគ្មានកូន មិនថាប្រុសឬស្រី។ គ្រីស្ទីណា និង យែតទ្រីណា មានអាយុស្របាលគ្នា ទើបត្រូវចិញ្ចឹមឲ្យដូចកូនភ្លោះ។

"ផ្ដាសាយទៀតហើយ ក្មេងនេះ ចំមែន"

"ពិតជាហើយ បងស្រីកុំខឹងអី"

"មិនចូន់ចូរក៏ល្អហើយ បងស្រីនឹងមិនខ្វល់ខ្វាយ ពេលនេះបងស្រីមានរឿងឲ្យគិតច្រើន ត្រូវមើលថែខ្លួនឯងឲ្យបានល្អទាំង យែត ទាំង គ្រីស្ទី"

"ចាំ បងស្រី ប្អូនដឹងហើយ"

ដំណឹងដែលបានឮល្បៀង មិនមែនជាពាក្យចចាមអារ៉ាម តែជាដំណឹងពិត ទើប យែតទ្រីណា ត្រូវមកសួរបងស្រីដោយផ្ទាល់ ព្រោះតែការព្រួយបារម្ភ





Scanned by CamScanner

ប៉ុន្តែចម្លើយដែលទទួលបាន បែរជាមិនធ្វើឲ្យនាងរសាយភាពខ្វល់ខ្វាយ។ នាងមានការភ័យខ្លាចជំនួសបងស្រី តែបងស្រីនិយាយត្រូវ ព្រោះកើតមកជាសមាជិករាជវង្ស ទើបជម្រើសនៃជីវិតនៅពេលខ្លះវាមានដែនកំណត់។

ដំណឹងនៃមង្គលការរបស់ រៃមសៀ និងព្រះនាង ការ៉ុន ត្រូវថ្លែងការណ៍ឲ្យប្រជាជនទូទាំងប្រទេសដឹង ហើយប្រជាជនកំពុងទន្ទឹងរង់ចាំពិធីមង្គលការរបស់បុរស និងស្ត្រីដែលសមគ្នាឥតខ្ចោះ...រៃមសៀ ឧត្តមសេនីយរបស់សាក់ខាវៀ និង ការ៉ុន ជាព្រះនាងដ៏ខ្ពង់ខ្ពស់។ ភាពរីករាយគ្របដណ្តប់ពេញផ្ទៃប្រទេស ដំណឹងនេះធ្វើឲ្យស្ថានការណ៍តានតឹងទៅជាធូរស្រាល ប្រជាជនភាគច្រើនចាប់អារម្មណ៍តាមដានព័ត៌មានមង្គលការនេះ ថ្នាក់អ្នកការពារនៅតែធ្វើការរបស់ខ្លួន ដើម្បីការពារប្រទេសសាក់ខាវៀ និងរាជវង្ស ម៉ាលខៃសេនតេ។

ខាឡូម៉ាន់ ធ្វើការហត់នឿយជាងគេជាងឯង ព្រោះហេតុផលនេះហើយទើបព្រះនាង ការ៉ុន ព្រមឲ្យមានការវាស់ខ្លួន ដើម្បីកាត់សម្លៀកបំពាក់កើតឡើង ដោយមិនតវ៉ា មិនរករឿងធ្វើឲ្យបងប្រុសត្រូវរវល់មួយរឿងទៀត។ បងប្រុសនឹងមិនឈឺក្បាលវៃមុខ តែនាងនឹងយកអាការៈនោះទៅបោះឲ្យ រៃមសៀ។

"ម៉េចក៏ធ្វើមុខបែបនេះ"

ចាស៊្មីន ធ្វើដំណើរមកដំណាក់របស់ ការ៉ុន ដើម្បីវាស់ខ្លួនកាត់ឈុតមង្គលការ ដោយនាំជំនួយការពីរនាក់មកជាមួយ។



"ឯងគិតថាខ្ញុំគួរធ្វើមុខយ៉ាងណា ចាស៊្មីន"

"ធ្វើមុខមានសេចក្តីសុខល្អទេ"

"មិនល្អ"

ចាស៊្មីន ញញឹមស្រស់ដាក់ចម្លើយដែលទទួលបាន... ព្រះនាង ការ៉ុន នៅតែមិនទាន់ត្រូវគ្នានឹងលោកឧត្តមសេនីយ រៃមសៀ។

"ខ្ញុំមិនចង់រៀបការ"

"មុននេះឯងយល់ព្រមតើ"

"ព្រោះខ្ញុំគិតដល់ប្រយោជន៍សម្ហូហភាព"

"ជាគំនិតល្អ"

"ពេលនេះមិនល្អទេ"

ការ៉ុន ព្រមឲ្យវាស់ខ្លួនទាំងមុខក្រមូវទាល់តែចរាល់ ទើប ចាស៊្មីន បក់ដៃឲ្យជំនួយការទាំងពីរចេញពីបន្ទប់។

"ការ៉ុន..."

"បើចង់និយាយដើម្បីឲ្យរកបុរ៉ៃ រៃមសៀ ល្អ អីចឹងមិនបាច់និយាយទេ"

"ម៉េចក៏ហៅអនាគតស្វាមីបែបនេះ"

"ចង់ហៅបែបនេះ មិនបាច់ផ្តល់កិត្តិយសទេ ព្រោះគេមិនផ្តល់កិត្តិយសឲ្យខ្ញុំដែរ"

ពេលគេមិនផ្តល់កិត្តិយសឲ្យនាង នាងក៏ធ្វើបែបហ្នឹងដាក់គេវិញដែរ។ នៅចំពោះមុខអ្នកដទៃ នាងត្រូវប្រុងប្រយ័ត្នរឿងមារយាទ ព្រោះបើនាងច្រងេង



ប្រងាង បងប្រុសនឹងរងការរិះគន់ថាមិនបានអប់រំទូន្មានប្អូនស្រី តែ ចាស្មីន មិនមែនអ្នកដទៃ ដូច្នោះហើយនាងនិយាយអីក៏បាន។

"ឯងមិនទាន់បាត់ខឹង លោកឧត្តមសេនីយ រ៉េមសៀ ឬ ?"

"មិនបានខឹងទេ" នាងបដិសេធ មុខក៏ក្រមូវ ហើយបែរខ្លួន ដើរមកដាក់បង្អួយលើសាឡុង ចាស្មីន ក៏ដើរតាមកអង្គុយលើសាឡុងមួយទៀត។

"ការ៉ុន"

"ដឹងហើយ ថាចង់និយាយជំនួសមនុស្សឆ្កួតនោះ ឯងមិនបាច់និយាយអីទេ ព្រោះម្ចាស់គេមិនឃើញនិយាយអីផង ពាក្យសុំទោសមួយម៉ាត់មិនទាន់ធ្លាយចេញពីមាត់ផង"

បើសិន គេហាមាត់សុំទោស នាងនឹងធ្វើចិត្តទូលាយ អភ័យទោសឲ្យ ប៉ុន្តែដែលត្រូវចិត្តចង្អៀតបែបនេះ ព្រោះ រ៉េមសៀ មិនធ្លាប់និយាយពាក្យហ្នឹង គេយកភាពរឹងរូសមកតតាំងនឹងនាង ហើយនាងកាន់តែឆ្អាសដាក់ ព្រោះត្រូវការយកឈ្នះ។

នាងល្បើយ មិនមែនទន់ជ្រាយ តែព្រោះកម្លាំងស៊ូនឹងគេមិនបាន។ នាងព្យាយាមហើយមិនឆ្អាសឆ្អើមដាក់គេ តែដែលធ្វើមិនបានសម្រេច គឺមកពីគេធ្វើបាបនាង។ រ៉េមសៀ ដាវ៉េហីណេស...បុរសម្នាក់នោះក្រៅពីឈ្លើយហើយនៅគ្មានមារយាទ ជាសុភាពបុរសទៀត។

"បើលោកឧត្តមសេនីយសុំទោស ឯងនឹងអភ័យឲ្យមែនទេ ?"

"មុននេះខ្ញុំនឹងអភ័យឲ្យ តែពេលនេះខ្ញុំមិនដឹង ត្រូវមើលស្ថានការណ៍មុន



នេះ"

ការ៉ុន និយាយដោយភាពក្រអឹតក្រទម។ នាងក៏លួចគិតដែរ រ៉េមសៀ អាចសុំទោសនាង ដោយសម្ដីនៅថ្ងៃនោះគេអាចនិយាយព្រោះភាពតានតឹង និងមិនបានជារៀបឬគគា ឬដោយហេតុផលអ្វីក៏ដោយ ហើយបើគេព្រមសុំទោស នាងក៏ព្រមឲ្យអភ័យ។ សូម្បីតែពេលនេះក៏ដោយ តែដែលត្រូវឆ្លើយតបមិត្តសម្លាញ់បែបនេះគឺដើម្បីរក្សាមុខឲ្យខ្លួនឯង មិនព្រមអភ័យឲ្យគេងាយពេក។ នាងរង់ចាំអភ័យឲ្យ តែ រ៉េមសៀ មិនត្រូវការទឹកចិត្តពីនាង និងក្រៅពីសុំទោសហើយ គេនៅលូកលាន់នាងម្ដងហើយម្ដងទៀត។

*មនុស្សអន់ចរិត!*

ការនឹកដល់គេ ធ្វើឲ្យនាងកាន់តែមួម៉ៅ។ នាងឆ្អាសឆ្អើមដាក់គេពេកក៏មិនបាន ព្រោះវានឹងប៉ះពាល់ដល់ប្រមុខប្រទេស។ បើមិនដើម្បីបងប្រុស នាងនឹងបដិសេធមង្គលការនេះដោយមិនព្រមទោរទន់ទៅហើយ តែដែលនាងត្រូវព្រមគឺព្រោះតែក្ដីស្រឡាញ់ដែលមានចំពោះបងប្រុស។

សុំត្រឹមធ្វើឲ្យគ្រឹះអំណាចរបស់បងប្រុសនឹងនបាន នាងសុខចិត្តអត់ធ្មត់ទោះចិត្តមិនចង់ទ្រាំនឹងស្ថានការណ៍នៅពេលនេះក៏ដោយ។ នាងនិងគេចាប់ផ្ដើមដោយភាពតានតឹង ដូច្នោះហើយជីវិតបន្ទាប់ពីមង្គលការ មុខជាក្ដៅគគុកដោយភ្លើងដែលពួកគេត្រៀមជះដាក់គ្នា។

រ៉េមសៀ ត្រូវតែព្យាយាមគាបសង្កត់ឲ្យនាងលុះក្រោមអំណាចរបស់គេ ព្រោះគេជាមនុស្សឆ្កួតអំណាច ចូលចិត្តចេញបញ្ជា ខណៈដែល ការ៉ុន ក៏ត្រៀម



ខ្លួនរឹងក្បាលដាក់គេពេញទី។ នាងនឹងមិនព្រមឲ្យ រ៉ែមសៀ បានដូចចិត្តងាយៗទេ នាងនឹងឆ្លាសឆ្លើម និងរឹងទទឹងដាក់គេឲ្យដល់ទីបំផុត ហើយបើគេហ៊ានតែប៉ះពាល់ ធ្វើឲ្យនាងមានរបួស ខាឡូម៉ាន់ នឹងចេញមុខចាត់ការ។ នាងដឹងថាខ្លួនឯងនឹងមានសុវត្ថិភាពពីការត្រូវធ្វើបាបរាងកាយ ទោះមិនមែនជាប្អូនស្រីរបស់ ខាឡូម៉ាន់ តែនាងជឿភាពជាបុរសដើមទ្រូងប្រាំហត្ថ ដែលមិនធ្វើបាបមនុស្សស្រីរបស់ រ៉ែមសៀ។ នោះអាចជាចំណុចល្អតែមួយគត់របស់គេក៏ថាបាន ដូច្នោះហើយក្នុងពេលដែលនាងជឿជាក់គេពីរឿងនេះហើយ អ៊ីចឹងចូរជឿជាក់បន្តទៅ។

ការ៉ុន ហាមខ្លួនឯងមិនឲ្យជឿមិនបាន គឺរកហេតុផលដែលធ្វើឲ្យខ្លួនឯងមានអារម្មណ៍ល្អនៅក្នុងការព្រមទទួលយក រ៉ែមសៀ។ នាងមិនចង់សរសើរគេ បន្ទាប់ពីសរសើរគេច្រើនណាស់ អារម្មណ៍របស់នាងក៏ត្រូវបំផ្លាញ ព្រោះវាជាក្រអឺតក្រទមរបស់គេ។

"ឯងជាមនុស្សចិត្តទូលាយ"

"សរសើរដើម្បីជួយគេ"

"ព្រោះខ្ញុំចង់ឲ្យឯងមានសេចក្ដីសុខ ឯងជាមិត្តរបស់ខ្ញុំ ចំណែកលោកឧត្តមសេនីយ រ៉ែមសៀ ជាអ្នកដទៃ"

"ខ្ញុំមិនចនឹងមានសេចក្ដីសុខទេ បើត្រូវរៀបការនឹងមនុស្សប្រុសដែលគេមិនស្រឡាញ់ខ្ញុំ ក្រៅពីនេះគេមិនផ្ដល់កិត្តិយសឲ្យខ្ញុំទៀត គេកាត់ក្ដីខ្ញុំមុនពេលបានស្គាល់ខ្ញុំច្បាស់"

"ហើយគេនឹងប្ដូរចិត្តពេលបាននៅជិតឯង"



"ខ្ញុំធ្លាប់ប្រាប់ឯងហើយ ចាស្មីន ខ្ញុំជាមនុស្សអន់ចរិតដែលគេជឿ"

"ចង់បញ្ឆោលោកឧត្តមសេនីយឬ?"

"មិនបានបញ្ឆោទេ តែគេសមតែបានទទួលការស្វាគមន៍បែបនេះ"

បែបនេះហើយដែលគេហៅថាបញ្ឆោ តែក្នុងពេលដែលមិត្តភក្តិមិនព្រមទទួល ចាស្មីន ក៏មិនបង្ខំ ដែលនឹងធ្វើឲ្យ ការ៉ុន ខឹងកាន់តែខ្លាំង។

"ខ្ញុំចង់ឲ្យឯងមានសេចក្ដីសុខពិតមែន ការ៉ុន"

"ខ្ញុំនឹងមានសេចក្ដីសុខលើគំនរទុក្ខរបស់ រ៉ែមសៀ ដាវ៉ៃហ៊ីណោស ខ្ញុំនឹងធ្វើគ្រប់រឿងដែលគេមិនចូលចិត្ត ដើម្បីដាក់ទោសទេ"

ចាស្មីន ញញឹម ទោះមិនយល់ស្របនឹងការសម្រេចចិត្តរបស់មិត្តភក្តិ តែពេល ការ៉ុន បញ្ជាក់បែបនេះទៅហើយ នាងត្រូវតែគោរពការសម្រេចចិត្តនេះ មិនច្បាស់ទេ បន្តិចទៀត ការ៉ុន អាចប្ដូរចិត្តក៏ថាបាន។

"ញញឹមបែបនេះ មិនជឿថាខ្ញុំធ្វើមែនឬ?"

"ជឿតើ"

"ឯងនឹងបានឃើញអាប៉ិ រ៉ែមសៀ ក្លួតឈាម ខ្ញុំមិនព្រមឲ្យគេគ្រប់គ្រងទេ តែគេទៅវិញទេដែលត្រូវលុះក្រោមអំណាចរបស់ខ្ញុំ"

"កុំធ្វើឲ្យខ្លួនឯងទុក្ខសោកទៅបានហើយ"

"ខ្ញុំមិនទុក្ខសោក ដោយសារមនុស្សឆ្កួតបែបហ្នឹងទេ ចាស្មីន" ការ៉ុន បញ្ជាក់។

ការនិយាយពី រ៉ែមសៀ ធ្វើឲ្យនាងមួម៉ៅ តែនាងត្រូវបានឮឈ្មោះរបស់គេ





Scanned by CamScanner

ញីកញាប់ ព្រោះពេលនេះជាគូបម្រុងភ្ជាប់ពាក្យនឹងគ្នា និងជិតរៀបការឆាប់ៗនេះហើយ ហើយកូនក្រមុំកូនកំលោះដែលមិនចូលចិត្តគ្នានឹងរស់នៅជាមួយគ្នាដើម្បីប្រយោជន៍សមូហភាពបានយូរប៉ុណ្ណា ដែលសំណួរនេះនាងបានតែសួរខ្លួនឯង តែរកចម្លើយមិនបាន។

រ៉មសៀ សម្ងំនៅក្នុងព្រៃ។ គេមិនបានធ្វើវា ដើម្បីដាក់ទោសខ្លួនឯង ឬត្រូវការរកកន្លែងស្ងប់ស្ងាត់ ដើម្បីគេចវេះពីពិធីមង្គលការនឹងព្រះនាងមេបញ្ញា តែវាជាភារកិច្ចដែលគេជាអ្នកដឹកនាំ មានអ្នករួមដំណើរចំនួនបួននាក់ ដោយគ្រប់គ្នាសុទ្ធតែមានជំនាញនៅក្នុងការបង្កប់ខ្លួនក្នុងភាពងងឹត។

បើពួកប្រឆាំងនៅមានកម្លាំងធ្វើសង្គ្រាមនឹង ខាឡូម៉ាន់ បែបស្ងាត់ៗ គេនិងក្រុមអ្នកការពារ រួមទាំងសម្ព័ន្ធមិត្តក៏មិនហត់នឿយនឹងតាមកាត់ក្បាលពួកវា។ ភាពវឹកវរដែលកើតមាននឹងត្រូវបង្រ្កាបរាល់ថ្ងៃ តែត្រូវធ្វើស្ងាត់ៗ ដើម្បីមិនឲ្យប្រជាជនភ័យខ្លាច ឬធ្វើឲ្យប្រជាជននៅតែមិនទុកចិត្តចំពោះសមត្ថភាពរបស់ ខាឡូម៉ាន់ តែពួកគេក៏កម្ចាត់កងកម្លាំងរបស់ពួកវាបានរាល់ថ្ងៃ។

មិនដឹងថាត្រូវចំណាយពេលដល់ពេលណា និងមិនដឹងថាគេ ឬមេពួកប្រឆាំង អ្នកណាងាប់មុន ជួនកាលអាចជាគេក៏ថាបាន ប៉ុន្តែពេលនៅមានដង្ហើមជក គេនៅតែបំពេញភារកិច្ចតាមការស្បថស្បែដែលមានចំពោះ ខាឡូម៉ាន់។

'គាំទ្រនិងការពារ ខាឡូម៉ាន់ ដោយជីវិត'

គេស្បថថានឹងប្រគល់ជីវិតឲ្យ ខាឡូម៉ាន់ ដរាបណាដែល ខាឡូម៉ាន់ នៅ



តែមានគោលដៅនៅក្នុងការអភិវឌ្ឍប្រទេសសាក់ខាវៀ។ គេមានឈាមរបស់សាក់ខាវៀ នៅក្នុងខ្លួន ការបានឃើញប្រទេសជាតិមានសុខសន្តិភាពនិងមានភាពរីកចម្រើនដូចប្រទេសដទៃ គឺជាគោលដៅរបស់គេ។

គេវារទៅមុខយឺតៗ តែម៉ឺងម៉ាត់ និងពោរពេញដោយថាមពល ដៃចាប់កាំភ្លើងជាប់ កាំភ្លើងទុកផ្តាច់ជីវិតពួកប្រឆាំងរាប់មិនអស់ ហើយបើមិនសម្លាប់ពួកវា គេនឹងត្រូវពួកវាសម្លាប់។ ភ្នែកសម្លឹងកាត់ភាពងងឹតទៅបរិវេណផ្ទះដែលដូចត្រូវបោះបង់តែមិនបោះបង់។ កែវភ្នែករបស់ រ៉មសៀ ពេលប្រតិបត្តិភារកិច្ចប្រាសចាកពន្លឺ វាត្រជាក់ រឹងកំព្រឹស ឃោរឃៅ ព្រៃផ្សៃ ឬចង់ប្រាប់ថាយង់ឃ្នងឈាមត្រជាក់ក៏បាន។ គេជាមនុស្សបែបនោះ ពេលសម្លាប់សត្រូវ តែមិនសម្លាប់ផ្តេសផ្តាស គេនឹងចាត់ការទាល់តែច្បាស់ថាពួកវាជាគ្រោះភ័យចំពោះរាជបល្ល័ង្ករបស់រាជវង្ស ម៉ាលខៃសេនតេ។

សង្គ្រាមតែងតែឃោរឃៅជានិច្ច បើចិត្តទន់នឹងក្លាយជាអ្នកចាញ់ ហើយបើចាញ់ តើមានអ្នកអាណិតគេឬអត់ ចម្លើយគឺគ្មាននោះទេ ហើយគេនឹងត្រូវចាប់ខ្លួន ដាក់ទណ្ឌកម្មឈ្លេចយកអាថ៌កំបាំង ចុងក្រោយនឹងត្រូវផ្តាច់ជីវិត។

គេធ្វើសញ្ញាដៃដាក់អ្នកនៅក្រោមបង្គាប់បញ្ជា ទើបមានការពង្រាយកម្លាំងកើតឡើង។ ពួកគេធ្វើការជាមួយគ្នាប្រើចំនួនមនុស្សតិច តែពោរពេញដោយសម្ថភាព ញើសហូរជោកខ្លួន តែរាងកាយរបស់គេទ្រាំទ្រនឹងអាកាសធាតុបានយ៉ាងល្អមិនថាក្តៅ ឬត្រជាក់។ រាងកាយរបស់គេត្រូវបង្វឹកយ៉ាងសាហាវស្ទើរតែដាច់ខ្យល់ ពេលឆ្លងផុតពេលវេលានោះ ក៏ចូលបម្រើក្នុងជួរកងទ័ព។



តេស្អប់ការប្រើអំណាច ដែលបានមកដោយភាពមិនត្រឹមត្រូវ រកផលប្រយោជន៍ឲ្យខ្លួនឯងនិងបក្សពួក។ គេសម្ងំនៅជួរកងទ័ព ប្រមូលទិន្នន័យ ទាល់តែ ខាឡូម៉ាន់ ចេញបញ្ជា។ គេជាកងកម្លាំងដ៏សំខាន់ មិនត្រឹមតែបញ្ចេញកម្លាំងទេ នៅបញ្ចេញខួរទៀត។

គេតាមដានពួកវាទាល់តែច្បាស់ថាទីនេះជាសម្បុកមួយ ហើយរាងកាយរបស់គេហត់នឿយនឹងការសម្ងំនៅក្នុងព្រៃបីថ្ងៃហើយ ដោយសង្កេតការណ៍មិនឲ្យបាត់ពីភ្នែក។

ការសម្រុកចូលទៅបោសសម្អាតនឹងកើតឡើង ប្រសិនបើមានការបញ្ជាក់គោលដៅច្បាស់លាស់ ព្រោះខ្លាចប៉ះជនបរិសុទ្ធ ឬបុគ្គលដែលមិនដឹងរឿ ទើបត្រូវធ្វើការឲ្យម៉ត់ចត់។

ខ្លួនប្រាណរបស់គេត្រូវមូសខាំនិងត្រូវសត្វល្អិតទិច តែគេគ្មានអារម្មណ៍នឹករឃើញវា ព្រោះមានរឿងសំខាន់ជាងឲ្យទទួលខុសត្រូវ ទើបរឿងមូសសត្វល្អិត ត្រូវបំភ្លេចចោល។

វែមសៀ ខិតចូលទៅជិតបន្តិចទៀត ពេលឆ្លងផុតរបងបន្លាលួសដែលពួកវាបង្កប់នឹងស្លឹកឈើស្លឹកព្រៃ ហើយដើបឈរយឺតៗ។ គេមានមាឌធំ តែរហ័សរហួន ព្រោះរាងកាយត្រូវបង្វឹកដើម្បីចម្បាំង និងប៉ប៉ុកនឹងចម្បាំងយូរឆ្នាំ ស្ទើរស្លាប់ស្ទើររស់រាប់មិនអស់ ហើយគេក៏មិនខ្លាចស្លាប់ដែរ ទោះថ្ងៃនេះអាចនាំជីវិតត្រឡប់ទៅវិញមិនបាន ក៏មិនស្តាយនឹងពលីដើម្បីប្រទេសជាតិ។

ការដែល សាក់ខារៀ ស្ថិតនៅក្រោមការមើលថែរបស់ ខាឡូម៉ាន់ តែងតែ



ល្អជាងស្ថិននៅក្នុងកណ្តាប់ដៃរបស់ពួកប្រឆាំង ដែលគ្រប់គ្រងប្រទេសដោយភាពអាត្មានិយម ប្រជាជនក្រីក្រមិនទទួលបានការសិក្សាអប់រំ ដែលការសិក្សានៅ សាក់ខារៀ ជារឿងដែលត្រូវហាម ព្រោះវានឹងធ្វើឲ្យប្រជាជនឆ្លៀវឆ្លាត។

ខាឡូម៉ាន់ ត្រូវកែប្រែប្រព័ន្ធការសិក្សាធំណាស់ វាត្រូវចំណាយពេល ប៉ុន្តែបើឧត្តមគតិរបស់ ខាឡូម៉ាន់ មិនប្រែប្រួល គេជឿជាក់ថាការរស់នៅរបស់ប្រជាជននឹងល្អប្រសើរ និងដើម្បីឲ្យ ខាឡូម៉ាន់ ធ្វើការសម្រេចគោលដៅ អ្នកដែលរារាំងផ្លូវនឹងត្រូវកម្ចាត់ តែមានម្នាក់ត្រូវទុកជីវិតដើម្បីទុកស៊ើបរកទិន្នន័យ។

វែមសៀ ញញឹមត្រជាក់ វាជាស្នាមញញឹមរបស់មច្ចុរាជ។ គេនិងមនុស្សរបស់គេ សម្រុកចូលទៅក្នុងផ្ទះគោលដៅ ចំណាយពេលដប់នាទីនៅក្នុងការកម្ចាត់របស់មានជីវិតនៅក្នុងផ្ទះនោះអស់ ទុកតែម្នាក់ដែលត្រូវចាប់ឲ្យលុតជង្គង់នៅចំពោះមុខគេ។

"អញមិនប្រាប់ស្អីទាំងអស់"

ចប់ការប្រកាស វាក៏បើកភ្នែកធំៗ។ ក្នុងពេលដែលវាប្រកាសសច្ចាគ្រាប់កាំភ្លើងរបស់គេ ក៏ទម្លុះក្បាលរបស់វា ផ្អាកការចរចាតែម្តង។

"សំណាងដែលប្រាប់មុន កុំឲ្យខាតពេលសួរ"

វែមសៀ ឈរព្រលែងខ្លួននៅក្នុងផ្ទះរបស់គេ ដែលជាផ្ទះស្នាក់នៅបណ្តោះអាសន្នក្នុងក្រុងសេនជាម៉ារ៉ា ជាទីក្រុងធំរបស់ប្រទេស សាក់ខារៀ ជាមណ្ឌលសេដ្ឋកិច្ច និងការគ្រប់គ្រងប្រទេស។





Scanned by CamScanner

តេលាងសម្អាតដៃស្មោកគ្រោកនៅក្នុងឡាបូស្អាត យឺតៗ បន្ទាប់ពីការសម្លាប់ អាដ្រេណាលីននៅក្នុងខ្លួនកំពុងពុះ តេត្រូវការកម្ចាយភាពតានតឹងដែលមានប៉ុន្មានវិធីប៉ុណ្ណោះឲ្យប្រើ ហើយវិធីដែលទទួលបានផលល្អបំផុតគឺ ការធ្វើឲ្យខ្លួនឯងហត់នឿយ។

*តេត្រូវការរឿងលើគ្រែ!*

វ៉ែមសៀ ត្រូវការខ្លាំងណាស់ តែគ្មានពេលសម្រាប់រឿងនេះ ព្រោះត្រូវធ្វើដំណើរទៅប្រាសាទវ៉ែរូសា របស់ ខាឡូម៉ាន់ ដើម្បីចូលរួមទទួលទានអាហារពេលល្ងាច។ ការប្រតិបត្តិការភារកិច្ចសម្ងាត់ ឈ្មោះវាបញ្ជាក់ច្បាស់ ដូច្នេះហើយនៅក្នុងពិធីជប់លៀង គួបការប្រកាសឲ្យអ្នកនៅជិតខ្លួនដឹងពីពិធីមង្គលការរបស់គេ និងព្រះនាង ការ៉ុន គឺមិនអាចខ្វះតេ។

បើមិនត្រូវទៅពិធីជប់លៀង តេនឹងហៅមនុស្សស្រីមកបម្រើ ដួងផងយកសេចក្តីសុខដើម្បីកម្ចាយភាពតានតឹង តែតេត្រូវបញ្ឈប់គំនិតនោះ។

តេសម្លឹងមើលកញ្ចក់ ឃើញបុរសម្នាក់មានបុគ្គលិកលក្ខណៈអង់អាចក្លាហាន កែវភ្នែករឹងកំព្រឹង មុខមាត់មានទម្រង់ច្បាស់ចែស រូបរាងសង្ហាបែបបុរសព្រៃផ្សៃ មិនមែនបុរសចូលចិត្តសម្លាង ស្រ្តីដែលលង់ស្នេហ៍តេ បើមិនចូលចិត្តភាពកំណាចរបស់តេ គឺមានតែខ្លាចតេ។

វ៉ែមសៀ លាងដៃយឺតៗម្តងទៀត ហើយដើរទាំងនរលតកចូលបន្ទប់ទឹកផ្កាឈូក បើមានពេលការត្រាំទឹកនៅក្នុងអាងជារឿងគួរឲ្យចាប់អារម្មណ៍ ប៉ុន្តែតេគ្មានពេលធ្វើរឿងទាំងនោះ តេត្រូវងូតទឹកជម្រះខ្លួនឲ្យស្អាត យក



ចាក់ស៊ីដូ មកពាក់ដើម្បីធ្វើដំណើរទៅប្រាសាទវ៉ែរូសា។

"អ៊ំ..."

តេស្រែកតិចៗ ពេលទឹកក្តៅឧណ្ហៗស្រក់លើខ្លួន សាច់ដុំតានតឹងកំពុងតែទទួលបានការលួងលោម។

"ឈឺណាស់"

តេទើបតែមានអារម្មណ៍ថាឈឺគ្រគាក និងទើបតែនឹកឃើញថា វាទង្គិចនឹងដុំថ្មពេលបង្កប់ខ្លួន ក្រោមភាពងងឹតនោះ ទោះខ្សែភ្នែកធ្វើការបានល្អ តែវាជៀបនឹងពេលភ្លឺមិនបាន ភាពថ្លោះធ្លោយតូចតាច។

"បើជួបពួកឯងទៀត អញនឹងសម្លាប់ទៀត"

តេខាំថ្គាមណែន ប្រសាទសម្ផស្សនៅតែជ្រួលច្រាល់នឹងអាចបំពេញប្រតិបត្តិការជានិច្ច។

**ពេលធ្វើដំណើរមកដល់ប្រាសាទវ៉ែរូសា នាងក៏ដកដង្ហើមចូលឲ្យជ្រៅៗ** ដើម្បីជាកម្លាំងចិត្តឲ្យខ្លួនឯង ព្រោះដឹងថាត្រូវជួបអ្នកណានៅថ្ងៃនេះ តើមានអ្នកណាទៀត បើមិនមែនបុរសដែលនាងចង់ខ្ទាចមុខ ចង់ធ្វើឲ្យកឆ្កាសឆ្អើមដាក់ និងចង់រត់តេចពីតេនៅក្នុងពេលតែមួយ...វ៉ែមសៀ ដាវ៉ៃហ៊ីណោស...ឈ្មោះនេះតាមលងបន្លាចនាង។

ការ៉ុន នៅក្នុងបន្ទប់សម្រាកសម្រាប់ភ្ញៀវ ដែលបងប្រុសឲ្យអ្នកបម្រើរៀបចំ ហើយត្រូវរៀបចំខ្លួនប្រាណឲ្យកាន់តែស្អាត ទាក់ទាញភ្នែកលើសដើម





Scanned by CamScanner

ដោយថ្វីដៃនៃការមើលថែផ្នែកសម្លៀកបំពាក់មុខមាត់ពី ចាស្មីន។

នាងធ្លាប់និយាយថា ដៃរបស់ ចាស្មីន ដូចមានវេទមន្ត ព្រោះអាចនិម្មិតសម្រស់ឲ្យអ្នកណាក៏បាន ស្ត្រីដែលឆ្លងកាត់ដៃរបស់ ចាស្មីន ត្រូវតែស្អាត។

ការ៉ិន ពាក់រ៉ូបរាត្រីចោមពុង រៀលត្រង់ដើមទ្រូង មើលឃើញគល់ទ្រូងទ្រលុកទ្រលន់ ទាំងខាងលើនិងចំហៀង។ ត្បិប ទោះមើលទៅទាក់ទាញ តែត្រូវប្រខាំជាប់នឹងរាងកាយរបស់នាងដោយមានសុវត្ថិភាព ហើយនាងមានចេតនាជ្រើសរើសរ៉ូបនេះដើម្បីបញ្ឈឺ រ៉ែមសៀ ជាពិសេស។ វាមិនបានសិចស៊ីគួរឲ្យស្អប់តែវាទាក់ទាញ នាងមិនដឹងទេថា ធ្វើឲ្យគេកើតទោសៈបានឬអត់ ដែលនាងមិនមែនជាកុលស្ត្រី ដែលស្លៀកពាក់បិទជិតតាំងពី.ក មកដល់កជើង។

នាងបង្វិលខ្លួននៅមុខកញ្ចក់ បរិវេណរៀលមានក្រណាត់ស្តើងបិទបាំងហើយនាងក៏ការពារខ្លួនឯងបានល្អ។ នាងបង្វិលខ្លួនម្តងទៀត រ៉ូបចោមពុងនៅលើដងខ្លួននៅតែតោងជាប់មិនរបូត។

សក់ទន់ល្មើយរលោងស្អាតត្រូវលើកបួងល្អដោយគ្រឿងលម្អធ្វើពីពេជ្រហើយដើរដោយដំណើរសិចស៊ី ត្រង់កន្លែងឆែកមើលឃើញជើងស្រឡូន។

"អរគុណ ចាស្មីន ឯងធ្វើឲ្យខ្ញុំស្អាតណាស់"

"ព្រោះឯងស្អាតស្រាប់ហើយ"

ចាស្មីន មិនបាននិយាយបញ្ហារមិត្តភក្តិ តែ ការ៉ិន ជាស្ត្រីដែលគ្មានអ្នកណាប្រៀបបាន ហើយរ៉ូបដែលកំពុងពាក់ក៏ប្រណិតធ្វើឲ្យភាពទាក់ទាញរបស់ស្ត្រីគេទកាន់តែលេចធ្លោ តែមិនបានសិចស៊ី អាក្រក់មើល វាត្រូវថ្លៃម៉ូតឲ្យ



ចេញមកគួរឲ្យស្ញែងរកដោយការបង្ហាញសាច់បង្ហាញឈាមតិចៗ។ វាជាម៉ូតដែលទាក់ទាញចំណាប់អារម្មណ៍បុរសបានល្អដោយមិនបាច់សង្ស័យ រូបឆ្យនឹងរូបរាងមុខមាត់របស់អ្នកពាក់ បុរសមុខជាពិបាកដកខ្សែភ្នែកចេញ។

ព្រះនាងបង្វិលខ្លួនម្តងទៀត ដើម្បីពិនិត្យខ្លួនឯងនៅក្នុងកញ្ចក់ និងសរុបឃើញថានាងពេញចិត្តនឹងសម្រស់ដែលបានឃើញក្នុងកញ្ចក់នោះ។

"ឯងចូលចិត្ត ខ្ញុំក៏សប្បាយចិត្ត ការ៉ិន"

"ចូលចិត្តណាស់"

ការ៉ិន ងាកទៅញញឹមដាក់មិត្តភក្តិ។ មនុស្សស្រីនិងរឿងសម្រស់ជារបស់គូនឹងគ្នា។

"សូមឲ្យរីករាយនឹងពិធីជប់លៀង"

"ខ្ញុំចង់ឲ្យឯងចេញទៅដែរ"

"ខ្ញុំគ្មានតួនាទីនៅទីនោះទេ"

"ឯងជាមិត្តរបស់ខ្ញុំ ចាស្មីន"

"ខ្ញុំធ្វើការឲ្យរាជវង្ស ម៉ាលខៃសេនតេ ខ្ញុំត្រូវប្រុងប្រយ័ត្ន ដើម្បីមិនឲ្យឯងរងការរិះគន់ដោយសារខ្ញុំ ការ៉ិន"

ចាស្មីន នឹងមិនបង្ហាញភាពស្និទ្ធស្នាលដោយមិនចាំបាច់ពេលនៅខាងក្រៅ នាងយកចិត្តទុកដាក់ធ្វើការ និងនៅកន្លែងរបស់នាងស្ងាត់ៗ ដើម្បីមិនឲ្យមានការរិះគន់កើតឡើង។

"ខ្ញុំមិនខ្វល់ពីអ្នកទាំងនោះទេ"





Scanned by CamScanner

"តែខ្ញុំខ្វល់ ខ្ញុំជាមិត្តរបស់ឯង និងមិនចូលចិត្តឲ្យអ្នកណាជាឲ្យឯងទេ"

"ពួកនោះធ្វើបានត្រឹមនិយាយនៅក្រោយខ្នង នៅចំពោះមុខពួកគេមិនហ៊ានទេ"

នាងជាប្អូនស្រីរបស់ព្រះអង្គម្ចាស់ ខាឡូម៉ាន់ បើអ្នកណានិយាយដើមមិនល្អ នឹងត្រូវបានដាក់ទោស។

"ឯងទៅចូលរួមឲ្យរីករាយទៅ នេះជាកម្មវិធីរបស់ឯង"

"ជាកម្មវិធីរបស់ប្រទេស សាក់ខាវៀ ខ្ញុំធ្វើដើម្បីប្រទេសជាតិ ដើម្បីបងប្រុស មិនអីចឹង ខ្ញុំមិនព្រមទៅចូលរួមទេ ព្រោះខ្ញុំមិនចង់ជួបអាប៉ុ រ៉ែមសៀ"

"ឯងជាមនុស្សមានហេតុផល ខ្ញុំដឹង"

"ទោះអាប៉ុនោះមើលខ្ញុំនៅក្នុងផ្លូវអាក្រក់ក៏ដោយ ព្រោះខ្ញុំមានឯងដែលស្គាល់ខ្ញុំច្បាស់ជាងគេ"

"មិនដូចគ្នាទេ ការ៉ិន ខ្ញុំជាមិត្តភក្តិ តែលោកឧត្តមសេនីយ រ៉ែមសៀ ជាគូស្នេហ៍របស់ឯង"

"គេមិនមែនគូស្នេហ៍របស់ខ្ញុំ"

ការ៉ិន ធ្វើមុខក្រមូវ ព្រោះនាងនិង រ៉ែមសៀ មិនមែនជាគូស្នេហ៍នឹងគ្នា មិនធ្លាប់ជាគូស្នេហ៍ និងគ្មានថ្ងៃបានធ្វើដែរ មានតែភាពជាសត្រូវប៉ុណ្ណោះ។

"អីចឹងជាអនាគតស្វាមី"

"ហ្នឹង គេជាអនាគតស្វាមី តែគ្មានថ្ងៃបានធ្វើជាគូស្នេហ៍របស់ខ្ញុំទេ"

ដើម្បីមិនឲ្យមិត្តភក្តិមួម៉ៅ ទើប ចាស្មីន បញ្ឈប់ការសន្ទនាពី រ៉ែមសៀ និងអញ្ជើញព្រះនាងឲ្យទៅចូលរួមពិធីជប់លៀង។



# ៥

## សាំងនិងភ្លើង

ពេលចេញពីបន្ទប់ ការ៉ិន ក៏ជួប ខាឡូម៉ាន់ ដែលដើរមករក។ បងប្រុសសង្កាពិនិត្យមើលប្អូនស្រី ហើយសម្លឹងមើលទៅក្រោយខ្នងរបស់នាង ដែលមាន ចាស្មីន តាមដោយ ស៊ីឡា និង ហ្វីរ៉ា ទើបពួកនាងបន្ទន់ជង្គង់ ធ្វើការគោរព ហើយឈរឈ្ងោកមុខ ស្រាក់ដៃដាក់លើពោះ។

ខាឡូម៉ាន់ នឹកឆ្ងល់នឹងការតែងខ្លួនរបស់ប្អូនស្រីដែល ចាស្មីន ជាអ្នករៀបចំឲ្យ។ ប្អូនស្រីរបស់គេស្អាត សិចស៊ីមែនទែនពេលតែងខ្លួនដោយរ៉ូបម៉ូតនេះ តែវាទាក់ទាញអារម្មណ៍បុរសភេទពេកហើយ។

"បងប្រុសមកទទួលប្អូនឬ"

ការ៉ិន មិនមែនជាមនុស្សស្រីល្ងង់។ នាងដឹងថាបងប្រុសមិនពេញចិត្តនឹងការតែងខ្លួនរបស់នាង ទើបយកភាពទន់ភ្លន់មកទប់ទល់ ដោយពេលបន្ទន់ជង្គង់គោរពរួចរាល់ ក៏ដើរទៅឱបដៃគេ។

"មែន រ៉ែមសៀ ធ្វើដំណើរមកដល់ហើយ"

"ចាំ បងប្រុស" នាងតប។

ការធ្វើខ្លួនជាគូបដិបក្សនឹង រ៉ែមសៀ ឲ្យបងប្រុសឃើញ វាមិនមែនជា





Scanned by CamScanner

រឿងល្អទេ ដូច្នេះហើយនាងនឹងធ្វើខ្លួនស្លូតបូត រាបសារ ស្ដាប់បង្គាប់ ហើយចាំបញ្ចេញតេជឫទ្ធិដាក់គេ ពេលនៅជាមួយគ្នាតែពីរនាក់។ បើធ្វើឲ្យបងប្រុសបានឃើញអាកប្បកិរិយាដែលនាងធ្វើដាក់ វ៉ែមសៀ ហើយដល់ពេលដែល វ៉ែមសៀ រាយការណ៍សកម្មភាពរបស់នាង ខាឡូម៉ាន់ នឹងកាន់ជើងគេ ដូច្នេះហើយនាងត្រូវតែបង្ការ ដោយការស្ដាប់បង្គាប់បងប្រុស ហើយចាំចាត់ការគេពេលក្រោយ។

"ប្អូនតែងខ្លួនដោយរ៉ូបនេះហើយ ស្អាតណាស់ ខ្លារីហ្សា"

"អរគុណបងប្រុស ជារ៉ូបដែលប្អូនចូលចិត្តណាស់"

"តែវាមើលទៅទាក់ទាញអារម្មណ៍ពេកឬអត់ ?"

"មិនអីទេ បងប្រុស ប្អូនធំហើយ គឺគ្រាន់តែបង្ហាញមន្តស្នេហ៍របស់ប្អូនតិចតួច ដែលលោកឧត្តមសេនីយ វ៉ែមសៀ អាចចូលចិត្តរ៉ូបដែលពាក់ពាក់ក៏ថាបាន"

"ខ្លារីហ្សា ពាក់ដើម្បី វ៉ែមសៀ ?"

"ច្បាស់ណាស់ បងប្រុស"

នាងមិនបានពាក់ដើម្បីទាក់ទាញអារម្មណ៍ស្នេហារបស់គេ តែពាក់ដើម្បីទាក់ទាញអារម្មណ៍ផ្ដោចទោសៈ ដែលចម្លើយរបស់នាងមានឬដែល ខាឡូម៉ាន់ មិនយល់ន័យដែលបង្កប់នៅក្នុងនោះ ប៉ុន្តែសុខចិត្តនៅស្ងៀម មិនមាត់មិនក។

"ជារឿងល្អ បើប្អូនគិតដល់ វ៉ែមសៀ"

"ប្អូនត្រូវតែគិតដល់គេ ព្រោះគេជាបុរសដែលប្អូនត្រូវរៀបការជាមួយ"

កាអ៊ីន តបដោយទឹកមុខញញឹមស្រស់ តែស្នាមញញឹមស្រស់ពេកនោះ



មានពិរុទ្ធពេកហើយ។ គេស្និទ្ធស្នាលនឹងប្អូនស្រីតាំងពីតូចដល់ធំ ការទន្ទូន់ដើម្បីចូលទៅរក វ៉ែមសៀ ងាយបែបនេះ វាមិនអាចទៅរួច ប៉ុន្តែមិនថានាងដាក់ផែនការអ្វី គេជឿថាឧត្តមសេនីយខ្លាំងរបស់គេអាចទប់ទល់បាន ទើបការមើលកំលោះក្រមុំពីចម្ងាយជាជម្រើសដែលគេគិតល្អជាង ចំណែក វ៉ែមសៀ ក៏សុំសិទ្ធិដាច់ខាតក្នុងការមើលថែ កាអ៊ីន គេក៏ប្រគល់ឲ្យ និងមិនអាចលេបសម្ដីបាន។

"អីចឹងប្អូនគួរទៅទទួលគេជំនួសបង"

"ចុះបងប្រុស ?"

"បងនឹងទៅតាមក្រោយ អញ្ជើញព្រះនាង ខ្លារីហ្សា"

ទោះស្រឡាញ់ និងទំយើប្អូនស្រីយ៉ាងណា តែសម្ដីរបស់គេគឺជាបញ្ជាដែល កាអ៊ីន ត្រូវអនុវត្តតាម។ នាងបន្ទន់ជង្គង់ ធ្វើការគោរពលា ហើយបែរខ្លួនដើរចេញទៅ ដោយឆ្លៀតលួចមើលមិត្តភក្តិ គិតថាត្រូវបងប្រុសរបស់នាងស្ដីឲ្យឬអត់ ប៉ុន្តែនាងមិនអាចនៅត្រង់នេះយូរបាន។

ពេលព្រះនាងដើរចេញ អ្នកបម្រើទាំងពីរក៏ដើរតាម ដោយទៅឈរនៅផ្នែកខាងមុខនៃបរិវេណសាលរៀបចំពិធី ដែលមានកន្លែងសម្រាប់ឲ្យអ្នកបម្រើទាំងឡាយបាននៅបម្រើចៅហ្វាយ។

ចាស៊ីន ស្រាក់ដៃដាក់ពីមុខ នៅចំពោះមុខ ខាឡូម៉ាន់ បុគ្គលដែលមានរស្មីចែងចាំងដោយអំណាចបំភាយចេញពីរាងកាយ ព្រោះថាគេជាអ្នកគ្រប់គ្រងប្រទេសសាក់ខាវៀ។ ទោះនាងជិតដិតនឹងព្រះនាង កាអ៊ីន តែនៅឆ្ងាយពីពាក្យថាជិតដិតនឹងព្រះអង្គម្ចាស់ ខាឡូម៉ាន់។



"នោះជារូបដែលនាងជ្រើសរើសឲ្យ ខ្លារិហ្សា ?"

ចាស៊ីន មានតួនាទីមើលខុសត្រូវរូបភាពដែលពាក់ព័ន្ធនឹងសម្លៀកបំពាក់ មុខមាត់ ដូច្នេះហើយរឿងនេះ តេត្រូវការចម្លើយសមរម្យ។ សម្រាប់រូបស្អាត និងទាក់ទាញអារម្មណ៍ប្រាថ្នានោះ រ៉េមសៀ ច្បាស់ជាពុះតក្រោកដោយទោសៈ។

រឿងស្នេហាមិនបាច់ចាប់អារម្មណ៍ តែ ការ៉ុីន ក្លាយជាស្រីរបស់ រ៉េមសៀ ទៅហើយ ហើយបុរសនៅប្រទេសសាក់ខារៀភាគច្រើន ហួងហែងសម្បត្តិផ្ទាល់ខ្លួនណាស់ ជាពិសេសស្ត្រីដែលជាភរិយា ទោះ ការ៉ុីន មិនទាន់ចូលរោងការជាមួយ រ៉េមសៀ ក៏ដោយ តែពិធីមង្គលការនឹងកើតឡើងឆាប់ៗនេះហើយ។

ទោះមិនបានបង្ហាញសាច់បង្ហាញឈាម មើលទៅអាក្រក់ក្រក៏ពេក ប៉ុន្តែភាពទាក់ទាញផ្នែកអារម្មណ៍កាមាដ៏គួរឲ្យស្រឡាំងកាំងនោះ រ៉េមសៀ ពេញចិត្តឲ្យបុរសផ្សេងតយគន់ដោយខ្សែភ្នែករីចិងឬ ហើយតាំងពីស្គាល់ រ៉េមសៀ គេឲ្យចម្លើយបានថា មិត្តភក្តិគួបតំណែងបងប្អូន និងកំពុងថែមតំណែងប្អូនថ្លៃមានអារម្មណ៍បែបណា។

"ក្រាបទូល រូបដែលព្រះនាងពាក់ ជារូបដែលថ្លៃម៉ូតតាមតម្រូវការរបស់ទ្រង់ ខ្ញុំម្ចាស់ក៏មានតួនាទីធ្វើឲ្យបានសម្រេច"

"នាងគួរហាមប្រាម ខ្លារិហ្សា មិនចាំបាច់តាមចិត្តគ្រប់រឿងទេ"

"សុភាពស្ត្រី បើសិនគ្រងឈុតដែលខ្លួនមិនពេញចិត្ត តើយកទំនុកចិត្តមកពីណាទៅ ព្រះអង្គម្ចាស់" ចាស៊ីន តបយ៉ាងសុភាពនិងមានហេតុផល។ បើ ការ៉ុីន គ្មានទំនុកចិត្តចំពោះសម្លៀកបំពាក់ ទោះឈុតស្អាតយ៉ាងណាក៏មិនអាច



ជួយបង្កើនសម្រស់ឲ្យបានដែរ។

"ម្តងនេះចាត់ទុកជានាងរួចខ្លួន"

ចាស៊ីន បន្ទន់ជង្គង់ធ្វើការគោរព តែពេល ខាឡូម៉ាន់ ដើរចេញទៅ ខាងសឹងតែទន់ជង្គង់ ត្រូវរកអ្វីទប់ជំហរ ព្រោះគេគួរឲ្យខ្លាចពេកហើយ។

"អុំ!"

ដំណើររបស់ ការ៉ុីន ត្រូវរាំង ហើយអ្នកដែលហ៊ានធ្វើបែបនេះដាក់នាងគឺមានតែម្នាក់គត់។ រ៉េមសៀ ចាប់ដើមដៃរបស់នាងជាប់ កែវភ្នែករឹងកំព្រឹស ហើយអូសចូលបន្ទប់ដែលនៅជិតជាងគេ ដោយ ស៊ីឡា និង ហ្សីរ៉ា ទោះជារម្តពីសុវត្ថិភាពរបស់ម្ចាស់ស្រីយ៉ាងណាក៏មិនហ៊ានហាមប្រាម និងពេលប្រសព្វនឹងភ្នែករបស់លោកឧត្តមសេនីយ ពន្លឺភ្នែកនោះកាចនិងគួរឲ្យខ្លាចមែនទែន ដល់ថ្នាក់ធ្វើឲ្យពួកនាងញ័រខ្លួន ទើបបានត្រឹមតែឈ្ងោកមុខឈ្ងោកមាត់ឈរបៀតគ្នានៅមួយកន្លែង។

"មិនបាច់តាម"

ពេលឮដូច្នេះ អ្នកដែលប្រុងឈានជើងដើរតាមក៏ឈរឆ្កឹងភ្លាម មិនហ៊ានជំទាស់បញ្ជារបស់ រ៉េមសៀ។

"លែង!" ព្រះនាងកំពូលសម្រស់ស្រែកតំហិក តែ រ៉េមសៀ មិនខ្លាច មិនញញើត ជាពិសេសនៅពេលនេះ អារម្មណ៍របស់គេកំពុងពុះត្រុកៗ ព្រោះឈុតនៅលើដងខ្លួនរបស់នាង។



រាងកាយមួយនេះជាកម្មសិទ្ធិរបស់គេតែម្នាក់គត់ មានតែគេប៉ុណ្ណោះដែលមានសិទ្ធិបានឃើញ។

"បិទមាត់ ខ្លារិហ្សា!" គេគ្រហឹមដាក់។

ទោសៈរបស់គេនៅថ្ងៃនេះលាយឡំនឹងអារម្មណ៍មួម៉ៅ។ គេលួចចេញពីសាលរៀបចំពិធី ដើម្បីរកកន្លែងជក់បារីកម្ចាយភាពតានតឹង តែការបានឃើញព្រះនាងមេបញ្ជា មានតែធ្វើឲ្យគេតានតឹងលើសដើម និងត្រូវការទះកំប៉េះគូទនាងបានពីរបីដៃ។

"ខ្ញុំឈឺ"

នាងឈឺដើមដៃដែលត្រូវចាប់ បងប្រុសមិនធ្លាប់ដៃធ្ងន់បែបនេះដាក់នាងទេ តែមិនមែនសម្រាប់ រ៉ែមសៀ។

"វាសមហើយ"

"អ្ហឺ! មនុស្សគ្រោតគ្រាត"

នាងធ្វើមុខខ្ញូរដាក់គេដោយការពេញចិត្ត និងក្តាប់ដៃគក់ដើមទ្រូងរឹងមាំ តែគក់បានមួយដៃក៏ឈប់ ព្រោះសាច់ដុំរបស់គេរឹងដូចថ្ម។

"ខ្លារិហ្សា" គេគ្រហឹមហៅឈ្មោះនាង ហើយដកដង្ហើមចូលឲ្យជ្រៅៗប្រឹងរម្ងាប់ទោសៈ។ ថ្ងៃនេះអារម្មណ៍របស់គេពុះខុសពីធម្មតា ហើយនាងក៏ធ្វើឲ្យវាពុះកាន់តែខ្លាំង។

ពេលនេះ កាអ៊ិន មានអារម្មណ៍ថាខ្លាចគេហើយ តែនៅប្រឹងពើងទ្រូងដាក់ និងគិតថាត្រឹមរ៉ូបរាត្រីមួយ ធ្វើឲ្យគេខឹងសម្បាដល់ថ្នាក់នេះផងឬ មិនចេះ



គ្រប់គ្រងអារម្មណ៍ខ្លួនឯងឬយ៉ាងម៉េច ហើយបើត្រូវនៅជាមួយគ្នាមែនទែន នាងមិនត្រូវគេចាប់ដាំសាច់ទៅហើយ រ៉ែមសៀ ជាមនុស្សកម្លាំងយក្ស ឈ្លើយ និងមិនចេះថ្នាក់ថ្នម។

"មានការស្អី លោកឧត្តមសេនីយ រ៉ែមសៀ?" កាអ៊ិន សួរមុខខ្មី បើគេស្រឡាញ់អំណាចខ្លាំង នាងនឹងឲ្យគេខ្លាំងជាងក៏បាន។

រ៉ែមសៀ ខាំថ្គាមក្រតៗ ច្របាច់ដើមដៃរបស់នាងកាន់តែខ្លាំង។

"ឈឺ! ខ្ញុំឈឺមែនទែន"

"នេះជាឈុតដែលនាងរើស?"

អ្នកកំលោះមិនខ្វល់ពីសំឡេងស្រែកឡូឡាចេញមាត់ស្អាតនោះ តែសួរនូវអ្វីដែលធ្វើឲ្យគេក្តៅក្រហាយ។ នាងគួរតែចេះការពាររបស់ដែលជាកម្មសិទ្ធិរបស់គេ មិនមែនយកមកអួតគេអួតឯងតែពាសបែបនេះទេ។

"ហើយលោកឃើញស្អី?"

នាងខ្ទឹបមាត់ ព្រោះឈឺដៃដែលត្រូវច្របាច់ តែមិនចង់ស្រែកសុំជំនួយទៀតទេ អញ្ចើញគេច្របាច់ដៃរបស់នាងឲ្យបាក់ទៅ អាប្រុសឃោរឃៅ។

"ខ្ញុំឃើញមនុស្សស្រី ដែលតែងខ្លួនស្រដៀងនឹងសោភិនីតាមចិញ្ចើមផ្លូវនៅសេនថាម៉ាក៏"

នាងបើកភ្នែកធំៗ ភ្ញាក់ផ្អើល រលីងរលោងទឹកភ្នែក ពេលគេឈ្លើយដាក់នាងបែបនេះ។ មិនស្មានថាទេថាគេហ៊ានប្រៀបធៀបនាងនឹងសោភិនី ថែមទាំងជាសោភិនីតម្លៃថោកទៀត។



"ម៉េចក៏ហ៊ាននិយាយបែបនេះដាក់ខ្ញុំ ?" នាងខាំមាត់សួរ។

ម៉ែសៀ មិនខ្វល់ពីការប្រឆាំងរបស់នាង ព្រោះនាងជាអនាគតភរិយារបស់គេ។ យ៉ាងហោចណាស់ក៏ព្រះនាងមេបញ្ហានេះមិនគួរណាគ្មានខួរក្បាលដល់ថ្នាក់មិនដឹងថា គួរប្រើសម្លៀកបំពាក់បែបណាឲ្យសក្តិសមនឹងឋានៈរបស់នាងនិងគេ នាងគួររក្សាមុខមាត់ឲ្យគេខ្លះ។

"ខ្ញុំនិយាយការពិត"

គេលែងក្រែងចិត្តនាងហើយ មិនខ្វល់ទេថានាងជាប្អូនស្រីរបស់ប្រមុខប្រទេស មិនខ្វល់ថានាងជាព្រះនាងនៃសាក់ខាវៀ។

"ខ្លួនខ្ញុំ វែកទ្រូងនៅតិចពេកផង ទោះឈុតខ្ញុំវែកដល់ផ្ចិតក៏វាជារឿងរបស់ខ្ញុំ ខ្ញុំពាក់វាហើយរីករាយ ខ្ញុំអូខេ លោកមិនអូខេ តាមតែក្បាលលោកទៅ"

នាងមិនព្រមចុះញ៉មគេដូចគ្នា ទើបជះសម្តីមួយៗ ច្បាស់ៗដាក់ ដោយមិនឡូឡា ជាការបញ្ជាក់ថានាងមិនខ្វល់ពីគេ។

"នាងត្រូវដឹងខ្លួនថានាងជាអ្នកណា"

"ខ្ញុំជាព្រះនាង ខ្លារីហ្សា ម៉ាលខៃសេនទេ នៃសាក់ខាវៀ"

"ហើយនាងក៏ត្រូវបានញាត់ញៀតជាប្រពន្ធរបស់ខ្ញុំ"

នាងក្រមុំយារដៃទះកំផ្លៀងគ្រឹម តែមុខសង្ហាបែរទៅតាមកម្លាំងទះតែបន្តិចប៉ុណ្ណោះ ហើយងាកមកវិញ សម្លឹងមុខនាងដោយខ្សែភ្នែករឹងកំព្រឹស និងដូចមានអណ្តាតភ្លើងនៅក្នុងនោះ លៀនមកដុតនាង តែនាងមិនព្រមឲ្យគេមើលងាយទេ។ ទោះមិនអាចស៊ូនឹងកម្លាំងរបស់គេបាន ប៉ុន្តែនាងមានឈ្មោះ



មានកិត្តិយស នាងព្រមឲ្យគេប្រៀបធៀបនាងនឹងសោភិនីតាមចិញ្ចើមផ្លូវ និងបង្ហាញការភ័យខ្លាចដែលមានចំពោះគេ ដូចព្រមចាញ់ប្រៀបមិនបានទេ។

"មួយកំផ្លៀងនេះ សម្រាប់ភាពឈ្លើយរបស់លោក មនុស្សថ្នាក់ទាប"

នាងសង្កត់ធ្ងន់នៅចុងប្រយោគ ហើយពេលគេសម្លឹងមុខ នាងក៏សម្លក់វិញ។

គេប្រៀបនាងជាសោភិនីបាន ហេតុអីនាងហៅគេជាមនុស្សថ្នាក់ទាបមិនបាន។

"ខ្ញុំមិនមែនស្រីកំណាន់ ឬជាស្រីដែលត្រូវលុះក្រោមអំណាចរបស់លោក លោកគ្មានតម្លៃអីសម្រាប់ខ្ញុំទេ ខ្ញុំមិនប្រាថ្នា ខ្ញុំមិនត្រូវការលោក"

នាងគ្រប់គ្រងអាការៈញ័រខ្លួនបានល្អណាស់។ នាងមិនដឹងទេថាញ័រខ្លួនព្រោះខឹង ឬព្រោះខ្លាចគេ តែមិនថាព្រោះអ្វីក៏ដោយ នាងត្រូវលាក់វាឲ្យជិត។

"ខ្ញុំត្រូវរៀបការនឹងលោក មិនមែនខ្ញុំបេតិលោក តែដើម្បីផលប្រយោជន៍របស់រាជវង្ស ម៉ាលខៃសេនតេ"

នាងមិនអនុញ្ញាតឲ្យគេមានអំនួត ភាពក្រអឺតក្រទម និងសម្តីកោងកាចរបស់គេ ធ្វើឲ្យនាងចង់ស្ទុះទៅខ្វាចមុខសង្ហានោះឲ្យបង់សម្រស់។

មនុស្សចង្រៃ!

ទាំងដែលនិយាយពេញមាត់ថា នាងជាអនាគតភរិយារបស់គេ ហើយនេះឬការផ្តល់កិត្តិយសអនាគតភរិយា ផ្ទុយទៅវិញគេប្រតិបត្តិចំពោះនាងដូចនាងជាមនុស្សតូចទាប ទាំងដែលនាងមិនមែនជាមនុស្សតូចទាប វង្សត្រកូលរបស់នាងខ្ពង់ខ្ពស់ ទោះម្តាយរបស់នាងជាភរិយាទីប្រាំរបស់ឪពុកក៏ដោយ តែ





Scanned by CamScanner

យ៉ាងណាក៏ឋានៈរបស់នាងខ្ពស់ជាង វ៉ែមសៀ ដែរ ឬទោះនាងកើតមកតូចទាបរាបនឹងដី គេក៏ត្រូវផ្ដល់កិត្តិយសឲ្យមនុស្សស្រីដែលគេត្រូវរៀបការជាមួយ។ គេជំនាញរឿងធ្វើចម្បាំង មានសមត្ថភាពគស៊ីយ៉ាងអង់អាច តែមារយាទនៅក្នុងការប្រតិបត្តិចំពោះអនាគតភរិយារបស់គេ យ៉ាប់យ៉ឺនណាស់ ដែលសក្ដិសមនឹងទទួលបានការអប់រំ។

"ខ្លារិហ្សា!"

"ទោះលោកគំរាមខ្ញុំ ទោះលោកឈ្លើយដាក់ខ្ញុំ តែខ្ញុំមិនខ្លាចលោកទេ គ្មានស្អីដែលខ្ញុំត្រូវខ្លាច ខ្ញុំមិនបានធ្វើអីខុស លោកម្ចាស់ដែលយើងត្រូវរៀបការនឹងគ្នា លោកមិនពេញចិត្តរៀបការនឹងខ្ញុំ ខ្ញុំក៏មានអារម្មណ៍បែបហ្នឹង តែខ្ញុំនឹងរៀបការ ព្រោះទំនួលខុសត្រូវដែលខ្ញុំមានចំពោះ សាក់ខារៀ និងក្ដីស្រឡាញ់ដែលខ្ញុំមានចំពោះបងប្រុស"

"ព្រះអង្គម្ចាស់ប្រគល់នាងឲ្យខ្ញុំជាកាដូ កាដូដែលបានមកពីការបំពេញការកិច្ចគ្រោះថ្នាក់ស្ទើរតែយោងអាត្មាមិនរស់ កាដូគួរតែជារបស់ល្អមិនអីចឹងឬ"

វាចារបស់គេមុតដូចមុខកាំបិត ចាក់បេះដូងរបស់នាង។ គេមិនឲ្យតម្លៃនាង ព្រោះមិនគិតថានាងជាកាដូ តែជាបញ្ហា ជាបន្ទុកសម្រាប់គេ។ អារម្មណ៍ដែលត្រូវក្លាយជាបញ្ហា ឬបន្ទុករបស់នរណាម្នាក់ ជារឿងដែលនាងគិតថាគ្មានអ្នកណាចង់បានទេ។

"វ៉ែមសៀ លោកថាអ្នកដទៃជារបស់មិនល្អ ចុះខ្លួនលោក ល្អហើយឬ?" នាងក្រមុំចងចិញ្ចើមដាក់។



វ៉ែមសៀ ខឹងកាន់តែខ្លាំង ព្រោះសំណួរនេះ ទើបឆ្លៀយច្របាច់ដើមដៃរបស់នាង ឲ្យនាងឈឺ តែនាងមិនអនុញ្ញាតឲ្យសំឡេងនៃការឈឺចាប់នោះបុតចេញពីមាត់ ព្រោះបើនាងឡូឡា នោះបញ្ជាក់ថានាងខឹង តែមិនបានខឹងខ្លាំង តែបើនាងស្ងប់ស្ងាត់និងសោះកក្រោះ កំហឹងនោះជាកំហឹងលំដាប់ជាតិ។

"វ៉ែមសៀ លោកវាយតម្លៃអ្នកដទៃថាមិនល្អ ចុះលោក ល្អហើយនៅ លោកមិនសម សូម្បីតែប៉ះជាយសំពត់ខ្ញុំផង!" នាងមានចេតនាប្រើសម្ដីប្រមាថវ៉ែមសៀ។

ទោះនាងជាមនុស្សទំនើង តែមិនមែនជាមនុស្សគ្មានហេតុផល ក្រៅពីនេះក៏គ្មានចរិតប្រមាថមើលងាយអ្នកដទៃ នាងទទួលបានការអប់រំខ្ពង់ខ្ពស់ តែវ៉ែមសៀ ធ្វើឲ្យនាងធ្វើខ្លួនផ្ទុយពីគ្រប់យ៉ាងដែលគួរធ្វើ។

ការ៉ុន មើលគេដោយការថ្នាញ់ថ្នាល គេក៏សម្លឹងវិញដោយកំហឹង។ នាងដឹងថាគេខឹង តែមិនប្រើដៃប្រើជើងមកលើរាងកាយរបស់នាង ព្រោះបើគេធ្វើ បងប្រុសនឹងដឹងថាគេជាបុរសដែលមិនសមនឹងនាង ហើយនាងមិនជឿទេថាបងប្រុសនៅតែទុកចិត្តឲ្យបុរស ដែលចូលចិត្តប្រើកម្លាំងចាយដាក់មនុស្សស្រីមើលថែនាង។

"ហ៊ឺ!"

វ៉ែមសៀ មិនបានធ្វើបាបរាងកាយរបស់នាង និងព្រលែងដៃពីដើមដៃទៀតផង តែលើកដៃទាំងពីរក្រសោបថ្ពាល់រលោង ឱនទៅថើបបបូរមាត់លឿនដូចព្យុះ។



"លែង!"

នាងងាកមុខគេច ចេញបញ្ហាបានប៉ុណ្ណឹងក៏ត្រូវគេចាប់មុខបង្វែរមកវិញ ហើយថើបបន្ត ថើបបបូរមាត់ដែលហ៊ានតមាត់ត.កនឹងគេដោយមិនខ្លាចក្រែង និងគិតតែពីថើបឲ្យនាងទន់ជង្គង់ បន្ទាប់មកក៏ត្រូវលើកបី ដោយមិនឲ្យបបូរមាត់របេះពីគ្នា ជាការដាក់ទោស តែនេះជាការដាក់ទោសដែលធ្វើឲ្យនាងស្អប់។

ខួរក្បាលបញ្ជាឲ្យនាងស្អប់ តែរាងកាយបែរជាព្រមទទួលយកការថើបដ៏ក្តៅគគុក ឲ្យដៃរបស់នាងញ័រ និងមិនត្រឹមដៃទេ ពេលនេះកំពុងញ័រសព្វសាច់សំណាងដែលស្ថិតក្នុងរង្វង់ដៃរបស់បុរសរឹងមាំ និងឈ្លើយដាក់អនាគតភរិយាកុំអីនាងដួលខ្លោកទៅហើយ។

បបូរមាត់របស់គេកំណាចណាស់ បើឈ្លោះគ្នាដោយវាចា នាងនឹងតបតដោយមិនញញើត តែការឈ្លោះគ្នាបែបនេះ បបូរមាត់នៃបនិត្យ គ្មានប្រហោងឲ្យខ្យល់ចេញចូលបែបនេះ ធ្វើឲ្យនាងទ័លបញ្ញានឹងទប់ទល់ ហើយពេលនាងហាមាត់ ដើម្បីតវ៉ា គេក៏ជ្រែកអណ្តាតគ្រើមចូលមក ទើបលើកដៃ តែមិនទាន់បានគក់ផង ក៏ត្រូវគេបឺតជញ្ជក់អណ្តាត ឲ្យដៃនោះខ្សោះកម្លាំង។ នាងត្រូវថើបឲ្យអារម្មណ៍ហោះហើរ គ្រប់គ្រងរាងកាយមិនបាន និងត្រូវគេអូសទាញឲ្យថើបវិញ ហើយអណ្តាតមិនដឹងខ្យល់អីរបស់នាងកំពុងតែធ្វើតាម។

"អ៊ំ..." ការ៉ិន ថ្ងូរតិចៗ។

ស្ត្រីកំពូលសម្រស់ មានទំនុកចិត្តចំពោះខ្លួនហាក់ដូចរាជិនី ត្រូវមកអស់សភាព ព្រមចុះចាញ់ ព្រោះបបូរមាត់របស់គេថើបបានអារម្មណ៍ ធ្វើឲ្យនាងមិន



អាចតតាំង។ គេជាមនុស្សកំណាច ចាប់ផ្តើមដោយការដាក់ទោស ហើយគេរានទាល់តែបបូរមាត់មិនដឹងខ្យល់របស់នាងភ្លើតភ្លើនតាម។

អណ្តាតពីរមូលចូលគ្នាដោយមិនអាចគ្រប់គ្រងបាន សំឡេងថ្ងូរជំពីរោះឮខ្សាវៗគួរឲ្យស្តាប់។ សំឡេងរបស់នាងស្រោចលើបបូរមាត់របស់គេ ឲ្យអារម្មណ៍ក្តៅគគុកបានស្ងប់ តែពេលកំហឹងស្ងប់ អារម្មណ៍ផ្សេងរបស់បុរសដែលគេខំគ្រប់គ្រងក៏ផ្ទុះម្តង។ វាគ្រោះថ្នាក់ខ្លាំងណាស់ ពេលថើបមាត់របស់នាង តែមាត់ទន់ល្មើយនោះទាក់ទាញខ្លាំងណាស់ ធ្វើឲ្យគេកាត់ចិត្តដកបបូរមាត់ចេញមិនបាន។

"សុំទោសដែលមករំខាន"

សំឡេងរបស់ ខាឡូម៉ាន់ ធ្វើឲ្យបបូរមាត់ក្តៅគគុកព្រមដកចេញឆ្ងាយពីបបូរមាត់ផ្អែមល្ហែម និងសម្លឹងមើលមាត់ដែលបើកម្លុបៗ ដើម្បីដកដង្ហើម។

"គ្រប់យ៉ាងរៀបរយហើយ?"

ម្តងទៀតហើយដែល ខាឡូម៉ាន់ ឃើញប្អូនស្រីជាទីស្រឡាញ់បី និងថើបទាល់តែខ្សោះកម្លាំង ហើយ វ៉ែមសៀ ក៏បែរមករកគេ និងឱនគំនាប់ ធ្វើការគោរពដោយនៅតែបី ការ៉ិន ជាប់ដើមទ្រូង។

"រៀបរយហើយ ព្រះអង្គម្ចាស់" វ៉ែមសៀ ឆ្លើយតបដោយការគោរព តែសម្តីមាំ។

ខាឡូម៉ាន់ ញញឹមចុងមាត់ ហើយប្រញាប់បន្លំស្នាមញញឹមនោះ ព្រោះមើលឃើញថា វ៉ែមសៀ មានការពេញចិត្តចំពោះប្អូនស្រីរបស់ខ្លួន តាមរយៈការ



ទើបនាងឲ្យទន់ជង្គង់ចំនួនពីរដងហើយ។

"បើរៀបរយហើយ អញ្ជើញទៅសាលពិធីឧត្តមសេនីយ វែមសៀ"

កំលោះៗសន្ទនាគ្នាដោយការផ្ដល់កិត្តិយស ក្រែងលមានអ្នកដទៃឮ។

"ទូលបង្គំសុំត្រឡប់ទៅដំណាក់របស់ព្រះនាង ជាមួយម្ចាស់ដំណាក់"

"ចុះពិធីជប់លៀង ?"

"សូមរំខានទ្រង់ហើយ"

វែមសៀ ដាក់មនុស្សស្រីដែលគ្មានកម្លាំងកំហែងឲ្យឈរដោយខ្លួនឯង តែស្រវាឱបចង្កេះជាប់បង្ការនាងដួល។

នាងចង់ស្ទុះទៅរកបងប្រុស តែត្រូវគេឱបចង្កេះជាប់ មាត់របស់នាងក៏ញ័រ មិនអាចបញ្ចេញវាចាបាន ទើបនាងគ្មានជម្រើសច្រើន ហើយពេលគេលូកហោប៉ៅអាវយករបស់ មកបំពាក់នឹងម្រាមដៃនាងខាងស្ដាំរបស់នាងនោះឯង ទើបដឹងថាវាជាអ្វី។

នេះជាទំនៀមទម្លាប់របស់ប្រទេស សាក់ខាវៀ ចិញ្ចៀនភ្ជាប់ពាក្យត្រូវបំពាក់នឹងម្រាមដៃនាងខាងស្ដាំ ចំណែកចិញ្ចៀនរៀបការត្រូវបំពាក់នឹងម្រាមដៃនាងខាងឆ្វេង។

"ទ្រង់ជាសាក្សីពិធីភ្ជាប់ពាក្យហើយ ដូច្នេះហើយទូលបង្គំ និងព្រះនាងសុំទៅសិនហើយ"

វែមសៀ លើកបីព្រះនាង ឱនក្បាលជាការគោរពព្រះអង្គម្ចាស់ ហើយដើរសំដៅទ្វារ ដោយ ខាឡូម៉ាន់ មិនបានឃាត់ឃាំង។



ពិធីជប់លៀងត្រូវរៀបចំឡើង ដើម្បីជាការប្រកាសពិធីភ្ជាប់ពាក្យ រវាងឧត្ដមសេនីយ វែមសៀ និងព្រះនាង ការ៉ិន ប៉ុន្តែពេលគូភ្ជាប់ពាក្យបានធ្វើពិធីនៅចំពោះមុខប្រធានអង្គពិធីរួចហើយ គឺចាត់ទុកថាពិធីជប់លៀងបានសម្រេចគោលដៅ ទើប ខាឡូម៉ាន់ ដើរចូលសាលពិធី ប្រកាសឲ្យភ្ញៀវពន្លឺបានដឹងរួមទាំងអរគុណដែលបានមកចូលរួម និងជូនពរ។

"បែបនេះក៏បានដែរឬ" សីគីរ៉ាស និយាយអ៊ូៗ។

គូភ្ជាប់ពាក្យមិនបានមកអរគុណភ្ញៀវដោយផ្ទាល់ តែឲ្យប្រធានពិធីចេញមុខចាត់ការជំនួស។

"មានអីដែលមិនបានឬឧត្តមសេនីយ សីគីរ៉ាស"

"គ្មានទេ ក្រាបទូល"

ខាឡូម៉ាន់ ងាកទៅខ្សឹបសួរ ឲ្យបានឮតែពីរនាក់ តែ សីគីរ៉ាស បដិសេធ។ ក្នុងពេលដែលព្រះអង្គម្ចាស់គ្មានបញ្ហា តើអ្នកណាទៅហ៊ានមាន។

"ដោយសារឧត្តមសេនីយ វែមសៀ និងព្រះនាង ខ្លាំហ្សា ជាប់ភារកិច្ចបន្ទាន់ ទើបយើងត្រូវមកជូនដំណឹងឲ្យរស់លោកបានដឹង និងអរគុណជំនួស"

ខាឡូម៉ាន់ ចង់និយាយអីក៏បាន ទោះភ្ញៀវពន្លឺមានការសង្ស័យ តែមានអ្នកណាហ៊ានសួរបញ្ជាក់ ក្រៅពីនាំគ្នាជូនពរគូភ្ជាប់ពាក្យតាមរយៈទ្រង់ ដែលសិគីរ៉ាស គិតថានេះជារឿងកំប្លែងដែលមិនគួរឲ្យសើច។

"ជាប់ភារកិច្ចអី ?"

"ជាសំណួរល្អ"



សិតិក៉ាស អុិរទាំងដាក់ខ្លួនឯង តែព្រះអង្គម្ចាស់ៗ និងងាកមកឆ្លើយប្រាប់ ទើបគេងក់ក្បាលដាក់ និងតបដោយភាសាកាយថាគេជាអ្នកសួរសំណួរនោះ។

"គៀវភាគច្រើនប្រហែលសង្ស័យ ឧត្តមសេនីយ រ៉ែមសៀ មានភារកិច្ចបន្ទាន់ដែលយើងឲ្យធ្វើ អីចឹងហើយទើបត្រូវពន្លឿនពិធីមង្គលការរបស់ពួកគេ"

*សិយហើយ រ៉ែមសៀ!*

ម្ដងនេះ សិតិក៉ាស មិនបាននិយាយឲ្យឮ តែគិតក្នុងចិត្ត ហើយក៏ធ្វើអីមិនបាន។ រ៉ែមសៀ ឆ្លាត់ស្មៀតហើយដែលឲ្យព្រះអង្គម្ចាស់ចេញមុខជំនួស។

"ពិធីមង្គលការត្រូវពន្លឿន រៀបចំនៅដប់ថ្ងៃក្រោយ ទើបឧត្តមសេនីយ រ៉ែមសៀ និងព្រះនាង ខ្លារិហ្វា មានរឿងត្រូវរៀបចំ និងព្រមព្រៀងគ្នាច្រើន"

ខាឡូម៉ាន់ នៅតែនិយាយបន្ត សិតិក៉ាស ក៏ស្ដាប់បន្តដោយមិនមាត់ មិនក និងនឹកដល់ រ៉ែមសៀ ថាផ្ញើរពេលនេះដឹងខ្លួនហើយឬនៅថាបានធ្វើជាកូនកំលោះឆាប់ៗនេះហើយ។

"កុំ! អុំប!"

ការ៉ុិន មិនត្រូវបានអនុញ្ញាតឲ្យបដិសេធ ហើយពេលត្រូវចាប់ញាត់ឡាន នាងក៏ប្រឹងថយ តែត្រូវទាញមកអង្គុយលើភ្លៅ ពេល រ៉ែមសៀ ចូលមកក្នុងឡានរួចរាល់ហើយ។

គេបញ្ឈប់ការតមាត់ត.កនឹងនាងដោយការឱនថើបមាត់ ស្កាត់សំឡេងរបស់នាងដោយបបូរមាត់របស់ខ្លួន។ រថយន្តវែងរបស់គេបែងចែកផ្នែកអ្នកបើក



និងអ្នកដោយសារឲ្យាស់លាស់ ទើបគេអាចចាតការព្រះនាងឆ្លាសបាន។

ការ៉ុិន ក្ដាប់ដៃគក់ដើមទ្រូងមាំមួន តែគក់បានមួយដៃក៏ត្រូវអណ្ដាតក្ដៅជ្រែកចូលមកក្នុងប្រអប់មាត់។ នាងចង់ខាំអណ្ដាតគេ តែត្រូវប្រដាប់ថ្គាម និងរិតរួតអណ្ដាតរបស់នាង ទាល់តែនាងទន់ខ្លួន ទើបព្រមព្រលែងមុខ។

"ហ៊ឺ!"

នាងក្រមុំថ្ងូចថ្ងូរ ពេលត្រូវបាតដៃធំដាក់លើជើង ដែលមិនត្រូវបិទបាំងដោយសាច់ក្រណាត់។ នាងពាក់រ៉ូបនេះ ដើម្បីធ្វើឲ្យគេខឹង មិនបានដាក់ផែនការថាវាផ្ដល់ភាពងាយស្រួលឲ្យគេលូកលាន់។

"រ៉ែម...រ៉ែមសៀ..."

នាងហៅគេដោយសំឡេងរដាក់រដុប ដោយមិនអាចរក្សាកាយវិការជារាជិនីបានទៀត ព្រោះ រ៉ែមសៀ កំពុងឈ្មុលមុខនឹងប្រឡោះក។

"កុំ...កុំ!"

"ពាក់ចិញ្ចៀនស្ដាប់ពាក្យរបស់ខ្ញុំហើយ"

អ្នកកំលោះងើបមុខចេញពីប្រឡោះកក្រអូបប្រហើរ តែមិនត្រឹម.កទេ ខ្លួនប្រាណរបស់នាងក៏ក្រអូបដែរ។ គេចាប់ដៃស្រឡូនថើប ព្រោះបន្ទាប់ពីបំពាក់ចិញ្ចៀនឲ្យនៅចំពោះមុខ ខាឡូម៉ាន់ ហើយ គេមិនទាន់បានថើបខ្នងដៃរបស់នាងតាមទំនៀមទម្លាប់ទេ។

ការ៉ុិន មើលចិញ្ចៀនត្បូងកណ្ដៀងឡោមពេជ្រ ជាប់នឹងម្រាមដៃនាងខាងស្ដាំរបស់នាង ដែលសមនឹងម្រាមដៃល្អម ហាក់ដូច រ៉ែមសៀ វាស់ទំហំរួចហើយ



តែមនុស្សច្រងេងច្រងាងដូចគេ គ្មានផ្លូវធ្វើបែបហ្នឹងទេ វាគ្រាន់តែជារឿងចៃដន្យប៉ុណ្ណោះ។

"ចិញ្ចៀននេះជាចិញ្ចៀនដែលចាំភ្ជាប់ពាក្យជាមួយម៉ាក់ អីចឹងហើយត្រូវរក្សាឲ្យបានល្អ"

នាងគប់វាចោលក៏បាន បើជាចិញ្ចៀនរបស់ វែមសៀ តែពេលឮប្រភពមិនធម្មតារបស់ចិញ្ចៀន ទើបមិនអាចធ្វើបែបនោះបាន នាងត្រូវផ្តល់កិត្តិយសឲ្យឪពុកម្តាយរបស់គេ។

"លែង"

កាអ៊ិន ត្រូវការថយចេញឲ្យឆ្ងាយពីគេ ដើម្បីពង្រឹងស្មារតី និងទប់ទល់នឹងគេ ដែល វែមសៀ ស្តាប់បង្គាប់នាងណាស់ ពេលត្រូវបញ្ជាឲ្យលែង គេក៏ខិនមកថើបនាងម្តងទៀត ឈ្លានពានមាត់របស់នាងដោយមិនក្រែងរអែងចិត្ត ដូចគេមានសិទ្ធិ។

*តែគេមានសិទ្ធិមែនហ្នឹង ខ្លាំហ្វា អឺយ!*

នាងឆ្លើយប្រាប់ខ្លួនឯងនៅក្នុងចិត្ត ហើយគេបេតិនាងមែនឬ ចម្លើយគឺមិនបេតិ។ នាងគិតថា គេត្រូវការបង្ហាញអំណាចឲ្យនាងឃើញ អាចគ្រប់គ្រងនាងបាន នោះទៅវិញទេជាអ្វីដែលគេត្រូវការប្រាប់នាង។

គេឈ្លានពាននាង ដោយការថើបដ៏ក្តៅគគុក ថើបទាល់តែទន់ខ្លួនល្វក់ក្នុងរង្វង់ដៃមាំមួនម្តងទៀតឲ្យទាល់តែបាន ហើយស្នាមឆែករបស់រ៉ូបនោះធ្វើឲ្យគេអាចលូកដៃមករវង្វេលជើងបានស្រួល។ ស្បែករបស់នាងច្បាស់ជារលោង



សព្វសាច់ ព្រោះបបូរមាត់ទន់ល្មើយ ក្តៅក៏រលោង សាច់កក៏ម៉ដ្ឋខៃ ថែមទាំងក្រអូបប្រហើរទៀត។

នាងមានក្លិននៃភាពទាក់ទាញ លាយឡំមិនដឹងខ្យល់អីសាយកាយនៅជុំវិញខ្លួន ឲ្យគេត្រេកត្រអាល ហើយភ្លើតភ្លើន ស្រមើស្រមៃឃើញពេលនាងដេកនៅក្រោមរាងកាយមាំមួន សំឡេងពីរោះរបស់នាង ពេលថ្ងូរមិនដឹងធ្វើឲ្យរញ្ជួយអារម្មណ៍យ៉ាងណាទេ។ នាងនឹងអង្វរករឲ្យគេគ្រប់គ្រងដោយកាយវិការគួរឲ្យប្រាថ្នាប៉ុណ្ណ ពេលត្រូវដាស់រាងកាយ មិនឲ្យប្រឆាំងនឹងភ្លើងប្រាថ្នាដែលគេជាអ្នកដុត។

វែមសៀ នឹកដល់រូបភាពរបស់នាងពេលនលគក កាអ៊ិន ត្រូវតែស្ពាធទាក់ភ្នែកមិនខាន ទោះមិនទាន់មានឱកាសបានឃើញសព្វសាច់ក៏ដោយ តែតាមដែលបានឃើញ គឺមិនទាន់ជួបត្រង់ណានៃរាងកាយរបស់នាងដែលថាមិនត្រូវចិត្តរបស់គេ។ រូបរាងរបស់នាងតូចស្តើង តែដើមទ្រូងមូលក្លំ វាគួរតែប្រាល់ប្រអប់ដៃ។ គេគ្រហឹមនៅដើម.ក ពេលនឹកដល់ការច្របាច់វា ដោយប្រាសចាកទាមទារឲ្យនាងថើបតប មិនមែនជាការដាក់ទណ្ឌកម្ម ដើម្បីឲ្យនាងឈឺចាប់។ របស់បិទបាំង។ គេថើបនាងខ្លាំងទៅៗតាមអារម្មណ៍ តែជាអារម្មណ៍ប្រាថ្នាដែល

ផ្កាល់ដែលលម្អដោយពុកមាត់ពុកចង្កាកកិតនឹងស្បែកមុខម៉ដ្ឋខៃ នាងខ្ញាំអាវក្នុងរបស់គេជាប់ ទើបប៉ះសាច់ដើមទ្រូង ពេលសង្កត់បាតដៃ ទើបដឹងថារឹងដូចក្តារក៏។

"យើងនឹងនិយាយគ្នា ពេលទៅដល់ដំណាក់របស់នាង"





Scanned by CamScanner

វែមសៀ ដកបបូរមាត់ចេញបន្តិច ដើម្បីនិយាយ ហើយថើបបន្ត ដែលធ្វើឲ្យនាងភ្លឹក។

មានន័យថាខណៈពេលធ្វើដំណើរ ពួកគេនឹងមិននិយាយគ្នា តែគេនឹងឈ្លានពានបបូរមាត់របស់នាងអីចឹងឬ?

អាមនុស្សទំនើង ឆ្កួតអំណាច!

ការ៉ិន ធ្វើបានត្រឹមផ្តាសាគេនៅក្នុងចិត្ត តែជេរគេបានប៉ុណ្ណឹងក៏ត្រូវទាញអារម្មណ៍ឲ្យផ្តោតទៅលើបបូរមាត់ក្តៅភាយៗរបស់គេ ហើយនាងក៏លែងដឹងឮអ្វីទៀត ក្រៅពីបបូរមាត់ក្តៅដែលធ្វើសកម្មភាពនៅលើបបូរមាត់របស់នាង។



# ៦

## សងសឹក

**នេះជាដំណាក់របស់ ការ៉ិន តែម្ចាស់ដំណាក់បែរជាត្រូវរិបអូសអំណាច** និងត្រូវបីចូលបន្ទប់ដេក ដោយមាន ស៊ីឡា និង ហ្វីរ៉ា ដែលជិះឡានមួយទៀតតាមពីក្រោយ ជួយផ្តល់ភាពងាយស្រួលឲ្យ ប៉ុន្តែមិនហ៊ានចូលទៅជិត រួមទាំងអ្នកបម្រើឯទៀតដែរ ព្រោះខ្លាចធ្វើឲ្យ វែមសៀ មានទោសៈ។

វែមសៀ ប្រសព្វភ្នែកនឹងអ្នកដែលខ្លួនកំពុងបី កែវភ្នែករឹងកំព្រឹសដោយអំណាច ខណៈដែល ការ៉ិន ញ័របេះដូងទ្រើតៗ ព្រោះស៊ូកម្លាំងរបស់គេមិនបានទោះយ៉ាងណាក៏នាងតាញ់ប្រៀប តែខំប្រឹងប្រសព្វភ្នែកជាមួយគេ ដើម្បីបង្ហាញភាពក្លាហានដែលមាន។

"រៀងរឹងក្បាលនេះស្អាត់ណាស់" វែមសៀ ដាក់នាងលើគ្រែថ្នមៗ មិនហ៊ានធូន់ដៃ ព្រោះរាងកាយមួយនេះតូចស្តើងណាស់។

"នែ!" នាងតក់ស្លុតធំទូលាយ មុខឡើងក្រមូវ គិតថាគេធ្លាប់មើលគេនៅក្នុងផ្លូវល្អខ្លះទេ និងបានត្រឹមសម្លក់សម្លឹងគេដោយខ្សែភ្នែកឆ្មាសផ្អើម មិនអាចស៊ូដោយកម្លាំងបាយបាន ហើយប្រញាប់អូសតួទថយក្រោយ ខ្លួនប្រាណក៏ញ័រ តែប្រឹងពើងទ្រូងធ្វើខ្លាំង ពេលគេដាក់បង្អុយលើគ្រែ។



"លោក...លោកចង់ធ្វើអី?"

នាងនៅតែពើងទ្រូង ប៉ុន្តែគ្រប់គ្រងសំឡេងមិនបាន វាញ័រតិចៗ ពេល រ៉េមសៀ ដោះអាវចាក់ស៊ីជូសមនិងរូបរាងចេញ។

"រ៉េមសៀ ដាវ៉ៃហើណោស"

គេមិននិយាយស្ដី ពេលដោះអាវក្រៅរួច ក៏តាមដោយណេក់ បន្ទាប់មកក៏ប្រឡេះឡេវអាវស៊ើមី ហើយទាញទាំងអាវក្រៅ ទាំងណេក់ បោះទៅលើកៅអីសួលនៅចុងគ្រែ។

"នេះលោក..."

គេមិនចាប់អារម្មណ៍សំឡេងរបស់នាង គិតតែពីប្រេះឡេវអាវ មួរដៃអាវមកដល់កែងដៃ ទើបចង់រកស្ដីតប់ តែដឹងថាការធ្វើបែបហ្នឹងជាការកាត់បន្ថយសុវត្ថិភាពរបស់ខ្លួន។

"ថយចេញ"

ហើយពេលគេឱនមករក នាងក៏ខ្វល់ចិត្ត ទោះធ្លាប់ត្រូវគេថើបក៏ដោយ តែគ្មានម្ដងណាដែលពួកគេនៅក្នុងបន្ទប់ដេកតែពីរនាក់ដូចពេលនេះទេ។

"គិតយ៉ាងម៉េចបានជាពាក់ឈុតនេះទៅជប់លៀង"

គេលូនទៅរក ត្រដាងដៃ យុំឃាំងរាងកាយរបស់នាងដោយប្រយោល ទើបនាងលើកដៃរុញដើមទ្រូងរបស់គេ ទោះដឹងថារុញមិនចេញ តែសុំបង្ហាញការតតាំង ដើម្បីប្រកាសពីភាពមាំមួនរបស់ខ្លួន។

"វាស្អាត"

"និងសិចស៊ី"



ពេលគេត្បូកមកវិញលឿនដូចព្យុះ ទើបនាងសម្លក់សម្លឹង។ សិចស៊ីតិចតួចត្រង់ដើមទ្រូងប៉ុណ្ណោះ តែ រ៉េមសៀ ធ្វើឲ្យក្លាយជាធំ។ នាងមានចេតនាញ៉ោះឲ្យខឹងក៏ពិតមែន តែអារម្មណ៍ខឹងសម្បាកប្រិតនេះរបស់គេ ជារឿងដែលហួសពីការស្មានរបស់នាង។

*ស្រឡាញ់ក៏មិនបានស្រឡាញ់ នៅហួងហែងគេទៀត មនុស្សឆ្កួត!*

ប្រាប់មិនត្រូវទេថាមានអារម្មណ៍យ៉ាងណា បូករួមនឹងការភ័យខ្លាច និងទោសៈ នាងគិតថាខ្លួនឯងអាចរេតចិត្តតិចៗ ហើយមានការពេញចិត្តចំពោះអាការៈហួងហែងរបស់គេ ដែលមានចំពោះនាង ប៉ុន្តែគេបែរជាសោះកក្រោះគ្មានអារម្មណ៍អី ហាក់ដូចនាងជាមនុស្សស្រីគ្មានតម្លៃម្នាក់។

ការដែលគេហួងហែង មិនថាដោយហេតុផលអ្វីក៏ដោយ វាមានន័យរបស់វា។ មិនមែនថានាងគ្មានតម្លៃសម្រាប់គេទាំងស្រុង ហើយនាងក៏មោះមុតនឹងការស្វែងរកចំណុចខ្សោយរបស់គេដែរ ព្រោះត្រូវការក្ដាប់វាឲ្យជាប់ ដើម្បីវាយបកគេ ឲ្យបាត់បង់ការប្រុងប្រយ័ត្នចំពោះខ្លួនឯង តែរឿងខ្លះ បើទាក់ទាញឲ្យគេខឹង លទ្ធផលនៃទង្វើនោះអាចវាយបកនាងដូចគ្នា។

រ៉េមសៀ ទទួលបានអំណាចគ្រប់គ្រងនាងពី ខាឡូម៉ាន់ ដែលជាការដាក់សំណើរបស់គេ ហើយគេក៏មិនស្ដាយក្រោយដែលនឹងធ្វើបែបនោះ។ ការ៉ិន ជាមនុស្សស្រីដែលពិបាកគ្រប់គ្រងណាស់ បើមិនរឹបអូសយកការគ្រប់គ្រងនាងពីព្រះអង្គម្ចាស់ គេនឹងត្រូវប្រឈមនឹងស្ថានការណ៍យ៉ាប់យ៉ឺនមិនខាន។ ខាឡូម៉ាន់ស្រឡាញ់ប្អូនស្រីម្នាក់នេះជាងគេ អីចឹងហើយច្បាស់ជាចេញមុខការពារនាង។





Scanned by CamScanner

ព្រះនាងតូចដែល ខាឡូម៉ាន់ ប្រាប់ថាគួរឲ្យថ្នាក់ថ្នម នាងគួរឲ្យថ្នាក់ថ្នម តែខ្លួនប្រាណប៉ុណ្ណោះ ចំណែកចរិតវិញ គេត្រូវតែលុតដំឲ្យមានរបៀបរបប។ ព្រះនាងកំពូលសម្រស់ហ៊ានតែងខ្លួន ដោយសម្លៀកបំពាក់មិនសមរម្យនៅក្នុងខ្សែភ្នែករបស់គេ ដើមទ្រូងមូលក្លំស្ទើរតែប្រាស់ចេញពីរ៉ូបថ្លៃនោះជាឈុតដែលសមពាក់ទៅដើរកែក្រាយឲ្យបុរសផ្សេងតយតន់រូបរាងរបស់នាងឬយ៉ាងម៉េច។

នាងជារបស់គេ...នេះជាអ្វីដែលគេគិត។ ខាឡូម៉ាន់ ប្រគល់នាងឲ្យគេហើយ មិនថានាងនិងគេពេញចិត្តឬអត់ ក៏រលាស់ចំណងនេះចេញពីខ្លួនមិនផុតដែរ ដូច្នេះហើយ ការ៉ុន គួរតែស្តាប់បង្គាប់ ដើម្បីយកចិត្តគេ ធ្វើឲ្យគេមានចិត្តប្រាថ្នាចំពោះនាង ដើម្បីចងគេឲ្យជាប់ តែនាងបែរជាជ្រើសរើសធ្វើអ្វីដែលផ្ទុយពីនោះ ចរិតរបស់នាង គេមិនចូលចិត្ត។

គេព្រមទទួលស្គាល់ ថាចូលចិត្តរូបរាងមុខមាត់របស់នាង តែធុញទ្រាន់ចរិតល្ងីល្ងើពេញបន្ទុកហើយ ក្រៅពីនេះនាងមិនចេះរក្សាខ្លួនស្ងួនប្រាណឲ្យសមជាភរិយារបស់គេទៀត។ ទោះមិនទាន់រៀបការនឹងគ្នា តែតំណែងភរិយារបស់គេត្រូវបោះត្រានៅលើរាងកាយរបស់នាងហើយ តាំងពីព្រះអង្គម្ចាស់ ខាឡូម៉ាន់ មានបញ្ជាឲ្យពួកគេរៀបការម្ល៉េះ។ គេមិនធ្លាប់ហួងហែងស្រីកំណាន់ តែសម្រាប់ភរិយា ដែលត្រូវរួមរស់នឹងគ្នា គឺតែងតែហួងហែងជារឿងធម្មតា ហើយពេលនេះអនាគតភរិយាកំពុងតែធ្វាញ់ធ្វាលឲ្យគេអស់ការអត់ធ្មត់។

"មិនសិចស៊ី"

នាងនៅតែប្រកែក ព្រោះវាគ្រាន់តែជារ៉ូបរាត្រីចោមពុង រែកត្រង់ដើមទ្រូង



តិចតួច ឃើញសាច់ទ្រូងតិចៗ ព្រោះជ្រលងទ្រូងដែលរែក មានក្រណាត់ស្តើងបាំង។ វាជាឈុតដែលទាក់ទាញជាងសិចស៊ីបញ្ចេញសាច់បញ្ចេញឈាម តែរ៉ែមសៀ បែរជាចោទដូចនាងតែងខ្លួនដោយសម្លៀកបំពាក់លេចលើលេចក្រោមបញ្ចេញនេះបញ្ចេញនោះ។

"មិនសិចស៊ី ?"

"ចាំ ខ្ញុំគិតថាមិនសិចស៊ី"

នាងពើងទ្រូង ដើម្បីធ្វាញ់ធ្វាលគេតាមរយៈទង្វើ។ នាងគិតថាមិនសិចស៊ីតើគេចង់យ៉ាងម៉េច នាងជាម្ចាស់រាងកាយនេះ នាងចង់ពាក់អីក៏បាន ដែលធ្វើឲ្យសប្បាយចិត្ត និងមានទំនុកចិត្តចំពោះរូបសម្រស់របស់ខ្លួន។

"អីចឹងត្រូវពិសោធ"

"ពិសោធ អ៎ា!"

នាងស្រែកដោយភ្លេចខ្លួន ពេល រ៉ែមសៀ លូកដៃចូលមកក្នុងរ៉ូប ហើយខ្ទាំដើមទ្រូងណែនក្បៀ ដោយបាតដៃត្រើមៗ។

"រ៉ែម...រ៉ែមសៀ! មនុស្សឈ្លើយ"

ការ៉ុន ប្រឹងពត់ពេនខ្លួនគេច តែម្ចាស់បាតដៃមិនព្រមឲ្យនាងរបូតពីដៃហើយទាញនាងមកពិតនឹងដើមទ្រូង សម្លឹងមុខដោយកែវភ្នែកមុតស្រួច។

"ត្រឹមលូកដៃចូលទៅ ខ្ញុំក៏អាចធ្វើបែបនេះបានទៅហើយ"

"អាប៉ិឆ្នួត! លែង!"

នាងក្តាប់ដៃគក់ស្មាធំទូលាយ គេក៏ច្របាច់ ហើយពេលនាងគក់កាន់តែ





Scanned by CamScanner

ខ្លាំង គេច្រឡាច់កាន់តែខ្លាំង ទើបនាងផ្អាក ព្រោះហត់ ដកដង្ហើមដង្ហក់ ទាំងខឹង ទាំងរៀន និងអាម៉ាស់ចំពោះទង្វើរបស់គេ គេមិនផ្តល់កិត្តិយសឲ្យនាង។

"មនុស្សឆ្កួត!"

នាងគក់គេទាល់តែអស់កម្លាំង ហើយកណ្តាប់ដៃក៏ក្រហម ខណៈដែល វ៉ែមសៀ នៅតែមានស្ថានភាពធម្មតា។

*នេះមនុស្ស ឬមនុស្សយន្ត ខ្លួនប្រាណធ្វើពីដែកឬយ៉ាងម៉េច គក់ប៉ុណ្ណា ក៏មិនរង្គោះរង្គើ ធ្វើឲ្យនាងឈឺដៃ!*

នាងក្រមុំខឹងឡើងទឹកភ្នែករលីងរលោង តែគេធ្វើព្រងើយ ថែមទាំងចាប់ចង្ការបស់នាងភ្ញើយទៅរក និងឱនមកជិត ឲ្យចុងច្រមុះជល់គ្នា។

"នៅប្រាប់ថាមិនសិចស៊ីទៀតទេ?"

"គ្មានអ្នកណាគិតរឿងអាក្រក់បែបនេះដាក់ខ្ញុំដូចលោកទេ"

"នាងឆ្លាប់ពុះក្បាលរបស់ពួកវាមើលក៏អី មនុស្សប្រុសឃើញមនុស្សស្រីតែងខ្លួនសិចស៊ី វាដឹងតែមានអារម្មណ៍ហើយ ចាំទុក ខ្លារិហ្សា"

*មនុស្សល្ងើយ!*

នាងជេរគេនៅក្នុងចិត្ត មាត់ប្រាប់ថាស្អប់នាង ស្តីបន្ទោស រិះគន់នាង តែបែរជាប៉ះពាល់ខ្លួនប្រាណរបស់នាង អាប្រុសក្រាន។

"លោក...លោក..."

វ៉ែមសៀ សម្លឹងមុខនាង បន្ទាប់មកក៏សង្កត់បបូរមាត់លើថ្ពាល់រលោង ហើយពេលចាប់មុខបង្វែរមកវិញ ពេលនាងងាកចេញ ម្តងនេះសង្កត់ខ្លាំងៗតែ



ម្តង ដូចត្រូវការដាក់ទោសដែលនាងហ៊ានបដិសេធការប៉ះពាល់របស់គេ។

"ថ្ពាល់មនុស្ស មិនមែនក្រណាត់ជូតជើង ចេះញីទៅកើត ខ្ញុំឈឺ"

ច្រមុះនិងមាត់របស់ វ៉ែមសៀ ញាក់ញីថ្ពាល់ដែលប្រឹងគេចវេះ ញីខ្លាំងៗ ហើយពុកមាត់ពុកចង្កាក៏កកិតសាច់ថ្ពាល់ឡើងក្រហម និងផ្សា។

"ចាំទុក! នាងជារបស់ខ្ញុំ"

គេប្រកាសដាក់មុខ ដកបាតដៃចេញពីដើមទ្រូងណែនត្បុំ តែយកវាមកទាញរាងតូចច្រឡឹងឲ្យអង្គុយលើភ្លៅ និងចាប់ចង្កាឲ្យងើយមុខមករក។

"ខ្ញុំជាម្ចាស់ខ្លួនឯង"

"នាងជារបស់ខ្ញុំ ខ្លារិហ្សា ហើយនាងត្រូវចេះធ្វើខ្លួនស្តាប់បង្គាប់ដាក់ខ្ញុំ"

"លោកបញ្ជាខ្ញុំ?"

"អឺ! បញ្ជា" វ៉ែមសៀ គ្រហឹមដាក់ជាចម្លើយ។

នាងសម្លក់សម្លឹងគេ គិតថាហេតុអ្វីបងប្រុសលើកនាងឲ្យមនុស្សល្ងើយបែបនេះ ព្រោះនាងនិងគេអាចវាយគ្នាស្លាប់មុនពេលបានរៀបការក៏ថាបាន។

"អាប៉ិឆ្កួត! ល្ងើយ"

ព្រះនាងឆ្មាសក្តាប់ដៃគក់ស្មាធំទូលាយ គក់ហើយរលាស់ដៃ ព្រោះគក់ខ្លួនឯងឈឺខ្លួនឯង គិតថា វ៉ែមសៀ ច្បាស់ជាស៊ីដែកជំនួសបាយមិនខាន ទើបរឹងកំព្រឹសបែបនេះ។

"កុំឆ្មាសពេក ខ្លារិហ្សា ថ្ងៃនេះខ្ញុំមានអារម្មណ៍មិនល្អ នាងនៅមកញោះឲ្យខ្ញុំខឹងខ្លាំង ព្រោះលទ្ធផលនាងអាចគ្រោះថ្នាក់"



ពេលត្រូវបញ្ហាបែបនេះ នាងក៏កើងទ្រូងដាក់ ទោះខ្លាចគេយ៉ាងណាក៏មិនប្រាប់ថាខ្លាចដែរ តែទង្វើបែបនេះ វាធ្វើឲ្យគេត្រូវការយកឈ្នះនាង ទើបខិនមកថើបបបូរមាត់លឿនដូចព្យុះ។

*គេថើបនាងទៀតហើយ!*

វ៉ែមសៀ ថើបជញ្ជក់ ហើយមិនត្រឹមតែប៉ុណ្ណឹង នៅទាមទារឲ្យតបស្នងវាតអំណាច បញ្ជាក់រឿងសម្លៀកបំពាក់ហាក់ដូចខ្លួនឯងជាម្ចាស់ ធ្វើឲ្យនាងទន់ខ្លួនល្អកនៅក្នុងរង្វង់ដៃរឹងមាំ។ នាងស្អប់ដែលគេបញ្ជានាង តែចាញ់ការថើបដ៏ក្តៅគគុកនេះ។

ព្រះនាងឆ្មាសខឹងផង ខ្មាស វ៉ែមសៀ ផង ក្រៅពីនេះក៏ត្រូវខ្មាស ស៊ីឡា និង ហ្វ៊ីភ៊ ដែរ ព្រោះពេលថើបឲ្យនាងទន់ខ្លួនល្អកហើយ គេក៏ត្រឡប់ទៅវិញ ហើយត្រូវខ្មាសថែម ពេលព្រឹកឡើងខ្លួនប្រាណមានស្នាមដែលគេបន្សល់ទុក។ ទោះអ្នកបម្រើទាំងពីរមិនបានបង្ហាញអាកាសៈថាឃើញ តែស្នាមច្បាស់យ៉ាងនេះយ៉ាងណាដឹងតែមើលឃើញ។

ការ៉ិន គ្មានពេលខ្មាសច្រើន ព្រោះមានបញ្ជាពីបងប្រុសមកដល់ ដែលជាការប្រកាសពីពេលវេលានៃការរៀបការដែលត្រូវពន្លឿន ហើយមួយម៉ោងក្រោយមក ចាស្ទីន ក៏ធ្វើដំណើរមកដល់ ដើម្បីនិយាយពីរឿងឈុតមង្គលការ។

ឈុតមង្គលការរបស់ព្រះនាងត្រូវថ្លៃម៉ូតរួចរាល់ហើយ ពេលនេះនៅក្នុងដំណាក់កាលនៃការរៀបចំ តែពេលមង្គលការត្រូវពន្លឿនពេល ទើប ចាស្ទីន



ត្រូវរវល់ខ្លាំង។

"ខ្ញុំត្រូវការឈុតមង្គលការពេលធ្វើពិធីពីរឈុត"

ត្រឹមឈុតមង្គលការមួយត្រូវសឹងតែរៀបចំមិនទាន់ទៅហើយ ប៉ុន្តែនេះជាតម្រូវការរបស់ព្រះនាង ដូច្នេះហើយទើប ចាស្ទីន មានតួនាទីកត់ត្រា។

"មួយឈុតទៀត មិនបាច់ប្រណិតពេកក៏បាន"

ស្នាមញញឹមនៅលើបបូរមាត់របស់ព្រះនាង ជាប្រផ្នូលសម្រាប់ ចាស្ទីន គិតថាមិត្តភក្តិរបស់ខ្លួន មុខជាមិនបានត្រូវការឈុតមង្គលការសម្រាប់ពាក់ក្នុងពិធីនោះទេ។

"ចង់មានន័យថាម៉េច?"

"ឈុតមង្គលការដែលឯងកំពុងធ្វើ ខ្ញុំមិនកែកុនអីទេ វាល្អមនឹងខ្លួនហើយ ចំណែកមួយឈុតទៀត ខ្ញុំត្រូវការពាក់ដើម្បី វ៉ែមសៀ"

"ដើម្បីលោកឧត្តមសេនីយ វ៉ែមសៀ?"

"មែន តែជាការពាក់ដើម្បីញ៉ោះឲ្យគេខឹង ខ្ញុំមិនពាក់ចូលកម្មវិធីទេ ព្រោះខ្ញុំត្រូវរក្សាមុខមាត់ឲ្យបងប្រុស ខ្ញុំត្រូវការឈុតមង្គលការសិចស៊ី បើកទ្រូងឲ្យធំ"

"ល្អឬ?"

"ល្អ អាប៉ិឆ្កួត វ៉ែមសៀ ហាមខ្ញុំតែងខ្លួនសិចស៊ី ខ្ញុំត្រូវស្តាប់បញ្ជារបស់គេ ឬ ខ្ញុំមិនស្តាប់ដាច់ខាត គេនឹងបានដូចចិត្តគេគ្រប់រឿងទេ"

ការ៉ិន ជ្រើសរើសប្រឆាំងនឹង វ៉ែមសៀ ហើយសួរថាបារម្ភពីមិត្តភក្តិទេ ចម្លើយគឺបារម្ភ តែ ចាស្ទីន មិនអាចរារាំងបាន។





Scanned by CamScanner

"ហើយឯងពាក់ពីរឈុតយ៉ាងម៉េចឲ្យទាន់ពេល?"

"ឈុតញ៉ោះឲ្យខឹង ខ្ញុំនឹងពាក់នៅថ្ងៃល រ៉ែមសៀ ដាវ៉ៃហ៊ឺណេស ត្រូវតែខឹងចេញផ្សែងតាមត្រចៀក ត្រង់ទ្រូងត្រូវតែវែកឲ្យធំ"

"នេះជាបញ្ជារបស់ព្រះនាង ខ្ញុំត្រូវតែអនុវត្តតាម"

"អរគុណ ចាស្ទីន"

"តែមានទុកចិត្តទេ ថាឯងនឹងមិនគ្រោះថ្នាក់ដោយសារការសម្រេចចិត្តនេះ?"

ការ៉ិន នៅស្ងៀមមួយសន្ទុះ ពេលនឹកថា រ៉ែមសៀ នឹងចាត់ការនាងយ៉ាងណា ហើយក៏ធ្វើឲ្យថ្ពាល់ក្តៅ។

"គេអាចដាក់ទោសខ្ញុំខ្លះទេដឹង"

តើត្រូវខ្លាចអីទៀត បើនេះមិនមែនជាលើកដំបូងដែលគេថើបនាងផង។ គេថើបនាងច្រើនដងហើយ ខាតទុនច្រើនដងហើយ ដូច្នេះហើយត្រូវថើបទៀតក៏មិនអីដែរ សុំត្រឹមធ្វើឲ្យគេមួម៉ៅក្តៅក្រហាយបាន នោះឯងជាលទ្ធផលដែលនាងត្រូវការ ព្រោះបើឲ្យគេបានដូចចិត្តគ្រប់រឿង គេនឹងកាន់តែវាតអំណាច។

"បើឯងបញ្ជាក់ ខ្ញុំនឹងចាត់ការឲ្យ"

"ខ្ញុំបញ្ជាក់"

ការ៉ិន មិនប្តូរចិត្ត ប្រាប់ពីតម្រូវការរបស់ខ្លួនដល់ ចាស្ទីន រឿងម៉ូតរបស់ឈុតមង្គលការ សុំម៉ូតវៀលជ្រៅ ឃើញពាក់កណ្តាលដើមទ្រូង។ នាងត្រូវការឈុតបែបហ្នឹង ដោយមិនពាក់វាចូលកម្មវិធីទេ តែនឹងពាក់ញ៉ោះ រ៉ែមសៀ។ នាង



នឹងញ៉ោះគេដោយប្រយោល ឲ្យគេយល់ច្រឡំថាវាឈុតមង្គលការ ចំណែកឈុតមង្គលការពិតប្រាកដគឺត្រូវតែស្អាត ប្រណិត ថ្លៃថ្នូរសមនឹងឋានៈរបស់នាង និងដើម្បីរក្សាមុខមាត់របស់បងប្រុស។ នាងមិនធ្វើបាបមនុស្សជាទីស្រឡាញ់ដោយប្រយោល នាងមានបញ្ហាជាមួយ រ៉ែមសៀ ដូច្នេះហើយត្រូវតែចាត់ការគេដោយផ្ទាល់។

នាងស៊ូកម្លាំងបាយរបស់គេមិនបាន បានត្រឹមញ៉ោះគេក៏ល្អ មិនអីចឹងនាងនឹងមិនសប្បាយចិត្ត។ គេមានអំនួតចំពោះអំណាចរបស់ខ្លួនឯងពេក នាងមិនសង្ឃឹមថាឲ្យគេស្រឡាញ់ តែត្រូវការឲ្យគេផ្តល់កិត្តិយសខ្លះ តែគេមិនធ្លាប់ធ្វើឲ្យនាងមានអារម្មណ៍បែបនោះ គេមានតែពាបសង្កត់ជិះជាន់។

"គេត្រូវតែខឹងចេញផ្សែង!"

"មើលទៅឯងមានសេចក្តីសុខដល់ហើយ ការ៉ិន?"

"ត្រូវតែមានសេចក្តីសុខ មនុស្សឆ្កួតត្រូវតែបានមេរៀន គេជាមនុស្សឆ្កួតអំណាចដែលឈ្លើយ"

ចាស្ទីន ចង់ដាក់សំណើឲ្យធ្វើការសម្រុះសម្រួលគ្នា តែព្រះនាងមុខជាមិនស្តាប់ ក្រៅពីនេះបើមិនយល់ស្រប ការ៉ិន អាចមិនប្រាប់ផែនការសម្ងាត់ដល់នាង ហើយសុំឲ្យអ្នកដទៃជួយ ដែលនាងមិនត្រូវការឲ្យមានរឿងបែបនេះ។

រ៉ែមសៀ ទទួលបានបញ្ជាពីព្រះអង្គម្ចាស់ ជាបញ្ជាសម្ងាត់ពិសេស ដោយអ្នកយកបញ្ជាសម្ងាត់មកឲ្យគឺ ស៊ីតិពិស ព្រោះ ខាឡម៉ាន់ មិនត្រូវការឲ្យ



ឆ្លាយព័ត៌មាន ឬមានការសង្ស័យ ជាការបង្ការភាពឆ្លោះឆ្លោយ ហើយ សីតីរ៉ាស មិនបានយកមកឲ្យក្នុងនាមជាអ្នកនាំសារ តែមករកនៅក្រុងអាឡិចសានដេ។

សីតីរ៉ាស កំពុងស្ថិតនៅក្នុងពេលឈប់សម្រាក ទើបការធ្វើដំណើរមករកមិត្តភក្តិនឹងមិនត្រូវសង្ស័យ ទាំងដែលការពិតគេគ្មានទំនេរច្រើនទេ ការដើរលេងគ្រាន់តែហេតុផលបាំងមុខ ឯរឿងពិតគឺគេកំពុងត្រួតពិនិត្យរបៀបរៀបរយ។

"ខ្ញុំទទួលបញ្ជា"

រ៉េមសៀ ទទួលយកបញ្ជាពិសេស។ បន្ទាប់ពីរៀបការ គេត្រូវធ្វើដំណើរទៅស៊ីរ៉ូវើ តំបន់ស្វ័យតរបស់សាក់ខារៀ។ ស៊ីរ៉ូវើ ត្រូវអនុញ្ញាតឲ្យគ្រប់គ្រងខ្លួនឯងក្រោមកិច្ចសន្យាជាផ្នែកមួយនៃប្រទេស ត្រូវស្មោះត្រង់ចំពោះ សាក់ខារៀ និងរាជវង្ស ម៉ាលខៃសេនតេ ក្រោមការគ្រប់គ្រងរបស់ ខាឡម៉ាន់ ដែលជាកិច្ចសន្យាដូចគ្នានឹង រ៉េមសៀ ដើម្បីគ្រប់គ្រងក្រុងអាឡិចសានដេ។

ស៊ីរ៉ូវើ មានឈ្មោះមួយទៀតដែលប្រជាជនស្គាល់ក្នុងនាមជាកោះចោរ ដែលត្រឹមឈ្មោះក្រៅផ្លូវការរបស់កោះក៏មិនគួរឲ្យធ្វើដំណើរទៅទៅហើយ តែគេត្រូវទៅទីនោះ បន្ទាប់ពីរៀបការរួចបានពីរសប្តាហ៍ ទើបនេះអាចជាហេតុផលមួយដែល ខាឡម៉ាន់ ឆ្លៀតឱកាសនេះពន្លឿនពេលរៀបការ ព្រោះបើទៅទីនោះគេមិនអាចយកជីវិតត្រឡប់មកវិញបាន ពិធីមង្គលការគ្រាន់តែជាផែនការដែលមិនបានកើតឡើងពិតប្រាកដ។

អ្នកកំលោះដកដង្ហើមធំ ព្រោះមានបញ្ហាជាច្រើនឲ្យចាត់ការ ហើយនឹកដល់ ការ៉ុន ថានឹងមានអារម្មណ៍យ៉ាងណា ពេលដឹងថាស្វាមីដែលទើបរៀបការ



ថ្មីថ្មោងត្រូវធ្វើដំណើរផ្លូវឆ្ងាយ។ គេមិនអាចនាំនាងទៅជាមួយបាន ព្រោះមិនបានទៅស៊ីរ៉ូវើក្នុងនាម រ៉េមសៀ ជាវៃហ៊ោណេស តែទៅទីនោះដើម្បីធ្វើជាកម្មករ។

"ចប់ធុរៈរបស់ខ្ញុំហើយ ខ្ញុំត្រូវសុំទៅដើរលេងបន្ត"

"អញ្ជើញតាមសម្រួល ដើរឲ្យលេងឲ្យសប្បាយទៅ"

"ខ្ញុំក៏សង្ឃឹមបែបហ្នឹងដែរ"

សីតីរ៉ាស មិនត្រូវការឲ្យដំណើរកម្សាន្តរបស់ខ្លួនត្រូវជាប់គាំង មិនអីចឹងគេនឹងត្រូវប្រឈមនឹងបញ្ហា ហើយបើមានបញ្ហាគឺត្រូវតែជម្រះ។ វេសលីយ៍ប្រេន ដែលគេគ្រប់គ្រងមានឈ្មោះថាជាទីក្រុងស្មសាន ទើបពេលនេះមិនចង់បន្ថែមផ្នូរឲ្យទីនោះទេ។ រយៈពេលបីខែក្រោយនេះ មានផ្នូរថ្មីកើតឡើងច្រើន ដែលគេមិនចង់ឲ្យមាន ព្រោះមិនចង់ឲ្យកើនថ្លៃក្រឡាក្រុង។

ទេសភាពទាំងមូលរបស់ក្រុងវេសលីយ៍ប្រេនស្អាតណាស់ សីតីរ៉ាស ក៏បែងចែកជាផ្នែក តែអ្នកដេកនៅក្នុងផ្នូរគ្មានឱកាសបានរើសទេសភាពតាមចិត្ត ព្រោះរឿងនេះ ស្ថិតនៅលើម្ចាស់ក្រុងជាសម្រេចចិត្តឲ្យវាដាច់ខ្យល់នៅត្រង់ណា ដោយគេហៅវាថាជាការចាត់ការជាជំហាន គ្រប់គ្រងបរិមាណ ទំហំ និងថ្លៃម៉ូតដោយផ្ទាល់។

វេសលីយ៍ប្រេន មិនមែនជាទីក្រុងទេសចរណ៍ តែជាទីក្រុងស្ងប់ មានប្រជាជនអាស្រ័យនៅតិចណាស់ ហើយសំណាងល្អដែល សីតីរ៉ាស ជាមនុស្សចូលចិត្តភាពស្ងប់ស្ងាត់ ទើបគេអាចនៅទីនេះបានដោយមានសេចក្តីសុខ។



"ជំនួញរបស់ឯងយ៉ាងម៉េចដែរ សីតីរ៉ាស ?"

"រុងរឿង"

មុនពេលលាគ្នា រ៉េមសៀ ផ្ដៀតមានចិត្តសួរសុខទុក្ខបន្តិចបន្តួច ទាំងដែលដឹងហើយជំនួញគ្មានអ្វីឲ្យបារម្ភ ព្រោះផ្ទៃក្រឡារបស់ស្មាសាន អ្នកដែលចុះទៅដេកនៅក្នុងផ្នូរ ត្រូវតែបង់ប្រាក់។

គ្មានការបង់ប្រាក់ ដើម្បីជួលជាអចិន្ត្រៃយ៍ ទោះជាពួកនោះត្រូវស្លាប់ជាអចិន្ត្រៃយ៍ក៏ត្រូវ ហើយបើមិនបង់ប្រាក់រយៈពេលបីខែ ម្ចាស់ដីនឹងដេញចេញ ដើម្បីស្វាគមន៍អតិថិជនថ្មី តែអតិថិជនភាគច្រើនបង់ប្រាក់ប្រចាំឆ្នាំ ក្រៅពីនេះមានអតិថិជនមួយចំនួនជួលម្ដងមានរយៈពេលច្រើនឆ្នាំ ដោយបង់ប្រាក់ជាមុន និងពេលគ្រប់ការកំណត់ ស៊ីតីវ៉ាស និងអញ្ជើញអតិថិជនពីផ្នូរ ដើម្បីកម្ចាត់ឲ្យរួចរាល់ ដែលពិធីចាត់ការត្រូវបានបិទ ដោយឲ្យហេតុផលសាមញ្ញៗថា វាជាអាថ៌កំបាំងជំនួញ។

"ហើយឯងទៅ សេនថាម៉ារ៉ា ពេលណា រ៉េមសៀ ?"

"ថ្ងៃលឈុតមង្គលការ" រ៉េមសៀ នឹងបានជួប ការ៉ឺន ម្ដងទៀត។

ថ្ងៃនោះគេចាកចេញ ដោយយករសផ្អែមល្ហែមលាយឡំក្ដៅគគុករបស់នាងមកជាមួយ។ ចាប់ពីពេលនោះមក គេក៏ប្រាថ្នារាងកាយរបស់នាង ដោយមិនអាចហាមប្រាមបាន។

"ពិចឹងប្រហែលបានជួបគ្នានៅ សេនថាម៉ារ៉ា"

"អូខេ ធ្វើដំណើរដោយសុវត្ថិភាព"

រ៉េមសៀ ជូនពរ មិត្តភក្ដិកំលើបឈរ ឱនគំនាប់បន្តិចជាការលា។



"អូខេ ជួបគ្នាពេលក្រោយ"

ពេលល្ងាចរាល់ ស៊ីតីវ៉ាស ក៏ដើរចេញពីបន្ទប់ធ្វើការរបស់ម្ចាស់ផ្ទះ។ គេជ្រើសរើសធ្វើដំណើរដោយឡានដឹកទំនិញកញ្ចាស់សំណព្វរបស់គេ ហេតុផលឬ គឺគេចូលចិត្ត វាគ្មានអ្វីលើសពីហ្នឹងទេ។

**ការ៉ឺន លឈុតមង្គលការដោយទឹកមុខរីករាយ មាន ចាស្ទីន និងកូនទៅជួយ** ជាឈុតដែលត្រូវថ្លៃម៉ូតជាពិសេស នាងពាក់វាបានស្អាត គ្មានអ្វីឲ្យទាស់។

ឈុតមង្គលការពណ៌សព្រលែងស្វា មានក្រណាត់ស្តើងរុំត្រឹស្គាល់ ក្រងជាខ្សែវែង ព័ទ្ធកសខ្ចី ទម្លាក់ខ្លួនលើសាច់សផ្កូរផង់។ ក្រណាត់ខាងលើត្រូវអ៊ុតដោយតិចនិចពិសេស ដើម្បីឲ្យសាច់ក្រណាត់រឹងនិងមានម៉ូតផ្អិបជាប់នឹងទ្រូងទ្រលុកទ្រលន់ ព្រោះតួអាវមានស្នាមឆែក មើលឃើញសាច់ទ្រូងពីចំហៀង។ បើមើលដោយភ្នែកទទេ នឹងឃើញថារ៉ូបចោមពុងនៅជាប់ប្របេះៗនឹងទ្រូង អាចរបូតបានគ្រប់ពេល តែតាមពិតក្រណាត់ត្រូវបានដេរបានល្អ ដើម្បីឲ្យវារឹបជាប់នឹងរាងកាយ ឯសម្រស់វែងរូសដី។

ការ៉ឺន បង្វិលខ្លួននៅមុខកញ្ចក់ ក្នុងបន្ទប់តែងខ្លួន ដែលស្ថិតនៅក្នុងបន្ទប់ដេក។ នាងពេញចិត្តនឹងឈុតនេះណាស់ ចាស្ទីន និម្មិតឲ្យបានត្រូវចិត្តមែនទែន ហើយនាងជឿថា រ៉េមសៀ មុខជាខឹងផ្ទុះសរសៃឈាម ពេលឃើញវានៅលើដងខ្លួនរបស់នាង។



នាងបង្វិលខ្លួនម្ដងទៀត គិតថាពេល រ៉េមសៀ ធ្វើដំណើរមកដល់ នាង

និងដើរកែក្រោយទៅរក ហើយគេត្រូវតែស្រឡាំងកាំងនឹងឈុតស្អាត ដោយមិនប្រាប់ទេថា វាជាឈុតញ៉ោះកំហឹង ចំណែកឈុតមង្គលការពិតប្រាកដ នាងឲ្យអ្នកបម្រើយកទៅទុកនៅបន្ទប់ដេកផ្សេង ដើម្បីមិនឲ្យគេឃើញ ព្រោះគេធ្លាប់ចូលបន្ទប់ដេកនេះ ដែលគេអាចនឹងធ្វើបែបនោះទៀត។

បន្ទាប់ពី រ៉េមសៀ ខឹងផ្ទះឈាម គេនឹងបានដឹងថានៅថ្ងៃមង្គលការ នាងមិនបានពាក់ឈុតនេះ តែពាក់ឈុតមង្គលការពិតប្រាកដ ដែលពាក់ទៅស្អាតជាងឈុតនេះទៅទៀត។ នាងគ្រាន់តែចង់ឲ្យគេមួម៉ៅឲ្យដល់ថ្ងៃរៀបការ នាងមានកម្លាំងធ្វើបានតែប៉ុណ្ណឹងនៅក្នុងការបេះបួយគេ ដែលត្រឹមនឹកដល់ទឹកមុខពេលខឹងសម្បារបស់គេ នាងក៏អាចញញឹមញញែមបានទៅហើយ។

"ខ្ញុំចូលចិត្តណាស់"

"សង្ឃឹមថាមិនចូលចិត្ត ដល់ថ្នាក់ចង់ពាក់នៅថ្ងៃរៀបការ"

"កុំបារម្ភ ខ្ញុំមិនធ្វើបែបហ្នឹងទេ"

នាងដឹងថាមិត្តភក្តិបារម្ភ ខ្លាចការញ៉ោះ រ៉េមសៀ ធ្វើឲ្យមានបញ្ហាធំ តែនាងឆ្លាត ដឹងថាត្រូវធ្វើយ៉ាងណាដើម្បីមិនឲ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះបងប្រុស។

"ឈុតពិតប្រាកដស្អាតជាងនេះទៅទៀត ខ្ញុំចូលចិត្តឈុតហ្នឹងជាង"

នាងបង្ហាញឲ្យឃើញពីការជាប់ចិត្តចំពោះឈុតមង្គលការដែលត្រូវពាក់នៅថ្ងៃរៀបការ។

ព្រះនាងហុចដៃឲ្យ ស៊ីឡា ជួយនាំចេញពីបន្ទប់តែងខ្លួន មាន ចាស្ទីន ដើរនាំមុខ ហើយទប់ដំណើរ ពេលឃើញបុរសមាឌក្រអាញ ឈរឱបដៃនៅនឹង



មុខបន្ទប់នេះ។

"លោកឧត្តមសេនីយ រ៉េមសៀ"

ពេល ចាស្ទីន រក់ទាក់បែបនេះ ធ្វើឲ្យ ការ៉ុន ត្រូវប្រឈមនឹងគេបែបប៉ុបប៉ាប់ ទើបផែនការដើរកែក្រោយទៅបង្អួតឆោមនៅខាងក្រៅត្រូវផ្អើបចោល។

"លោកចូលមកក្នុងនេះធ្វើអី"

នាងក្រមុំមិនពេញចិត្ត ពេលគេអាចចេញចូលដំណាក់នេះបាន ហាក់ដូចគេមានសិទ្ធិ តែទោះមិនពេញចិត្តក៏មិនអាចហាមគេបាន។

"សួស្តី ខ្ញុំត្រូវការនៅជាមួយព្រះនាងតែពីរនាក់"

ពេលលោកឧត្តមសេនីយប្រាប់បែបនេះ ចាស្ទីន ដឹងភ្លាមថានេះជាការសម្តែងឃើញពីការមិនពេញចិត្ត...មិនពេញចិត្តជាខ្លាំងនឹងឈុតនៅលើដងខ្លួនរបស់ព្រះនាង ហើយទោះគេមិនទាន់បំផ្ទុះកំហឹងដាក់មិត្តភក្តិ និងទោះនាងបារម្ភពីមិត្តភក្តិយ៉ាងណា តែក៏ត្រូវចេញពីបន្ទប់នេះតាមតម្រូវការរបស់គេ ដោយអ្នកបម្រើក៏ត្រូវចេញដែរ ទុកឲ្យព្រះនាងឈរញ័រខ្លួននៅជាមួយគេតែពីរនាក់។

"ខ្លារិហ្សា" រ៉េមសៀ សម្លឹងមើលនាងជាច្រើនដង មើលដោយកំហឹង។

"សួស្តី លោកឧត្តមសេនីយ រ៉េមសៀ"

ក្រៅពីធ្វើមុខមិនដឹងមិនឮនឹងសំឡេងគ្រហឹមរបស់គេហើយ នាងនៅរក់ទាក់ដោយសំឡេងពីរោះ និងកាយវិការសុភាពរាបសារទៀត គឺបន្ទន់ជង្គង់លោទៅមុខបន្តិច ដើម្បីឲ្យគេឃើញថាឈុតរបស់នាងស័ចស៊ុំខ្លាំង។



អ្នកកំលោះខាំធ្មេញក្រតៗ បែរខ្លួន ដើរសំដៅទ្វារ ដែលធ្វើឲ្យនាងមាន



Scanned by CamScanner

ការរឿងឆ្ងល់ គិតថាគេត្រឡប់ទៅវិញហើយឬ ហេតុអីបានជាខឹងតិចម្ល៉េះ ឬថាខឹងខ្លាំង ដល់ថ្នាក់មិនចង់ឃើញមុខនាង។

"ម៉ោណេះ!"

ការ៉ុន ភ្ញាក់ព្រញ្ញាង តែគេមិនបានហៅនាង គេហៅអ្នកបម្រើនៅខាងក្រៅ។ នាងបានឮសំឡេងបញ្ជារបស់គេ ដែលបញ្ជាឲ្យអ្នកបម្រើអញ្ជើញចាស៊ីន ចេញពីដំណាក់ ដែលពាក្យថា អញ្ជើញ ស្ដាប់ទៅមានមារយាទ ធាតុពិតគឺជាការបណ្ដេញនោះឯង ដើម្បីចាត់ការនាងបានស្រួល។

រ៉ែមសៀ ដើរចូលមកក្នុងបន្ទប់ដេកវិញ បន្ទាប់ពីបញ្ជា ហាមអ្នកបម្រើមករំខាន ហើយពេលបិទទ្វាររួច ក៏ដើរមករកនាង កែវភ្នែករឹងកំព្រឹសដោយទោសៈជាងពេលកន្លងមក ព្រោះតេកំពុងខឹងខ្លាំង។

"នេះជាឈុតមង្គលការ ?"

"លោកឃើញថាជាឈុតស្អី"

"មិនច្បាស់ តែស្រីកំណាន់របស់ខ្ញុំតែងខ្លួនល្អជាងនេះ"

នាងក្រមុំក្ដាប់ដៃណែន គិតថាញ៉ោះឲ្យគេខឹង តែបែរជាត្រូវគេធ្វើឲ្យខឹងទៅវិញ ថែមទាំងហ៊ានយកនាងទៅប្រដូចនឹងស្រីកំណាន់របស់គេទៀត។



# ៧

## ខុសផែនការ

ការ៉ុន ស្ទុះទៅរក រ៉ែមសៀ ដោយភាពក្លាហាន ដែលភាពក្លាហានរបស់នាងជារឿងគួរឲ្យសរសើរ តែបែរជាយកមកប្រើខុសពេលខុសវេលា។

រ៉ែមសៀ រង់ចាំស្រាប់ហើយ ពេលនាងស្ទុះមករក គេក៏ធ្វើសកម្មភាពដែរស្រវាចាប់ដៃទាំងពីររបស់នាង ក្រពាត់ទៅក្រោយ និងក្រសោបជាប់។

"មនុស្សឈ្លើយ ម៉េចក៏ហ៊ាននិយាយបែបនេះដាក់ខ្ញុំ"

នាងក្រមុំពើងទ្រូងដាក់ ដកដង្ហើមដង្ហក់ ដើមទ្រូងផឹតផតឡើងចុះចាក់ភ្នែករបស់ រ៉ែមសៀ ទើបគេឱនមករកដោយមិនក្រែងរអែងចិត្ត។

"ហាមមើល!"

"មិនចង់ឲ្យមើល ហើយពាក់ឈុតបែបនេះធ្វើអី ?"

"ខ្ញុំត្រូវការឲ្យអ្នកផ្សេងមើលទៅវិញទេ"

ចម្លើយនេះដូចជះសាំងទៅលើភ្លើងទោសៈ ឲ្យគេខាំធ្មេញក្រតៗ និងឱនទៅរក តែបើបបូរមាត់ក្រពុំមិនបាន ព្រោះម្ចាស់បបូរមាត់គេចចេញទាន់ទើបមុខសង្ហាទៅជ្រប់នឹងប្រឡោះកសខ្ចី បានឱកាសឲ្យបបូរមាត់ក្រាស់បឺតជញ្ជក់សាច់ត្រង់នោះ។



"កុំ!"

នាងប្រឹងរើបម្រះ តែស៊ូនឹងកម្លាំងរបស់ វែមសៀ មិនបាន នាងប្រឹងរើ គេក៏ប្រឹងរឹត។

"កុំបឺតខ្លាំងពេក ស្នាមចាស់ទើបតែជាទេ"

ទោះនាងបែរខ្លួនទៅខាងណា វែមសៀ ក៏តាមឈ្លុល ព្រោះរាងកាយរបស់នាងអាចជួយពន្លត់ភ្លើងទោសៈរបស់គេបាន តែបង្កើនអារម្មណ៍ផ្សេងឲ្យកាន់តែពុះ។

"អុំ!"

ដៃរបស់នាងមានសេរីភាព ព្រោះគេព្រលែង ដើម្បីយកដៃនោះមករឹតក្រោមត្រគាកមូលក្លំ លើកព តែពដោយដៃម្ខាង ព្រោះម្ខាងទៀតចាប់ដៃរបស់នាងជាប់ បង្ការការប្រទូស្តរ៉ាយរាងកាយ។

"លែង!"

វែមសៀ មិនតបត ព្រមព្រលែងដៃរបស់នាង តែរឹតរួតរាងកាយតូចស្តើងកាន់តែណែន ចំណែក ការ៉ុន ក៏ដាក់ដៃលើស្មាធំទូលាយដើម្បីរុញចេញ ទាំងដែលពីដំបូងចង់ទះតប់ តែធ្វើមិនបានសម្រេច ត្រូវគេចាប់សង្កត់ក្បាល ហើយថើបផញ្ជក់បបូរមាត់។

"មិនឲ្យថើប"

នាងងាកមុខចេញ បដិសេធការប៉ះពាល់នេះ តែ វែមសៀ មិនខ្វល់ទៀតនោះឯង គិតតែពីឈ្លានពាន មិនព្រមនាំបបូរមាត់ទៅណាឆ្ងាយ តាមមកថើប



ធ្វើឲ្យនាងអស់ផ្លូវគេច មិនអាចនាំបបូរមាត់របស់ខ្លួនគេចពីបបូរមាត់ក្តៅគាយៗរបស់គេបាន ត្រូវព្រមឲ្យគេគ្រប់គ្រង ព្រមឲ្យគេបានចិត្តនឹងកម្លាំងពលំ ដែលមានច្រើនជាង និងដែលគួរឲ្យខឹងគឺនាងក្លាយជាថើបគេវិញទៀតហើយ។

វែមសៀ ថើបផញ្ជក់ខ្លាំងៗ ដោយភាពក្តៅគគុក។ អារម្មណ៍ទោសៈដែលនៅសេសសល់ឬអត់ គេមិនបានចាប់អារម្មណ៍ ខណៈដែល ការ៉ុន ដូចជាភ្លេចទៅហើយថាខ្លួនត្រូវការញ៉ោះគេ ទើបបង្ហើបមាត់ ព្រមចុះចាញ់មាត់និងអណ្តាតរបស់គេ។

អ្នកកំលោះឱបរឹត ស្ទាបរង្វេលខ្នងរបស់នាងថ្នមៗ ហើយពេលមានសំឡេងថ្ងូរបបូតចេញមក គេក៏បឺតផញ្ជក់យកទៀត ល្បួងឲ្យនាងព្រមលើកដៃឱបរឹត តែពេលត្រូវផ្អែកទៅលើពូក ក៏ភ្ញាក់ស្មារតី ទាស់ត្រង់គេមិនឲ្យនាងគេចទៅណាបាន ទើបឱបរឹត និងទ្រាបពីលើ សង្កត់ជាប់ បបូរមាត់នៅតែតាមមកថើបជាបន្តបន្ទាប់ ដៃក៏ស្រាយចំណងពីសក់វែងរសាយឲ្យមានសេរីភាព ហើយខ្ទាំសក់នោះតិចៗ។

គេដកបបូរមាត់ចេញ ហើយឱនមកប្រសព្វភ្នែកជាមួយ ដោយខ្សែភ្នែកត្រជាក់ស្រេង ខណៈដែល ការ៉ុន ដេកដកដង្ហើមចង្រិត ដើមទ្រូងជីតផត ឯរ៉ូបដែលតោងទ្រូងប្រហេះ វាចង់របូតទៅហើយ ហើយវាក៏ធ្វើឲ្យគេខឹង ពេលគិតថានាងពាក់ឈុតនេះចូលរោងការ។ គេមិនអាចទទួលយកបានទេ ដែលកូនក្រមុំរបស់ខ្លួនដើរបង្ហូតឆោមនៅចំពោះខ្សែភ្នែកអ្នកដទៃ។



គេលូកដៃទៅក្រោយ ទាញរ៉ូតរបស់វា ធ្វើឲ្យផ្នែកខាងមុខរបូតពីគ្នា ទើប



នាងលើកដៃសង្គ្រុបដើមទ្រូង ដើម្បីបិទបាំង។

"វ៉ែមសៀ លោក...លោក...ចង់ធ្វើអី ?"

នាងស្ទុះងើបអង្គុយ ដែលគេក៏ព្រមឲ្យងើប តែមិនមែនដោយសារផ្ដល់សេរីភាពឲ្យ ព្រោះពេលនាងអួសត្ដូទទៅរកក្បាលគេ គេក៏ចាប់ជាយរ៉ូប ទាញវាចេញពីរាងកាយសិចស៊ី ហើយមិនចាំបាច់ស្រមើស្រមៃដល់ល្បែងលើរបស់នាងតទៅទៀតទេពេលនេះ។

"ប្រុសឆ្កួតនេះ!"

អ្នកកំលោះចាប់គួឈុតល្បែងលើកញ្ចក់មួយទំហឹង ធ្វើឲ្យនាងចំហហាត់ផ្លូង ដោយស្មានមិនដល់នឹងកំហឹងរបស់គេ ហើយក្រណាត់ធន់នឹងការចាប់កញ្ចក់មិនបានក៏រហែកជាពីរ។

"ថយចេញ"

វ៉ែមសៀ មិនថយ ថែមទាំងចាប់ជើងស្រឡូនទាំងពីរទៀត កញ្ចក់នាងមកជិត។

"រ៉ាភ! ស៊ីឡា! ហ្វីរ៉ា!"

នាងស្រែកហៅរកអ្នកបម្រើ ពេលស៊ូនឹងកម្លាំងរបស់គេមិនបាន ស៊ីឡា និង ហ្វីរ៉ា ក៏នាំគ្នាស្ទុះចូលមក។

"ចេញ!"

គេងាកទៅគំហកខ្លាំងៗដាក់ ហាក់ដូចសំឡេងរន្ទះ អ្នកបម្រើទាំងពីរក៏ទន់ជង្គង់ ដួលខ្ពោកដោយការភ័យខ្លាច តែទោះជើងប្រើការមិនបាន ក៏ពួកនាង



ប្រញាប់វារដោយដៃចេញពីបន្ទប់។

"បើហ៊ានចូលម៉ោទៀត ដោយខ្ញុំមិនហៅ ងាប់!"

"ចាំ...ចាំ" ស៊ីឡា និង ហ្វីរ៉ា ទទួលបញ្ជាដោយសំឡេងរដាក់រដុប។

ហើយពេលទ្វារបន្ទប់ត្រូវបិទម្ដងទៀត ទើបគេងាកមកប្រសព្វភ្នែកនឹងអ្នកដែលដេកដង្ហក់ខ្យល់នៅលើគ្រែដោយខ្សែភ្នែករឹងកំព្រឹស។

"អាប៉ិឆ្កួត! តំរាមមនុស្សរបស់ខ្ញុំធ្វើអី"

"គ្រប់យ៉ាងដែលជារបស់នាង វាក្លាយជារបស់ខ្ញុំហើយ ខ្លារីហ្សា"

"មិនពិត!"

"វាជាការពិតដែលនាងត្រូវទទួលស្គាល់"

នាងតក់ទ្រូងតេឌឺបៗ តែដើមទ្រូងហាប់ណែនដោយសាច់ដុំបែរជាធ្វើឲ្យនាងឈឺដៃ ទើបក្រឡាស់ខ្លួនដេកផ្កាប់ ពេលគេលោមករក។

"មិនឲ្យថើបទេ មនុស្សឈ្លើយ!"

នាងប្រែខ្លួនគេច តែគិតឬ ថាវិធីនេះអាចគេចផុត។ វ៉ែមសៀ លោទៅទ្រាបពីលើខ្នង លូកដៃទៅក្ដោបដើមទ្រូង។

"អូ! កុំ"

នាងក្រមុំអស់ឱកាសរើបម្រះ ថយក្រោយក៏មិនបាន ព្រោះត្រូវសង្កត់ជាប់ ដើមទ្រូងក៏ត្រូវបាតដៃធំក្រាស់ក្ដោប ហើយការប៉ះពាល់នេះ ធ្វើឲ្យព្រឺសម្បុរខ្វាកៗ ហើយពេលប្រឹងរើ ការកកិតក៏កាន់តែខ្លាំង។

"កុំ វ៉ែមសៀ លែងខ្ញុំ"





Scanned by CamScanner

គេមិនខ្វល់ពីសម្ដីរបស់នាង ហើយក៏ធុញនឹងនិយាយជាមួយមនុស្សនិយាយមិនចេះស្ដាប់គ្នាដែរ។ នាងប្រឆាំងនឹងគេ ធ្វើគ្រប់រឿងឲ្យគេខឹង ដូច្នេះហើយដើម្បីតបស្នងភាពឧស្សាហ៍ព្យាយាមនេះ ម្យ៉ាងទៀត ជាប់នឹងម្រាមដៃនាងខាងស្ដាំ គេក៏លែងក្រែងចិត្តដែរ។

វ៉ែមសៀ ថើបសាច់.កសខ្ចី ហើយពេលនាងរើបម្រះទាល់តែអស់កម្លាំង ទើបចាប់បង្វែរឲ្យដេកផ្ងារ និងមិនឲ្យឱកាសបានប្រសព្វភ្នែកជាមួយ ព្រោះគេឱនទៅថើបមាត់លឿនដូចព្យុះ ហើយរឿងចុងក្រោយដែលនាងគិតឃើញ មុនពេលស្មារតីត្រូវរំខានឲ្យបែកខ្ញែក គឺពាក្យថា ខុសផែនការ។

វ៉ែមសៀ បញ្ជាឲ្យអ្នកបម្រើត្រៀមទឹកក្ដៅឧណ្ហៗ ហើយបីនាងទៅត្រាំនៅក្នុងអាងជាមួយគ្នា ចំណែក ស៊ីឡា និង ហ្វីរ៉ា ពេលធ្វើការរួចរាល់ក៏នាំគ្នាថយចេញពីបន្ទប់ទឹក ដើម្បីទៅរៀបចំពូកខ្នល់ខ្នើយជាថ្មី ព្រោះវាដូចសមរភូមិ។

ការ៉ិន ក្ដាប់ដៃណែនដោយកំហឹង គិតថាអ្នកបម្រើទាំងពីរមុខជាដឹងថាមានអ្វីកើតឡើងនៅក្នុងបន្ទប់ដេក ព្រោះកម្រាលពូកប្រឡាក់ឈាមព្រហ្មចារីជាភស្តុតាងបញ្ជាក់ថានាងត្រូវ វ៉ែមសៀ ប្រមាថ។ នាងខឹងគេណាស់ ហើយក៏ខឹងខ្លួនឯងដែរ ព្រោះត្រូវបទពិសោធរបស់គេល្បួង តែបន្ទោសគេទាំងស្រុងក៏មិនពេញហត់។ នាងនៅចាំបានព្រាលៗថា ខ្លួនឯងព្រមឲ្យគេថើបសព្វសាច់ មិនត្រឹមប៉ុណ្ណឹងនៅអែនទៅរកការប៉ះពាល់ទៀត។ នាងតតាំងតែពេលត្រូវគ្រប់គ្រងដំបូងប៉ុណ្ណោះ ព្រោះឈឺ តែពេលគេធ្វើឲ្យភ្លេចខ្លួន នាងក៏តបស្នងដូចខ្លួនឯងជា



ស្រីក្ដៅគគុក។ ឈុតមង្គលការសាក្សរបស់នាង ធ្វើឲ្យ វ៉ែមសៀ ខឹងសម្បា ហើយវាក៏ធ្វើឲ្យនាងបង់ខ្លួនដែរ។ នាងមិនបានត្រៀមចិត្តទទួលយករឿងនេះទេ តែបានបង់ព្រហ្មចារីឲ្យគេទៅហើយ។

"អ៊ូយ!"

នាងខ្ទានតិចៗ ប្រឹងត្រសុលទៅបៀតនឹងរាងកាយមាំមួន តែពេលនាងកម្រើកខ្លួន គេក៏យកជើងកៀវ ហើយពេលរាងកាយកកិតគ្នា វាក៏ធ្វើឲ្យគេមានអារម្មណ៍ម្ដងទៀត។

មុខរបស់ ការ៉ិន ឡើងក្រហមង៉ាំង មនុស្សឆ្កួតនេះ ធំគ្រប់យ៉ាងតែម្ដងហើយនៅលើខ្លួនប្រាណ។ គេធ្វើឲ្យនាងវិះតែស្លាប់ នាងឈឺ ឈឺខ្លាំងបំផុតតាំងពីកើតមក ទោះបន្ទាប់ពីឈឺចាប់ គេប៉ះប៉ូវ ដោយការធ្វើឲ្យមានសេចក្ដីសុខ តែនាងមិនចង់ចាំពេលដែលមានសេចក្ដីសុខទេ ចាំតែពេលឈឺចាប់ប៉ុណ្ណោះ។

"ត្រកកាម" នាងនិយាយរអ៊ូៗជាការស្ដីបន្ទោស តែគេបានឮ ទើបឱនមកថើបថ្ពាល់រលោងខ្សឹតៗ។

ស្រីស្អាតធ្វើឲ្យមនុស្សប្រុសមានអារម្មណ៍ល្អបានជានិច្ច គេអាចកាត់បន្ថយកំហឹងបាន បន្ទាប់ពីបានរួមដំណេកជាមួយនាង កម្ចាយអារម្មណ៍ក្ដៅគគុកនៅលើរាងកាយទន់ល្មើយទាល់តែរួចរាល់។ ការ៉ិន មិនដឹងខ្វល់អីតែតបស្នងគេបានដោយភាពក្ដៅគគុក។

វ៉ែមសៀ បិទភ្នែក ព្រោះមានច្បាប់សំខាន់ផ្ទាល់ខ្លួន ថាមិនរវីរវល់នឹងស្រីព្រហ្មចារី តែដូចដឹង មនុស្សស្រីនៅក្នុងរង្វង់ដៃ ធ្វើឲ្យគេបំពានច្បាប់នោះ។ គេ



Scanned by CamScanner

ត្រូវកាត់សន្ធះស្មើង ទើបអាចគ្រប់គ្រងនាងបាន វាជាគស្តុតាងបញ្ជាក់ថានាងនៅក្រមុំព្រហ្មចារី ផុរផង់សព្វសាច់។

គេអែនខ្លួងផ្អែកនឹងមាត់រាង មើលទៅដូចស្រួលខ្លួនណាស់ ខុសពីនាងដែលគ្មានអារម្មណ៍ថាស្រួលខ្លួនអីបន្តិច។ នាងមានភាពរឹងទទឹង ចង់យកឈ្នះគេ ចង់កម្ទេចភាពស្រួលខ្លួនរបស់គេ តែខណៈនោះខ្លាចថាគេធ្វើរឿងក្តៅគគុកនោះដាក់នាងទៀត។

"ដេកឲ្យស្ងៀម"

សំឡេងកាចរបស់ វែមសៀ ធ្វើឲ្យនាងបញ្ឈប់សកម្មភាពរាងកាយ តែរំពេចនោះ នាងក៏កាំងនឹងសំណួរដែលផុសនៅក្នុងចិត្ត...ហេតុអីនាងត្រូវស្តាប់បង្គាប់គេ?

វែមសៀ មិនសមនឹងទទួលបានភាពទន់ភ្លន់ គេប្រមាថនាង ឈ្លីយដាក់នាង ញាត់ញៀតឲ្យនាងជាព្រះនាងមេបញ្ជា ទើបនាងត្រូវធ្វើខ្លួនបែបហ្នឹងដើម្បីឲ្យសមនឹងការប្រមាថរបស់គេ។

"ខ្ញុំមិនស្តាប់បង្គាប់លោកទេ"

នាងនិយាយរអ៊ីៗដាក់ខ្លួនឯង ហើយស្ទុះងើបចេញ ដែលគេព្រមឲ្យងើបតែបានមួយភ្លែតប៉ុណ្ណោះ ក៏ត្រូវទាញទៅវិញ។

"រុំ! ប្រុសឆ្កួត! ឈឺ!"

នាងស្រែកឡូឡា ពេលត្រូវទាញទៅបុកនឹងរាងកាយមាំមួន ហើយនាងក៏ជួញទុក្ខដាក់ខ្លួនដែរ មុននេះអង្គុយបែរខ្នងស្រួលបួលសោះ តែពេលត្រូវទាញ



មកវិញបែរជាត្រូវអង្គុយច្រកកៀរលើភ្លៅរឹងមួន។

"មិនព្រម! មិនអង្គុយបែបនេះ!"

វែមសៀ ដកដង្ហើមធំ ធុញទ្រាន់នឹងនាងមែនទែន ទើបមិនតបត តែរុញមុខក្រមុំឲ្យងើយមករក ហើយគេក៏ឱនទៅគ្រប់គ្រងបបូរមាត់ទន់ល្មៀយ។

"ហ៊ឺ! កុំ! មិនថើប!"

នាងងាកមុខចេញ តវ៉ាបានតែមួយម៉ាត់ ក៏ត្រូវគេថើបទៀតឲ្យទាល់តែបាន។ បបូរមាត់របស់នាងមិនអាចគេចពីបបូរមាត់ក្តៅបាន គេគិតតែពីថើប ចង់ថាជាការថើបដាក់ទោសក៏មិនមែន ព្រោះបបូរមាត់ក្តៅគគុកនោះថើបធ្វើឲ្យមាត់របស់នាងក្តៅតាមដែរ។ គេមិនបានថើបខ្លាំងៗ តែការថើបរបស់គេបញ្ជាក់ពីការប្រាថ្នានៅក្នុងខ្លួនរបស់បុរស។

*គេនៅតែត្រូវការនាងអីចឹងឬ?*

នាងគិតដោយការងឿងឆ្ងល់។ ការថើបរបស់គេ ជាការថើបស្រូបយកវិញ្ញាណ ឲ្យនាងត្រសុលទៅបៀតនឹងរាងកាយនន់លគក។

វែមសៀ ក៏ចូលចិត្តវិធីនេះដូចគ្នា មិនចាំបាច់ឈ្លោះគ្នា មិនចាំបាច់ធ្វើឲ្យសរសៃប្រសាទរបស់គេស្ត្រេស ក៏អាចបង្ក្រាបឲ្យនាងលុះក្រោមអំណាចបានទៅហើយ ក្រៅពីនេះខ្លួនប្រាណរបស់នាងក៏ទន់ល្មៀយគួរឲ្យឱបរឹត ភ្លិនខ្លួនក៏ក្រអូបប្រហើរ មិនធុញទ្រាន់។

"វែម...អាំ..." នាងស្រែកថ្ងូរដាក់បបូរមាត់ក្រាស់។

អ្នកកំលោះលើកបីនាងចេញពីអាងទឹក ព្រោះទំហំរាងកាយដែលមិន



ដូចគ្នា មិនអាចឲ្យគេគ្រប់គ្រងនាងនៅក្នុងទឹកបាន វានឹងធ្វើឲ្យនាងឈឺចាប់។ ពេលដាក់នាងលើហត់រាងហើយ ក៏ចាប់ជើងស្រឡូនទាំងពីរ រុញចេញពីគ្នា ត្រសុលចូលទៅជិត គ្រប់គ្រងរាងកាយស្រឡៅស្រឡូន ឲ្យនាងថ្ងូចថ្ងូរ ពេលភ្លើងប្រាថ្នាឆាបឆេះម្តងទៀត។

...

សមហើយដែល រៃមសៀ ហែកឈុតមង្គលការក្លែងក្លាយចោល ហើយពេលនេះនាងក៏នឹកស្អប់វាណាស់ដែរ បន្ទាប់ពីធ្លាប់ចូលចិត្តខ្លាំង ព្រោះ រៃមសៀ មិនព្រមឈប់ខាន គេធ្វើឲ្យនាងហត់នឿយ រាងកាយត្រូវគ្រប់គ្រងឲ្យខ្សោះកម្លាំង តែនោះមិនមែនជាបញ្ហាសម្រាប់គេ នាងលើកដៃលើកជើងមិនរួច មានគេចាំបម្រើ ដោយការលើកជើងស្រឡូនដាក់លើដៃមាំមួនសម្បុរស្រគាំ។

វាំងននត្រូវទម្លាក់ជុំទិសគ្រែទាំងបួន ក្រណាត់ពណ៌ស្លេងឲ្យបរិយាកាសរ៉ូមែនទិក តែនាងបែរជាគ្មានពេលផ្ចិតយកអារម្មណ៍នោះ ព្រោះត្រូវទប់ទល់នឹងភាពក្ដៅគគុក ក្ដៅខ្លាំងបំផុត រាងកាយក៏នៅមិនជាប់ពូក ភ្នែកក៏ស្រវាំង ហើយមានជាច្រើនដងដែលនាងលើកដៃឱបរឹតគេ។

សេចក្ដីសុខដែលទទួលបានពីរាងកាយមាំមួន ធ្វើឲ្យនាងគិតថាខ្លួនឯងទទួលយកលែងបានហើយ ដល់ថ្នាក់ស្រែកសុំក្ដីមេត្តាពីគេ តែ រៃមសៀ នៅតែព្រងើយកន្តើយនឹងសំឡេងថ្ងូចថ្ងូរដោយអស់សភាព ជាងនោះទៅទៀត គេគិតតែបបោសអង្អែល ឲ្យនាងភ្លេតភ្លើនតាម។

"ប្រុសចិត្តខ្មៅ ហ៊ឹ...អ៉ា..."



កាអ៊ីន ស្ដីឲ្យ ហើយស្រវាឱបរាងកាយមាំមួនណែនដៃ ដើមទ្រូងណែនក្បុំនែបនិត្យនឹងដើមទ្រូងរឹងមាំ ដែលពេលនេះវាទាំងរមាស់ ទាំងតឹង ព្រោះគេទាំងបឺតទាំងជញ្ជក់ ប្រដាច់ ញាក់ញី។

"ប្រុសចិត្តខ្មៅ"

នាងទាំងតវ៉ា ទាំងត្អូញត្អែរ ទើប រៃមសៀ ថយចេញឲ្យឆ្ងាយ ដើម្បីងើបអង្គុយ ដោយលើកពនាងមកជាមួយ ឲ្យដាក់ដៃលើស្មាធំទូលាយ។

"ស្វាត់ សុំចូលទៅសិន"

"អាប្រុសឆ្កួត!"

ថ្ពាល់រលោងឡើងក្រហមង៉ាំង។ ហេតុអ្វីនាងត្រូវមកជួបអ្វីបែបនេះដែរ ទោះនាងរឹងទទឹង ប៉ិនងរង៉ក់ ទំនើងតិចតួច តែបានធ្វើអំពើល្អមិនតិចទេ ហេតុអីព្រះជាម្ចាស់បញ្ជូនមនុស្សប្រុសឈ្មោះថា រៃមសៀ ដាវ៉ែហ៊ីណេស មកឲ្យនាងទប់ទល់ឡើងជាំសាច់បែបនេះដែរ។

"ហើយព្រមឲ្យចូលទេ"

រាងកាយរបស់នាង គេត្រួតពិនិត្យគ្រប់កន្ទុកកន្លៀតទៅហើយ តែវត្ថុស្រទន់ឡើងតឃ្លើន គ្រគាកមូលភ្លុំក៏ប្រឹងអែនមករក ម៉េចក៏គេមិនដឹង ថានាងកំពុងវេទនាដោយអារម្មណ៍រញ្ជួយ។

"ម៉េចមិនចូលម៉ោ សួរធ្វើអី"

កាអ៊ីន និយាយដោយសំឡេងក្ងួរ ពើងទ្រូងដាក់ដោយភាពក្រអឺតក្រទម ទើបត្រូវគេថើបថ្ពាល់ខ្សឹតៗ ព្រោះភ្ញាញ់ ហើយគ្រប់គ្រង។





Scanned by CamScanner

"ហ៊ឺ!"

ពេលប្រកែកមិនបាន នាងក៏ថ្ងូចថ្ងូរតិចៗ ទើប វ៉េមសៀ អង្រួលខ្លួនជួយលួងលោម សង្កត់ក្បាលក្តោបដោយសក់រលោងនឹងប្រឡោះករឹងមាំ។ ពេលបានឱបក្រសោបបែបនេះ ឲ្យអារម្មណ៍ថារាងកាយរបស់នាងកាន់តែតូច តែគេហាមខ្លួនឯងមិនឲ្យធ្ងន់ដៃដាក់នាងមិនបាន។

ពេលដែលអារម្មណ៍ឡើងដល់ចំណុចពុះ គេគ្រប់គ្រងខ្លួនឯងមិនបានហើយ ការ៉ិន ជាមនុស្សស្រីដំបូងដែលធ្វើឲ្យការគ្រប់គ្រងខ្លួនឯងរបស់គេមានបញ្ហា។ គេគួរឲ្យនាងសម្រាក តែរាងកាយរបស់គេដង្ហោយរករាងកាយរបស់នាងមិនឈប់ឈរ ដូច្នេះហើយនាងត្រូវទទួលភាពក្តៅគគុកពីគេ យ៉ាងហោចណាស់គឺអាចដល់ព្រឹក។

វ៉េមសៀ គណនាចំនួនដែលលេបត្របាក់នាង តែវាមិនទាន់សមចិត្តបើយ៉ាងហោចណាស់ដល់ព្រឹក អីចឹងយ៉ាងច្រើនតើដល់ណាទៅ...គេចង់នៅលើគ្រែជាមួយនាងបីថ្ងៃបីយប់ជាប់គ្នា។

គេធុញទ្រាន់ស្រីកំណាន់អស់នោះហើយ មិនចង់បានអ្នកណាទៀតទេ ទោះរាងកាយត្រូវការក៏ដោយ តែមិនចង់នៅជិតស្រីៗទាំងនោះ។ គឺដូចពេលឃ្លាន ដឹងថាក្រពះត្រូវការ ប៉ុន្តែមិនដឹងថាចង់ទទួលទានអាហារអ្វីជាពិសេស ឃើញអាហារនៅលើតុក៏ទ្រលាន់។ ខុសពីព្រះនាងឆ្មាស នាងជាអាហារកំពូលរសជាតិ ដែលគេយកមកទទួលទាន ហើយមិនគិតថារសជាតិរបស់នាងធ្វើឲ្យគេឈ្លក់វង្វេងបែបនេះទេ។ ជាមនុស្សស្រីដូចគ្នា តែឲ្យអារម្មណ៍ខុសគ្នា។



ការ៉ិន ត្រូវទាញចូលមកក្នុងរង្វង់ដៃមាំមួន ពេលដែល វ៉េមសៀ មានតម្រូវការខ្លាំង និងមិនទាន់បានកម្ចាយ។

"ហ៊ឺ...អ៊ា...ឈឺ..."

ព្រះនាងឆ្មាសថ្ងូចថ្ងូរគួរឲ្យអាណិត នាងឈឺចាប់ ព្រោះត្រូវលេបត្របាក់មិនឲ្យរាងកាយគ្មានបទពិសោធរបស់នាងបានសម្រាក តែការឈឺចាប់ដែលទទួលបាននេះ វាលាយឡំដោយភាពរញ្ជួយ ដែលនាងមិនអាចតតាំងបាន ទើបត្រូវ វ៉េមសៀ ចាប់លើកត្រគាក ព្រោះនាងខ្សោះកម្លាំង ដល់ថ្នាក់លើកវាមកទទួលយកគេមិនបាន។

អ្នកកំលោះឈ្ងុលមុខនឹងប្រឡោះកក្រអូប បឺតជញ្ជក់សាច់ត្រង់នោះខ្លាំងៗ តែនាងមិនបានចាប់អារម្មណ៍ការបឺតជញ្ជក់នោះ ព្រោះកំពុងតែវិលខ្វាល់ក្នុងព្យុះសង្ឃ្រា ហើយនាងត្រូវការឲ្យគេគ្រប់គ្រងលឿនជាងនេះ ខ្លាំងជាងនេះ។

"វ៉េ...វ៉េម...ក"

នាងនិយាយមិនចេះជាភាសា តែគេមិនបានចាប់អារម្មណ៍ទេថានាងចង់និយាយអី ក្រៅពីលើកត្រគាកមូលក្លំឲ្យខ្ពស់ និងលុតជង្គង់ ទម្លាក់ទម្ងន់ខ្លួនទៅលើគ្រែ ហើយគ្រប់គ្រងរាងកាយស្រឡៅស្រឡូន ឲ្យម្ចាស់វាដកដង្ហើមដង្ហក់ និងប្រឹងត្រសុលមករកគេ បន្ទាប់មករាងកាយក៏កន្ត្រាក់ខ្លាំង ពេលសេចក្តីសុខធ្វើដំណើរទៅដល់គោលដៅ។

នាងស្រែកថ្ងូចថ្ងូរដោយមិនខ្មាសអៀន ដែលគេជឿថាពេលមានស្មារតីនាងមុខជាស្រែកច្រៀតៗ ឆ្មាសឆ្មាសដាក់មិនខាន តែគេមិនទាន់ចង់គិតដល់



វេលានោះ ព្រោះពេលនេះត្រូវនាំខ្លួនឯងទៅតាមនាងឲ្យទាន់ និងបណ្ដោយឲ្យខ្លួនឯងវង្វេងវង្វាន់ក្នុងពិភពក្ដៅគគុករបស់នាង ដោយមិនការពារ តាំងពីបានគ្រប់គ្រងនាងលើកដំបូងរហូតមកដល់ពេលនេះ មិនដូចពេលឡើងគ្រែជាមួយស្រីកំណាន់ទាំងឡាយ ដែលគេត្រូវការពារខ្លួនឯងដោយការប្រុងប្រយ័ត្ន។

*ហ្គារីឡា ឬ?*

អ្វីដំបូងដែល ការ៉ុន ឃើញពេលបើកភ្នែកឡើង គឺរោមទន់ៗលម្អស្បែក និងមិនទាន់បានភ្ញាក់ពេញភ្នែកផង ពេលដាក់ដៃលើដើមទ្រូងដែលមានសាច់ដុំទឹករលកគួរឲ្យល្អក់វង្វេង ទើបនឹកឃើញថានេះមិនមែនហ្គារីឡា តែជាដើមទ្រូងរបស់ រ៉ែមសៀ ដាវ៉ៃហ៊ីណេស ស្វាមីថ្មោងថ្មីដែលបានកាលពីយប់មិញ។

ទោះពេញចិត្ត ឬមិនពេញចិត្ត ក៏នាងមិនអាចហៅពេលវេលានោះមកវិញបានដែរ ហើយរឿងបែបនេះ ទោះយ៉ាងណាក៏ត្រូវតែកើតឡើង ព្រោះនាងត្រូវរៀបការជាមួយគេ ទើបគ្មានអារម្មណ៍ថាខូចចិត្ត ឬសោកស្ដាយ តែនាងមានអារម្មណ៍អាម៉ាស់មុខដែលភ្លើតភ្លើនដោយសារការប៉ះពាល់របស់គេ។

រ៉ែមសៀ មុខជាបានចិត្ត និងគិតថានាងល្ងក់វង្វេងនឹងសេស្នេហារបស់គេ ហើយអាចយករឿងនោះមកនិយាយឲ្យនាងអាម៉ាស់មុខ ក្រៅពីញាត់ញៀតនាងជាព្រះនាងឆ្មាសឆ្មើមហើយ អាចញាត់ញៀតឲ្យនាងជាព្រះនាងត្រេកកាមទៀតក៏ជាបាន។

*នាងនឹងកាត់អណ្ដាតគេ!*



ការ៉ុន គិតទុកមុន ហើយបើគេនិយាយមែន នាងនឹងកាត់អណ្ដាតរបស់គេដោយមិនរារែក ហើយពេលនេះបញ្ជាឲ្យក្រចកស្អាតខ្វាំដើមទ្រូងហាប់ណែនតែដៃចង្រៃបែរជាស្ទាបអង្អែលទៅវិញ។

ដើមទ្រូងរបស់ រ៉ែមសៀ ធំណាស់ អាចធំជាងដើមទ្រូងមនុស្សស្រីមួយចំនួនទៅទៀត សំណាងល្អដែលនាងបានពីម្ដាយមកច្រើន ទើបមិនខ្មាសមួយទៀតរឿងមានដើមទ្រូងតូចជាងបុរសដែលមានឈ្មោះថា រ៉ែមសៀ ដែលបើត្រូវចំអន់មែន នាងសុំទៅស្លាប់ល្អជាង ព្រោះត្រូវខ្មាសគេម្ដងហើយម្ដងទៀត អ្ហ៎! ពេលនេះ ក្រៅពីអាម៉ាស់មុខហើយនៅបង់ខ្លួនឲ្យគេទៀត ហើយមិនបានបង់ខ្លួនធម្មតាៗ តែហៅបានថាជាការបង់ខ្លួបបែបម៉ាក៉ាតុង។

នាងធ្លាប់ឮខ្លះដែរ ថាលើកដំបូងរបស់មនុស្សស្រីត្រូវតែឈឺខ្លាំង ហើយនាងក៏ឈឺស្ទើរដាច់ខ្យល់ សឹងសន្លប់ម្ដងៗ។ បើគេមិនតំរាម នាងមុខជាស្រែកហាក់ដូចត្រូវអារ.កបាត់ទៅហើយ តែនាងរកឃើញភាពអស្ចារ្យដែលគេបង្រៀនសេចក្ដីសុខនៃការបាននៅជិតគ្នារវាងមនុស្សប្រុសស្រី វាឲ្យអារម្មណ៍ប្លែកៗ។

ព្រះនាងឆ្មាសឆ្មើមតិតបណ្ដើរ អង្អែលដើមទ្រូងបុរសបណ្ដើរ គិតដោយភាពភ្លើតភ្លើន អង្អែលដោយភាពភ្លើតភ្លើន ដោយមិនបានដឹងទេថាម្ចាស់ទ្រូងបានបើកភ្នែកមើលតាំងពីពេលដែលនាងប្រែខ្លួនម្ល៉េះ។ រ៉ែមសៀ មានជីវិតជាអ្នកចម្បាំង ប្រសាទសម្ផស្សរបស់គេរហ័សរហួន និងរវាសរវៃ មិនថាពេលភ្ញាក់ ឬពេលដេកលក់ ដូច្នេះហើយទើបការដេកលក់ស្កប់ស្កល់ មិនធ្លាប់កើតឡើងចំពោះជីវិតរបស់គេ តាំងពីចូលហ្វឹកហាត់កងទ័ព។



"ភ្លៀងធ្លាក់ឬ"

នាងដកភ្នែកចេញពីដើមទ្រូងមាំមួន ហើយប្រែខ្លួនដោយការប្រុងប្រយ័ត្ន ដើម្បីមើលទៅក្រៅបង្អួច ពេលនោះ វៃមសៀ ក៏លើកដៃដាក់លើខ្លួនរបស់នាង ចំណែកកំពេបមាត់ ចងចិញ្ចើម ដោយសារអាការៈឈឺសង្កៀរសព្វសាច់ ប៉ុន្តែពេលគិតដល់ពេលវេលានៃភាពក្តៅគគុក ដែលទើបតែកន្លងផុតទៅ មិនទាន់បានមួយម៉ោងស្រួលបួលផង ទើបគ្មានហេតុផលអីត្រូវឆ្ងល់ច្រើន។

គឺវាសមហើយដែលត្រូវឈឺ!

នាងងើយមើលមុខគេ ហើយពេលឃើញថាភ្នែកបិទជិត ទើបលួចដេរ។

"ឃោរឃៅ"

នាងយកក្បាលរុកនឹងក្រោមចង្ការបស់គេតិចៗ និងឲ្យលក្បាលទៅរករង្វង់ដៃមាំមួន និងកក់ក្តៅ ព្រោះអាកាសធាតុពេលព្រឹកព្រលឹមនៅរងា ហើយពេលគេរឹតរង្វង់ដៃ ឲ្យរាងកាយកាន់តែនៃបនិត្យត្នា នាងក៏គិតថាគេខិតមករកព្រោះត្រូវការប្រែខ្លួន ពេលដេកលក់ប៉ុណ្ណោះ។

នាងដេកមើលភ្លៀង នៅក្នុងរង្វង់ដៃរបស់គេបានមួយសន្ទុះក៏លង់លក់ព្រោះរាងកាយហត់នឿយខ្លាំង និងត្រូវការសម្រាក ហើយពេលនោះឯង ទើបម្ចាស់រង្វង់បើកភ្នែក និងរង្កែលចិញ្ចៀនជាប់ម្រាមដៃនាងខាងស្តាំរបស់នាង។

"បើពេលភ្ញាក់មិនល្បីល្បើដូចពេលដេកលក់ក៏ល្អ"

គេថើបសៀតផ្ការបស់នាង តែប្រហែលសង្កត់បបូរមាត់ធ្ងន់ពេក ទើប



នាងតវ៉ាទាំងមិនបើកភ្នែក។ គេមិនធ្លាប់ភ្ញាក់ផ្អើមអ្វីទេ គេមានជីវិតរស់នៅបានដោយភាពរឹងមាំ និងចិត្តគំនិតត្រជាក់ស្រេងដូចទឹកកកតំបន់ប៉ូល ហើយក៏មិនធ្លាប់ចូលចិត្តចរិតរបស់ព្រះនាងឆ្មាស តែពេញចិត្តរាងកាយស្រឡៅស្រឡូនបន្ទាប់ពីគិតថានាងផុយស្រួយ មិនគួរណាទប់ទល់នឹងតម្រូវការរបស់គេបានតែពេលនេះដឹងហើយថាគេគិតខុស ព្រោះ ការ៉ុន ជាមនុស្សស្រីតែម្នាក់គត់ ធ្វើឲ្យគេស្កប់ស្កល់ចំពោះនាង ដោយមិនធ្លាប់មានស្រីណាធ្វើបាន តែខណៈដែលស្កប់ស្កល់នោះ វាមានការប្រាថ្នាក្តៅគគុករង់ចាំ។

វៃមសៀ មិនបានដេកទៀតបន្ទាប់ពីនោះ គេសម្លឹងឱបនាង ហើយពេលនាងប្រែខ្លួនមករក ក៏ជួយទាញ ឲ្យមកជ្រប់នឹងលង្វែកទ្រូងរបស់ខ្លួន។ គេមានពេលឱបនាងមិនច្រើនទេ ព្រោះត្រូវដំណើរទៅកាន់ក្រុងសេនជីរ៉ក ទើបចុះពីគ្រែទៅងូតទឹក ហើយស្លៀកពាក់ ដើរមករកគ្រែវិញ មើលអ្នកដែលកំពុងលង់លក់នៅលើស្រួល។

ឈុតមង្គលការមេបញ្ជា ដែលធ្វើឲ្យគេបាត់បង់ភាពម្ចាស់ការ គេបានបញ្ជាឲ្យ ស៊ីឡា និង ហ្វ៊ីរ៉ា កម្ចាត់វាចោល ដើម្បីបង្ការ ការ៉ុន ពាក់វាទៀត។ គេហែកវាចោលក៏ពិតមែន តែនាងក៏រឹងណាស់ដែរ អាចបញ្ជាឲ្យកែកុនវាឡើងវិញ ហើយយកមកពាក់ញ៉ោះគេទៀត ទើបការកម្ចាត់វាចោល ជាជម្រើសល្អបំផុតសម្រាប់គេ។ គេមិនត្រូវការឃើញវាទៀត ព្រោះវានឹងធ្វើឲ្យគេឆ្កួត។

"វៃមសៀ មនុស្សអន់ចរិត" នាងនិយាយរអ៊ូៗ តែម្ចាស់ឈ្មោះព្ញាស់។

*សូម្បីតែពេលដេកលក់ នាងនៅយល់សប្តិឃើញគេ និងផ្តាសាទៀតឬ?*



វែមសៀ បែរខ្លួន ដើរចេញពីបន្ទប់ដេក ដោយគ្មានអារម្មណ៍ដឹងខុសអ្វី បន្តិចដែលគ្រប់គ្រងនាងមុនរៀបការ ទោះយ៉ាងណានាងជារបស់គេស្រាប់ទៅហើយ ជួនកាលវាអាចធ្វើឲ្យនាងស្ដាប់បង្គាប់គេក៏ជាបាន។

"សង្សៀសេព្វសាច់" ការ៉ុន និយាយរឿៗ ដោយប្រយោគដដែលៗ។

នាងធ្លាក់ពីដំណេកនៅលើគ្រែតែម្នាក់ឯង និងហៅ ស៊ីឡា និង ហ្វ៊ីរ៉ា មកជួយគ្រាហ៍ទៅដេកត្រាំទឹកក្ដៅឧណ្ហាៗក្នុងអាងទឹក។ ទោះអ្នកបម្រើមិននិយាយក៏នាងនៅតែខ្មាស តែត្រូវធ្វើដូចគ្មានអ្វីកើតឡើង។

នាងងូតទឹក តែងខ្លួនដោយអារម្មណ៍វេទនា ពេលរួចរាល់ក៏មកដេកលើសាឡុងវែង។

"ព្រះនាងសោយក្រយាសម្រន់ទេ ?"

"មិនសោយ"

"ឬសោយភេសជ្ជៈក្ដៅៗទេ ?"

"មិនសោយ"

សំណើរបស់ ស៊ីឡា ត្រូវបដិសេធ ព្រោះព្រះនាងមិននឹកចង់ទទួនទានអ្វីទាំងអស់ នាងចង់ដេកស្ងៀមៗ មិនត្រូវការកម្រើកខ្លួន។

"ឈុតរបស់ខ្ញុំទៅណា ?"

"ឈុតស្អីទៅ ព្រះនាង ?"

"ឈុតមង្គលការភ្លែងក្លាយដែលខ្ញុំពាក់ពីម្សិល"



"លោកឧត្ដមសេនីយ វែមសៀ បញ្ជាឲ្យដុតចោលហើយ"

"ស្អីគេ !"

ហេតុអីគេហ៊ានបញ្ជាឲ្យដុតខោអាវរបស់នាង នាងមិនបានគិតថាពាក់វានៅថ្ងៃសំខាន់ឯណា...វែមសៀ ប្រុសសាហាវ។

"ដុតហើយនៅ ?"

"ដុតហើយ លោកឧត្ដមសេនីយទៅមើលដោយផ្ទាល់ អីចឹងហើយ មិនដុតគឺមិនបានទេ"

"ឆ្កួតមែន"

នាងធ្វើមុខខ្មូរ ព្រោះចាញ់គេទៀតហើយ ដែលជាការចាញ់អស់ពីខ្លួន ចាញ់ដោយមិននៅសល់អ្វី ចាញ់ប្រភេទដែលមិនទាន់ដឹងទេថាពេលជួបមុខគេហើយ នាងនឹងធ្វើមុខយ៉ាងណា។

"ចេញទៅចុះ ខ្ញុំសម្រាក"

"ព្រះម៉ែ"

ការ៉ុន ផ្ដេកខ្លួនទៅលើសាឡុងដោយការប្រុងប្រយ័ត្ន សម្លឹងបើលទៅសួននៅខាងក្រៅ ហើយពេលនៅម្នាក់ឯង ក៏អត់មិនបាននឹងខឹង វែមសៀ ដែលបង្ហាញឲ្យឃើញនៅចំពោះមុខអ្នកបម្រើ។ ថ្ពាល់របស់នាងក្ដៅភាយៗ ពេលនឹកដល់គេ ទើបជ្រប់មុខនឹងខ្នើយផ្អែក គេដែលមិនត្រឹមតែជាគូបម្រុងការ តែគេជាស្វាមីមិនទាន់ពេញច្បាប់។



## ៨

### ដាក់ទោស

"ម៉ោធ្វើអី ?"

រែមសៀ ធ្វើមុខក្រមូវ មើលមនុស្សស្រីដែលលើកដៃចង្អុលមុខរបស់គេ មនុស្សស្រីពាក់ឈុតស មានសម្រង់វែង ជាឈុតធម្មតា តែមានភាពប្រណីត ព្រោះនាងជាព្រះនាង ការិន នៃរាជវង្ស ម៉ាលខៃសេន មានស្បែស្តើងដណ្ដប់ ស្នាតែឲ្យភាពកក់ក្ដៅមានពណ៌ដូចគ្នានឹងភួយដែលគ្របលើខ្លួន។

"ត្រឡប់ម៉ោផ្ទះ"

នាងក្រមុំចងចិញ្ចើមគិត...ត្រឡប់ម៉ោផ្ទះ ហើយហេតុអីបានជាម៉ោទីនេះ ទីនេះជាដំណាក់របស់នាង មិនមែនប្រាសាទគ្រេវីត្រយ របស់គេឯណា។

"ទីនេះផ្ទះរបស់លោកឬ ?" នាងសួរដោយការសង្ស័យ តែគេមិនឆ្លើយ ថែមទាំងដើរមករកហើយស្រវាទាញនាងទៅជិតទើបនាងពើងទ្រូងដាក់។

ការដែលត្រូវធ្វើក្រទេិដាក់ព្រោះនៅងរដែលគេទុកនាងចោលនៅលើគ្រែ ប្រើប្រាស់រាងកាយរបស់នាងរួចហើយ ក៏បាត់ខ្លួនបាត់ក្បាលអស់រយៈពេលបីថ្ងៃ ទើបលេចមកឲ្យឃើញ។

*នេះកំពុងរណ៉ា!*



"ប្ដីប្រពន្ធ ត្រូវនៅផ្ទះជាមួយគ្នា"

"ប្រុសឆ្កួត! អ្នកណាជាប្រពន្ធលោក!"

នាងគួរខឹង ឬអៀនគេទើបល្អទៅ ហើយបើគេព្រងើយកន្តើយចំពោះហេតុការណ៍ដែលកើតឡើង នាងមុខជាមិនពេញចិត្ត តែពេលគេប្រកាសក្តែងៗបែបនេះ នាងអៀនហើយក៏ខឹងតិចតួចដែរ។

"អ្នកដែលថ្នូរខ្នងដំណាក់កាលពីបីយប់មុន"

"ខ្ញុំថ្នូរឬ ?"

"សួរ ស៊ីឡា និង ហ្វ៊ីភ៉ា ទៅ"

"មនុស្សពាល!"

នាងជេរគេជាមនុស្សឆ្កួតឡើងពុញទៅហើយ ទើបជេរថាជាមនុស្សពាលម្តង។ ជាអ្នកគ្រប់គ្រងក្រុងអាឡិចសានឌេតែបែរជាមិនចេះដឹងរឿងមារយាទក្នុងសង្គម សង្គមរបស់នាងតែម្នាក់គត់ព្រោះសង្គមផ្សេង គេមានមារយាទ។

"និយាយស្តីដាក់ប្តីឲ្យល្អបន្តិច ខ្លារិហ្សា"

"ចង់និយាយល្អចង់ងាប់ហើយ អាងអីស្ដីឲ្យៗ ស្មានថាខ្លាចក៏អី"

នាងដាក់ដៃលើដើមទ្រូងធំទូលាយ ប្រឹងរុញចេញដូចអ្នកលេងមាឌល្អិតដែលមិនស្គាល់អ្នកគ្រប់គ្រងទឹកដី និងចង់សាករបស់ខ្លាំង ទើបឡុងខ្ចាតខ្លួនឯង តែត្រូវគេលូកដៃទៅឱបង្កេះ ទាញនាងមកជិត។

"ល្ងង់ណាស់"





Scanned by CamScanner

"រ៉េមសៀ ដាវ៉ៃហ៊ីណេស"

អ្នកកំលោះចង់ចិញ្ចើម ព្រោះសំឡេងច្រៀងរបស់នាងមិនចម្រើនត្រចៀក ហើយបើជ្រើសរើសបាន គេចូលចិត្តសំឡេងពេលនាងថ្ងូរ ដោយការប្រាថ្នា ដែលគេផ្តាប់ផ្ទុន។

"លោកដេរថាខ្ញុំល្ងង់ឬ?"

"បាទ"

កាអ៊ិន គក់ដើមទ្រូងរឹងមាំ ហើយធ្វើមុខខ្វរ ព្រោះគេមិនឈឺ តែនាងឈឺខ្លួនឯង។ នាងតែងតែភ្លេចខ្លួនគ្រប់ពេលដែលខឹង ទាំងដែលធ្លាប់គក់ច្រើនដង ហើយនឹងដឹងលទ្ធផលច្បាស់។

"លែង កុំមកប៉ះពាល់ខ្លួនខ្ញុំ!"

រ៉េមសៀ ចង់ដកដង្ហើមធំឲ្យឮខ្លាំងៗ ព្រោះគេធ្វើលើសពីប៉ះពាល់ទៅទៀត នាងនៅបិទភ្នែកបិទត្រចៀក ហួងហែងខ្លួនប្រាណទៅទៀត តើមានអ្វីនៅលើខ្លួនប្រាណមួយនេះដែលគេមិនបានដឹងរសដោយមាត់ អង្អែលដោយដៃ ហើយតាមដែលគិតឃើញគឺគ្មានទេ។

"ឈប់ល្ងិល្ងើទៅ ខ្លារីហ្សា ខ្ញុំហាត់"

គេលើកបីនាង ដែលដូចទេពធីតាពេលមិនហាមាត់តវ៉ា មុខមាត់ស្អាតមើលមិនចេះជិនណាយ នាងរូបល្អតល្ងន់ គួរឲ្យថ្នាក់ថ្នម ហើយបើរាចដេរមាត់នាងបានគេប្រហែលធ្វើបាត់ហើយ។

"ទៅធ្វើអីម៉ោ ទើបហាត់"



"ស៊ីនាងពេញមួយយប់ហើយនៅទៅធ្វើការបន្តទាល់តែដល់ថ្ងៃនេះ"

នាងស្អប់ភាពគ្រង់ដូចបន្ទាត់របស់គេមែនទែន ទើបគក់ស្មាមាំមួនដែលទើបតែគក់អម្បាញ់មិញ នាងឈឺតែគេមិនឈឺ។

*ស្រីល្ងង់ ខ្លារីហ្សា!*

នាងល្ងង់ដូច រ៉េមសៀ ថាឲ្យមែនហ្នឹង តែអ្ហ៎! ហេតុអីនាងត្រូវព្រមទទួលស្គាល់ថាខ្លួនឯងល្ងង់ដែរ នាងត្រូវតតាំងទើបត្រូវ។

"ហើយទៅណា មិនឃើញមុខច្រើនថ្ងៃ អ្ហ៎! ដែលសួរនេះមិនបានចាប់អារម្មណ៍អីទេ គ្រាន់តែសង្ស័យតិចតួច តិចតួចពិតមែន"

ពេលត្រូវមើលមុខ នាងក៏ពើងទ្រូងបន្តិចដាក់ ដែលធ្វើឲ្យគេចង់ដាក់ទោសឲ្យឈ្លោកមុខចុះបន្តិច។ បង្រ្កាបពួកក្បត់ក៏រវល់សឹងស្លាប់ទៅហើយ ត្រូវចំណាយពេលបង្រ្កាបប្រពន្ធឆ្នាសទៀត ប៉ះខ្លាំងក៏មិនបាន ក្បាលនឹងរបូតពីស្មា ព្រោះនាងប្អូនស្រីសំណព្វរបស់ប្រមុខប្រទេស ព្រះអង្គម្ចាស់ ខាឡូម៉ាន់។

គិតថាខ្លួនស្អាត ទើបពើងទ្រូងដាក់ប្តី ព្រឹកឡើងសៀលពើង ល្ងាចពើង ខ្លួនប្រាណនេះគិតថាធ្វើពីមាស ប៉ះពាល់តិចតួចក៏ស្រែកចេចចាច មានប្រពន្ធដូចមានម៉ែ ល្វើយចិត្ត!

"ទៅសេនដឹងរ៉ែត ថ្ងៃនេះត្រូវមកជួបព្រះអង្គម្ចាស់ ខាឡូម៉ាន់"

"ទើបធៀងមកដេកទីនេះឬ?"

"អ្ហឹម"

"បាត់ទុកទីនេះជាសណ្ឋាគារឬក៏អី"



នាងសម្លក់សម្លឹងគេដោយខ្សែភ្នែកឆ្មាសឆ្មើម ទើប រ៉ែមសៀ កម្ចាត់ភាពគួរឲ្យពុញទ្រាន់នេះដោយការចាប់កញ្ចឹង.ក របស់នាង សង្កត់មករក។

"ហ៊ឺ! អឺ..."

នាងនិយាយមិនចប់ប្រយោគផង ក៏ត្រូវឧត្តមសេនីយក្រេកកាមចាប់ថើបបបូរមាត់ក្តៅរបស់គេ គឺហាក់ដូចមានវេទមន្ត ហើយពេលហាមាត់ដើម្បីតវ៉ា តេក៏ជ្រែកអណ្តាតចូលមកក្នុងប្រអប់មាត់ រឹតរួតអណ្តាតរបស់នាងឲ្យភ្នែកអស់ការតតាំង រាងកាយហាក់ដូចសាំនឹងការប៉ះពាល់របស់គេ និងត្រូវគេបឺបណ្តើរថើបបណ្តើរដោយមិនខ្មាស់ខ្សែភ្នែកអ្នកបម្រើ។

រ៉ែមសៀ បិព្រះនាងឆ្មាសចូលទៅបន្ទប់ដេក ដោយនៅតែឱបរឹតនាងជាប់ទ្រូង ថើបបបូរមាត់ក្រពុំមិនព្រមលែង ព្រោះពេលបានថើបហើយ គឺគេមិនអាចបញ្ឈប់ខ្លួនឯងបានបបូរមាត់របស់នាងផ្អែមល្ហែមនិងថើបទាល់តែពេញចិត្ត ទើបដកបបូរមាត់ចេញ។

កាអ៊ិន ឈ្មុលមុខនឹងប្រឡោះករឹងមាំលើកដៃឱបគេ ដកដង្ហើមដង្ហក់ព្រោះត្រូវថើបយូរពេក ទម្រាំតែគេឈប់ថើប នាងសឹងតែដាច់ខ្យល់ស្លាប់ ហើយបើត្រូវថើបយូរជាងនេះតែមួយវិនាទីទៀត មុខបានដាច់ខ្យល់មែនទែនហើយ។

"ព្រះនាង ឈុតនេះយកមកទុកក្នុងបន្ទប់តែងខ្លួន"

អ្នកបម្រើដែលត្រូវបញ្ជាឲ្យយកឈុតមង្គលការ ដែលមុននេះត្រូវយកទៅលាក់នៅបន្ទប់ផ្សេង ឱបវាចូលមកក្នុងបន្ទប់ដេក។

"សូមអភ័យទោសលោកឧត្តមសេនិយ ព្រះនាង"



អ្នកបម្រើប្រញាប់លុតជង្គង់ភ្លាម។

រ៉ែមសៀ មើលឈុតពណ៌ស ដែលម៉ូតរបស់វាបញ្ជាក់ច្បាស់ថាជាឈុតមង្គលការ ហើយឈ្ងោកមើលអ្នកដែលសម្ងំនៅក្នុងរង្វង់ដៃ ដែល កាអ៊ិន ធ្វើមុខខ្វារ។

"ឈុតអី ?"

"ឈុតមង្គលការរបស់ព្រះនាង"

រ៉ែមសៀ ងក់ក្បាលឲ្យអ្នកបម្រើយកឈុតនោះទៅទុកដាក់ក្នុងបន្ទប់តែងខ្លួន ហើយពេលអ្នកបម្រើចេញទៅបាត់ ទើបគេដើរទៅអង្គុយលើសាឡុងដោយដាក់នាងឲ្យអង្គុយលើភ្លៅ។

"ឈុតថ្មី ?"

នាងក្រមុំខ្ទឹបបបូរមាត់ ដែលម្ចាស់ភ្លៅមើលឃើញភាពមិនប្រក្រតីនេះតែគេរង់ចាំចម្លើយពីនាង។

"ឈុតមង្គលការពិត ? មានន័យថាមានឈុតមង្គលការក្លែងក្លាយ"

"មិនចំទេ"

កាអ៊ិន ក្លាយជាជនដែលត្រូវស្ងៀមចម្លើយ ហេតុអ្វីនាងត្រូវមកជួបនឹងអ្វីបែបនេះដែរ តែពេលប្រសព្វភ្នែកនឹងគេ ក៏ដឹងហើយថាមិនអាចកុហកបាននាងស៊ូនឹងកម្លាំងរបស់គេមិនបាន ហើយបើគេដឹងនៅពេលក្រោយនាងនឹងរងគ្រោះដំណាក់កាលធ្ងន់ធ្ងរបាន។

ប្រុសឃោរឃៅធ្វើស្អីនាងខ្លះក៏មិនដឹង អីចឹងហើយ សុខចិត្តសារភាព



ការពិតនៅពេលនេះល្អជាង។

"នៅញញឹមបាន"

រ៉េមសៀ កំពុងសន្ទនាជាមួយព្រះអង្គម្ចាស់ បន្ទាប់ពីត្រូវបានអញ្ជើញឲ្យមកចូលរួមទទួលទានអាហារជាមួយ។ ខាឡូម៉ាន់ មានមោទនភាពនឹងភាពឆ្លាសឆ្លៀមរបស់ប្អូនស្រីសំណព្វ ខណៈដែលគេត្រូវចងចិញ្ចើម លើកប្រាន់ឌីធីកមិនយល់ពីគំនិតរបស់នាង។

"ខ្លារិហ្សា គ្រាន់តែញ៉ោះឯងតិចតួច"

"ម៉ោពីឯងមិនទាន់ឃើញល្បិចឆ្លូតនោះ"

ពួកគេសន្ទនាគ្នាបែបមិត្តភក្តិ ព្រោះពេលនេះនៅក្នុងបន្ទប់ទទួលភ្ញៀវផ្ទាល់ខ្លួន។

"តែឯងដាក់ទោសនាងរួចហើយ" ខាឡូម៉ាន់ ត្បកដោយសំឡេងរាបស្មើ ព្រោះបានដឹងពីទំនាក់ទំនងរវាងកំលោះក្រមុំថា ទៅដល់ណាដល់ណាហើយ។

"សមតែត្រូវ"

"ឯងកំពុងនិយាយពីប្អូនស្រីជាទីស្រឡាញ់របស់ខ្ញុំ"

"ពេលនេះនាងជាប្រពន្ធរបស់ខ្ញុំ" រ៉េមសៀ ត្បកទៅវិញបានពេញពាក្យពេញមាត់។

ខាឡូម៉ាន់ លើកប្រាន់ឌីជិប។ ទ្រង់ដឹងចំណុចខ្លាំង ចំណុចខ្សោយរបស់រ៉េមសៀ ច្បាស់។ មិត្តម្នាក់នេះជាបុរសដែលហួងហែងសម្បត្តិផ្ទាល់ខ្លួនណាស់



ដែលប្រពន្ធក៏ត្រូវចាត់ចូលជាសម្បត្តិមួយប្រភេទរបស់បុរស សាក់ខាឡៀ។

"ឯងហ៊ាននិយាយពីប្អូនស្រីខ្ញុំបែបនេះឬ រ៉េមសៀ"

"នាងជាប្រពន្ធខ្ញុំ" រ៉េមសៀ បញ្ជាក់ដោយមិនញញើត។

"ថែរក្សាគ្នាឲ្យបានល្អ"

"បើមិនទុកចិត្តខ្ញុំក៏មិនលើកប្អូនស្រីឲ្យខ្ញុំដែរ មែនទេ"

"ឯងយល់ខុសហើយ រ៉េមសៀ"

"ខ្ញុំយល់ត្រូវទៅវិញទេ"

រ៉េមសៀ នៅតែភ្ញាក់ព្រះនាងឆ្លាសមិនទាន់បាត់។ គេចាប់នាងសង្កត់លើគ្រែម្តងទៀត មុនពេលមកជួប ខាឡូម៉ាន់ ជាការដាក់ទោស ដែលនាងហ៊ានបោកប្រាស់គេ។

"ខ្ញុំត្រូវការការគោរពជឿទុកចិត្តពីប្រជាជនទៅវិញទេ"

"ហ៊ឺ! ខ្ញុំស្មានថាឯងត្រូវការអ្នកមើលថែប្អូនស្រីតើ"

"បើគិតថា ខ្លារិហ្សា ក្មេង ឯងប្រហែលមិនស៊ីក្មេងទេ មែនទេ ?"

រ៉េមសៀ វិះតែឈ្លក់ប្រាន់ឌី ហើយពេលប្រសព្វភ្នែកនឹង ខាឡូម៉ាន់ បានមួយភ្លែត ក៏គេចភ្នែកមិនតមាត់។

"តែឯងគួរមើលជ្រុងម្ខាងទៀត"

"ជ្រុងអី ?"

"ខ្លារិហ្សា ធ្វើបែបនេះបញ្ជាក់ថាប្អូនស្រីខ្ញុំជាមនុស្សឆ្លាត នាងដឹងច្បាស់លាស់ថាត្រូវធ្វើខ្លួនយ៉ាងណា ត្រូវរក្សាមុខមាត់ខ្ញុំយ៉ាងណា ហើយនាង





Scanned by CamScanner

មានចេតនាឲ្យឯងឃើញឈុតនោះតែម្នាក់ នាងជ្រើសរើសគោលដៅច្បាស់លាស់"

"ឯងមានមោទនភាពនឹងប្អូនស្រីណាស់ណ៎"

"ប្អូនស្រីខ្ញុំក្រៅពីមានសម្រស់ផ្ដាច់គេហើយ នៅមានភាពឆ្លៀវឆ្លាតទៀត ខ្ញុំតែងតែមានមោទនភាព"

"ឆ្លាតល្បិចកល"

ទោះមិនយល់ស្របនឹងការសរសើរនេះ តែគេក៏តបតដោយប្រាស់ចាកទោសៈ។ ចង់ប្រាប់ថាទំនាក់ទំនងផ្លូវកាយជ្រាលជ្រៅ វាមិនបានជួយដល់ទំនាក់ទំនងផ្លូវចិត្តក៏មិនអាចប្រកែកបាន យ៉ាងហោចណាស់គេក៏មិនមួម៉ៅខ្លាំងពេលនឹកដល់ ខ្លារិហ្សា។

"ជីវិតរបស់ឯងមានពន្លឺរស្មី មិនល្អឬ"

"ខ្ញុំត្រូវរំភើបនឹងក្ដីមេត្តារបស់ឯងហើយ ខាឡូម៉ាន់"

"គួរតែបែបហ្នឹង"

ខាឡូម៉ាន់ ឱនក្បាលបន្តិច ញញឹមចុងមាត់។

"ខ្ញុំព្យាយាមរំភើបទៅចុះ"

"ខ្ញុំមិនរើសអើង ចំពោះការរំភើបនោះទេ រ៉ែមសៀ"

ព្រះអង្គម្ចាស់តបតដោយទឹកមុខរីករាយ។ ការ៉ិន និង រ៉ែមសៀ មើលទៅមិនគួរណាចុះសម្រុងនឹងគ្នាបាន ព្រោះខ្លាំងរៀងខ្លួន តែគេបែរជាគិតថាពីរនាក់នេះសមគ្នាឥតខ្ចោះ ហើយសង្ស័យថាខ្លួនគិតមិនខុស។



ក្រៅពីនេះ គេត្រូវការព្យាបាលអារម្មណ៍របស់ រ៉ែមសៀ ដែរ។ បើ រ៉ែមសៀ មាននរណាម្នាក់ឲ្យស្រឡាញ់ បេះដូងរឹងកំព្រឹងអាចទន់ភ្លន់ខ្លះ។ រ៉ែមសៀ សមនឹងបានសេចក្ដីសុខនៅក្នុងជីវិតបន្ទាប់ពីធ្វើដើម្បី សាក់ខាវៀ យូរមកហើយ។

"ហើយរបស់មួយដែលឯងនឹងទទួលបានពី ខ្លារិហ្សា បើឯងយកឈ្នះចិត្តនាងបាន ឯងនឹងទទួលបានភាពស្មោះត្រង់មួយជីវិត"

រ៉ែមសៀ ស្ដាប់ដោយមិនតបត ស្ត្រីដែលមានភាពស្មោះត្រង់ចំពោះបុរសពីចឹងឬ។ គេលើកប្រាន់ឌី អកអស់ពីកែវ ហើយលាព្រះអង្គម្ចាស់ធ្វើដំណើរត្រឡប់ទៅដំណាក់របស់ព្រះនាងវិញ។

"ព្រះនាងចូលទៅចាំលោកឧត្តមសេនីយ ក្នុងក្រឡាបន្ទំល្អទេ ?"

ការ៉ិន ងាកទៅសម្លក់ ស៊ីឡា និងពើងទ្រូងដាក់។ នាងឬរង់ចាំ រ៉ែមសៀ គេចង់ទៅណាក៏ទៅទៅ។

"ខ្ញុំមិនបានរង់ចាំប៉ុនោះទេ"

"ព្រះនាង ហៅលោកឧត្តមសេនីយ៍បែបនោះមិនបានទេ"

ស៊ីឡា ស្ទុះមកដាក់បង្អួយក្បែរ លើកដៃដាក់លើភ្លៅរបស់ព្រះនាង តែទ្រង់មិនចាប់អារម្មណ៍។

"ចង់ហៅ ប៉ុនោះៗ"

"ព្រះនាង បើមានអ្នកដទៃឮ មិនល្អទេ"

"អ្នកណាមកឮ នៅក្នុងដំណាក់របស់ខ្ញុំ"





Scanned by CamScanner

បើអ្នកបម្រើនៅក្នុងដំណាក់របស់នាង មិនយកទៅនិយាយ គឺមិនសម និងនៅបម្រើព្រះនាង ការ៉ិន តទៅទៀតទេ។

"ព្រះនាងមិនខឹងទេ ?"

"មិនបានខឹងទេ"

"អីចឹង ចូលទៅចាំលោកឧត្តមសេនីយ៍នៅក្នុងបន្ទប់ទៅ"

"អូ! ប្រាប់ថាមិនបានរង់ចាំហើយ" នាងបដិសេធដោយទឹកមុខក្រមូវ ទាំងដែលមុននេះប្រឹងអើតកមើលទៅទ្វារចូលរបស់ដំណាក់ញឹកញាប់។

"មិនបានរង់ចាំក៏មិនបានរង់ចាំ"

"សង្ស័យត្រូវបង្កើតច្បាប់ហើយ"

"ច្បាប់អីឬ ព្រះម៉ែ"

"ហាមចូលផ្ទះលើសពីម៉ោងប្រាំបី"

នាងមើលនាឡិកាព្យួរជញ្ជាំង ប្រុសឆ្កួត រ៉េមសៀ មិនបានពាក់នាឡិកាទៅឬយ៉ាងម៉េច នេះជិតអធ្រាត្រទៅហើយ មិនទាន់មកផ្ទះមកសំបែងទៀត។

"សួរម៉េចក៏មិនឆ្លើយ"

"ឆ្លើយអីព្រះម៉ែ"

"ខ្ញុំនឹងបង្កើតច្បាប់រឿងពេលវេលាត្រឡប់មកផ្ទះវិញល្អទេ"

"មិនហ៊ានបញ្ចេញយោបល់ទេ"

"ហ៊ឺ! ខ្លាចអ្នកដទៃជាងខ្ញុំទៅទៀត"

នាងសម្លក់សម្លឹងអ្នកបម្រើ ហើយងើបឈរ អើតមើលទ្វារម្តងទៀត។



"មិនព្រមប្រាប់ថាមកវិញពេលណា"

"ធ្វើចិត្តឲ្យត្រជាក់ព្រះម៉ែ"

ស៊ីឡា មិនហ៊ានដាស់តឿនឲ្យព្រះនាងដឹងខ្លួន ព្រោះអាការៈដែលបង្ហាញឲ្យឃើញ គឺការទន្ទឹងរង់ចាំស្វាមីត្រឡប់មកផ្ទះវិញច្បាស់ណាស់ ប៉ុន្តែបើនិយាយនាងនឹងត្រូវទ្រង់ស្តីបន្ទោស។

"មើលចុះ លើសម៉ោងដេកខ្ញុំឡើងយូរទៅហើយ ដែលត្រូវរង់ចាំនេះព្រោះប៉ុនោះមកដេកទីនេះ បើមិនមកក៏មិនរង់ចាំបែបនេះដែរ"

នាងរអ៊ូរទាំ ទោះយ៉ាងណាក៏នាងជាស្ត្រីដែលមាន រ៉េមសៀ ជាបុរសនៅក្នុងជីវិតម្នាក់ ពេលទំនាក់ទំនងមកដល់ដំណាក់កាលនេះទៅហើយ សម្រាប់នាងគេគឺស្វាមី ហើយការរង់ចាំដូចភរិយាត្រឡប់មកផ្ទះនេះ វាកើតឡើងដោយស្វ័យប្រវត្ត។

"មកដល់នឹងទាញត្រចៀកឲ្យដាច់" នាងលើកដៃច្រត់ចង្កេះ រអ៊ូរទាំ ស៊ីឡា និង ហ្វីកា លួចមើលមុខគ្នា ញញឹមក្របួចមាត់។ ទោះយ៉ាងណា ការបានឃើញព្រះនាងនិងលោកឧត្តមសេនីយ៍មានទំនាក់ទំនងល្អនឹងគ្នា គឺជារឿងគួរឲ្យរីករាយ ហើយទន្ទឹងរង់ចាំបែបនេះ តែងតែល្អជាងការសោះអង្គើយដាក់គ្នា។

"ព្រះនាង ទាញត្រចៀកលោកឧត្តមសេនីយ៍មិនបានទេ"

"បានតើ ចាំមើលទាញឲ្យមើល មនុស្សឆ្កួត ចេះទុកឲ្យចាំទៅកើត មិនព្រមប្រាប់ឲ្យដឹង ទៅស្រវឹងអ្ហទិន្ននៅឯណាក៏មិនដឹង"

"លោកឧត្តមសេនីយ៍ទៅរកព្រះអង្គម្ចាស់ ខាឡូម៉ាន់"





Scanned by CamScanner

"ហ្នឹងហើយ មនុស្សប្រុសជួបគ្នា តើមានស្អីទៀត បើមិនរឿងស្រាស្រី ម៉ូរ...ស្រីឬ?"

នាងចង់ចំពើម រឿងស្រាអាចទទួលយកបាន តែរឿងស្រី បើ វ៉ែមសៀ ទៅរកសេចក្តីសុខពីស្រីដទៃ នាងទទួលយកមិនបាន គេបាននាងហើយ មិនថាគេធ្វើព្រោះត្រូវការដាក់ទោស ឬព្រោះអ្វីក៏ដោយ គេរំលោភនាង ធ្វើឲ្យនាងក្លាយជារបស់គេ ដូច្នេះហើយត្រូវតែទទួលខុសត្រូវនាង។

គ្មានផ្លូវដែលនាងបដិសេធទំនួលខុសត្រូវនោះ នាងនិងគេមានចំណងនឹងគ្នា ហើយបើនាងមិនព្រមទទួលយកការទទួលខុសត្រូវពីគេ នោះមានន័យថា នាងត្រូវធ្វើជាស្រ្តីដែលមានស្វាមីលើសពីម្នាក់ ព្រោះអនាគតនាងអាចនឹងត្រូវរៀបការជាមួយបុរសណាម្នាក់ក៏ថាបាន។

នាងនៅក្មេង ស្អាត វាពិបាកណាស់ដែលនឹងត្រូវរស់នៅម្នាក់ឯងមួយជីវិត ដូច្នេះហើយ នាងនឹងតោងគេឲ្យជាប់ មិនព្រមឲ្យគេរលាស់នាងរបូត ថ្លៃព្រហ្មចារីរបស់នាង គឺជីវិតនៅលីវរបស់គេ នាងរឹបអូសយក ហើយមិនប្រគល់ឲ្យវិញទេ។

"កុំឲ្យដឹងថាទៅលួចមានស្អីៗជាមួយស្រីផ្សេង"

អ្នកបម្រើទាំងពីរមិនបានចាត់ទុកថានេះជារឿងធំ ព្រោះបុរសថ្នាក់អ្នកគ្រប់គ្រងប្រទេស ឬបុគ្គលលំដាប់មហាសេដ្ឋីទាំងឡាយ សុទ្ធតែមានស្រីកំណាន់ក្រៅពីភរិយា មិនមែនជារឿងប្លែក។

"ព្រះនាង សោយទឹកត្រជាក់ទេ?"



"មិនផឹក"

នាងបដិសេធ ព្រោះផឹកអីមិនចូល ការស្រវឹងស្រវៃវាធ្វើការហួសកម្រិត បើផឹកតែស្រា ចាំបាច់ត្រឡប់មកផ្ទះវិញយប់ជ្រៅបែបនេះឬ។

"បើមានក្លិនទឹកអប់ជាប់ខ្លួន នឹងខាំត្រចៀកឲ្យឈាមដោក"

"ព្រះនាង និយាយបែបនេះមិនបានទេ"

ជាមនុស្សស្រីប្រងេងប្រងាងដាក់ស្វាមីបែបនេះមិនល្អទេ ហ៊ីវ៉ា ហាមាត់ហាមប្រាម ដោយសំឡេងញ័រ ព្រោះមានការភ័យខ្លាច ជំនួសម្ចាស់ស្រី ប៉ុន្តែការ៉ិន មិនខ្លាច វ៉ែមសៀ អ្វី...នាងចង់មានន័យថាមិនហ៊ាន បើមិនចាំបាច់ ព្រោះបើប្រាប់ថាមិនខ្លាច ជួនកាលក៏មានអារម្មណ៍ថាខ្លាចគេខ្លះដែរ គឺមើលគេចុះ មាឌធំដូចយក្ស ដៃម្ខាងធំប៉ុនណាប៉ុនណី ធំជាងដៃរបស់នាងពីរបួកបញ្ចូលគ្នាទៅទៀត ចាប់លើកនាងដោយដៃម្ខាង ហើយបី អាចធ្វើបានស្រួល ហើយនាងទៅយកកម្លាំងពីណាមកស៊ូនឹងគេ ក្នុងពេលដែលស៊ូដោយកម្លាំងបាយមិនបាន នាងត្រូវស៊ូនឹងគេដោយមាត់។

"តាប៉ិនោះត្រេកកាមណាស់"

"ព្រះនាងនិយាយអី"

"អត់មានទេ គ្មានអីទេ"

នាងរអ៊ូរទាំម្នាក់ឯង ហើយក៏អៀនម្នាក់ឯង។ ឃើញមិះៗបែបហ្នឹង ប៉ុន្តែពេលនៅលើគ្រែ វ៉ែមសៀ ត្រេកកាម ធ្វើឲ្យនាងចង់សន្លប់លើទ្រូងរបស់គេ។ នាងប្រហែលត្រូវកែប្រែទម្លាប់ផ្ទាល់ខ្លួនបន្តិចហើយ គិតថាត្រូវតែកំណត់ច្បាប់





Scanned by CamScanner

ចំពោះគេរឿងការប៉ះពាល់ខ្លួនប្រាណនាង។

ត្រូវហួងហែងខ្លួនប្រាណឲ្យគេស្ដាយលេង តែបើហួងហែងហើយ គេទៅប៉ះពាល់ស្រីផ្សេង មនុស្សត្រេកកាមបែបហ្នឹង បណ្ដោយឲ្យស្រេកឃ្លាន មិនល្អចំពោះជីវិតក្រុមគ្រួសារទេ ប៉ុន្តែបើនាងព្រមឲ្យគេពេក គេនឹងបានចិត្ត ហើយចាត់ទុកជាគេឈ្នះនាង។

'ត្រូវឈ្នះគេដោយស្នេហា'

សម្ដីរបស់ សិតិភិស រត់ចូលមកក្នុងសោតប្រសាទ។ ការយកឈ្នះដោយស្នេហា បើនាងធ្វើឲ្យ រៃមសៀ ឈ្លក់វង្វេងបានដោយការទោរទន់ទៅរកគេ ប្រណិប័តន៍ឲ្យរាងកាយរបស់គេស្កប់ស្កល់ នាងមានសិទ្ធិក្លាយជាអ្នកឈ្នះ។

"តាមពិតវិធីនេះគួរឲ្យចាប់អារម្មណ៍"

"វិធីអីព្រះនាង ?"

"ត្រូវយកឈ្នះដោយស្នេហាហ្នឹងអី ស៊ីឡា"

"ទ្រង់នៅចង់យកឈ្នះលោកឧត្ដមសេនីយ៍ទៀតឬ ?"

ស៊ីឡា និង ហ្វីរ៉ា សួរដំណាលគ្នា ព្រះនាងក៏ញញឹមញញែម ព្រោះសម្រេចចិត្តរួចហើយថាវិធីនេះ គឺជាវិធីល្អបំផុត។

"ខ្ញុំត្រូវតែជួប សានេនេ ដើម្បីសុំការណែនាំ"

ព្រះនាង បង្វិលខ្លួនដើរទៅអង្គុយលើសាឡុងវិញ ដោយនៅតែអះអាងថាអង្គុយត្រង់នេះ ប៉ុន្តែមាត់រឹង មិនព្រមប្រាប់ថាខ្លួនឯងកំពុងរង់ចាំ រៃមសៀ។



"ខ្ញុំមិនបានអង្គុយចាំតាប៉ុនោះទេ ខ្ញុំគ្រាន់តែ...មិនទាន់ងងុយ"

"ព្រះម៉ែ"

ស៊ីឡា និង ហ្វីរ៉ា ឆ្លើយដំណាលគ្នា បានឮបែបនេះហើយ ព្រះនាងក៏សប្បាយចិត្ត។ នាងមិនព្រមទទួលស្គាល់ទេថាខ្លួនកំពុងរង់ចាំ រៃមសៀ សូម្បីតែខ្លួនឯងក៏ដោយ ក៏នាងបោកខ្លួនឯងដែរ ប្រាប់នៅក្នុងចិត្តថា នាងមិនបានរង់ចាំគេអីបន្តិចទេ។

"ព្រះនាង"

ស៊ីឡា ចូលមកទប់ព្រះនាងឲ្យដេកលើសាឡុង។ អ្នកដែលប្រាប់ថាមិនទាន់ងងុយដេក ស្ងាបហាមៗ ហើយផ្ទួលខ្លួនដេក ដោយមានអ្នកបម្រើជួយ ចំណែក ហ្វីរ៉ា ទៅយកខ្នើយផ្អែកមកដាក់ឲ្យកើយ។

ពេល រៃមសៀ ត្រឡប់មកដល់ដំណាក់ គេឃើញព្រះនាងដេកលក់លើសាឡុង ដោយមានអ្នកបម្រើទាំងពីរអង្គុយងោកថ្ងក់ៗតាមនៅលើកម្រាល តែគេដើរមកឈ្ងោកលើអ្នកដេកលើសាឡុង ធ្វើឲ្យអ្នកបម្រើទាំងពីរភ្ញាក់ព្រើត។

"លោក លោកឧត្ដមសេនីយ៍"

"ម៉េចក៏ព្រះនាងមកដេកត្រង់នេះ ?"

ស៊ីឡា ស្ទុះងើប កេះ ហ្វីរ៉ា ឲ្យភ្ញាក់ ហើយស្រាក់ដៃដាក់លើពោះ ថយទៅឈរឲ្យឆ្ងាយពីសាឡុងវែង។

"អ្អឺ..."

"ឆ្លើយការពិត"





Scanned by CamScanner

ពេលអ្នកបម្រើមិនចង់និយាយ គេក៏ចេញបញ្ជា ព្រោះ ការ៉ិន អាចបញ្ជាឲ្យមនុស្សរបស់ខ្លួនបិទមាត់ មិនព្រមប្រាប់ការពិតដល់គេ ថ្នាក់ឈុតមង្គលការនាងនៅបញ្ជាឲ្យកាត់ពីរឈុត ដើម្បីញ៉ោះគេឲ្យខឹង។ នាងជាមនុស្សស្រីគួរឲ្យខឹង តែខណៈនោះក៏គួរឲ្យត្របាក់ឲ្យអស់ឆ្អឹងដែរ។

"ដូចព្រះនាងរង់ចាំលោកឧត្តមសេនីយ៍ តែទ្រង់ប្រាប់ថាមិនបានរង់ចាំគ្រាន់តែមិនទាន់ងងុយ"

ស៊ីឡា ឆ្លើយតាមត្រង់ ប៉ុន្តែយកពាក្យសម្តីរបស់ព្រះនាងមកឆ្លើយជំនួសធ្វើឲ្យ រ៉េមសៀ ចងចិញ្ចើម មិនមែនថាគេមិនពេញចិត្ត តែនោះគឺជាអារម្មណ៍ប្លែកៗ ដែលមានមនុស្សរង់ចាំគេ។

"សរុបទៅព្រះនាងរង់ចាំខ្ញុំ ?"

"ទ្រង់ប្រាប់ថាមិនបានរង់ចាំ តែទ្រង់មិនព្រមចូលផ្ទំ"

"ទើបត្រូវមកផ្ទំក្រង់នេះ ?"

"ព្រះនាងមើលទ្វារដំណាក់រហូត បន្ទប់នេះមើលទៅឃើញទ្វារចូលដំណាក់បានច្បាស់ ទើបទ្រង់មកបន្ទប់នេះ"

ចម្លើយនោះច្បាស់លាស់ ថានាងរង់ចាំគេឬអត់ រ៉េមសៀ ឈ្ងោកមើលអ្នកដេកលក់ ដែលពេលនេះដេកលក់ស្រួលណាស់ ថ្នាក់គេអង្អែលថ្ពាល់ដោយប្រាមដៃក៏នាងមិនដឹងខ្លួន ហើយដាក់បង្អួយចោងហោង ពិនិត្យមើលមុខមាត់ស្រស់ស្អាត។

"តាមធម្មតាទ្រង់ចូលផ្ទំម៉ោងប៉ុន្មាន ?"



"មិនលើសពីម៉ោងដប់"

ស៊ីឡា មិនហ៊ានកុហក ពេលគេសួរបែបនេះក៏ឆ្លើយតាមត្រង់ ទើប រ៉េមសៀ លើកព្រះនាងបីថ្នមៗ។

"រ៉េមសៀ មកវិញនឹងទាញត្រចៀកឲ្យដាច់"

ការ៉ិន មមើ ធ្វើឲ្យអ្នកបម្រើទាំងពីរត្រសុលចូលគ្នា ព្រោះខ្លាច រ៉េមសៀ ខឹង ប៉ុន្តែគេគ្មានប្រតិកម្មអី បន្ទាប់ពីឮប្រយោគនោះ។

"មិនបាច់តាម ទៅសម្រាកចុះ"

"ចាំលោកឧត្តមសេនីយ៍"

អ្នកបម្រើទាំងពីរទទួលបញ្ជា ទើបគេបីព្រះនាងចូលបន្ទប់ដេក ដោយអ្នកត្រូវបី យកមុខមកត្រដុសនឹងដើមទ្រូងរឹងមាំ។

"ពេលដេកលក់ដូចទេពធីតា ពេលភ្ញាក់ដូចបិសាច"

គេនាំនាងចូលបន្ទប់ដេក ដាក់លើគ្រែថ្នមៗ ប៉ុន្តែពេលនាងប៉ះគ្រែក៏ស្រវេស្រវាចាប់អាវរបស់គេជាប់។

"រ៉េមសៀ ទើបមកពីណា ?" នាងសួរទាំងសំឡេងត្រអៀន ព្រោះភ្ញាក់មិនទាន់ពេញភ្នែក។

"ទៅជួបព្រះអង្គម្ចាស់ ខាឡម៉ាន់"

"មិនបានទៅរកស្រី ?"

"មិនបានទៅទេ ដេកទៅ ខ្ញុំទៅងូតទឹកសិន"

នាងដេកលក់បន្ទាប់ពីបានឮចម្លើយនោះ ទើប រ៉េមសៀ បេះដៃនោះ



ចេញពីអាវរបស់ខ្លួនយឺតៗ ជាទង្វើថ្នាក់ថ្នមបំផុត តាំងពីគេប៉ះពាល់រាងកាយរបស់នាង ហើយឱនទៅរក និងមានសំណួរកើតឡើងថា គេចង់ធ្វើអី?។

គេបានចម្លើយនោះ ព្រោះបបូរមាត់របស់គេប៉ះថ្ពាល់របស់នាង ភាពជាម្ចាស់វាជ្រួលច្រាលនៅក្នុងទ្រូង គេហួងហែងនាង ព្រះអង្គម្ចាស់ ខាឡូម៉ាន់ ច្បាស់គេត្រូវចំណុច គេត្រូវការភាពស្មោះត្រង់ពីនាង តែមិនចង់ហាមាត់សុំ។

គេងើបចុះពីគ្រែ ដើរចូលបន្ទប់ទឹក ចំណាយពេលមិនយូរប៉ុន្មានក៏ចេញមកវិញដើម្បីចូលដេក។ គេដោះអាវឃ្លុំពាក់និងកៅអី ហើយដើរខ្លួនទទេ សំដៅគ្រែដេក ផ្ទួលខ្លួនដេកក្បែរ និងទាញនាងមកឱប។

"រាត្រីសួស្តី ព្រះនាងសាំញ៉ាំ"

គេស្រវាឱប ការ៉ុន ក៏ត្រសុលមករក ទើបបិទភ្នែក។ គេមិនធ្លាប់ដេកឱបមនុស្សស្រី តែក៏ចង់ឱប ការ៉ុន ហើយពួកគេក៏ឱបក្រសោបគ្នានៅក្នុងភាពងងឹត និងរកកន្លែងដែលសក្តិសមសម្រាប់ការឱបក្រសោបនេះ។



# ៩

## ស្វាមីភរិយា

"យប់មិញទៅណាហាស!"

សំណួរដំបូងពីព្រះនាង ពេលភ្ញាក់ពីដំណេកនាពេលព្រឹក ព្រមទាំងគក់ដើមទ្រូងរបស់ស្វាមីឮឌឹបៗ បន្តិចឡើង។ គេភ្ញាក់ដឹងខ្លួនតាំងពីនាងប្រែខ្លួនម្ល៉េះ ប៉ុន្តែបិទភ្នែកសម្ងំដូចដេកលក់ រហូតដល់ត្រូវនាងគក់នោះឯង។

ការ៉ុន ងើបអង្គុយ សម្លឹងគេដោយខ្សែភ្នែកឆ្ងាសឆ្ងើម។ នាងនៅមានការសង្ស័យពីរឿងយប់មិញ ហើយក៏ឱនទៅហិតរាងកាយរបស់គេ ប៉ុន្តែមិនធុំក្លិនស្រា ឬទឹកអប់របស់មនុស្សស្រី។

"ឆ្លើយមក!" នាងម្ចាស់ សួរហើយនៅគិតតែពីដេកសម្លឹងមុខនាងទៅកើត ឬកំពុងគិត រកលេសដោះសា។ ចាំមើល បើទៅទាក់ទងស្រីផ្សេង នាងនឹងកាត់ចោល ហើយបោះទៅក្រៅដំណាក់ របស់បែបហ្នឹង ចែកគ្នាប្រើមិនបានទេ ហើយបើមានអ្នកមកសុំចែកប្រើ អីចឹងគេមិនចាំបាច់ប្រើវាមួយជីវិតទៅ។

"ឆ្ងាសអីទាំងព្រឹក"

"ឆ្ងាសស្អី ប៉ុនេះ កុំមកគេចវេះ"

នាងវារឡើងមកទ្រាបលើពោះរឹងមាំ រ៉េមសៀ ក៏មើលស្រីស្អាតនៅលើ



ខ្លួន មើលនាង ចាញ់ខ្សែភ្នែកផ្ទាសដាក់ និងគក់ដើមទ្រូងរបស់គេញាប់ដៃ។

"មានប្រពន្ធចុងមែនទេ ឆ្លើយ!"

"ប្រពន្ធចុងមកពីណា"

"មិនបាច់មកកុហកទេ ហើយម៉េចក៏មកវិញយប់ជ្រៅ"

នាងប្រសព្វភ្នែកជាមួយគេ កែវភ្នែកនោះបញ្ជាក់ឲ្យដឹងថា នាងលេងមែនទែន ទើប រ៉េមសៀ ងើបអង្គុយផ្អែកនឹងក្បាលគ្រែ ដោយមាននាងទៅតាមមិនព្រមចុះ។

"ទៅរកព្រះអង្គម្ចាស់"

"ទៅធ្វើអី?"

"ផឹកស្រា ហើយនិយាយរឿងការងារ"

"ត្រឹមផឹកស្រានិយាយគ្នា?"

"បាទ"

គេស្រវាចាប់ដៃរបស់នាង ដែលបំណងទះតប់គេទៀត ទើប ការ៉ុន ព្រមដាក់ដៃចុះ ពេលបានឮចម្លើយច្បាស់ ប៉ុន្តែគេនៅតែចាប់ដៃនាងជាប់។

"គ្មានស្ត្រី?"

"គ្មាន មានតែអ្នកបម្រើ"

"ស្ត្រីទេ! ដល់ថ្នាក់ទៅទាក់ទងអ្នកបម្រើផងឬ ប៊ិស្ទូត!"

នាងដោលទៅជិត ហើយគក់ដើមទ្រូងរឹងមាំ រ៉េមសៀ ក៏បណ្ដោយឲ្យគក់ទាល់តែនាងហត់ ទើបឱនមកថើបថ្ពាល់រលោងខ្សឹតៗ។



"ឈប់ឡូឡា មិនបានទៅទាក់ទងអ្នកបម្រើណាទេ"

"អ្ហាំ! ហើយនិយាយធ្វើអី មើលចុះ គក់ឡើងឈឺដៃគេអស់ហើយ"

ទោះយ៉ាងណាក៏ រ៉េមសៀ ក្លាយជាអ្នកខុស នាងមិនព្រមស្ដាប់គេ ឬហៅថាស្ដាប់ហើយយល់ច្រឡំក៏បាន ប៉ុន្តែនៅតែទម្លាក់កំហុសឲ្យគេទៀត។

"ដៃក្រហមអស់ហើយនេះ មើលចុះ"

នាងដាក់ដៃចំពីមុខរបស់គេ ម្រាមវែងស្ទើរតែចាក់គ្រាប់ភ្នែកទៅហើយ ទើបគេចាប់វាពិនិត្យ។

"ហើយគក់ធ្វើអី?"

"ខឹងហ្នឹងណ៎ា"

នាងរអ៊ូរទាំ រ៉េមសៀ ក៏ជួយពិនិត្យដៃឲ្យ ឃើញឡើងក្រហមក៏មុខក្រមូវមិនពេញចិត្តដែលនាងធ្វើឲ្យខ្លួនឯងឈឺ។

"ម៉េចក៏មកវិញយប់ជ្រៅ សួរហើយឆ្លើយផង"

"ជាប់និយាយការងារ"

"ហាមកុហក"

"មិនបានកុហក មិនចាំបាច់អីត្រូវធ្វើបែបហ្នឹង"

"អីចឹងក៏ហិតទៅចុះ"

នាងឈប់ដេញដោលទៀត ព្រោះជឿសម្ដីរបស់គេ តែនៅតែឱនទៅធ្វើប្រមុះខិតខត ដើម្បីហិតរកក្លិនប្លែកៗ។

"គ្មានក្លិនទឹកអប់មនុស្សស្រី អីចឹងម្ដងនេះចាត់ទុកជាចប់ តែលើក



ក្រោយបើមកវិញយប់ជ្រៅ ជួយប្រាប់ផង"

"ចាំឬ?"

"រឿងអីចាំ គ្រាន់តែមិនទាន់ងងុយដេក"

នាងឆ្លើយហើយពើងទ្រូងដាក់ វ៉េមសៀ នៅតែចាប់ដៃជាប់ ទើបរូបភាពនៅពេលនេះដូចនាងស្ថិតនៅក្នុងក្រញាំដៃរបស់គេ។

"អីចឹងឬ"

"ធ្វើសំឡេងបែបនេះមានន័យថាម៉េច?"

"ខ្ញុំជាអ្នកបីនាងចូលដេក"

នាងតែពើងទ្រូងដាក់ តែ វ៉េមសៀ មើលឃើញពេញភ្នែកថា ថ្ពាល់រលោងឡើងក្រហម។

"គឺ...គឺ..."

"គឺស្អី?"

"ពេលចេញទៅអង្គុយចាំ មិនទាន់ងងុយហ្នឹងណា"

"ក្រែងថាមិនបានចាំ"

"គឺមិនបានចាំ អ្នកណាចាំ ឆឺះ!"

ពេលស៊ូនឹងគេមិនបានក៏ពើងទ្រូងដាក់ទៀត ធ្វើឲ្យ វ៉េមសៀ ចង់តែទះកំប៉េះគូទព្រោះភ្ញាញ់។

"រឿងស្អីត្រូវចាំ"

នាងបញ្ជាក់ម្ដងទៀត តែគេមិនឆ្លើយ ឆ្លើយប្រាប់ថាជឿឬមិនជឿ ហើយ



ពេលគេមិនឆ្លើយ នាងក៏ឆ្ងល់ ព្រោះខ្លាចអាម៉ាស់មុខ។

"មិនបានចាំពិតមែន"

*យី! នៅស្ងាត់ទៀត ហើយសម្រេចថាជឿសម្ដីរបស់នាងឬអត់!*

នាងត្រូវការឲ្យគេឆ្លើយមួយម៉ាត់ ទើបនាងសប្បាយចិត្ត។

"បានឮឬអត់នេះ"

"បានឮ"

"បានឮហើយម៉េចមិនឆ្លើយ"

"ចង់ឲ្យឆ្លើយអី?"

"អ្ហ! គឺឆ្លើយមកថាជឿឬមិនជឿ"

នាងងរង៉ក់ដាក់គេដូចកូនក្មេងបេះបិទ ហើយបើគេតបត ដូចគេត្រូវកាត់បន្ថយអាយុតាមនាងដែរ ដូច្នេះហើយទើបមិនមាត់។

"តាមហ្នឹង"

"ឆ្លើយបែបនេះ ប្រើការមិនបានទេ"

នាងធ្វើមុខខ្មួរ ទើប វ៉េមសៀ ឱនមករក នាងក៏ថ្ពួលខ្លួនទៅក្រោយ លើកដៃឱប.ករងមាំ។

"ចង់ធ្វើអី?"

"ដឹងហើយតើ"

តេឱបក្រសោបរាងកាយតូចស្ដើង កាលពីយប់មិញនាងដេកលក់ ទើបថាមពលរបស់គេមិនទាន់ត្រូវបានកម្ចាយ ការអ៊ឺន ក៏បិទភ្នែកពេលបបូរមាត់ត្រូវ



គ្រប់គ្រង។

"យូរទេ អាហារពេលព្រឹកត្រូវញ៉ាំឲ្យទៀងពេល"

គេផ្ទួលនាងទៅលើគ្រែ ពាមមកទ្រាបពីលើ ថើបបបូរមាត់ម្តងទៀត ដែលម្តងនេះ ថើបយ៉ាងយូរ។

"ស្ងាត់ទៅ កុំឲ្យខាតពេល"

គេឆ្លើយតែប៉ុណ្ណឹង ហើយថើបនាងម្តងទៀត សម្លៀកបំពាក់ក៏ត្រូវចាប់ដោះនិងបោះចោលដោយមិនស្រណោះ បន្ទាប់មកសំឡេងថ្ងូចថ្ងូរដោយអារម្មណ៍ពេញយក៏បន្លឺឡើងនៅក្នុងបន្ទប់។

"មិនបាច់បិ"

ការ៉ិន ធ្វើឫកឆ្មាសឆ្មើមដាក់ មិនឲ្យគេបិព្រោះនៅងងឹត ដោយសារសំឡេងថ្ងូចថ្ងូររបស់ខ្លួន ឮខ្លាំងពេក គួឲ្យខ្មាសគេ។ នាងអៀនគេ ហើយក៏ពាលខឹងដែរ មិនព្រមឲ្យបិចេញពីបន្ទប់តែងខ្លួន ប៉ុន្តែពេលឈានជើងបានមួយជំហានក៏រកកល់ចង់ដួល សំណាងដែលគេឱបចង្កេះជាប់។

"នៅរឹងក្បាលទៀត"

"ព្រោះអ្នកណា"

គេលើកនាងបិ ចំណែកអ្នកដែលត្រូវបិ អៀនឡើងក្រហមមុខង៉ាំង ពេលគិតដល់មូលហេតុដែលធ្វើឲ្យខ្លួនទន់ជើង គឺជើងរបស់នាងត្រូវញែចេញពីគ្នា



អស់រយៈពេលយ៉ាងយូរ បើជើងរបស់នាងទន់ គ្មានកម្លាំងក៏មិនមែនជារឿងប្លែក។

"ឈ្លានខ្លាំង ?"

"ឆ្កួត"

នាងផ្អែកក្បាលនឹងដើមទ្រូងធំទូលាយ ដោះសានៅក្នុងចិត្តថាមិនចង់សម្លំបែបនេះ ប៉ុន្តែតក់គេទៅវាឈឺដៃ ទើបគិតថាធ្វើបែបនេះវាល្អជាង។

"ថ្ងៃនេះទៅណាឬអត់ ?"

"ថ្ងៃនេះឬ ?"

"នែ! កុំប្រាប់ថាត្រូវធ្វើការ នេះជាថ្ងៃឈប់សម្រាក ត្រូវ..."

នាងនិយាយមិនទាន់ចប់ប្រយោគផង បបូរមាត់ក៏ត្រូវ រំមសៀ បិទដោយបបូរមាត់ក្តៅរបស់គេ ដើម្បីមិនឲ្យរអ៊ូរទាំទៀត។

"ហ៊ឺ! មាត់ជាំអស់ហើយ"

នាងលើកដៃបិទមាត់របស់គេ ពេលដែលគេដកបបូរមាត់ចេញ ហើយពេលដែលគេមើលមកដោយខ្សែភ្នែកកាច នាងក៏សម្លក់សម្លឹងវិញដោយខ្សែភ្នែកឆ្មាសឆ្មើម ដើម្បីឲ្យគេដឹងថានាងមិនខ្លាចគេ។

"ស្តាប់ឲ្យចប់ចាំឡូឡា"

"និយាយមក"

នាងដកដៃចេញពីបបូរមាត់ក្រាស់នោះ ពេលឃើញហើយថាគេមិនថើបទៀត។





Scanned by CamScanner

"ថ្ងៃនេះប្រហែលមិនទៅណាទេ សម្រាកពីរថ្ងៃ ហើយត្រូវទៅក្រុងសេនដារីក"

"ទៅទៀតហើយ"

"ជាទីក្រុងមិនទាន់មានស្ថេរភាព គឺត្រូវប្រុងប្រយ័ត្ន"

"គ្រោះថ្នាក់ឬ ?"

រ៉ែមសៀ ប្រសព្វភ្នែកជាមួយនាង បើនិយាយការពិត មនុស្សស្រីទន់ជ្រាយដូចនាង និងត្រូវបានចិញ្ចឹមមើលថែហាក់ដូចត្បូងនៅក្នុងបាតដៃ មុខជាភិតភ័យ។

"មិនគ្រោះថ្នាក់ទេ"

សម្រាប់គេតែប៉ុណ្ណោះ ព្រោះគិតថាគេអាចមើលថែខ្លួនឯងបាន ប៉ុន្តែបើប្រៀបធៀបនឹង ការ៉ុន គឺត្រូវប្រាប់ថាគ្រោះថ្នាក់ខ្លាំងណាស់។

"មិនគ្រោះថ្នាក់ល្អហើយ ដែលនិយាយនេះមិនបានបារម្ភអីទេ គ្រាន់តែសួរតាមមារយាទ"

រ៉ែមសៀ មិនបានជាគិតថា ការ៉ុន បារម្ភពីគេ ប៉ុន្តែពេលនាងនិយាយបែបនេះ គឺដូចប្រាប់ដោយប្រយោលឲ្យដឹងនោះឯង ថានាងបារម្ភ។ នាងមិនចង់ឲ្យគេដឹង តែធ្លោយធ្វើខ្លួនព្រួយបារម្ភលឿនដូចព្យុះ ដែលគេដឹងឲ្យទាល់តែបាន។

"បានឮទេ"

នាងក្តៅខ្លួន ខ្លាចគេមិនជឿសម្តី ពាប៉ុនេះហេតុអីចូលចិត្តធ្វើឲ្យនាងគិត



ច្រើន ជួយឆ្លើយឲ្យច្បាស់លាស់បន្តិច មិនបានឬយ៉ាងម៉េច។

"បានឮអី"

"ខ្ញុំប្រាប់ថាមិនបានបារម្ភ"

"តាមហ្នឹង"

"ឆ្លើយបែបនេះទៀតហើយ"

នាងរអ៊ូរទាំ ហើយត្រូវ រ៉ែមសៀ បីទៅបន្ទប់អាហារ មាន ស៊ីឡា និង ហ្វ៊ីភ៍ ជួយទាញកៅអីឲ្យ ទើបគេដាក់នាងលើនោះ។

"អរគុណ"

រ៉ែមសៀ ស្មានមិនដល់ទេថាបានឮពាក្យអរគុណចេញពីមាត់របស់នាង ថែមទាំងត្រូវសម្លក់សម្លឹងមួយភ្លែត និងងាកមុខចេញភ្លាមទៀតផង។

"ខ្ញុំមានមារយាទ ចង់អរគុណ តើមានបញ្ហាអីទេ"

រ៉ែមសៀ ឱនមកថើបថ្ពាល់រលោង ចង់ទះកំប៉េះគូទមួយដៃពីរដែរ ប៉ុន្តែមិនអាចវាយនាងផ្តេសផ្តាសបាន។

"ចង់ថើបឲ្យថ្ពាល់បែកឬយ៉ាងម៉េច"

"បែកហើយឬនៅ"

"ឆ្កួត"

នាងរអ៊ូរទាំ និងទើបតែដឹងថា រ៉ែមសៀ មោះអង្គុយនៅឆ្វេងដៃ ខណៈដែលគេអង្គុយនៅក្បាលតុ ដែលត្រង់នោះធ្លាប់ជាកន្លែងរបស់នាង តែណ្ហើយចុះ គេជាស្វាមីហ្នឹងណា៎ អង្គុយនៅត្រង់នោះគឺត្រឹមត្រូវហើយ។



"លោកចូលចិត្តញ៉ាំអី អ្ហ៎...ដែលសួរនេះមិនបានចង់ដឹងទេ តែសួរដើម្បីប្រាប់ចុងភៅ"

"ខ្ញុំញ៉ាំអីក៏បាន"

វ៉ែមសៀ ឆ្លើយតែប៉ុណ្ណឹង បន្ទាប់មកពួកគេក៏ស្ងប់ស្ងាត់ ព្រោះត្រូវទទួលទានអាហារ។ ការអ៊ិន ប្រាប់មិនត្រូវទេថា មានអារម្មណ៍យ៉ាងណា ប៉ុន្តែការដែលមាន វ៉ែមសៀ នៅក្នុងដំណាក់របស់ខ្លួន វាធ្វើឲ្យមានអារម្មណ៍ល្អតិចតួច។

"ហ៊ឹ! មិនឲ្យអាហាររលាយសិនទេអី"

នាងគេចឡើងទៅលើគ្រែ គេចបែបណាក៏មិនដឹង ប៉ុន្តែមើលទៅការគេចរបស់នាង ជាការផ្ដល់ភាពងាយស្រួលឲ្យ វ៉ែមសៀ ច្រើនជាង។ គេតាមមកជិតមិននិយាយឲ្យខាតទឹកមាត់ លើកដៃទាំងពីរដើម្បីដោះអាវ តាមដោយខោក្រៅនិងខោក្នុង។

"គ្រេកភាម!"

ថ្ពាល់របស់នាងក្រហមឆ្អាំង ប៉ុន្តែភ្នែកសម្លឹងមើលរាងកាយរបស់អ្នកកំលោះមិនព្រិច អ្វីម្យ៉ាងនៅលើខ្លួនប្រាណរបស់គេ បញ្ជាក់ច្បាស់ថាគេកំពុងតែមានអារម្មណ៍ប្រាថ្នា។

វ៉ែមសៀ នាំរាងកាយនទលគក មកជិត ហើយចាប់ដោះសម្លៀកបំពាក់របស់នាង តែនាងរើបម្រះ។

នាងគិតថាខ្លួនឯងរើបម្រះ ដើម្បីគេច តែហេតុអី មើលទៅដូចផ្ដល់ភាពងាយស្រួលឲ្យគេយ៉ាងម៉េចក៏មិនដឹង ពេលគេដោះអាវនាងក៏លើកដៃ បំណងទះតប់ ប៉ុន្តែនាងប្រហែលលើកខ្ពស់ពេក ទើបគេឆ្លៀតឱកាសនេះ ទាញវាចេញពីខ្លួនរបស់នាងបានសម្រេច បន្ទាប់មកនាងក៏បែរខ្នងគេច ប៉ុន្តែក្លាយជាការបែរខ្នងឲ្យគេដោះតម្កក់អាវក្នុង ទើបលើកដៃបំណងបិទដើមទ្រូង ប៉ុន្តែបែរជាត្រូវគេទាញខ្សែអាវក្នុងនោះចេញពីស្មាបានស្រួល និងបោះវាចោល។

ពេលគេដោះតម្កក់សំពត់ នាងក៏ប្រឹងរើបម្រះ គេចាប់ទាញសំពត់ នាងក៏ក្រញែងខ្លួន ធ្វើឲ្យសំពត់វារុំខ្លួន ទើបនាងលើកត្រគាក វ៉ែមសៀ ក៏ឆ្លៀតឱកាសនេះទាញវាចេញពីជើងបានសម្រេច ហើយពេលដែលនាងភ្ញាក់ លើកត្រគាកបែបហ្នឹង មិនព្រមដាក់ចុះ ខោក្នុងក៏ត្រូវទាញមួយទៀត។

នាងព្យាយាមហើយ រើបម្រះដើម្បីឲ្យរួចផុតពីក្រញាំដៃរបស់គេ ប៉ុន្តែកាន់តែរើកាន់តែចាញ់ប្រៀប រើទាល់តែសម្លៀកបំពាក់របូតបាញ ហើយពេលនេះនាងនិងគេនទលគកដូចគ្នា និងពេលចង់គេចក៏មិនអាចធ្វើបែបនោះបាន នាងត្រូវបង្ហាញភាពក្លាហាន ដូច្នេះហើយ ត្រូវតែប្រឈមមុខនឹងគេបន្ត ទោះជាការប្រឈមមុខដោយគ្មានសម្លៀកបំពាក់បិទបាំងក៏ដោយ។

"អុំយ!"

នាងត្រូវលើកឲ្យច្រកកៀរលើភ្លៅរឹងមាំ ទើបលើកដៃដើម្បីរុញគេចេញ តែបើរុញគេចេញ គេនឹងឃើញរាងកាយនទលគករបស់នាង ទើបនាងប្ដូរចិត្តស្រវាឱបគេ។

"ងើយមុខឡើង"



រ៉ែមសៀ ចេញបញ្ជា នាងមិនចង់អនុវត្តតាម តែរឿងតើងទ្រូងនាងជំនាញ មិនបានងើយមុខ តែពើងទ្រូងដាក់គេទៅវិញទេ ហើយពេលនាងពើងបែបនេះ វាដូចយកបបូរមាត់ទៅទទួលយកបបូរមាត់ក្ដៅគគុក។ នាងអង្អែលសាច់ដុំរឹងមាំ ខ្លួនប្រាណរបស់គេរឹងដូចថ្ម ខណៈដែលរាងកាយរបស់នាងទន់ល្មៀននិងក្រអូបប្រហើរ។

រ៉ែមសៀ ថើបនាងខ្លាំងៗ តែការថើបនោះ បែរជាធ្វើឲ្យស្មារតីរបស់នាងមិននៅក្នុងខ្លួន។ នាងឈ្លក់វង្វេងនឹងការថើបរបស់គេ រាងកាយស្រៀវស្រើបដោយអារម្មណ៍ប្រាថ្នា ពិបាកនឹងកម្ចាត់ ហើយអ្នកដែលអាចកម្ចាត់វាបាន មានតែ រ៉ែមសៀ ម្នាក់ប៉ុណ្ណោះ។

រោមនៅលើខ្លួនរបស់ រ៉ែមសៀ កកិតនឹងស្បែកទន់ល្មើយ ក្រៅពីធ្វើឲ្យរាងកាយរមាស់ហើយ នៅធ្វើឲ្យរញ្ជួយអារម្មណ៍ទៀតផង។ នាងបង្កើបបបូរមាត់ថើបគេវិញ ដោយមិនដឹងទេថានាងនិងគេផ្ដួលខ្លួនដេកតាំងពីពេលណា។

ពេលនេះពួកគេឱបរឹតគ្នា បបូរមាត់នៃបនិត្យជិតគ្នាដោយការដង្ហោយរកទាំងដែលទើបតែបញ្ចប់រឿងបែបហ្នឹងជាមួយគ្នា មុនអាហារពេលព្រឹក។ រ៉ែមសៀ ស្ទាបអង្អែលស្បែកទន់ល្មើយ ត្រហឹមនៅដើម.កដោយការពេញចិត្តនឹងការប៉ះពាល់ដែលទទួលបាន។

"ហ៊ឺ! ថើបខ្លាំងពេកហើយ" នាងរអ៊ូទាំ ពេលបបូរមាត់មានសេរីភាព រ៉ែមសៀ ក៏សង្កត់បបូរមាត់នឹងច្រមុះនិងថ្ពាល់រលោង។ គេថើបហើយថើបទៀតក្លិនរបស់នាងក្រអូបមែនទែន និងឱបរឹតពេញដៃ រាងកាយនាងតូចពេកហើយ



ពេលស្ថិតនៅក្នុងរង្វង់ដៃរបស់គេ តែរាងកាយមាំមួនរបស់ រ៉ែមសៀ បែរជាធ្វើឲ្យនាងមានអារម្មណ៍ស្នេហាចំពោះភាពរឹងមាំរបស់គេកាន់តែខ្លាំង បុរសទន់ជ្រាយនិងមិនត្រូវនាងយកភ្នែកមើល ប៉ុន្តែ រ៉ែមសៀ ខុសប្លែកពីគេ គេមានភាពក្លាហានរឹងមាំ និងមាំមួន សមជាបុរស។

ដើមទ្រូងទ្រលុកទ្រលន់ បៀតនឹងដើមទ្រូងរឹងមាំ លម្អដោយរោម ដែលធ្វើឲ្យរមាស់ស្បែក ហើយក៏ធ្វើឲ្យអារម្មណ៍របស់នាងរញ្ជួយ។ ការ៉ុន ថ្ងូចថ្ងូរនៅដើម.ក ពេលត្រូវគេឈ្ងុលមុខនឹងប្រឡោះក ហើយអូសបបូរមាត់មករកដើមទ្រូងគួរឲ្យឈ្លក់វង្វេង។

គេឈ្លក់វង្វេងនឹងវាមែននោះឯង គេមានអារម្មណ៍ដល់ជាតិក្រអូបផ្អែមនៅក្នុងមាត់ វាជារសជាតិ ដែលបបូរមាត់របស់គេទទួលបាន និងនៅតែជាប់ចិត្ត។ គេហាមាត់ក្រសោបចុងទ្រូងពណ៌ស្រស់ ហើយត្រវាសដោយអណ្ដាតគ្រើម ធ្វើឲ្យនាងអែនទ្រូងមករក។

រាងកាយរបស់នាងមិនអាចកុហកគេបាន ការ៉ុន ប្រាថ្នាគេ គេល្បងរាងកាយរបស់នាង ឲ្យមានតម្រូវការចំពោះគេ ហើយប្រាថ្នា គេដូសដងដូចមនុស្សស្រេកឃ្លាន បឺតជញ្ជក់ទ្រូងរបស់នាងឮខ្លាំងៗ ឲ្យនាងថ្ងូចថ្ងូរព្រោះកម្ដៅចេញពីមាត់របស់គេ។

"រ៉ែម..."

ហេតុអីគេធ្វើដាក់រាងកាយរបស់នាងបែបនេះ នាងក្ដៅភាយៗ សព្វសាច់ហាក់ដូចក្ដៅ ប៉ុន្តែមិនបានគ្រុន រ៉ែមសៀ គ្រប់គ្រងនាងដោយ



តម្រូវការរវាងបុរសស្ត្រី វាក្ដៅគគុក ពុះកញ្ជ្រោល និងមិនអាចគ្រប់គ្រងបាន ពួកគេមិនអាច ហាមប្រាមខ្លួនឯង ពួកគេត្រូវការគ្នា។

"រ៉េម..."

នាងថ្ងូចថ្ងូរនៅដើម.ក ពេលត្រូវគេគ្រប់គ្រងដោយកម្ដៅ និងការប្រាថ្នា។ នាងរៃនេត្រតាកទៅទទួលយក នាងត្រូវការគេគ្រប់សកម្មភាពដែលកើតឡើង មិនត្រឹមតែជាសេចក្ដីសុខផ្លូវកាយទេ វាកំពុងតែវេញជាចំណងសន្សឹមៗ នៅក្នុងបេះដូងរបស់នាង។ នាងថើបករបស់គេ ថ្ងូចថ្ងូរនៅក្រោមរាងកាយរបស់គេ ទាល់តែហត់នឿយ។

រ៉េមសៀ ជាមនុស្សប្រុសដែលបើកពិភពលោកធំល្វឹងល្វើយឲ្យ កាអ៊ីន គេផ្ដោតអារម្មណ៍ទៅលើការបង្រៀននាងរឿងលើគ្រែ ដោយមិនចេះហត់នឿយ តែមិនចាំបាច់នៅលើគ្រែ ក៏គេអាចធ្វើឲ្យនាងថ្ងូចថ្ងូរបាន ដោយការនាំចុះពីគ្រែធំទូលាយ ទៅលើសាឡុងវែង។

ដៃរបស់នាងខ្ទាំសក់ ខ្មៅក្រាស់របស់អ្នកដែលអង្គុយនៅលើកម្រាលឥដ្ឋមុខសាឡុង។ រ៉េមសៀ ជាមនុស្សមាំមួន នាងដឹងថាគេមិនចូលចិត្តឲ្យនាងរឹងទទឹងដាក់គេ ឬធ្វើខ្លួនមានអំណាចលើគេ ប៉ុន្តែពេលខ្លះនាងប្រទះឃើញថាខ្លួនឯងអាចមានអំណាចលើគេបានដូចគ្នា។

រ៉េមសៀ ព្រមឲ្យនាងចាប់ក្បាលរបស់គេ សង្កត់នឹងរាងកាយផ្អែមល្ហែម គេដាស់នាងដោយអណ្ដាតក្ដៅគគុក បាតដៃធំក្រាស់ក្រសោបដើមទ្រូង



ទ្រលុកទ្រលន់ នាងមិនទាន់មានឱកាសបានស្លៀកពាក់ តាំងពីដោះវាចេញលើកចុងក្រោយ បន្ទាប់ពីអាហារពេលព្រឹក ហើយពេលនេះក៏ជិតដល់អាហារថ្ងៃត្រង់ដែរ ប៉ុន្តែគេមិនទាន់រួចរាល់ធុរៈនឹងនាងទៀត។ ពេលគេរវល់ នាងក៏ត្រូវរវល់តាមដែរ ព្រោះធុរៈរបស់គេ មិនអាចធ្វើម្នាក់ឯងបាន ឬបើនាងមិនសហការណ៍ គេអាចនឹងទៅរកស្រីផ្សេងឲ្យជួយ ដែលនាងមិនអាចទទួលយកបាន។

*ចែករំលែកអីចែកបាន តែចែករំលែកស្វាមី នាងមិនព្រមចែក!*

នាងហួងហែងគេ នាងមិនត្រូវការឲ្យគេមានស្រីផ្សេងក្រៅពីនាង។ នាងមានរឿងជាច្រើនដែលត្រូវនិយាយជាមួយគេ នាងចេញបញ្ជាឲ្យមន្ត្រីផ្នែកច្បាប់របស់នាង ពង្រាងកិច្ចសន្យាមុនរៀបការច្រើនចំណុច ដែលពួកគេត្រូវស៊ីញ៉េជាមួយគ្នា ដោយចំណុចមួយនៅក្នុងនោះ គឺរឿងស្រីកំណាន់ទាំងឡាយរបស់គេ។ នាងចិត្តទូលាយរឿងផ្សេង ប៉ុន្តែរឿងលើគ្រែ នាងមិនចែករំលែកស្វាមីឲ្យទៅស្រីណាទាំងអស់ រ៉េមសៀ ត្រូវតែបិទស្តុកស្រីកំណាន់របស់គេ ព្រោះនាងគ្មានជម្រើសឲ្យគេទេ សម្រាប់រឿងនេះ។

នាងនឹងរៀបការជាមួយគេ ហើយគេត្រូវតែចាត់ការរឿងស្រីកំណាន់ឲ្យនាង ហើយបើគេមានស្រីកំណាន់បាន នាងនឹងរកប្រុសកំណាន់មកទុកក្បែរខ្លួន។ នាងមិនគិតថាធ្វើខ្លួនជាស្រីសាវ៉ា តែនាងគ្រាន់តែគិតទុកសម្រាប់តំរាប រ៉េមសៀ តែប៉ុណ្ណោះ។



"អ្វី...រ៉េម..."



Scanned by CamScanner

តេចាប់ដៃរបស់នាង ស្រាក់ម្រាមដៃជាមួយគ្នា នាងក៏លើកត្រគាកដោយអារម្មណ៍រញ្ជួយ ពេលត្រូវគេថើបភ្លៅ ហើយអូសទៅដល់ម្រាមជើង។

"អ៊ុំ! កុំ...កុំ"

វែមសៀ មិនធ្លាប់មានគំនិតជាចង់ថើបជើងរបស់មនុស្សស្រី ប៉ុន្តែជើងសស្រឡូនគួរឲ្យស្រឡាញ់របស់ ការ៉ិន ធ្វើឲ្យគេចង់ថើប។ គេថើបខ្នងជើងទាំងសងខាងរបស់នាង នាងក៏មើលមុខគេដោយភ្នែកស្រឡឹង តាមមើលពេលដែលគេអូសបបូរមាត់មករកដើមទ្រូងទ្រលុកទ្រលន់។

នាងរែនទ្រូងទៅរកបបូរមាត់ក្ដៅ ប្រគល់ខ្លួនប្រាណឲ្យគេ ដោយមិនភ្លេចតតាំង ពេលដែលគេឱនមករក ជាងនោះទៅទៀត នៅក្រសោបដើមទ្រូងទាំងពីរ ដើម្បីឲ្យគេបឺតជញ្ជក់ទៀត។

ការ៉ិន ងើយក្បាលទៅផ្អែកនឹងបង្អែកសាឡុង បិទភ្នែកព្រិមៗ ព្រោះការប៉ះពាល់របស់ វែមសៀ ធ្វើឲ្យរាងកាយរបស់នាងក្ដៅ ហាក់ដូចត្រូវដុតដោយភ្លើង តែជាភ្លើងដែលនាងមិនចង់គេច មានតែចង់បោលសម្រុកទៅរកភ្នក់ភ្លើងនោះ ហើយរាំជាមួយគេ។

វែមសៀ លើកនាងបី នាងក៏លើកដៃឱប.ក និងថ្ងូចថ្ងូរពេលត្រូវគេគ្រប់គ្រងដោយភាពក្ដៅគគុក។ វែមសៀ មានកម្លាំងខ្លាំង ហើយការលើកនាងពបែបនេះ មិនមែនជាបញ្ហាសម្រាប់គេ។

"វែម វែម..."

នាងធ្វើបានត្រឹមហៅឈ្មោះ ខ្សឹបខ្សៀវអង្វរករ សុំក្ដីមេត្តាពីគេ ដែលនឹង



នាំនាងទៅកាន់គោលដៅនៃសេចក្ដីសុខ។

វែមសៀ គ្រប់គ្រងនាងដោយកាយវិការនេះ ខណៈនោះក៏នាំដើរពិនិត្យបន្ទប់ដេក ដែលគេមិនទាន់បានពិនិត្យឲ្យច្បាស់លាស់។ នាងថ្ងូចថ្ងូរនៅដើម.ក នាងអាចបានទទួលសេចក្ដីសុខហួសហេតុ ដល់ថ្នាក់ខ្យល់គនៅក្នុងលង្វែកទ្រូងរបស់គេ រាងកាយនទលគកទាំងពីរនៃបនិត្យជិតគ្នា ឲ្យអារម្មណ៍ក្ដៅគគុក ហើយនាងក៏ឱនខាំស្មារឹងមាំ និងស្រែកថ្ងូចថ្ងូរខ្លាំងៗ។

គ្រែធំទូលាយ គឺជាគោលដៅចុងក្រោយរបស់ វែមសៀ បន្ទាប់ពីគ្រប់គ្រងរាងកាយរបស់នាងស្ងប់ស្ងល់ម្ដងហើយម្ដងទៀត គេក៏ដាក់នាងទៅលើគ្រែ នាងក៏ត្រដាងដៃចាំ ពេលគេឱនមករក ក៏ស្រវាឱប។

"វែម..."

គេដូចភ្ញៀវដែលមកគោះទ្វារផ្ទះ ហើយនាងក៏បើកទ្វារស្វាគមន៍ ត្រូវការឲ្យគេចូលមកក្នុងផ្ទះជាបន្ទាន់។ ព្រោះខាងក្រៅកំពុងតែមានខ្យល់ព្យុះ ចំណែកខាងក្នុងមានភាពកក់ក្ដៅរង់ចាំគេ។

"ចូលមក"

អ្នកកំលោះគ្រហឹមនៅដើម.កព្រោះការអញ្ជើញនោះ ហើយនាំខ្លួនឯងចូលទៅធ្វើជាភ្ញៀវនៅក្នុងផ្ទះកក់ក្ដៅ ម្ចាស់ផ្ទះក៏ស្វាគមន៍ដោយភាពទន់ភ្លន់បន្ទាប់មកក៏បើកចង្ក្រានកម្ដៅឲ្យ ដើម្បីឲ្យគេមានភាពកក់ក្ដៅ ដោយមិនភ្លេចលើកនំចំណីផ្អែមល្ហែម មកទទួលដោយមិនហ្មងហែង។



វែមសៀ រេរានៅមាត់ទ្វារ ធ្វើដូចមិនចង់ចូលទៅ ទើបត្រូវម្ចាស់ផ្ទះទាញ

ចូលតែម្តង ឲ្យគេជ្រមិលចូលទៅក្នុងផ្ទះនាង ទើបត្រូវស្រែកគ្រហឹមនៅដើម.ក ព្រោះផ្ទះមួយនេះធ្វើឲ្យគេចូលហើយមិនចង់ចេញ។

"ខ្លារិហ្យា..."

គេក្រសោបក្បាលរបស់នាង ថើបថ្ពាល់រលោង ថើបខ្លាំងៗ ដែលទោះខ្លួនប្រាណរបស់នាងជោគទៅដោយញើស ក៏នៅតែក្រអូប។

"ឈឺទេ"

នាងគ្រវីក្បាលដាក់ដើមទ្រូងធំទូលាយ នាងធ្វើឲ្យគេជ្រមិល ចូលមករកដោយមិនបានត្រៀមខ្លួន ទើបគេត្រូវសួរនាំពីស្ថានភាពផ្ទះដ៏កក់ក្តៅដែលគេកំពុងតែជ្រក។

"ងើយមុខឡើង"

គេបញ្ជា ហើយផ្ទើយចង្ការបស់នាង ឱនទៅថើបបបូរមាត់ គេថើបនាងរាប់មិនអស់ តែមិនធ្លាប់ធុញទ្រាន់នឹងថើប។ គេមិនចូលចិត្តថើបមនុស្សស្រី ប៉ុន្តែគេថើប ការ៉ិន ដោយមិនចេះហត់នឿយ ហើយក៏គ្មានគំនិតថាប្រៀបធៀបនាងនឹងស្រីកំណាន់ដែរ។

ការ៉ិន តែងតែខុសពីស្រីៗទាំងនោះ ព្រោះនាងជាមនុស្សស្រីដែលត្រូវរៀបចំឲ្យធ្វើជាភរិយារបស់គេ ក្រៅពីនេះនាងមានគេជាបុរសដំបូង គេមិនធ្លាប់គិតទេថា ខ្លួនឯងចាប់អារម្មណ៍ភាពបរិសុទ្ធផ្ទផង់របស់មនុស្សស្រី ប៉ុន្តែពេលប្រពន្ធរបស់គេជាស្រីបរិសុទ្ធ គេតែងតែមានការពេញចិត្ត ចំពោះភាពជាម្ចាស់ដែលបានបោះត្រាលើខ្លួនប្រាណរបស់នាង នាងជារបស់គេ ជារបស់គេតែម្នាក់



គត់។

"នាងជារបស់ខ្ញុំ"

គេបង្ហាញភាពជាម្ចាស់ នាងក៏លើកដៃមកអង្អែលថ្ពាល់ ដកដង្ហើមចូលឲ្យពេញសួត ព្យាយាមនិយាយឲ្យច្បាស់ៗ។

"លោកទេដែលជារបស់ខ្ញុំ"

នាងមិនព្រមចាញ់ នាងត្រូវការ រ៉េមសៀ ប៉ុន្តែគេមិនប្រកែក គេប្រើវិធីធ្វើឲ្យនាងថ្ងូចថ្ងូរដល់ថ្នាក់ភ្លេចរឿងដែលនាងត្រូវការតវ៉ានឹងគេឲ្យដឹងចាញ់ឈ្នះ។

ការ៉ិន ភ្លេចទៅថាអ្នកណាជាម្ចាស់របស់អ្នកណា នាងត្រូវការឲ្យគេបម្រើនាង ធ្វើឲ្យនាងមានសេចក្តីសុខ រាងកាយនឹងឈប់វេទនា ដោយការប្រាថ្នាដ៏ក្តៅគគុក។ នាងខ្ទាំខ្នងរបស់គេ ដោយក្រចកមុតស្រួច ធ្វើឲ្យខ្នងរបកស្បែក ហើយពេលដែលវាប៉ះនឹងញើស ក៏ធ្វើឲ្យផ្សា តែ រ៉េមសៀ មិនបានយកចិត្តទុកដាក់ ហើយក៏មិនបានចាប់អារម្មណ៍វា។

"អ្ហ៎...ល្អដល់ហើយ..."

នាងចូលចិត្តភាពកក់ក្តៅចេញពីស្បែករបស់គេ នាងថើបថ្ពាល់របស់គេដែលការថើបដោយការថ្នាក់ថ្នមនេះ ធ្វើឲ្យ រ៉េមសៀ ភាំងមួយដង្ហើម ដូចបេះដូងរឹងកំព្រឹសបានទទួលការប្រោះព្រំដោយភាពទន់ភ្លន់ ដែលគេមិនធ្លាប់បានទទួល។

គេឱបក្រសោបនាងជាប់ដើមទ្រូង នៅក្រោមភាពកំណាចរបស់គេ ក៏មានភាពទន់ភ្លន់លាយឡំដែរ ដែលវាបានមកពី ការ៉ិន។





Scanned by CamScanner

កំលោះក្រមុំស្វាគមន៍ការធ្វើសកម្មភាពរបស់គ្នា ព្យុះព្យោមាក់ពុងតែបក់បោកយ៉ាងសាហាវ បន្ទាប់មកគេក៏ដឹកដៃគ្នា ធ្វើដំណើរទៅដល់គោលដៅនៃសេចក្តីសុខដ៏អស្ចារ្យនេះ។



# ១០

## សន្យារវាងយើងទាំងពីរ

"ទៅដើរលេង!"

ការ៉ុន ត្រូវការចេញទៅក្រៅខ្លះ ព្រោះបើនៅក្នុងដំណាក់ រ៉ែមសៀ នឹងនាំនាងនៅតែលើគ្រែ ធ្វើខ្លួនជាប់គ្នាដូចឆាខ្វៃ បេះមិនចេញ ដូច្នេះហើយ នាងចង់ទៅដើរលេង ទៅដើរលេង និងត្រូវតែបានទៅដើរលេង។

"ខ្លាំហ្យ៉ា"

"ទៅដើរលេង" នាងបញ្ជាក់ តែបន្តិចទៀត ប្រហែលស្រែកដាក់មុខគេហើយ ព្រោះសំឡេងស្រួចរលែមនោះ។

អ្នកកំលោះ លើកដៃសុំផ្អាកសង្គ្រាម ហើយងក់ក្បាល ជាការយល់ព្រម នាងក៏ឱបដៃ ញញឹមញញែម ពេលត្រូវបានអនុញ្ញាត។

ក្រោយពីបាននាំរ៉ែមសៀ សម្រាកផ្អាករឿងលើគ្រែហើយ នាងក៏លាក់លៀមរឿងផ្សេងដែរ នោះគឺចង់ទៅលេងនៅផ្សារនៅខាងក្រៅ ព្រោះមិនធ្លាប់ត្រូវបានអនុញ្ញាតពី ខាឡូម៉ាន់ ដោយហេតុផលរឿងសុវត្ថិភាព ប៉ុន្តែបើ រ៉ែមសៀ ជាអ្នកនាំ ទៅ គឺជារឿងមួយទៀត។

"ងក់ក្បាលតី?"

"អូខេ ទៅដើរលេងក៏បាន"



គេព្រមផ្អាកសង្គ្រាម នាងក៏សម្លក់សម្លឹង នាងតាមចិត្តគេស្ទើរតែចុះពីគ្រែមិនបានទាំងថ្ងៃទាំងយប់ ឡើងឈឺចង្កេះឈឺខ្នងរស់ទៅហើយ ថ្ងៃនេះ គេត្រូវតែតាមចិត្តនាងម្តង មនុស្សឆ្កួតស្នេហ៍ក៏មិនដឹង ក្រែកកាមម៉ាក់គុង អាងអីចាប់នាងសង្កត់លើគ្រែ។

នាងមិនមែនជាមនុស្សស្លឹកស្រពន់ ទើបចូលចិត្តដេក ប៉ុន្តែ រ៉ែមសៀញាត់ញៀតឲ្យនាងដេកទៅកើត តែគេមិនអនុញ្ញាតឲ្យនាងដេកលក់ តែឲ្យដេកអស់កម្លាំង មានតែពេលទទួលទានអាហារប៉ុណ្ណោះ ដែលគេព្រមឲ្យនាងនៅឆ្ងាយពីខ្លួន។

"យល់ព្រមហើយ ហាមក្រឡាស់សម្តី"

"ទៅឬមិនទៅ"

ស្ងប់ញ្ញឹង ចាំចាប់សម្លុត រាងអីសម្លុតៗ បើមិនបានសម្លុតក៏ចាប់សង្កត់ រ៉ែមសៀ ដាវ៉ៃហឺណោស ប្រហែលចេះធ្វើតែរឿងពីរមុខនេះទេ។

"ទៅ ទៅឥឡូវទេ"

គេខំនាំទៅដើរលេងហើយ និយាយស្តីពីរោះដាក់បន្តិចក៏បាន ចាត់ទុកថា ជាការដោះដូរ។ នាងកំពុងមានសេចក្តីសុខ ទើបខ្ជិលធ្វើខ្លួនរឹងទទឹងដាក់រ៉ែមសៀ។

"ទៅមិនទាន់បាន"

"អេ៎! ចង់ទៅ ទៅថ្ងៃនេះ និងពេលនេះដែរ"

បើមិនចង់ឲ្យខ្នងជាប់នឹងគ្រែនាងត្រូវតែឆាប់បញ្ជាក់ នាងរង់ចាំមិនបាន



ទេ រ៉ែមសៀ អាចនាំនាងឡើងគ្រែទៀតជាការដោះដូរនឹងបានទៅក្រៅដើរលេង ទោះនាងជាប់ចិត្តក៏ដោយ ប៉ុន្តែក៏ចង់សម្រាករាងកាយដែលត្រូវគេប្រើប្រាស់ហួសហេតុពេកខ្លះដែរ។

"ទៅប្តូរខោអាវ"

"ឈុតនេះមិនបានឬ"

នាងបង្វិលខ្លួនឲ្យគេត្រួតពិនិត្យ ឈុតធម្មតារបស់នាង ប្រណីតជាងឈុតធម្មតារបស់ប្រជាជន ប៉ុន្តែគេមិនមែនជាមនុស្សដែលចូលចិត្តអធិប្បាយ ទើបគ្រវីក្បាល ព្រមទាំងគំរាម។

"ទៅទេ ?"

"ទៅ ហាមប្តូរចិត្ត!"

"អីចឹងទៅផ្លាស់ខោអាវ"

"ទៅឥឡូវហើយ"

នាងបន្ទន់ជង្គង់ ធ្វើការគោរព ដែលជាការបញ្ឈឺ តែ រ៉ែមសៀ បែរជាមិនខឹង ព្រោះស្នាមញញឹមរបិលរប៉ូចនៅលើបបូរមាត់ក្រៀវរូបផ្អែមនោះ ហើយហៅអ្នកបម្រើឲ្យទៅជួយ។

"ត្រូវប្តូរឈុតណា"

ពេលចូលមកក្នុងបន្ទប់តែងខ្លួន នាងក៏មានបញ្ហានឹងការរើសឈុត ព្រោះសម្លៀកបំពាក់នៅក្នុងទូ សុទ្ធតែមិនធម្មតា ទោះព្យាយាមរើសហើយរើសទៀតក៏ដោយ។



"សុំពេលមួយភ្លែត ព្រះនាង"

ហ្វ៊ីវ៉ា ប្រាប់ ហើយទៅបាត់មួយសន្ទុះ ក៏ត្រឡប់មកវិញ ដោយសម្លៀក-បំពាក់មួយឈុត ដែលធ្វើឲ្យព្រះនាង មើលមិនដាក់ភ្នែក។

"ពាក់ឈុតនេះ"

"ប្ដូរៗ ឲ្យឆាប់ឡើង តិចតាប៉ិនោះប្ដូរចិត្ត"

"ត្រូវហៅឲ្យពីរោះ" ហ្វ៊ីវ៉ា ជួយដាស់តឿនឲ្យហៅឲ្យពីរោះ។

រ៉ែមសៀ ដែលឈរឱបដៃនៅមុខបន្ទប់តែងខ្លួន ចង់តែចាប់នាងទះកំប៉េះគូទឲ្យខ្លាំងៗ ហើយគិតថា ការ៉ែន ត្រូវតែចូលវគ្គអប់រំរឿងមារយាទនៅក្នុងការប្រណិបត្តន៍ចំពោះស្វាមី ទាំងនៅចំពោះមុខនិងក្រោយខ្នង។

"ក៏បាន តិចលោកឧត្តមសេនីយ៍ រ៉ែមសៀ រង់ចាំ ឆាប់ផ្លាស់ទៅ"

នាងឈរឲ្យអ្នកបម្រើ ជួយដោះសម្លៀកបំពាក់ និងស្លៀកពាក់ឲ្យ ហើយពេលរួចរាល់ក៏ពិនិត្យខ្លួនឯងនៅក្នុងកញ្ចក់បន្តិចបន្តួច ទើបងាកទៅហៅអ្នកបម្រើជំនិតឲ្យទៅតាម។

នាងចង់ទៅដើរលេងផ្សារយូរហើយ បានឮអ្នកបម្រើនិយាយគ្នាថាមានរបស់ឲ្យជ្រើសរើសច្រើនណាស់។

នាងដើរដូចរត់ ទៅរក រ៉ែមសៀ ដោយភាពរីករាយ ដោយឈុតដែលនាងពាក់ ស៊ីឡា ទៅសុំខ្ចីអ្នកបម្រើនៅក្នុងដំណាក់មកឲ្យ ជាអាវដៃវែងពណ៌ស មានប៊ូតុងនៅត្រង់កអាវ ពាក់អាវដៃវាលពីលើ និងសំពត់ជាប់ខោ តួសំពត់ ត្រូវកាត់ពីក្រណាត់សូត្រ ពណ៌ស្រស់ ដេរជាប់នឹងខោជើងវែងពណ៌ស ហើយនាងពាក់



ស្បែកជើងកែងទាប ត្រៀមខ្លួនរួចរាល់សម្រាប់ការដើរស៊ីបភីង។

គំនិតកំណាចតិចតួច កើតឡើងនៅក្នុងចិត្ត រ៉ែមសៀ មិនមែនជាមនុស្សប្រុសដែលចូលចិត្តដើរស៊ីបភីង ខណៈដែលនាងចូលចិត្តខ្លាំងណាស់ គ្រាន់តែនាងប្ដូរពីការស៊ីបភីងនៅក្នុងហាងទំនើបឬស៊ីបភីងតាមកាតាឡុកពិសេសដែលប្រេនដ៍ល្បីឈ្មោះយកមកឲ្យ មកជាការស៊ីបភីងនៅក្នុងផ្សារ។

ឌីអិនអេនៃការបំផ្លាញលុយ មាននៅក្នុងឈាម ដូច្នេះហើយ មិនថាស៊ីបភីងនៅឯណា ក៏នាងអាចចាត់ការវាបាន ចំណែក រ៉ែមសៀ ច្បាស់ជាមួម៉ៅនឹងការដើរតាមនាង។ ក្រៅពីនាងទទួលបានសេចក្ដីសុខពីការស៊ីបភីងហើយក៏ទទួលបានសេចក្ដីសុខពីការធ្វើបាបគេដែរ។

"ទៅបានហើយឬនៅ"

រ៉ែមសៀ ងក់ក្បាល ហើយដើរនាំមុខនាង ចេញពីដំណាក់ សំដៅសេះពណ៌ខ្មៅធំ ដែលអ្នកមើលថែសេះ ឈរកាន់ខ្សែនៅត្រង់នោះ។

"ត្រូវជិះសេះទៅឬ ?"

រ៉ែមសៀងក់ក្បាលជំនួសចម្លើយមាត់ប្រហែលជាធុញណាស់ហើយមើលទៅ មនុស្សឆ្កួត!

នាងលួចជៀមដាមគេនៅក្នុងចិត្ត ហើយត្រដាងដៃឲ្យគេជួយលើកដាក់លើខ្នងសេះ។ នាងឃើញសេះមានតែមួយ ដូច្នេះហើយ នាងត្រូវតែបានជិះសេះជាមួយគេ ហើយក៏មិនចំណាយពេលលេងខ្លួន ព្រោះចង់ទៅដើរលេងជាងការឈរឈ្លោះនឹង រ៉ែមសៀ។



ការជិះសេះនៅក្នុងប្រទេសសាក់ខាវៀ មិនមែនជារឿងប្លែក ព្រោះក្រៅពីមានផ្លូវថ្នល់សម្រាប់ឲ្យយានយន្តហើយ ក៏មានផ្លូវសម្រាប់ឲ្យសេះរត់ អមផ្លូវយានយន្តដែរ។

វ៉ែមសៀ លើកនាងដាក់ទៅលើខ្នងសេះ ហើយឡើងមកតាម ទើបនាងស្រសុល ទៅបៀតនឹងដើមទ្រូងធំទូលាយ មិនងរង៉ក់ មិនលេងខ្លួន។

នាងរៀបចំខ្លួនឯងឲ្យអង្គុយស្រួលខ្លួនបំផុត និងមានសុវត្ថិភាពបំផុត ចំណែកតួនាទីបញ្ជាសេះ ទុកឲ្យ វ៉ែមសៀ ជាអ្នកចាត់ការ ហើយនាងងាកទៅស្រាវដៃដាក់អ្នកបម្រើទាំងពីរ បន្ទាប់មក វ៉ែមសៀ ក៏យកមួកពីអ្នកបម្រើដែលហុចឲ្យមកដាក់ពីលើក្បាលរបស់នាង។

"ចងឲ្យផង"

"ចងខ្លួនឯង"

"មិនចេះចង"

នាងតប ដោយភាពក្រអឺតក្រទមមួកមានខ្សែចងនៅក្រោមចង្កា វ៉ែមសៀ ដកដង្ហើមធំ តែក៏ព្រមលើកដៃស្ទាបរកខ្សែដើម្បីចងឲ្យនាង ទាល់តែរួចរាល់។

"អរគុណ"

"រីករាយដល់ហើយ"

"ខ្ញុំមិនមែនជាមនុស្សបៀមទុក្ខដូចលោកហ្នឹងណា" នាងស្ទុកទៅវិញលឿនដូចព្យុះ។

វ៉ែមសៀចាប់បង្ហៀកន្ត្រាក់ឲ្យសេះចេញដំណើរដែលធ្វើឲ្យនាងភ្ញាក់ព្រើត



ព្រោះគេបេះបួយនោះឯង ដោយការធ្វើឲ្យសេះចេញដំណើរលឿនពេក ទើបស្រសុលទៅរក ខ្ញាំស្លៀវបស់គេ ដែលសៀកខោខូវប៊ោយសាច់ក្រាស់ ទើបគេមិនឈឺ មិនរសើបស្បែក។

ធ្វើទុកសិនចុះ!

នាងចងអាឃាតគេនៅក្នុងចិត្តតិចតួច បើមិនភ្លេច និងមានឱកាសច្បាស់ជាសងសឹក ប៉ុន្តែពេលនេះ នាងធ្វើទុកសិនចុះ ព្រោះកំពុងតែបានទៅដើរលេង នាងត្រូវធ្វើខ្លួនឯងឲ្យមានអារម្មណ៍ល្អ ធ្វើឲ្យខួរក្បាលស្រឡះល្អ ហើយគំនិតក៏ធ្វើការបានល្អដែរ ពេលទៅដល់ផ្សារ នាងនឹងសងសឹកគេ។

កាអ៊ុន លួចញញឹម មិនហ៊ានញញឹមឲ្យគេឃើញ ព្រោះគេច្បាស់ជាខឹងចេញផ្សែងតាមត្រចៀកមិនខាន។ នាងរំភើបញាប់ញ័រនឹងផ្សារនៅក្នុងក្រុងក៏ពិតមែន ប៉ុន្តែបន្ថែមភាពរីករាយចូលទៅ ដើម្បីក្រឡុកក្រឆាគេជាពិសេស បានសងសឹកតិចតួចក៏ល្អដែរ។

នាងមានចេតនាចូលហាងនេះចេញហាងនោះ ឲ្យគេដើរតាមដែលពេល ខ្លះគេក៏តាមសង្រ្គបនាងឲ្យដើរក្បែរ ប៉ុន្តែដើរមិនបានយូរប៉ុន្មាន នាងក៏ចេញហាង នេះចូលហាងនោះ សប្បាយរីករាយបន្ត។



នាងធ្វើខ្លួនរីករាយ រំភើបញាប់ញ័រនឹងរបស់នៅជុំវិញខ្លួនដែលឃើញបានទំនងណាស់ ទើប វ៉ែមសៀ មិនដឹងទេថាខ្លួនកំពុងតែត្រូវធ្វើបាប ទាំងដែលការពិតទៅគេដឹង ទើបខាំធ្មេញក្រតៗ។ ឃើញបែបហ្នឹងហើយ នាងកាន់តែពេញ

ចិត្ត ព្រោះអាងអីក៏ស៊្តិឲ្យ អាងអីក៏ខឹង អីចឹងឲ្យគេខឹង ផ្ទុះសរសៃឈាមក្នុងខួរក្បាលទៅ។

"ខ្លារិហ្សា"

គេហៅ ពេលនាងប្រុងចូលទៅក្នុងហាងគ្រឿងលម្អ ហើយស្រវាចាប់ដៃជាប់ នាងមិនស្មានទេថាគេចាត់ការនាងដោយវិធីនេះ ប៉ុន្តែនាងក៏ងាកទៅមើលមុខព្រមទាំងធ្វើភ្នែកម៉ក់ៗមោយៗដូចមិនដឹងថាគេកំពុងហាត់រឿយនឹងការដើរតាមនាង។

"ដើរយឺតៗ"

"សុំទោស ភ្លេចខ្លួន ទីនេះមានសុទ្ធតែរបស់គួរឲ្យស្រឡាញ់"

កាអ៊ីន ដើរចេញហាងនេះចូលហាងនោះដូចមុននេះ ដើម្បីធ្វើឲ្យរ៉ែមសៀ ឈឺក្បាលដូចមុនលែងបានទៀត ទើបត្រូវប្តូរផែនការ ដើរមើលរបស់ដែលខ្លួន ចូលចិត្តពិតប្រាកដ ដោយគេចាប់ដៃជាប់ មិនព្រមលែង។ ប៉ុន្តែនាងរង់ចាំឱកាសដែលគេព្រលែងដៃ និងធ្វើបាបគេជាថ្មី។

"ក្រវិលស្អាតដល់ហើយ"

នាងចូលទៅហាងគ្រឿងលម្អ រើសក្រវិលមើល ដែលពេលនោះត្រូវរ៉ែមសៀ ព្រលែងកដៃបណ្តោះអាសន្នឲ្យនាងដើររើសនេះរើសនោះបានតាមចិត្ត ដោយគេដើរតាមពីក្រោយ តែមិនភ្លេចក្រឡេកមើលទៅជុំវិញខ្លួន ដើម្បីជាការការពារសុវត្ថិភាព។ ពួកគេមិនបានបង្ហាញសមាសភាពពិត ចូលមកបន្លំខ្លួនជាមួយអ្នកភូមិអ្នកស្រុកនៅក្នុងផ្សារ ប៉ុន្តែគេត្រូវតែប្រុងប្រយ័ត្នដដែល ព្រោះអាច



មានមនុស្សចំណាំបាន។ រឿងមួយទៀតដែលគេបានដឹង គឺ កាអ៊ីន ក្លាយជាចំណាប់អារម្មណ៍របស់អ្នកផង ព្រោះរូបរាងមុខមាត់របស់នាងស្អាតលេចធ្លោទោះស្លៀកសាមញ្ញៗក៏ដោយ។ មនុស្សស្រីមើលនាងមិនប៉ុន្មាន តែខ្សែភ្នែកមនុស្សប្រុស ដែលមើលមក ដោយមិនក្រែងអែងចិត្ត ធ្វើឲ្យគេមួម៉ៅ។

ប្រពន្ធអញ!

គេកើតចិត្តហួងហែងនាង ទើបដើរទៅឈរបៀត នាងក៏ងាកមកញញឹមដាក់ ព្រមទាំងលើកក្រវិល ដាក់នឹងទងត្រចៀក ឲ្យមើល។

"ស្អាតទេ"

នាងមើលរបស់ច្រើនហាង ប៉ុន្តែទើបតែនឹកឃើញថាចង់ទិញនៅហាងនេះ ព្រោះឈប់ធ្វើបាបគេហើយ។

"ចង់ទិញក៏ទិញទៅ"

"ស្ងួរប៉ុណ្ណឹងចាំបាច់មួម៉ៅ"

នាងជ្រួញច្រមុះដាក់ ហើយងាកទៅរើសក្រវិលបន្ត ដោយរើសបានបីគូ ពេលរួចរាល់ក៏លូកហោប៉ៅ ហើយនឹកឃើញថា ម៉ោជាមួយ រ៉ែមសៀ ចាំបាច់ចេញលុយខ្លួនឯងធ្វើអី។

"ឲ្យលុយថ្លៃក្រវិលផង"

នាងងាកទៅកេះ ហើយពេលប្រពន្ធបញ្ជា គេក៏លូកហោប៉ៅ យកលុយមកឲ្យអ្នកលក់ ដោយមិនអែនអន ហើយពេលយកថង់ក្រវិលពីអ្នកលក់ នាងក៏ហុចឲ្យគេកាន់។



"ជាសុភាពបុរស ត្រូវជួយសុភាពនារីកាន់អីវ៉ាន់"

នាងញញឹមពព្រាយខុសពីធម្មតា ហើយប្រាប់ រ៉ែមសៀ កឹដកដង្ហើមធំ យកថង់ក្រដៃមកកាន់ ចំណែកដៃម្ខាងទៀតនៅតែចាប់កដៃរបស់នាងជាប់ បង្ការនាងទុកគេចោលព្រោះតែសប្បាយនឹងការដើរសើបតឹង។

រ៉ែមសៀ សង្កេតការណ៍នៅជុំវិញខ្លួន បុរសនៅក្នុងផ្សារនៅតែមើល ការ៉ិន ដោយការចាប់អារម្មណ៍ ទើបគេត្រូវប្រើរាងកាយរបស់ខ្លួនឯង បិទបាំងរាងតូចស្ដើងរបស់នាង ដោយនាងមិនដឹងខ្លួន ព្រោះរវល់តែចាប់អារម្មណ៍របស់របរហើយពេលនាងចង់ចូលហាងសម្លៀកបំពាក់តាមការអញ្ជើញរបស់អ្នកលក់ គេក៏មិនអនុញ្ញាត។

កន្លែងលខោអាវនៅក្នុងហាងសម្រាប់គេវាគ្មានសុវត្ថិភាព ព្រោះវាគ្រាន់តែជាក្រណាត់បួនជ្រុងដែលត្រូវដាក់បាំង ឬចង់ប្រាប់ថាគេហ្វូងហែងខ្លួនប្រាណរបស់នាងក៏ជាបាន គេអាចឱបលើប ស្ដាប់អង្គែលបានតែម្នាក់ប៉ុណ្ណោះ ម៉េចនឹងព្រមឲ្យនាងមកផ្លាស់សម្លៀកបំពាក់នៅក្នុងហាងកណ្ដាលផ្សារបែបនេះបានទៅ គេមិនអនុញ្ញាត។

"ចង់ទិញ ក៏ទិញទៅ តែមិនបាច់ល"

សំឡេងកាចបន្តិចឡើង អមដោយមុខក្រមូវ ធ្វើឲ្យអ្នកលក់ ដែលបញ្ចុះបញ្ចូលឲ្យនាងជួយទិញ និងល ញញឹមមិនសប ដូច្នេះហើយដើម្បីលួងចិត្តអ្នកលក់ ទើប ការ៉ិន ទិញពីឈុតដោយចង់ទៅផ្ញើ ស៊ីឡា និង ហ្វីវ៉ា។

នាងចូលហាងផ្សេងដែរ និងមិនបានល ព្រោះដឹងហើយថាវានឹងធ្វើឲ្យ



រ៉ែមសៀ ខឹងជាងពេលដែលគេតាមសង្គ្រប់នាងឲ្យដើរក្បែរទៅទៀត។ នាងទិញខោអាវបានច្រើន និងរបស់របរឯទៀត យកទៅផ្ញើអ្នកបម្រើ ចំណែក រ៉ែមសៀ មានតួនាទីចេញប្រាក់ និងកាន់អីវ៉ាន់ឲ្យ ទាល់តែនាងហត់នឿយនិងចង់ត្រឡប់ទៅដំណាក់វិញនោះឯង។

"ហត់ដល់ហើយ"

"សមហើយ"

ដើរមិនឈប់ ទិញអីវ៉ាន់យួរសំពីងសំពោង ព្យួរឡើងធ្ងន់តូទសេះ បើមិនហត់ទើបចម្លែក។

ការ៉ិន អែនខ្នងផ្អែកនឹងដើមទ្រូងធំទូលាយ ព្រមទាំងដោះមួកទុកព្រោះអាកាសធាតុត្រជាក់ហើយ មិនចាំបាច់ពាក់ឲ្យហប់។

"ហត់ តែសប្បាយណាស់"

នាងប្រាប់ពីអារម្មណ៍ពិតប្រាកដបានចេញមកក្រៅក៏ធ្វើឲ្យមានអារម្មណ៍ធូរស្រាល។ ការមានឋានៈខ្ពង់ខ្ពស់ ទោះទទួលបានភាពសុខស្រួល ប៉ុន្តែសេរីភាពគឺជារឿងដែលមានភាពតឹងតែង សូម្បីតែនៅបរទេស ក៏ត្រូវរស់នៅក្រោមច្បាប់ទម្លាប់ នោះគឺដើម្បីសុវត្ថិភាពរបស់នាង។

"ខ្យល់ត្រជាក់ដល់ហើយ" នាងមិនចាប់អារម្មណ៍ទេថា រ៉ែមសៀ ចង់និយាយជាមួយឬអត់ មិនចង់និយាយ អីចឹងនាងនិយាយម្នាក់ឯងក៏បាន 
អាកាសធាតុល្អដល់ថ្នាក់នេះ ខ្យល់ដ៏ត្រជាក់ស្រេង ពិះសេះនៅក្នុងបរិយាកាស



Scanned by CamScanner

បែបនេះ ឲ្យអារម្មណ៍រីករាយមែនទែន ចំណែកអ្នកដែលគ្មានអារម្មណ៍រីករាយ បណ្ដោយឲ្យគេម្ចុម៉ៅតែម្នាក់ឯងទៅ។

"អាកាសធាតុល្អមែនទែន"

នៅតែមិនព្រមនិយាយរកទៀត អីចឹងនាងនឹងនិយាយម្នាក់ឯងបន្ត ហើយលើកដៃត្រដាង ប៉ុន្តែត្រូវ រ៉ែមសៀ ចាប់សង្កត់។

"អង្គុយឲ្យស្រួល"

"កំពុងគយគន់ទេសភាព"

"គយគន់ទេសភាព មិនចាំបាច់ច្រងេងច្រងាងទេ"

នាងខ្ញាំភ្លៅរបស់គេ ប៉ុន្តែដោយសារសាច់ខោខូវប៊យក្រាស់ពេក ទើបវាមិនឆ្លុះដល់ស្បែក។

"ហាត់ដាច"

"និយាយអី"

"មិនបានឮចាត់ទុកថាមិនបាននិយាយ"

ចាត់ទុកថានាងបានជេរគេប្រហែលបន្តិចបន្តួចទៅចុះ។ ការ៉ុន លើកដៃចាប់ស្បៃឃ្មុំ វាជាស្បៃវែង ដណ្ដប់ពីលើខោអាវដែលនាងពាក់ និងមានឡេវរូបមេអំបៅនៅត្រង់ក។ នាងចូលចិត្តវាណាស់ ទិញវាដោយប្រាក់របស់ រ៉ែមសៀ ហើយក៏ពាក់ភ្លាម។

"លួចជេរខ្ញុំ ?"

"បើលួចជេរ លោកត្រូវតែមិនបានឮ អុំ!"



នាងភ្ញាក់ព្រើត ពេលគេលូកដៃចូលមកក្នុងអាវរបស់នាង។

"រ៉ែមសៀ!"

"ឡូឡា សេះផ្អើល"

គេចាប់បង្ហៀរសេះដោយដៃម្ខាង ចំណែកដៃម្ខាងទៀតដែលលូកចូលមកក្នុងអាវរបស់នាង ក៏លូកទៅប៉ះដើមទ្រូងដែលក្រសោបដោយអាវក្នុង ហើយខ្ញាំ។

"ប្រុសឆ្កួតនេះ លែង...លែងសិន"

ថ្ពាល់របស់នាងឡើងក្ដៅ ចង់ទាញដៃគេចេញពីអាវ តែធ្វើមិនបាន ហើយពេលម្រាមដៃនោះ ត្រវាសលើចុងទ្រូង ក៏ធ្វើឲ្យនាងទន់ខ្លួនល្ហុក។

"អ្ហឺ! ដកចេញ តិចមានគេឃើញ"

"អ្នកណាឃើញ"

គេសួរ ដោយសំឡេងរាងរឹង និងខ្ញាំដើមទ្រូងរបស់នាងដោយអារម្មណ៍ភ្លើតភ្លើន។ ឆ្នាសឆ្មើមបែបនេះ គឺត្រូវតែដាក់ទោសខ្លះ ហើយការដាក់ទោស ការ៉ុន មានវិធីមិនប៉ុន្មានប៉ុណ្ណោះដែលគេយកមកប្រើ។

គេនាំនាងជិះសេះតាមផ្លូវស្ងប់ស្ងាត់ ដែលគ្មានមនុស្ស។ គេមិនខ្លាចហើយជឿថាបើមានអ្វីកើតឡើង អាចការពារនាងបាន ចំណែក ការ៉ុន គ្មានអារម្មណ៍ថាភ័យខ្លាច ប៉ុន្តែមិនដឹងខ្លួនទេថានោះមកពីមាន រ៉ែមសៀ នៅជិត។



នាងរឹតដៃរបស់គេ គេក៏បន្ថែមកម្លាំងច្របាច់ ធ្វើឲ្យថ្ពាល់របស់នាងឡើងក្ដៅគគុក និងក្រហម ដោយការខ្មាសអៀន និងខឹង។

"វែមសៀ មនុស្សឆ្កួត"

"អង្គុយឲ្យស្ងៀម ស្ដាប់បង្គាប់ មិនអីចឹងនឹងច្របាច់ខ្លាំងជាងនេះ"

តេតំរាម នាងក៏ទះភ្លៅរបស់គេ ហើយទាញស្បៃបិទបាំងរាងកាយ ក្រែងលោមានអ្នកណាឆ្លងកាត់ឃើញ ប៉ុន្តែផ្លូវមួយនេះ ហាក់ដូចជួយគេ ព្រោះវាស្ងប់ស្ងាត់។

"វែម...វែម..."

ការច្របាច់ ដែលក្លាយជាការញោចអារម្មណ៍ ធ្វើឲ្យម្ចាស់ដើមទ្រូងទ្រលុកទ្រលន់ថ្ងូចថ្ងូរ។ វែមសៀ ឱនមកបើបសៀតផ្ការបស់នាង ដោយដៃនៅតែធ្វើតួនាទី ញោចអារម្មណ៍របស់នាងជាបន្តបន្ទាប់ ទាល់តែជិតដល់ដំណាក់នោះឯង ទើបដកដៃចេញ។

"ទុកដាក់របស់ឲ្យរៀបរយ" គេចេញបញ្ជាក់ដាក់ ស៊ីឡា និង ហ៊្វីភ៉ា ពេលត្រឡប់មកដល់ដំណាក់។

វែមសៀ ចុះពីខ្នងសេះ ហើយហុចដៃទៅរកស្រីស្អាត លើកនាងចុះពីខ្នងសេះ តែមិនព្រមដាក់ចុះ ហើយឱនថើបបបូរមាត់ដែលនាងក៏ថើបតវិញភ្លាម ព្រោះត្រូវគេដាស់អារម្មណ៍ឲ្យភ្ញាក់ទៅហើយ។

ហ៊្វីភ៉ា និង ស៊ីឡា ដឹងតួនាទីថាមិនត្រូវទៅរំខានចៅហ្វាយនាយ ដែលឱបថើបគ្នាចូលទៅក្នុងបន្ទប់ដេក និងសម្ងំនៅក្នុងនោះរាប់ម៉ោង ហើយបើមានអ្នកណាព្រហើនយកត្រចៀកទៅផ្ទឹបនឹងទ្វារបន្ទប់ ដើម្បីលួចស្ដាប់ គឺអាចបានឮសំឡេងថ្ងូចថ្ងូរតិចៗ។

វែមសៀ ក្រសោបរាងកាយជោកដោយញើសរបស់អ្នកដែលនៅតែដកដង្ហើមដង្ហក់ មកឱបជាប់ទ្រូង ការ៉ុន ក៏សម្ងំនៅក្នុងរង្វង់ដៃរបស់គេ ឲ្យគេថើបថ្ពាល់ និងប្រសព្វភ្នែកជាមួយគ្នាមួយសន្ទុះ ហើយនាងក៏គេចភ្នែក ដោយការឈ្ងោកមុខឈ្ងោកមាត់ ប៉ុន្តែរាងកាយនៅតែត្រសុលទៅរក។

វែមសៀ មានមាឌធំ ប៉ុន្តែវាមិនបានផ្ទុកដោយខ្លាញ់សុទ្ធសាធ ភាគច្រើនសុទ្ធតែសាច់ដុំរឹងមាំ។ នាងដាក់ដៃលើដើមដៃរបស់គេ ពេលប្រៀបធៀបទៅឃើញថាដៃរបស់នាងតូចមែនទែន ខុសពីដៃរបស់គេ ដែលទាំងធំ មានសាច់ដុំរឹងមាំ។

វែមសៀ មិនធ្លាប់ការពារ ទំនាក់ទំនងរវាងនាងនិងគេដូចស្វាមីភរិយាដែលរវល់នឹងការបង្កើតទាយាទ ក្នុងពេលដែលគេលេបត្របាក់នាងម្ដងហើយម្ដងទៀតដោយប្រាសចាកការការពារ នោះមានន័យថាគេត្រូវការឲ្យនាងពពោះកូនរបស់គេ។

កូនរបស់នាងដែរ!

នាងភ្លេចខ្លួន អង្អែលពោះខ្លួនឯង ហើយបើនាងនិងគេមានកូនជាមួយនាង តើកូននឹងមានមុខមាត់ដូចឪពុកឬម្ដាយ។

"បាត់ហត់ហើយឬនៅ"

វែមសៀ លើកដៃអង្អែលត្រគាកមូលក្លំ ការ៉ុន ទន់ល្មៀយសព្វសាច់ តេ



ចូលចិត្តឲ្យរាងកាយរបស់ពួកគេនៅនែបនិត្យជិតគ្នា។

"ចាំ" នាងតបតែប៉ុណ្ណឹង ដៃនៅតែអង្អែលដើមទ្រូងលម្អដោយសាច់ដុំ និងរោមដែលធ្វើឲ្យរមាស់បាតដៃតិចៗ។ វែមសៀ ជាបុរសសិចស៊ី តែនាងមិនប្រាប់ឲ្យគេដឹងថាជាដាច់ខាត។

"និងអាលបន្ត"

"ស្អី...ស្អីគេ"

នាងភ្លាត់ស្មៀតឲ្យគេទៅហើយតើមែនឬអត់ នាងចង់បបោសអង្អែលឱបក្រសោប និយាយគ្នា ថើបគ្នាខ្លះក៏បាន ហើយបើគេចង់បន្តម្ដងទៀត គឺត្រូវរង់ចាំ នាងត្រូវការពេលវេលាសម្រាកឲ្យរាងកាយមួយសន្ទុះ ប៉ុន្តែ វែមសៀ មិនឲ្យឱកាសនោះ។

"តាប៉ិត្ត វែមសៀ!"

នាងស្រែកបានតែប៉ុណ្ណឹង បបូរមាត់ក៏ត្រូវគ្រប់គ្រង និងត្រូវរុញឲ្យដួលទៅលើគ្រែ ដោយបបូរមាត់របស់ពួកគេនៅតែនែបនិត្យជិតគ្នា យកពេលឈ្លោះជាមួយនាងទៅក្រោចអារម្មណ៍របស់នាងវាមានប្រយោជណ៍ជាង។

នាងជាស្រីក្ដៅគគុក ដុតងាយឆេះថើបមួយសន្ទុះស្ទាបអង្អែលរាងកាយបន្តិចទៀត នាងក៏ទោរទន់តាមទៅហើយ ដៃដែលប្រឹងរុញច្រាន ក៏លើកឱបរឹតពេលត្រូវគេថើបខ្លាំងៗពេលណា នាងក៏ទោរទន់តាមការប៉ះពាល់នោះ ត្រូវតេថើបសព្វសាច់ ឰនាទីរបស់នាង គឺទោរទន់តាម និងថ្ងូចថ្ងូរ ហើយបន្តដោយការស្រែកខ្លាំងៗ ពេលដែលរាងកាយរបស់ពួកគេរលាយក្លាយជាសាច់មួយ។



មន្ត្រីផ្នែកច្បាប់របស់ខាឡម៉ាន់ត្រូវបញ្ជូនឲ្យមកជួប កាអ៊ីន និង វែមសៀ នៅក្នុងបន្ទប់ធ្វើការក្នុងដំណាក់របស់ព្រះនាង ក្រៅពីនេះ វែមសៀ ក៏ហៅអ្នកច្បាប់របស់ខ្លួនមកដែរ។

កិច្ចសន្យាមង្គលការរបស់ពួកគេ ត្រូវយកមកឲ្យត្រួតពិនិត្យ។ រឿងផលប្រយោជន៍ និងទ្រព្យសម្បត្តិ វែមសៀ គ្មានបញ្ហាចំពោះខ្លឹមសារពិស្ដារនៅក្នុងកិច្ចសន្យាមង្គលការ កាអ៊ីន ក៏អីចឹងដែរ។ នាងដឹងថាគេមានទ្រព្យសម្បត្តិ តែមិន នឹកស្មានថាច្រើនដល់ថ្នាក់នេះ តែនាងក៏មិនបានចាប់អារម្មណ៍អីណាស់ណា សូមត្រឹមគេមើលថែនាងបានល្អទៅគឺគ្រប់គ្រាន់ហើយ។

នាងគ្មានបញ្ហា នឹងការមិនបានទទួលសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរបស់គេ ព្រមទទួលយកប្រាក់ខែពីគេ ដែលវាមាននៅក្នុងសេចក្ដីលម្អិតតូចៗដែលនាងត្រូវការល្មម។ កិច្ចសន្យាទ្រព្យសម្បត្តិ ពួកគេយល់ឃើញដូចគ្នានិងស៊ីញ៉េភ្លាមៗ ប៉ុន្តែមានកិច្ចសន្យាពិសេស ដែល កាអ៊ិន ឲ្យមន្ត្រីផ្នែកច្បាប់របស់ខ្លួនពង្រាងតាមតម្រូវការរបស់នាងជាពិសេស។ នាងញញឹមញញែម ពេលហុចកិច្ចសន្យានោះឲ្យ វែមសៀ ដែលគេទទួលយក និងមើលមកនាង ពេលឃើញស្នាមញញឹមហើយ ក៏មានអារម្មណ៍មិនស្រួលចិត្ត ជាតួអក្សរនៅក្នុងកិច្ចសន្យានោះ បង្ករឿងឈឺក្បាលអីឲ្យគេទៀត។

"លោកត្រូវស៊ីញ៉េកិច្ចសន្យាពិសេសនេះដែរ ជាកិច្ចសន្យាបន្ថែម"

"ខ្ញុំត្រូវអានសិន"

"បើលោកឧត្តមសេនីយ៍ វែមសៀ ត្រូវការអីបន្ថែម អាចជូនដំណឹងបាន"



មន្ត្រីផ្នែកច្បាប់របស់ ការ៉ុន ប្រាប់លោកឧត្តមសេនីយ៍ដោយការគោរព។

"កិច្ចសន្យាតែបន្តិចហ្នឹងឯង លោកជាបុរសចិត្តទូលាយ ត្រូវព្រមទទួលយក មែនទេ"

ការ៉ុន ផ្ទួលខ្លួនទៅរក ដាក់ដៃលើដើមទ្រូងធំទូលាយ ឱបរឹតតែ ធ្វើដូចទាក់ទាញ តែតាមពិតទៅ រ៉ែមសៀ គិតថានាងចង់ញ៉ោះឲ្យគេខឹងច្រើនជាង។

បពោសអង្អែលគេតិចតួច នាងក៏ថយទៅអង្គុយស្រួលបួលវិញ លើកដៃទ្រចង្ការ ញញឹមញញែមដាក់។

កិច្ចសន្យាបន្ថែមច្បាប់ពិសេស

គោលបំណង ៖ ដើម្បីរក្សាភាពសុខសាន្តនៅក្នុងគ្រួសារ និងជាការប្រគល់សេចក្តីសុខឲ្យភរិយា ដែលត្រូវជាកូនក្រមុំរបស់ រ៉ែមសៀ ដាវ៉ៃហ៊ីណេស

គូភាគីនៃកិច្ចសន្យា ៖

ការ៉ុន ខ្លារិហ្សា ចាង ម៉ាលខៃសេនតេ និង រ៉ែមសៀ ដាវ៉ៃហ៊ីណេស

សូមធ្វើកិច្ចសន្យាដូចខាងក្រោម ៖

១- រ៉ែមសៀ ដាវ៉ៃហ៊ីណេស ត្រូវលុបចោលការមានស្រីកំណាន់ និងត្រូវមាន ការ៉ុន ខ្លារិហ្សា ចាង ម៉ាលខៃសេនតេ ជាភរិយាតែម្នាក់គត់ បញ្ជាក់! ការ៉ុន ត្រូវជាភរិយាតែម្នាក់គត់របស់ រ៉ែមសៀ។

២- រ៉ែមសៀ ដាវ៉ៃហ៊ីណេស មិនថារៀបការដោយហេតុផលអ្វីក៏ដោយ ប៉ុន្តែត្រូវផ្តល់កិត្តិយសឲ្យភរិយា ស្តាប់បង្គាប់ភរិយា និងមើលថែភរិយាឲ្យមានសុភមង្គល បញ្ជាក់! ការ៉ុន ត្រូវជាភរិយាតែម្នាក់គត់របស់ រ៉ែមសៀ។



៣- ហាមក្បត់ចិត្តភរិយា បញ្ជាក់! ការ៉ុន ត្រូវជាភរិយាតែម្នាក់គត់របស់ រ៉ែមសៀ។

៤-ហាមត្រឡប់មកក្រោយម៉ោងប្រាំបីយប់ត្រូវត្រឡប់មកផ្ទះវិញឲ្យទៀងពេលរាល់ថ្ងៃ បើចាំបាច់ត្រូវរាយការណ៍ឲ្យភរិយាដឹងជាមុន និងត្រូវតែទទួលបានការអនុញ្ញាតពីភរិយា បញ្ជាក់! ការ៉ុន ត្រូវជាភរិយាតែម្នាក់គត់របស់ រ៉ែមសៀ។

៥-ហាមផឹកស្រាឲ្យស្រវឹង បញ្ជាក់! ការ៉ុន ត្រូវជាភរិយាតែម្នាក់គត់របស់ រ៉ែមសៀ។

៦- ហាមជក់បារីលើសពីពីរដើមក្នុងមួយថ្ងៃ ( បើចង់ឆាប់ស្លាប់ ជក់មួយថ្ងៃពីរកញ្ចប់ទៅ) បញ្ជាក់! ការ៉ុន ត្រូវជាភរិយាតែម្នាក់គត់របស់ រ៉ែមសៀ (តែបើ រ៉ែមសៀ ស្លាប់ ការ៉ុន អាចមានស្វាមីថ្មីបាន)

៧- ត្រូវមើលថែភរិយាឲ្យបានល្អ អាហារត្រូវធ្វើដោយចុងភៅល្បីឈ្មោះ សម្លៀកបំពាក់ ស្បែកជើង កាបូប ត្រូវតែជារបស់ប្រ៊ែនដ៍នេមល្បីឈ្មោះ របស់ថោកប្រើប្រាស់មិនបាន វាមាស់ស្បែក ខ្ទង់ចំណាយនៅក្នុងការតែងខ្លួន ត្រូវបែងចែកឲ្យដាច់ពីប្រាក់ខែ បញ្ជាក់! ការ៉ុន ត្រូវជាភរិយាតែម្នាក់គត់របស់ រ៉ែមសៀ។

៨- ការងារក្រៅផ្ទះ រ៉ែមសៀ ត្រូវប្រឹងប្រែងធ្វើឲ្យអស់ពីសមត្ថភាពដើម្បីសុខសន្តិភាពស្ថេរភាពរបស់ប្រជាជនប្រទេស សាក់ខារៀ បញ្ជាក់! ការ៉ុន ត្រូវជាភរិយាតែម្នាក់គត់របស់ រ៉ែមសៀ។



៩- ការងារនៅលើគ្រែមិនចាំបាច់ធ្វើច្រើនក៏បានដែរ ឲ្យរាងកាយមាន



Scanned by CamScanner

ពេលសម្រាកខ្លះ រៀងលើគ្រែគួរកំណត់មួយសប្ដាហ៍ ៣-៤ដង បញ្ជាក់! ការ៉ិន ត្រូវជាភរិយាតែម្នាក់គត់របស់ រ៉េមសៀ។

១០- ប្រាក់ខែត្រូវចូលក្នុងបញ្ជីទៀងពេលវេលា បញ្ជាក់! ការ៉ិន ត្រូវជាភរិយាតែម្នាក់គត់របស់ រ៉េមសៀ។

ដើម្បីសុវត្ថិភាព សុខភាពត្រចៀករបស់ រ៉េមសៀ ដាវ៉ែហ៊ីណេស សូមយល់ពីកិច្ចសន្យានេះ និងចុះហត្ថលេខាព្រមទាំងអនុវត្តតាមឲ្យខ្ជាប់ខ្ជួន កុំឲ្យលោកជំទាវជំទាលទាន់។

ការ៉ិន នៅតែញញឹមញញែម មើល រ៉េមសៀ ក្ដាប់ក្រដាសនោះស៊ីងតែខ្ទាំទៅហើយ ពេលគេអានដល់ចំណុចទី៦ ប៉ុន្តែនាងបែរជាធ្វើមុខមិនដឹងមិនឮនៅតែញញឹមពព្រាយដាក់។ គេងាកមកប្រសព្វភ្នែកជាមួយនាង ហាមគេមានប្រពន្ធចុង តែនាងបែរជាត្រៀមការណ៍រួចរាល់ក្នុងការមានប្ដីថ្មី បើគេស្លាប់អីចឹងឬស្រីជើងល្អ។

"មានអីសង្ស័យឬ លោកឧត្ដមសេនីយ៍ រ៉េមសៀ" នាងហៅគេដោយសំឡេងដ៏ពីរោះ អ្នកកំលោះក៏ទាញប៊ិចមកគូសគ្រីសគ្រប់ចំណុច រួមទាំងការព្រមព្រៀងដែលនាងបញ្ជាក់ថានាងត្រូវតែជាប្រពន្ធតែម្នាក់គត់របស់គេនៅចុងប្រយោគគ្រប់ចំណុច ទាំងដែលដាក់មួយបន្ទាត់នៅចុងក្រោយក៏ចប់ទៅហើយ ប៉ុន្តែនាងពូកែបញ្ជាក់ ពូកែគិត។

រ៉េមសៀ គូសខ្វែងចំណុចទី ៩ ហើយសរសេរសារឡើងវិញ ដាក់ថា៖

៩- រៀងលើគ្រែ Unlimited មិនកំណត់ចំនួនដង មិនកំណត់ចំនួន



ពេលវេលា មិនកំណត់កាយវិការ ហាមរអ៊ូ បញ្ជាក់! នាងបានធ្វើជាភរិយាតែម្នាក់គត់របស់ខ្ញុំសមបំណង។

រ៉េមសៀ កែតែចំណុចទី ៩ ដែលធ្វើឲ្យម្ចាស់កិច្ចសន្យាបើកភ្នែកធំៗពេលឃើញគេស៊ីញ៉េបញ្ជាក់ ហើយហុចវាទៅឲ្យមន្ត្រីផ្នែកច្បាប់ ព្រិនចេញមកពីច្បាប់ បន្ទាប់មក គេក៏ស៊ីញ៉េលើឯកសារពីរច្បាប់នោះ និងព្រមកឲ្យ ដែលនាងត្រូវស៊ីញ៉េ ដោយញញើតនឹងចំណុចទី ៩ ដែលត្រូវកែប្រែ។



## ១១

### ស្នេហកក្តៅតតុក

"រៀបរយហើយ"

មន្ត្រីផ្នែកច្បាប់របស់ព្រះនាង និងលោកឧត្តមសេនីយ៍សរុប គ្រប់យ៉ាងបញ្ចប់យ៉ាងរលូន ទោះ រ៉េមសៀ មិនអាចនិយាយបានពេញមាត់ថាគេមានអារម្មណ៍ល្អ មើលទៅរាងក្រមូវ ធ្វើឲ្យមន្ត្រីដែលក្រែងរអែងចិត្តស្រាប់ទៅហើយកាន់ល្វែញខ្លួន ត្រូវប្រញាប់ចាត់ការឯកសារជាបន្ទាន់។

"សុំថ្វាយបង្គំលាព្រះនាង លោកឧត្តមសេនីយ៍"

មន្ត្រីផ្នែកច្បាប់ទាំងពីរគោរពលា ព្រោះទឹកមុខរបស់ រ៉េមសៀ បញ្ជាក់ថានឿយណាយនឹងការទទួលភ្ញៀវពេញបន្ទុក ហើយពេលមន្ត្រីចេញទៅពីបន្ទប់ធ្វើការ ការ៉ីន ក៏ប្រញាប់ប្រញាល់ងើបដែរ ប៉ុន្តែពេលដែលបែរខ្លួនដើរបានមួយជំហានប៉ុណ្ណោះ ក៏ត្រូវគេចាប់កដៃជាប់។

"ស្តី...ស្តីគេ ?"

"ចង់ទៅណា"

"រួចរាល់ការងារហើយតើ"

នាងធ្វើជាមិនដឹងខ្យល់អី តាប៉ុន្តែ រ៉េមសៀ ត្រេកកាម ទុកចិត្តមិនបានទេ ឃើញម៉ឺះៗ ប៉ុន្តែរឿងត្រេកកាមនាងទប់ទល់មិនដែលឈ្នះ។



"ខ្ញុំមិនទាន់ស្រេច"

"ស្រេចស្អីគេ! និយាយបែបនេះខ្ញុំតិតជ្រៅ!" នាងក្រមុំមិននិយាយ ឲ្យគេសៀតសិក ខ្លាចត្រូវខ្លួនឯង បង់ញើសបង់កម្លាំងកំដរគេ យ៉ាងណាក៏នាងមិនរួចខ្លួនដែរ ប៉ុន្តែសុំសម្រាកខ្លះ ចាំពេលយប់អីទៅ ព្រោះភ្ញាក់ឡើងគេចាត់ការឡើងពីរដងទៅហើយ ធ្វើឲ្យចង្កេះរបស់នាងចង់ដាច់ អីចឹងហើយនាងត្រូវកផ្សរស់ឲ្យខ្លួនឯង។

"វាជារឿងរបស់លោក"

នាងតើងទ្រូងដាក់គេទៀតហើយ និងប្រឹងទាញដៃចេញ ប៉ុន្តែមិនរបូត។

"ចាប់ធ្វើអីនេះ"

"ចង់រត់បន្ទាប់ពីបង្ករឿង ?"

"បង្ករឿងអី ?"

"អាកិច្ចសន្យាហេងស៊ុយនោះ"

"មាត់ដាច កិច្ចសន្យាសន្តិភាពទៅវិញទេ"

"អ្ហ៎! អីចឹងឬ"

រ៉េមសៀ ងើបចេញពីកៅអី នាងក៏ស្ទុះថយក្រោយ តែថយទៅណាមិនបាន ព្រោះត្រូវគេចាប់ដៃជាប់នោះឯង ហើយគេកញ្ឆក់តែបន្តិច រាងកាយរបស់នាងក៏ប៉ើងមកបុកនឹងរាងកាយមាំមួន ហើយត្រូវគេឱបចង្កេះ លើកដាក់លើតុធ្វើការ ទាត់កៅអីចេញឲ្យឆ្ងាយពីតុធ្វើការ ហើយលើកនាងដាក់ទៅលើនោះ។



អ្នកកំលោះចូលមកឈរនៅត្រង់ប្រឡោះជើងស្រឡូន ទ្រាន់ដៃនឹងតែម



Scanned by CamScanner

កុ យុំឃាំងនាងដោយរាងកាយ ប៉ុន្តែអ្នកនៅលើកុនៅតែពើងទ្រូង ទោះបេះដូងលោតដុកដាក់ក៏ដោយ។ ស្ថានភាពបែបនេះ នាងព្រមទទួលក៏បានដែរថា ខ្លួនឯងអស់ផ្លូវតែ។

"ត្រូវការអី ?"

"ត្រូវការចេញពីបន្ទប់នេះ"

"តបឲ្យត្រូវសំណួរ"

"សួររឿងអី ?"

"ខ្ញុំដឹងថានាងយល់"

គេប្រើកែវភ្នែកមុតស្រួចសម្លឹងមុខ នាងក៏សម្លក់វិញ នាងក៏ចង់ខឹងគេដែរ កែខៃរឿងលើគ្រែបែបហ្នឹង មន្ត្រីច្បាប់ដឹងអស់ទៅហើយថាគេត្រេកកាមបំផុត។

"ដើម្បីការសប្បាយចិត្តរបស់ខ្ញុំ"

"ហើយយ៉ាងម៉េចទៀត"

"វាស្អីក៏ម្លេះៗ"

"អធិប្បាយមក ខ្លារិហ្យា"

ព្រមស៊ីញ៉ េតែនាងត្រូវមានការអធិប្បាយសម្រាប់កិច្ចសន្យាបន្ថែមនោះ។ នាងក្រមុំមើលមុខគេដោយការងរង៉ក់ ហើយពើងទ្រូងដាក់ ដែលធ្វើឲ្យអ្នកមើលភ្ញាញ់ ទើបឱនមកបឺតជញ្ជក់បបូរមាត់ ឮសំឡេងខ្លាំងៗ។

"ហ៊ឺ! ឈឺ"



នាងលើកដៃរុញដើមទ្រូងធំទូលាយ រំមសៀ បើបម្តងទៀត និងងើបចេញ ខ្សែភ្នែកកាចក៏សម្លឹងមុខស្រស់ស្អាត ដែលធ្វើឲ្យនាងគិតថា រាចនឹងមិនបានចេញពីបន្ទប់នេះ បើធ្វើឲ្យគេមិនពេញចិត្ត។

"លោកមានស្រីកំណាន់ច្រើន ខ្ញុំទទួលយកមិនបាន បើលោកមានស្រីចាំប្រណិប័តន៍បែបហ្នឹង"

"ហើយនាងប្រណិប័តន៍ខ្ញុំអីបានខ្លះ"

"តាប៉ិត្តនេះ"

នាងខឹង សម្លក់សម្លឹង ស្រែកច្រៃតៗដាក់។ សម្តីបែបនេះបញ្ជាក់ថាគេស្គាយស្រីកំណាន់ទាំងនោះ មនុស្សចង្រៃ ប្រុសព្រាន សាវ៉ា។

"ខ្ញុំសួរនាងត្រូវតែឆ្លើយ មិនមែនជេរ"

"និយាយបែបនេះ បញ្ជាក់ថាស្តាយស្រីកំណាន់"

"យ៉ាងហោចណាស់ស្រីកំណាន់ មិនរឿងច្រើនដូចនាង"

នាងក្រមុំក្តាប់ដៃ តក់ដើមទ្រូងរឹងមាំ ហើយជេរខ្លួនឯងនៅក្នុងចិត្ត ដែលមិនចេះចាំ តក់ដើមទ្រូងរបស់គេពេលណា ឈឺដៃខ្លួនឯងពេលនោះ តែបែរចេះតែភ្លេច។

"មនុស្សល្មោភ"

"ខ្ញុំគ្មានបញ្ហាទេរឿងលុបចោលទំនាក់ទំនងនឹងស្រីកំណាន់ ប៉ុន្តែនាងត្រូវទប់ទល់ឲ្យបានល្អ ហាមរអ៊ូរទាំ"

នាងក្រមុំប្រឹងលេបទឹកមាត់ គិតថាខ្លួនឯងគិតខុសឬត្រូវ ដែលបញ្ជាឲ្យ



គេលុបចោលការមានស្រីកំណាន់ ប៉ុន្តែគិតចុះគិតឡើងក៏គិតថាគិតត្រូវ ព្រោះគ្មានស្រីណា ចង់ចែករំលែកប្ដីរបស់ខ្លួនឲ្យស្រីផ្សេង។

"យល់ទេ"

"យល់...យល់ក៏បាន"

រ៉ែមសៀ ខិនមកថើបតែបមាត់ទន់ល្មើយ នាងក៏ងាកខ្លួនគេច តែគេចមិនបាន ព្រោះត្រូវគេលើកដៃម្ខាងសង្កត់ខ្នងឲ្យនៅមួយកន្លែង។

"ការកំណត់របស់នាង ខ្ញុំព្រមទទួលទាំងអស់ តែអ្វីដែលខ្ញុំត្រូវការ នាងក៏ត្រូវព្រមទទួលដែរ"

កិច្ចសន្យាមួយច្បាប់នោះ នាងធ្វើដើម្បីចងខ្លួនឯងឬអត់ណំ ហេតុអីបានជានាងគ្មានអារម្មណ៍ថាខ្លួនឯងឈ្នះ រ៉ែមសៀ យ៉ាងអីចឹង!

"ដឹង...ដឹងហើយ"

"ចាំបាច់ត្រដិត"

"ខ្ញុំមិនបានត្រដិត តែនិយាយជាប់គ្នាច្រើនរាប់សិបឆ្នាំ ទើបអណ្ដាតវាហត់នឿយ ពិបាកគន្លាស់ អណ្ដាតវាល្វើយ យល់ទេ"

"ត្រូវពិសោធន៍"

គេចាប់ចង្កានាងជាប់ ខិនថើបបបូរមាត់ទន់ល្មើយ នាងក៏បង្ហើបមាត់ដើម្បីស្រូបយកខ្យល់អាកាស ព្រោះគេថើបលឿនពេក មិនឲ្យត្រៀមខ្លួន ហើយនាងក៏ភ្លេចខ្លួនពេលដែលបើកមាត់ គេក៏ជ្រែកអណ្ដាតចូលមក អណ្ដាតដែលនាងអាងថាវាធ្វើការយូរពេក ទៅជាល្វើយ ពេលនេះបែរជាគន្លាស់ មកក្បៀរ



អណ្ដាតរបស់គេ។

គេខឹងនាងខ្លាំងមែនឬ ព្រោះការថើបរបស់គេ ប្រាស់ចាកភាពក្ដៅគគុកដែលជាការដាក់ទោស តែជាភាពក្ដៅគគុកខាងអារម្មណ៍ ដែលពុះទៅដោយការប្រាថ្នា ហើយនាងក៏លើកដៃឱបរឹតគេ ព្រោះត្រូវថើបឡើងទន់ខ្លួនទៅហើយ។

បបូរមាត់ទន់ល្មើយ ដូចអាហារដ៏ឆ្ងាញ់ពិសារបស់ រ៉ែមសៀ គេស្ទើរតែលេបត្របាក់វាចូលទៅក្នុងពោះទៅហើយបើអាចធ្វើបាន។ គេថើប បបោសអង្អែល ដៃក៏លូកចូលទៅក្នុងអាវដែលនាងពាក់ ការ៉ុន ដូចជួរនៅដើម.ក ព្រោះការផ្ទោចអារម្មណ៍ក្ដៅគគុក។

ខោក្នុងក៏ត្រូវទាញទម្លាក់តាមជើងស្រឡូន ហើយត្រូវគ្រវាត់ចោលហើយគេក៏ដាស់រាងកាយរបស់នាងដោយដៃនិងមាត់ ធ្វើឲ្យនាងអង្វរករ ឲ្យជួយបំពេញបន្ថែមដោយភាពក្ដៅគគុក ដែលនឹងធ្វើឲ្យខ្លួនរួចផុតពីភាពវេទនានេះ។

"រ៉ែម..."

នាងក្រសោបមុខសង្ហា មាត់នៅតែថើបជញ្ជក់គ្នាជាបន្តបន្ទាប់ បន្ទាប់មក រ៉ែមសៀ ក៏ប្រឡេះខ្សែវខោ ទាញរូតទម្លាក់ និងគ្រប់គ្រងនាងដោយភាពមហិមា ដែលវាអាចបង្ក្រាបនាងឲ្យបាត់ឆ្ងាសបាន។

"ហ៊ឺ!" ព្រះនាងឆ្ងាស ឱបរឹតតែណែនដៃ គេក៏ឱបក្រសោបវិញ ដោយការថ្នាក់ថ្នម ហើយពេលគេគ្រប់គ្រងម្ដងបន្តិចៗ នាងក៏មានអារម្មណ៍ហាក់ដូចចង់ដាច់ខ្យល់ឲ្យបាន អារម្មណ៍រញ្ជួយកាន់តែកើនឡើង។





Scanned by CamScanner

វែមសៀ ឱនមកថើបកណ្ដាលក្បាលរបស់នាង គេកំពុងតែដាក់ទោសនាង ប៉ុន្តែការដាក់ទោសនេះបែរជាទន់ភ្លន់បំផុត តាំងពីធ្លាប់ធ្វើដាក់មនុស្សស្រី។

នាងមិនដឹងទេថាមួយថ្ងៃៗគេធ្វើអ្វីខ្លះ ប៉ុន្តែអ្នកដែលមានទីក្រុងមួយក្រោមការគ្រប់គ្រង ក្រៅពីនេះត្រូវប្រុងប្រយ័ត្នរឿងក្រុមខ្មាំង ប្រហែលការងាររវល់មែននោះឯង ទាស់ត្រង់ថា នាងក៏ប្រកាន់យកច្បាប់របស់នាងយ៉ាងខ្ជាប់ខ្ជួនដែរ។

គេត្រូវទូរសព្ទមករកនាងមុនម៉ោងប្រាំបីយប់ជារៀងរាល់ថ្ងៃ ហើយគេត្រូវនៅកន្លែងសម្រាកប៉ុណ្ណោះ ទោះមិនបានត្រឡប់មកផ្ទះ ក៏ត្រូវត្រឡប់ទៅផ្ទះសម្រាករបស់គេឲ្យទៀតពេលវេលា។ នាងមិនឲ្យគេចេញទៅផឹកស៊ីបន្ទាប់ពីចេញពីធ្វើការ ព្រោះការផឹកស៊ីមានន័យដល់ឱកាសដែលស្រីផ្សេង អាចនឹងមកក្រវែលស្វាមីរបស់នាងបាន កាន់តែនៅឆ្ងាយត្រចៀកឆ្ងាយច្រមុះផង គឺពិបាកការពារ ក្រៅពីនេះនាងត្រូវគេស៊ីសព្វសាច់ តើឲ្យគេធ្លាក់ទៅក្នុងដៃស្រីផ្សេងឬគ្មានថ្ងៃទេ វែមសៀ ជារបស់នាង ហើយនាងក៏មិនត្រូវការបាត់បង់គេដែរ។

កាអ៊ីន ចំណាយពេលវេលានៅក្នុងការមើលថែខ្លួនឯង ធ្វើកិច្ចការប្រចាំថ្ងៃ ខាតខ្លួនខាតស្បែក ត្រៀមខ្លួនធ្វើជាកូនក្រមុំ ហើយថ្ងៃនេះនាងក៏ធ្វើដំណើរទៅជួបនឹង សានេនេ ដើម្បីសុំការពិភាក្សា។ នៅក្នុងប្រទេស សាក់ខារៀ មានស្ត្រីដែលផ្ដល់ការពិភាក្សាពីរឿងការងារផ្ទះសំបែង រឿងលើគ្រែ រឿងក្រៅគ្រែ



ដល់រាជវង្សានុវង្សដែលជាស្ត្រី នោះមកពីស្ត្រីជាន់ខ្ពស់ ត្រូវចិញ្ចឹមបីបាច់ដោយការឧបត្ថម្ភសោបដូចត្បូងក្នុងបាតដៃ និងនៅឆ្ងាយពីរឿងរស់នោះ។ សានេនេ ជាអ្នកផ្ដល់ការប្រឹក្សា តំណែងត្រូវបានផ្ទេរពីម្ដាយ ដែលរាជវង្ស ម៉ាលខៃសេនពេរក្សាប្រពៃណីទំនៀមទម្លាប់ទីប្រឹក្សារឿងនេះមករហូត មិនធ្លាប់ឲ្យបាត់បង់ ឬខ្វះខាត ទើបនាងត្រូវមកទីនេះ។

'យើងត្រូវធ្វើឲ្យខ្លួនឯងមានអំណាចលើគេដោយស្នេហា'

ធ្វើសង្គ្រាមជាមួយគេដោយកម្លាំង ធានាថាមិនឈ្នះ ពិចារណាឲ្យម៉ត់ចត់ ហើយឃើញថាការណែនាំរបស់ សិគីរ៉ាស គឺជាជម្រើសដ៏ល្អបំផុត ទើបនាងត្រូវណាត់ជួប សានេនេ។

"ថ្វាយបង្គំ"

សានេនេ ជាស្ត្រីដែលមានរាងកាយស្រឡៅស្រឡូន សមសួន ស្លៀកពាក់ពណ៌ស និងពាក់អាវធំពណ៌ខ្មៅពីលើ ដោយអាវធំធ្វើពីក្រណាត់សូត្រ បញ្ចេញពន្លឺផ្លេកៗ ត្បាញដោយទិចនិកពិសេស វានឹងចាំងនៅក្រោមពន្លឺភ្លើង ហើយជះមកលើស្បែក។

សានេនេ មានស្បៃបិទមុខ ហើយការចូលជួបនាង ត្រូវចូលមកជួបក្នុងបន្ទប់ផ្ដល់ការប្រឹក្សាតែម្នាក់ឯង អ្នកបម្រើត្រូវឲ្យចាំនៅខាងក្រៅប៉ុណ្ណោះ។

ក្នុងបន្ទប់ត្រូវតុបតែងដោយពណ៌ត្នោត ឲ្យអារម្មណ៍កក់ក្ដៅ ក្លិនកំញាននៅក្នុងបន្ទប់ ជួយឲ្យអារម្មណ៍ធូរស្រាល។ កាអ៊ីន ដាក់បង្អួយលើកៅអី ទល់មុខសានេនេ ស្ដាប់សំឡេងដ៏ពីរោះនិងកក់ក្ដៅរបស់អ្នកផ្ដល់ការប្រឹក្សា ជាសំនៀង



ដែលធ្វើឲ្យមានអារម្មណ៍ធូរស្រាលពេលបានឮ។

នាងផ្ងារបាតដៃទាំងពីរ សានេនេ ក៏ដាក់បាតដៃរបស់ខ្លួនលើ ហើយពួកនាងក៏ចាប់ដៃគ្នាមួយសន្ទុះ ដើម្បីបន្សាំ ដែលធ្វើឲ្យ កាអ៊ិន គ្មានអារម្មណ៍តានតឹងពេលត្រូវនិយាយគ្នា។ នាងដកដង្ហើមចូលឲ្យពេញសួត ពេលការសន្ទនាចាប់ផ្ដើម។

"សានេនេ ខ្ញុំមានរឿងរំខាន"

"ខ្ញុំម្ចាស់រីករាយបម្រើព្រះនាង"

"ខ្ញុំជិតរៀបការហើយ ហើយខ្ញុំក៏ត្រូវការយកឈ្នះ វែមសៀ ដាវ៉ៃហ៊ីណេស"

"ឈ្នះបេះដូងឬឈ្នះរាងកាយ ?"

សំណួររបស់ សានេនេ ធ្វើឲ្យអ្នកត្រូវសួរភាំង។ នាងមិនធ្លាប់គិតដល់រឿងនេះ ហើយវាក៏ផ្ទោចអារម្មណ៍មួយ។ នាងត្រូវការយកឈ្នះគេដោយអំណាចស្នេហាតែម្យ៉ាងប៉ុណ្ណោះឬ តើមិនត្រូវការយកឈ្នះដោយបេះដូង ធ្វើឲ្យគេស្រឡាញ់ទេឬ ?

"ខ្ញុំមិនច្បាស់"

សានេនេ ងាកទៅយកថ្មចរណៃ មូលមកប្រមៀល ដូចត្រូវការធ្វើឲ្យថ្មក្តៅ ហើយដាក់វានៅលើបាតដៃរបស់ កាអ៊ិន។

"ចូរប្រើពេលពិចារណាទៅព្រះនាង"

កាអ៊ិន ក្រសោបថ្មមូលដោយដៃទាំងពីរ និងបិទភ្នែក ដែលត្រឹមប៉ុណ្ណឹងរូបភាពរបស់ វែមសៀ ក៏បង្ហាញឲ្យឃើញច្បាស់ ទើបនាងប្រញាប់បើកភ្នែក។



នាងកើតអីទៅណ៎ា រូបភាពរបស់គេច្បាស់ខ្លាំងណាស់នៅក្នុងគំនិត ?

"សានេនេ...ខ្ញុំមិនដឹងថាឆ្លើយយ៉ាងណា"

ម្ចាស់ឈ្មោះញញឹមនៅក្រោមស្បៃបិទមុខ បាតដៃទន់ល្មើយនោះក្រសោបដៃរបស់ព្រះនាង ដូចកំពុងតែផ្ទេរថាមពលអ្វីម្យ៉ាងឲ្យ ដែលមិនមែនជាវេទមន្តពិសេស ប៉ុន្តែជាការប៉ះពាល់ និងផ្ទេរថាមពលផ្លូវចិត្តឲ្យ។

"ព្រះនាងសាកគិតដល់អារម្មណ៍ បើទ្រង់មានបេះដូងដូចលោកឧត្តមសេនីយ៍ វែមសៀ"

"វាប្រហែលជាល្អខ្លាំងណាស់"

ពេលឆ្លើយហើយ កាអ៊ិន ក៏ចង់ចិញ្ចើម ព្រោះមិនចំណាពេលគិត។ ត្រូវការបេះដូងរបស់ វែមសៀ អីចឹងឬ នេះនាងទើបតែដឹងខ្លួន!

"អ្វី...ខ្ញុំឆ្លើយហើយឬ ?"

"ទ្រង់មានចម្លើយនៅក្នុងចិត្តហើយ"

"ហើយខ្ញុំត្រូវធ្វើយ៉ាងណា សានេនេ"

នាងត្រូវភាពកក់ក្តៅរបស់ សានេនេ ឬអត់ ទើបព្រមទទួល វែមសៀ ងាយៗដល់ថ្នាក់នេះ ?

កាអ៊ិន សន្ទនាជាមួយ សានេនេ អស់រយៈពេលជាច្រើនម៉ោង មានអារម្មណ៍ដូចបេះដូងត្រូវបានដោះលែង ក៏ត្រូវទាញចេញមក។ វាជាអារម្មណ៍របស់នាង ប៉ុន្តែមុននេះបែរជាមិនពិនិត្យមើល។

ថ្ពាល់របស់នាងឡើងក្រហម ពេល សានេនេ លើកដៃអង្អែលកក្រង់





Scanned by CamScanner

ស្នាមសាក់ថើប ដែល វែមសៀ បង្កទុក ដោយនាងមិនបានជាសង្កេត ហើយនិយាយដោយសំឡេងពីរោះថា រំណរកចស្នេហា មាននាងជាម្ចាស់ហើយ។

វែមសៀ ហៅមនុស្សជំនិតរបស់ខ្លួនមកចូលរួមបេសកម្មពិសេស ព្រោះពួកក្បត់ ព្រហើន លួចចូលក្រុង អាឡិចសានដេ។ គេមិនអនុញ្ញាតឲ្យពួកវាធ្វើមធំ ហើយការលួចចូលក្រុង អាឡិចសានដេ មានន័យថា ពួកវាព្រមយកជីវិតមកគ្រវែងចោល។

គេបំពេញបេសកម្មស្ងាត់ៗ ប្រើកូនចៅដែលមានថ្វីដៃល្អ ដើម្បីចាត់ការ។ ពួកវាបង្កប់ខ្លួននៅក្នុងផ្ទះបាក់បែកកណ្តាលព្រៃជ្រៅ ទើបគេនិងកូនចៅត្រូវធ្វើដំណើរដោយថ្មើរជើង ចេញពីជាយព្រៃ ដើម្បីមិនឲ្យពួកវាដឹងខ្លួន។ គេមានពេលវេលាកំណត់ ពេលវេលាការធ្វើការនៅក្នុងមួយថ្ងៃៗមិនច្រើននោះទេ ដោយមិនអាចធ្វើការតាំងពីព្រលឹមទល់ព្រលប់នៅខាងក្រៅបានដល់ម៉ោងប្រាំបីយប់ គេត្រូវត្រឡប់ចូលកន្លែងសម្រាក និងទូរសព្ទទៅរាយការណ៍ប្រាប់ព្រះនាងមេបញ្ជារបស់គេ។ ក្រៅពីនេះនាងនៅមានវិធីដាក់ទណ្ឌកម្មគេថែមទៀត ដោយថ្ងៃខ្លះគេមករកមុនពេលនាងចូលដេក ដើម្បីឆែកមើលថាគេនៅក្នុងផ្ទះមែនឬអត់ ហើយគេរៀបចំខ្លួនចូលដេកហើយឬនៅ ទើបគេត្រូវធ្វើខ្លួនឲ្យដូចចូលដេក ដើម្បីឲ្យនាងសប្បាយចិត្ត។

គេមិនចាំបាច់ធ្វើដល់ថ្នាក់នេះ ប៉ុន្តែក៏ព្រមធ្វើ ព្រោះបានស៊ីញ៉េក្នុងកិច្ចសន្យារួចហើយ គឺត្រូវតែទទួលខុសត្រូវចំពោះពាក្យសម្តីរបស់ខ្លួន។ មុននេះ



គេប្រាប់នាងថា មានការងារបន្ទាន់ត្រូវធ្វើ និងត្រូវនៅកន្លែងដែលគ្មានសេវាយៈពេលបីថ្ងៃ នាងដឹង តែនៅតែងរង៉ក់ រអ៊ូរទាំ ហើយគេក៏ទ្រាំស្តាប់សំឡេងដ៏ពីរោះនោះរអ៊ូរទាំបានដោយរបៀបណាក៏មិនដឹង ទាំងដែលគេជាមនុស្សប៉ិនធុញទ្រាន់អាចមកពីពាក្យសម្តីរបស់នាង ភាគច្រើនជាការរអ៊ូរទាំរឿងសុខភាពរបស់គេ។

វែមសៀ មិនសូវសុំនឹងការមានអ្នកចាំសួរនាំគេថា ទទួលទានអាហារហើយឬនៅ មានម្តងគេធ្លាប់ឆ្លើយថា នៅ ហើយក៏ឈប់ធ្វើទៀត ព្រោះត្រូវនាងរអ៊ូរទាំពីផលវិបាកនៃការមិនទទួលទានអាហារឲ្យទៀងពេលវេលា វិធីតែមួយគត់ដែលធ្វើឲ្យគេមិនបាច់ជួបនឹងស្ថានការណ៍បែបនេះទៀត គឺត្រូវទទួលទានអាហារឲ្យទៀងពេល គ្រប់ពេល និងហាមភ្លេចទទួលទានអាហារជាដាច់ខាត។

រឿងតែមួយគត់ដែលគេមិនធ្វើ គឺប្រកែកនឹងនាង ព្រោះប្រកែកមិនទាន់គេទើបតែហាមាត់ នាងក៏និយាយដល់ណាដល់ណីទៅហើយ ដូច្នោះហើយទើបគេសុខចិត្តស្ងាត់មាត់ និងធ្វើឲ្យខ្លួនឯងស្រួលចិត្តបំផុត ដោយការធ្វើតាមបញ្ជារបស់នាង។ យ៉ាងហោចណាស់នាងក៏មានពេលវេលាដ៏គួរឲ្យស្រឡាញ់គួរឲ្យភ្ញាក់ផ្អើលដែរ។ ពេលនៅលើគ្រែ ទោះងរង៉ក់ដាក់គេ តែក៏ធ្វើឲ្យរាងកាយរបស់គេស្ពប់ស្ពល់។ គេមិនធ្លាប់មានអារម្មណ៍ថានឿយណាយនឹងធ្វើរឿងបែបនោះជាមួយនាង ថ្ពាល់ក្រអូបទន់ល្មៀយ បបូរមាត់ផ្អែមល្ហែម និងរាងកាយស្រឡៅស្រឡូន សំឡេងថ្ងូចថ្ងូរដ៏ពីរោះ ធ្វោចឲ្យគេកើតអារម្មណ៍ព្រៃផ្សៃចំពោះនាង។ គេចាត់ទុកថាវាជារង្វាន់នៃការធ្វើខ្លួនជាស្វាមីល្អ។



ពិធីមង្គលការរបស់ពួកគេ ត្រូវប្តូរការកំណត់ ដោយសារបន្ទុកតួនាទី



Scanned by CamScanner

ការងាររបស់គេ ដែលគេមិនបានប្រាប់ថា វាជារឿងពាក់ព័ន្ធនឹងពួកខ្មាំង។ គេត្រូវការកម្ចាត់ពួកវាចេញពីក្រុង រាឡិចសានដេ ឲ្យអស់ មុនពេលនាំ ការ៉ិន មករស់នៅទីនេះ។ ខាឡូម៉ាន់ បានអនុម័តរួចទៅហើយ តែគេក៏ត្រូវបង្ហាញឲ្យឃើញទំនួលខុសត្រូវដែលមានចំពោះនាងមួយកម្រិតទៀត ដោយការចុះសំបុត្ររៀបអាពាហ៍ពិពាហ៍ មុនពេលមានពិធី ដូច្នោះហើយទើបពេលនេះ ការ៉ិន ក្លាយជាភរិយាស្របច្បាប់របស់គេ សល់តែពិធីដែលត្រូវរៀបចំឲ្យត្រឹមត្រូវតាមទំនៀមទម្លាប់ប្រពៃណីនៃប្រទេស សាក់ខារៀ ប៉ុណ្ណោះ។

ជិតដល់ថ្ងៃរៀបការ គេក៏ត្រូវប្រឹងប្រែងធ្វើការ កម្ចាត់ពួកក្បត់ឲ្យអស់។ គេចង់ប្រើវិធីហិង្សាទៅលើពួកវា ឲ្យងាប់ឆាប់ៗ ប៉ុន្តែការប្រើទារុណកម្មបែបនោះមិនអាចបើកចំហបាន ព្រោះមានប្រទេសជាច្រើនទៀត កំពុងតែឃ្លាំមើលសកម្មភាពនៅក្នុងប្រទេស សាក់ខារៀ និងអាចលូកដៃមកជ្រៀតជ្រែកនយោបាយក្នុងប្រទេសនេះ ទើប ខាឡូម៉ាន់ ត្រូវដឹកនាំប្រទេសដោយការប្រុងប្រយ័ត្ន ហើយអ្នកនៅក្រោមការបង្គាប់បញ្ជា ក៏ត្រូវអនុវត្តឲ្យបានខ្ជាប់ខ្ជួនរួមទាំងគេដែរ។

គេរារទៅរកគោលដៅ ធ្វើគ្រប់យ៉ាងដោយការប្រុងប្រយ័ត្នបំផុត។ ពេលដែលរាងកាយរបស់គេប៉ះនឹងមែកឈើ ឬប៉ប៉ុកនឹងដី គេតែងតែនឹកដល់ភរិយាខ្លួនប្រាណទន់ល្មើយដែលធ្លាប់បពោសអង្អែល ក្លិនខ្លួនក្រអូបប្រហើរ សូម្បីតែសំឡេងរអ៊ូរទាំរបស់នាងដែលគេឮញទ្រាន់ខ្លាំង ក៏គេនឹក។ ប្រហែលមកពីគេមិនធ្លាប់មានអ្នកណាឲ្យនឹកក៏ថាបាន។



បន្ទាប់ពីធ្វើកិច្ចសន្យារៀបការរួចរាល់ គេក៏បិទឃ្លាំងស្រាក់ណាន់ ឲ្យប្រាក់ដល់ពួកនាងមួយចំនួន ដើម្បីរកស៊ីធ្វើការចិញ្ចឹមជីវិត ដោយមិនទទួលឲ្យធ្វើការក្នុងតំណែងផ្សេង ព្រោះមិនត្រូវការឲ្យ ការ៉ិន មានបញ្ហា។ ព្រះនាងឆ្លាសផ្ញើមហួងហែងគ្រប់យ៉ាងដែលជារបស់ខ្លួនឯង ជាពិសេសគេ នាងហួងហែងខ្លាំងណាស់ ដែលការហួងហែងរបស់នាង ធ្វើឲ្យគេមួម៉ៅនៅពេលខ្លះ ព្រោះនាងបង្ហាញភាពជាម្ចាស់ពេក ប៉ុន្តែពេលនេះគេស៊ាំនឹងវាហើយ។

"ជិតដល់ពេលរបស់ពួកឯងហើយ"

វ៉ែមសៀ ត្រូវបញ្ឈប់ការនឹករឭកដល់ភរិយាឆ្លាសផ្ញើមបណ្តោះអាសន្ន ព្រោះត្រូវបំពេញភារកិច្ចឲ្យរួចរាល់ កម្ចាត់ពួកវាមិនឲ្យនៅសេសសល់ ហើយព័ត៌មាននៃការកម្ចាត់នេះ ទោះយ៉ាងណាក៏ត្រូវតែបញ្ជូនទៅឲ្យមិត្តភ្នាបរបស់ពួកវាដឹង។

នៅក្នុងក្រុង សេនដីវិក មានពួកនេះបង្កប់ខ្លួនច្រើនណាស់ ប៉ុន្តែពួកវាឆ្លងដែនចេញទៅក្រៅក្រុង សេនដីវិក មិនបាន វាដូចជាការស្លាបស្លង់ ហើយបើគេបណ្តោយឲ្យពួកវាបង្កភាពវឹកវរ ពួកនោះកាន់តែបានចិត្ត ដូច្នេះហើយគេមិនព្រមឲ្យពួកវាបានចិត្តនៅក្នុងក្រុងដែលគេគ្រប់គ្រង។

"កម្ចាត់ពួកវាឲ្យអស់"

នេះជាបញ្ជារបស់ វ៉ែមសៀ ការប្រតិបត្តិការក៏ចាប់ផ្តើម។

**ការ៉ិន ស្វាគមន៍ស្វាមី ដោយសំឡេងស្រែកបែកបំពង់ក ដែលធ្វើឲ្យគេ**



ឈឺក្រដាសត្រចៀក ដល់ថ្នាក់ពេបមាត់ ចងចិញ្ចើម។

"ទៅធ្វើស្អី!" នាងដើរលឿនស្ទើរមករក ទើបគេយល់ពីមូលហេតុនៃការស្រែកនោះ ព្រោះនាងឃើញឈាមជាប់នឹងក្បាលគេនោះឯង។

វិវរហើយ!

អ្នកកំលោះឧទាននៅក្នុងចិត្ត មិនអាចឲ្យចម្លើយនាងត្រង់ៗបាន ព្រោះមានឧបទ្ទវហេតុកើតឡើងតិចតួច ពេលប៉ះទង្គិចនឹងពួកក្បត់ គេភ្លាត់ស្នៀតបុកក្បាលនឹងជ្រុងតុ ធ្វើឲ្យរងរបួសបន្តិចបន្តួច ខណៈដែលពួកក្បត់គ្មានឱកាសបានដកដង្ហើមនៅលើលោកនេះទៀត។

"បន្ថយសំឡេងបន្តិច"

គេបញ្ចប់បញ្ហាដោយការលើកនាងបី ស្មានថាស្រែកព្រោះឃើញខ្លួនប្រាណស្រមេកស្រមករបស់គេតើ។ គេធ្វើដំណើរចេញពីក្រុង អាឡិចសានដេជាបន្ទាន់ គឺដើម្បីមកឲ្យដល់ដំណាក់របស់ព្រះនាងឆ្អាស មុនម៉ោងប្រាំបីយប់ ដែលមកដល់ទាំងប្រញាប់ប្រញាល់ ដាក់ជើងជាន់លើដំណាក់នេះល្មមនៅម៉ោងប្រាំបីយប់។

"ស៊ីឡា ហ្វីវ៉ា គេរហៅលោកគ្រូពេទ្យឲ្យមកទីនេះ"

ការ៉ិន ងាកទៅបញ្ជាអ្នកបម្រើ ដោយនៅតែត្រូវ រ៉ែមសៀ បី។

នេះមានប្តីឬកូន បើមិនស្រមេកស្រមកត្រឡប់មកផ្ទះវិញ ក៏ត្រូវតែមានរបួសឲ្យនាងភ័យដែរ!

"មិនបាច់"



"ម៉េចក៏មិនបាច់ ឈាមហូរឃើញទេ ឈាម មិនមែនទឹកស៊ីរ៉ូទេ"

"វាឈប់ហូរហើយ"

"ឈប់ហូរក៏ត្រូវពិនិត្យ"

"មិនបាច់"

នាងធ្វើមាត់រអេចអូច ចង់ក្តិចគេឲ្យជាំសាច់ ប៉ុន្តែព្រោះគេមានរបួស ទើបត្រូវផ្អាកការប្រទូស្តរ៉ាយរាងកាយនេះសិន។

"ហៅលោកគ្រូពេទ្យមកទីនេះ ស៊ីឡា"

"ព្រះ...ព្រះម៉ែ"

ស៊ីឡា ទទួលបញ្ជា តែធ្វើខ្លួនមិនត្រូវ ព្រោះព្រះនាងបញ្ជាផ្សេង ឧត្តមសេនីយ៍បញ្ជាផ្សេង ជីវិតជាអ្នកបម្រើនេះ ចំជាលំបាកមែន។

"ហាមប្រកែក ហាមតវ៉ា ហាមងរង៉ក់ បើមិនព្រមឲ្យគ្រូពេទ្យពិនិត្យ ខ្ញុំនឹងឲ្យលោកដេកក្រៅបន្ទប់ មិនជឿសាកមើលទៅ"

នាងយករឿងលើគ្រែមកគំរាមដោយប្រយោល ព្រោះមិនដឹងថាចាត់ការគេយ៉ាងណា ហើយមើលទៅដូចបានផល។

រ៉ែមសៀ សម្លឹងមុខ តែមិនបានចេញបញ្ជា នាងក៏លើកដៃអង្អែលរបួសរបស់គេថ្នមៗ មិនហ៊ានប៉ះខ្លាំង ព្រោះមិនដឹងថាវាធ្វើឲ្យឈឺឬអត់។

"ឈឺទេនេះ"

"មិនឈឺ"

"ជាមនុស្សដែកឬយ៉ាងម៉េច ឈាមហូរហើយមិនឈឺទៀត"





Scanned by CamScanner

រ៉ែមសៀ មិនមាត់មិនក ក្រៅពីបីនាងដើរសំដៅបន្ទប់ដេក។ គេស្ងិតទាំងស្បែកស្ងិតទាំងឆ្អឹង គេស្ងិតខ្លួនណាស់ និងចង់ងូតទឹក ឲ្យស្រឡះខ្លួនបន្តិច។

"ម៉េចក៏មិនស្នាក់នៅប្រាសាទ ត្រពាំងត្រយ សិន តេរមកប្រាប់ក៏បាន"

"ព្រោះនាងរអ៊ូហ្នឹង"

គេប្រញាប់ប្រញាល់ដល់ថ្នាក់មិនបានគិតរឿងផ្សេង ចប់ភារកិច្ចក៏បញ្ជាឲ្យពីឡុតបង្ហោះឧទ្ធម្ភាគចក្រឆ្លងក្រុង មកក្រុង សេនជាម៉ារ៉ា ហើយពេលមកដល់គេសង្កេតឃើញថាភ្នែករបស់នាង មិនបានចាប់អារម្មណ៍ផ្នែកផ្សេងនៃរាងកាយរបស់គេ ក្រៅពីសៀតផ្កា ដែលមានកំណក់ឈាម។

"មើលចុះ ខ្លួនប្រាណស្រមេកស្រមកអស់ ជាប្រមុខក្រុង ឬជាកម្មករនៅអណ្តូងរ៉ែ"

នាងរអ៊ូរទាំដាក់ដៃលើស្មាធំទូលាយ។ អាវយឺតរបស់គេសុទ្ធតែធូលីដីប៉ះតែបន្តិច វាក៏ជាប់តាមដៃ ប៉ុន្តែនាងមិនខ្ពើមរអើមធូលីដីនៅលើខ្លួនរបស់រ៉ែមសៀ ស្មានថានាងស្រែកថាគេស្មោកគ្រោក និងរើបម្រះចុះពីដៃតើ ប៉ុន្តែនាងមិនបានធ្វើបែបហ្នឹង។

"នេះមែនទេ ដែលសុំទៅបំពេញភារកិច្ចបីថ្ងៃ"

"អ៊ឹម"

"ដេកនៅកន្លែងណា ?"

គេមិនឆ្លើយ ហើយដែលមិនឆ្លើយនេះព្រោះមិនចង់កុហក ព្រោះបើឲ្យឆ្លើយត្រង់ៗ វានឹងប៉ះពាល់ដល់ភារកិច្ចសម្ងាត់របស់គេ។



"ហើយញ៉ាំបាយគ្រប់ពេលដែរទេ ?"

"គ្រប់" គេតប ព្រោះជាចម្លើយដែលអាចឆ្លើយបាន។ ប្រពន្ធនេះមានសមត្ថភាពពិសេស ពួកនាងមានញាណពិសេសម្យ៉ាងដូចគ្នា។ គេធ្លាប់បានឮកូនចៅនិយាយថា ប្រពន្ធរបស់ពួកនោះប៉ិនរអ៊ូទាំ ដែលគេមិនធ្លាប់គិតទេថាត្រូវជួបដោយផ្ទាល់។ ក្រៅពីប៉ិនរអ៊ូហើយ នាងក៏ពូកែសិបភឹងណាស់ដែរ នាងអាចធ្វើតេស្តការអត់ធ្មត់របស់គេក៏ថាបាន គេត្រូវបង់ថ្លៃកាតក្រេឌីតឲ្យ ដែលវិក័យបត្រត្រូវចំណាយម្តងៗ វែងជាងកន្ទុយខ្លែង ធ្វើឲ្យគេអត់គិតមិនបានថាបើនាងឧស្សាហ៍រឿងលើគ្រែ ឲ្យដូចឧស្សាហ៍សិបភឹង ប្រហែលជាល្អ។

ប្រាក់នៅក្នុងគណនេយ្យរបស់គេ នាងគិតតែពីចាយ ទោះជាការចាយដោយប្រយោល ប៉ុន្តែគេក៏ត្រូវតែចំណាយ ឬមានអ្នកណាលួចខ្សឹបនាងឬអត់ថាធនាគារធំមួយនៅក្នុងចំណោមធនាគារធំៗជាច្រើនរបស់ សាក់ខារៀ ជាកម្មសិទ្ធិរបស់គេ ហើយបើមានអ្នកណាប្រាប់មែន គេជឿថាមាត់របស់ម្នាក់នោះគឺរបស់ សិតិភ៉ស។

"ហើយនេះញ៉ាំអាហារពេលល្ងាចហើយឬនៅ ?"

"នៅទេ ចប់ការងារក៏មកផ្ទះ"

"ម៉េចក៏មិនញ៉ាំមុនពេលមក"

"បើខ្ញុំមកផ្ទះមិនទៀងពេល នាងនឹងរអ៊ូ"

"មែន" នាងងក់ក្បាល ពេលនោះក៏ត្រូវ រ៉ែមសៀ ដាក់ឲ្យឈរនៅក្នុងបន្ទប់ដេក។





Scanned by CamScanner

នាងមិនបានឲ្យអ្នកបម្រើចូលមករៀបរៀប ព្រោះត្រូវប្រណិប័តន៍ស្វាមីដោយផ្ទាល់ តាមការណែនាំរបស់ សានេនេ។

"ចង់ធ្វើអី ?"

ពេលត្រូវនាងចាប់ដៃ នាំចូលបន្ទប់តែងខ្លួន គេក៏សួរនាំ។

"ងូតទឹកឲ្យហ្នឹងអី កុំនិយាយច្រើនបានទេ កំពុងតែរៀនផង កុំមាត់កុំកធ្វើខ្លួនល្អៗ អូខេ"

នាងប្រាប់គេ ហើយក៏ឈ្ងោកមុខឈ្ងោកមាត់ដោះខោអាវឲ្យ ទោះសុំនិងការឃើញរាងកាយនរលតករបស់គេរាប់មិនអស់ក៏ដោយ ប៉ុន្តែនាងនៅតែរៀន។

"មានផែនការអីឬអត់ ?"

"ផែនការអី ?"

"ផែនការអាក្រក់"

"ឆ្កួត ហេតុអីខ្ញុំត្រូវមានផែនការអាក្រក់ដាក់លោក"

"មិនដឹងទេ"

នាងឆ្លលបុងច្រមុះតែម្តង អូសដៃគេចូលបន្ទប់ទឹក ហើយរុញចូលបន្ទប់ទឹក រុញចូលទៅក្រោមទឹកផ្កាឈូក ហើយដើម្បីឲ្យបានលឿនរហ័សទាន់ចិត្ត នាងក៏ងូតទឹកឲ្យគេទាំងខ្លួនឯងស្លៀកពាក់ ម្យ៉ាងទៀតនាងមិនចង់ដោះព្រោះបើដោះទៅ ព្រៃស្រៀ និងឆ្វេចឆ្វាច។

"ម៉េចមិនដោះ"



"ប្រាប់ថាកុំឲ្យមាត់"

នាងឈ្ងោកមុខឈ្ងោកមាត់ ដុសក្អែលឲ្យស្វាមី ខណៈដែលអ្នកកំលោះគិតថាបែបនេះក៏ល្អដែរ មាននាងបម្រើ។

"ឱនមុខមក"

គេឱនទៅរក នាងក៏លុបលាងមុខមាត់ឲ្យ ដោយប៉ះត្រង់របួសរបស់គេថ្មីៗ ហាក់ដូចរោមបក្សី និងមេភ្លៀង លាងជម្រះកំណាក់ឈាមរួចរាល់ នាងក៏ដកដង្ហើមធំ ថ្ងូរទ្រូងខ្សាកតែម្តង។

"រាងគ្រាន់បើបន្តិច"

"តែយ៉ាងណាក៏ត្រូវឲ្យពេទ្យពិនិត្យសិនដែរ"

នាងនិយាយអីអើតែម្នាក់ឯងរួចរាល់ ងូតទឹកឲ្យស្វាមីរួចរាល់ដែរ ហើយរុញគេចេញពីបន្ទប់ទឹក ដើម្បីជូតខ្លួនស្លៀកពាក់ឲ្យ។





Scanned by CamScanner

# ១២

## ថ្ងៃជ័យ

"គ្មានអ្វីឲ្យបារម្ភទេ ព្រះនាង"

វ៉ែមសៀ បណ្ដោយឲ្យពេទ្យដែលត្រូវអញ្ជើញមកទប់ទល់នឹងព្រះនាងឆ្លាស ចំណែកខ្លួនឯងក៏អង្គុយទទួលទានអាហារដែលព្រះនាងឆ្លាសដដែលបញ្ជាឲ្យអ្នកបម្រើយកមករៀបចំក្នុងបន្ទប់ បន្ទាប់ពីរាងកាយរបស់គេទទួលបានការត្រួតពិនិត្យរួចរាល់។

វ៉ែមសៀ ស្ដាប់នាងរអ៊ូរទាំ ហើយមិនត្រឹមរអ៊ូដាក់គេប៉ុណ្ណោះទេ នាងនៅតេរទៅទូលពិតបងប្រុសជិតប្លែនាទីទៀត។ គេគិតថា ខាឡូម៉ាន់ អាចស្លឹកត្រចៀកដូចគេមិនខាន បើលោកគ្រូពេទ្យក្រមកដល់ ហើយបន្ទាប់ពីនោះបុគ្គលដែលត្រូវស្លឹកត្រចៀកបន្តគឺ លោកគ្រូពេទ្យនោះឯង។

គេមិនរវីរវល់នឹងរឿងនោះដាច់ខាត ទោះខ្លួនឯងជាមូលហេតុក៏ដោយ ដោយការអង្គុយទទួលទានអាហារស្ងាត់ៗ ចំណែកករិយាកំពូលរអ៊ូ ទោះលោកគ្រូបញ្ជាក់ហើយបញ្ជាក់ទៀតឡើងខះកទៅហើយ ក៏នៅតែសួរបញ្ជាក់ថាគេមានសុវត្ថិភាព គ្មានអ្វីឲ្យបារម្ភខ្វល់ខ្វាយ។

នាងមិនធ្លាប់ឃើញស្ថានភាពរបួសរបស់គេ ដែលធ្ងន់ធ្ងរជាងនេះទៅ



ទៀត ស្ថានភាពពនេចរសឹងតែយោងអាក្នាមិនរស់ក៏ធ្លាប់កើតឡើងចំពោះជីវិតរបស់គេរួចមកហើយ ហើយគេក៏មិនធ្លាប់ស្ដាយជីវិតមួយនេះ ព្រមពលីវាដើម្បីដល់ព្រះអង្គម្ចាស់ ខាឡូម៉ាន់ និងប្រទេស សាក់ខាវៀ។

អ្នកកំលោះ ដាក់ស្លាបព្រាចុះ ហើយចងចិញ្ចើមពេលនឹកដល់វេលានេះ។

*បើគេស្លាប់ តើ ខ្លារីហ្សា នឹងរស់នៅជាមួយនរណា?*

ប្រពន្ធរបស់គេ នៅក្មេងថែមទាំងស្អាតផ្ដាច់គេនៅក្នុងប្រទេសនេះ ដើរទៅណាមកណា មនុស្សប្រុសតាមមើលចង់ចាក់.ក ហើយរឿងនេះក៏ធ្វើឲ្យគេស្រួសខ្លាំងតែម្ដង។

*គេមិនស្លាប់ងាយៗទេ!*

អ្នកកំលោះសរុបឲ្យខ្លួនឯង ហើយងក់ក្បាលដាក់ ស៊ីឡា និង ហ្វីវ៉ា មកសម្អាតតុអាហារ ចំណែកគេក៏ដើរចូលបន្ទប់ទឹកជុសធ្មេញជាការកំដរពេលវេលាទុកឲ្យលោកគ្រូពេទ្យប្រឈមនឹងផតាកម្មបន្ត។

"ទូលបង្គំសូមជានា ព្រះនាង"

វ៉ែមសៀ មិនធ្លាប់ខ្លាចអ្វី តែ ការអ៊ុន ធ្វើឲ្យគេជកដង្ហើមមិនពេញពោះ ហើយពេលនេះនាងបញ្ជាឲ្យអ្នកបម្រើជូនដំណើរលោកគ្រូពេទ្យ ដោយមិនភ្លេចអរគុណ ថែមទាំងបញ្ជាក់ពីអាការៈរបស់គេម្ដងទៀតដែរ។

"គ្មានអីឲ្យបារម្ភមែនណ៎ា?"

"ក្រាបទូល"



ព្រះនាងអរគុណម្តងទៀត ហើយដើរទៅរកស្វាមី។

"ច្បាស់ហើយថាដួល?"

ស្វាមីងក់ក្បាលជាចម្លើយ តែនាងមើលមកដោយទឹកមុខមិនចង់ជឿ។

"ងើយមុខឡើង"

ពេលគេមិនធ្វើតាមបញ្ជា ទើបត្រូវនាងចាប់ក្រសោបមុខសង្ហាឲ្យងើយមករក ដើម្បីឲ្យនាងបានពិនិត្យរបួសដែលត្រូវបានសម្អាតរួចរាល់ហើយ។

"ឈឺទេ?"

"មិនឈឺ"

គេក្រសោបនាងមកដាក់លើភ្លៅ ឲ្យនាងអង្គុយពិនិត្យរបួសរបស់គេបានស្រួល មិនបាច់ឈរឲ្យចុកជើង ខណៈនោះក៏មានអារម្មណ៍ប្លែកៗដែលទទួលបានការយកចិត្តទុកដាក់ពីភរិយាឆ្នាស។

"ដេកពួន"

"មិនដេក"

"ម៉េចក៏រឹងម្លេះ!"

ការ៉ុន ឆ្ងល់ចុងប្រមុះ មានប្តីដូចគេដូចឯងដែរ ម៉េចក៏ពិបាកនិយាយម្លេះ ពេលមិនពេញចិត្តក៏ចូលចិត្តធ្វើមុខកាចដាក់ជាការតំរាម នាងត្រូវចំណាយកម្លាំងកាយកម្លាំងចិត្តមិនតិចទេដើម្បីតស៊ូនឹងគេ។

"ខ្លារីហ្សា ថ្លង់"

"ត្រូវតែថ្នាំ អ្នកណាបញ្ជាឲ្យរឹងក្បាល មិនស្រួលខ្លួនតិត្រូវតែដេកពួន"



"មិនទាន់ងងុយ"

វែមសៀ ដាក់ដៃលើដើមទ្រូងមូលក្លំ មាត់ក៏ឱនទៅថើបថ្ពាល់រលោងខានដេកឱបប្រពន្ធយូរ ធានាថាដេកមិនលក់ទេ ហើយនាងក៏យល់ចិត្ត លើកដៃមកឱប.ក ឲ្យដោះខោអាវត្រវាត់ចោលងាយៗ។ គេឱនទៅឈ្ងុលមុខនឹងប្រឡោះ.កសខ្ចី ដោយបបូរមាត់ក្រពុំ បន្ទាប់មកក៏អង្អែលថ្ពាល់ត្រើម។

"ថើបថ្នមៗ តិចមានស្នាម ត្រូវពាក់ឈុតកូនក្រមុំ"

វែមសៀ ប្តូរគោលដៅពីប្រឡោះកទៅរកដើមទ្រូងទ្រលុកទ្រលន់ ថើបជញ្ជក់ខ្លាំងៗ ព្រោះយ៉ាងណាក៏នាងមិនត្រូវអនុញ្ញាតឲ្យបង្ហាញជាសាធារណៈ ប៉ុន្តែពេលចាប់ដៃស្រឡូន នាំលូនចូលទៅក្នុងខោរបស់ខ្លួន ឲ្យនាងជួយអង្អែលឲ្យមានអារម្មណ៍ ទ្វារបន្ទប់ដេកក៏ត្រូវគោះញាប់ស្អេក។

"សូមអភ័យទោសដែលរំខាន ព្រះអង្គម្ចាស់ ខាឡូម៉ាន់ គោះហៅលោកឧត្តមសេនីយ"

លោកឧត្តមសេនីយដកដង្ហើមធំ ដោយអារម្មណ៍ប្រាថ្នាក្តៅគគុក តែត្រូវកាត់ចិត្តពីរាងកាយក្រអូបក្រហើររបស់ភរិយា ដើម្បីធ្វើដំណើរទៅជួបអ្នកគោះហៅ។

វែមសៀ កំពុងមានអារម្មណ៍ថាត្រូវប្រើពេលហើយដោយចេតនារបស់ព្រះអង្គម្ចាស់ប្រមុខប្រទេស ព្រោះគេមិនបានត្រឡប់ទៅដំណាក់របស់ព្រះនាងវិញ និងត្រូវបញ្ជាឲ្យដេកនៅបន្ទប់សម្រាប់ភ្ញៀវក្នុងប្រាសាទវ៉េរូសា។



ដោយហេតុផលរឿងការងារ គេត្រូវសម្រាកនៅទីនេះរហូតដល់ថ្ងៃរៀបការ និងមិនបានឃើញមុខភរិយាទាល់តែដល់វេលាប្រារព្ធពិធី ទើបធ្វើឲ្យគេមួម៉ៅក្តៅក្រហាយ ម្យ៉ាងទៀតក៏មិនបានត្រៀមខ្លួនអីច្រើនដែរ គ្រាន់តែកាត់សក់កាត់ក្រចក កោរពុកមាត់ពុកចង្កា កាត់បន្ថយភាពស្រមេកស្រមករបស់ខ្លួន ប៉ុន្តែការមើលថែខ្លួនឯងបន្តិចបន្តួចនេះធ្វើឲ្យគេសង្ហាគួរឲ្យឈ្លក់វង្វេង។

គេពាក់ឯកសណ្ឋានអ្នកដឹកនាំកងទ័ពរបស់ប្រទេស សាក់ខាវៀ ពាក់អាវផាយ កពណ៌ខ្មៅពីលើ ដែលជាអាវធំចាក់ត្រាប្រចាំតំណែង។ សក់ត្រូវសិតឲ្យមានប៉ុតមានម៉ាក បើកឲ្យឃើញមុខសង្ហាមាំច្បាស់ រស្មីនៃបុរសមានអំណាចបំភាយចេញពីរាងកាយ គួបផ្សំនឹងឯកសណ្ឋានអ្នកចម្បាំងធ្វើឲ្យគេប្រៀបដូចរាជបុត្រនៅក្នុងក្តីស្រមៃរបស់សុភាពនារីទាំងឡាយ។

វែមសៀ ដើរចូលមកលុតជង្គង់ម្ខាងនៅនឹងមុខបល្ល័ង្ករបស់ព្រះអង្គម្ចាស់ខាឡូម៉ាន់ ដើម្បីទទួលយកការជូនពរតាមទំនៀមទម្លាប់ប្រពៃណីជាមុនសិន ទើបអាចធ្វើដំណើរទៅកន្លែងប្រារព្ធពិធីសក្តិសិទ្ធិ ដើម្បីរៀបការនឹងព្រះនាងការ៉ិន បាន។

ព្រះអង្គម្ចាស់ដាក់ដៃលើស្មាធំទូលាយរបស់ វែមសៀ ជូនពរតាមទំនៀមទម្លាប់ ទើប វែមសៀ ក្រាបថ្វាយដល់កម្រាលដើម្បីបង្ហាញពីភាពស្មោះត្រង់ភក្តីដែលមានចំពោះទ្រង់ ដែលចិត្តស្មោះត្រង់នោះគ្មានអ្វីធ្វើឲ្យរង្គោះរង្គើបាន។

"សូមស្វាគមន៍ការមកកាន់រាជវង្ស ម៉ាលខៃសេនពេ លោកឧត្តមសេនីយជាសមាជិកម្នាក់របស់រាជវង្សហើយពេលនេះ ចំណែករាជវង្សក៏ជាសម្ព័ន្ធមិត្តដ៏



ល្អរបស់ ដាវីហើណេស ដូចគ្នា"

ពេលព្រះអង្គម្ចាស់ ស្វាគមន៍ដោយការផ្តល់កិត្តិយសរួចរាល់ វែមសៀក៏ងើបឈរ ឈានជើងថយក្រោយ ឱនគំនាប់ម្តងទៀតជាការគោរពដល់ទ្រង់។

"យើងនឹងនាំ ខ្លារិហ្សា ទៅឲ្យលោកឧត្តមសេនីយដោយផ្ទាល់"

ខាឡូម៉ាន់ និយាយដាក់ វែមសៀ ក្នុងឋានៈជាព្រះអង្គម្ចាស់ និយាយដាក់អ្នកគ្រប់គ្រងក្រុងអាឡិចសានដេ បន្ទាប់មកទ្រង់ក៏ធ្វើដំណើរទៅយកប្អូនស្រីចំណែក វែមសៀ ធ្វើដំណើរទៅកាន់កន្លែងប្រារព្ធពិធី។

វែមសៀ គួរតែស៊ាំនឹងសម្រស់របស់ភរិយា តែពេលបានឃើញនាងគ្រងរ៉ូបកូនក្រមុំ ក៏ត្រូវព្រិចភ្នែកម្តងហើយម្តងទៀត។ នាងដើរយឺតៗ ដោយដំណើរកុលស្ត្រី និងនៅក្រោមភាពថ្លៃថ្នូរនោះ បង្កប់ដោយភាពទន់ភ្លន់ ព្រោះនាងកំពុងដើរតួជាព្រះនាង ការ៉ិន មិនមែនភរិយាដែលងរង៉ក់ដាក់ស្វាមី ពេលនៅជាមួយគ្នាតែពីរនាក់។

រ៉ូបកូនក្រមុំពណ៌សបរិសុទ្ធ ជាយរ៉ូបវែងៗ វែងអូសដី កៀកដៃព្រះអង្គម្ចាស់ ខាឡូម៉ាន់ ដែលតែងខ្លួនដោយឯកសណ្ឋានប្រចាំតំណែងរបស់រាជវង្ស។

ការ៉ិន គិតថា នាងមិនញាប់ញ័រទេ តែដល់ទៅមែនទែនទៅក៏ញ័រជើងដៃសើមដោយញើស ជាពិសេសពេលត្រូវបងប្រុសចាប់ដៃដាក់លើបាតដៃរបស់ វែមសៀ និងត្រូវគេមើលមកដោយខ្សែភ្នែកមុតស្រួច។

"ដៃអូនញ័រ" វែមសៀ និយាយខ្សឹបៗដាក់ ហើយឲ្យនាងកៀកដៃ ដើរទៅឈរនៅផ្ទះជៀមប្រារព្ធពិធី។





Scanned by CamScanner

កន្លែងរៀបចំពិធីនៅផ្នែកខាងក្រៅ មានរនាំងសម្រាប់ឲ្យប្រជាជនបានយល់សម្រស់កូនកំលោះកូនក្រមុំ ចំណែកភ្ញៀវដែលមកចូលរួម គឺសមាជិករាជវង្សរួមទាំងសម្ព័ន្ធមិត្តរបស់រាជវង្ស ម៉ាលខៃសេនតេរួមទាំងអ្នកនៅក្រោមការបង្គាប់បញ្ជា ដែលបម្រើការងារជូនរាជវង្ស ដោយកន្លែងអង្គុយ ត្រូវបានបែងចែកតាមវណ្ណៈ ឋានៈ។

ពិធីមង្គលការ ប្រព្រឹត្តទៅតាមប្រពៃណីទំនៀមទម្លាប់របស់រាជវង្ស ម៉ាលខៃសេនតេ យ៉ាងត្រឹមត្រូវ គ្រប់ជ្រុងជ្រោយ មិនឲ្យមានខ្វះចន្លោះ ដោយចំណាយពេលពីរម៉ោងក៏ចប់សព្វគ្រប់ ចិញ្ចៀនមង្គលការត្រូវបំពាក់នឹងម្រាមដៃនាងខាងឆ្វេង ថែមដោយស្នាមថើបក្តៅគគុកពីកូនកំលោះលើបបូរមាត់របស់កូនក្រមុំ ដោយការដង្ហោយរក។

ការ៉ិន ទឹកភ្នែករលីងរលោង ពេលត្រូវប្រកាសថានាងក្លាយជាភរិយាត្រឹមត្រូវតាមប្រពៃណីរបស់ រ៉េមសៀ ហើយ។ វាជាភាពរំភើបញាប់ញ័រ ហើយអារម្មណ៍នៅថ្ងៃនេះ នាងនឹងមិនអាចបំភ្លេចបានមួយជីវិត វាជាអារម្មណ៍ដែលមានអត្ថន័យចំពោះនាង។ ប្រហែលមកពីស្និទ្ធស្នាលនឹងគ្នាមុនរៀបការ ជាភាពស្និទ្ធស្នាលរបស់ស្វាមីភរិយា ធ្វើឲ្យចំណងដែលមានចំពោះគេតឹងបន្តិចម្តងៗ។ បើពួកគេរៀបការនឹងគ្នា ដោយមិនទាន់ស្និទ្ធស្នាលគ្នា នាងអាចគ្មានអារម្មណ៍រំភើបដល់ថ្នាក់នេះក៏ថាបាន។

"អុំ..."

នាងក្រមុំភ្ញាក់ក្រញាង ព្រោះត្រូវ រ៉េមសៀ ក្រសោបមុខ និងឱនមកថើប



ផ្លិតទឹកភ្នែកឲ្យ ទើបលើកដៃឱបចង្កេះបាវខ្សាច់ គេក៏ឱបចង្កេះរបស់នាងវិញដែរ ហើយលើកព នាំទៅរានហាលធំទូលាយ ដែលតុបតែងលម្អដោយផ្កាពណ៌ស និងថ្ងៃមេឃ ដើម្បីបោះផ្កាមង្គលការ។

បាច់ផ្កាស្អាតតំណាងឲ្យសេចក្តីសុខ និងការចាប់ផ្តើមជីវិតគូពិតប្រាកដរបស់នាងនិង រ៉េមសៀ ត្រូវបោះទៅក្នុងលំហ ដូចសេចក្តីសុខ កំពុងតែបាចពីខាងលើ ទៅរកអ្នកដែលកំពុងរង់ចាំ។

បាច់ផ្កាហោះទៅរកម្ចាស់ ដែលមានជំនឿថានឹងមានឱកាសបានធ្វើជាកូនក្រមុំបន្ទាប់។

រ៉េមសៀ ស្រវាទាញកូនក្រមុំរបស់គេមកឱប ហើយឱនថើបបបូរមាត់ទន់ល្មើយដោយការដង្ហោយរក។ គេញៀនការប៉ះពាល់ខ្លួនប្រាណរបស់នាង ការប្រាថ្នាដែលមានចំពោះនាងមានពេញរាងកាយ ហើយលើកនាងព ដើម្បីថើបនាងបានស្រួល។

ការ៉ិន ដកបបូរមាត់ចេញ ដកដង្ហើមដង្ហក់ តែញញឹមស្រស់ ហើយឈ្ងោកទៅមើលអ្នកដែលទទួលបានបាច់ផ្កានៅខាងក្រោម ដោយស្ថិតនៅក្នុងរង្វង់ដៃរឹងមាំរបស់ស្វាមីដដែល។ ថ្ងៃនេះ រ៉េមសៀ ទាំងអង់អាច ទាំងសង្ហាថ្លៃថ្នូរ ចំណែកនាង ស្អាត ល្អន់ល្អត់។ ពួកគេសមគ្នាគ្មានអ្វីឲ្យទាស់។

អ្នកកំលោះឱនថើបថ្ពាល់រលោង។ គេមិនចូលចិត្តឲ្យនាងផាត់មុខ ព្រោះវាធ្វើឲ្យគេជុំក្លិនថ្ពាល់របស់ភរិយា ដែលខុសប្លែកពីធម្មតា ប៉ុន្តែទោះយ៉ាងណាក៏ថ្ពាល់នេះនៅតែក្រអូប។ គេប្រទះឃើញថា អារម្មណ៍មួម៉ៅរបស់ខ្លួនឯងដែល





Scanned by CamScanner

កើតឡើងតាំងពីត្រូវចេញបញ្ជាឲ្យចេញពីបន្ទប់ដេករបស់នាង វារលាយបាត់ទៅហើយ។

"ថ្ងៃនេះបងមិនដូចចោរ"

ការ៉ិន មិនចង់សរសើរឲ្យគេបានចិត្ត ទើបខិនទៅខ្សឹបប្រាប់ ឲ្យឮតែពីរនាក់។

"តាមធម្មតាបងដូចចោរ ?"

"ស្រមេកស្រមកត្រឡប់ម៉ោផ្ទះវិញរាល់តែដង តើឲ្យដូចអី"

"ដូចប្ដីអូន"

ពេលគេឆ្លើយបែបនេះ នាងក៏អត់មិនបាននឹងគក់ស្មា សំណាងល្អដែលគេនិយាយតិចៗឲ្យឮតែពីរនាក់។

រ៉ែមសៀ ដាក់នាងចុះ ហើយស្រវាចាប់ដៃ អង្គុញជើងបន្តិច ដើម្បីក្រសោបជាយរ៉ូបអូសដីរបស់នាង ដើម្បីមិនឲ្យវាក្លាយជាឧបសគ្គនៅក្នុងការដើរហើររបស់នាង ដែលធ្វើឲ្យនាងភ្ញាក់ផ្អើលនឹងទង្វើនោះ ស្មានមិនដល់ថាគេព្រមកាត់បន្ថយភាពច្រងេងច្រងាងរបស់ខ្លួន ដើម្បីមើលថែនាងដល់ថ្នាក់នេះ ទាំងដែលអាចហៅអ្នកបម្រើឲ្យមកចាត់ការបាន ប៉ុន្តែគេមិនធ្វើ។

ពួកគេត្រូវជិះរទេះសេះ ដើម្បីអរគុណប្រជាជន ដែលឈរត្រៀបត្រានៅតាមដងផ្លូវតាំងពីកន្លែងប្រារព្ធពិធី រហូតដល់ដំណាក់របស់នាងនោះឯង ហើយពួកនាងនឹងធ្វើដំណើរទៅក្រុងអាឡិចសានដេនៅបីថ្ងៃក្រោយ។



តាមទំនៀមទម្លាប់របស់ សាក់ខារៀ បន្ទាប់ពីគោរពប្រមុខប្រទេសរួចកូនកំលោះនឹងបីកូនក្រមុំឡើងរទេះសេះ ដែលរទេះសេះត្រូវតុបតែងលម្អឲ្យដូចរទេះសេះរបស់រាជបុត្រ និងព្រះនាងក្នុងព្រេងនិទាននៅកណ្ដាលក្បួន ចំណែកខាងមុខ និងក្រោយក្បួនជាទាហានសេះរបស់ សាក់ខារៀ។

អាវធាយរបស់ រ៉ែមសៀ ប៉ើង ពេលបីកូនក្រមុំដើរសំដៅរទេះសេះ។ គេដាក់នាងទៅលើកៅអី ហើយឡើងមកអង្គុយក្បែរ ឲ្យជាយរ៉ូបវែងអូសដីគ្របលើស្បែកជើងក្រោមរបស់ស្វាមីដែរ។

ការ៉ិន ញញឹមពព្រាយ ងើយមុខមកសើចដាក់ ទើបគេឱនទៅថើបថ្ពាស ព្រោះស្នាមញញឹមនិងសំឡេងសើចរបស់នាងទាក់ទាញចំណាប់អារម្មណ៍របស់គេ ហើយពួកគេក៏ចាប់ដៃគ្នាម្ខាង ម្ខាងទៀតគ្រវីដាក់ប្រជាជន។

"ស្អាតដល់ហើយ" នាងប្រាប់ស្វាមី ហើយងាកទៅមើលប្រជាជននៅតាមដងផ្លូវ ដែលបាចគ្របកកុលាបពណ៌សដាក់ជំនួសពាក្យជូនពរ។

"ចូលចិត្តទេ ?"

"ចូលចិត្តណាស់ បងធ្វើបែបនេះឲ្យអូនមួយឆ្នាំម្ដងបានទេ មិនបាច់បាចច្រើនយ៉ាងនេះក៏បានដែរ"

"អូនគិតថាបងធ្វើទេ ?"

"មិនធ្វើ" នាងតប និងញញឹមពព្រាយដាក់។

នាងមានសេចក្ដីសុខណាស់ វាជាអារម្មណ៍ពិសេស បន្ទាប់ពីលួចគិតថាពិធីមង្គលការ មានឬមិនមានក៏បាន វាមិនសំខាន់ទេ តែនាងបែរជាគិតខុស



ព្រោះពិធីនៅថ្ងៃនេះ ជាអនុស្សាវរីយដ៏កក់ក្តៅ មានន័យ មានតម្លៃ និងជាការចងចាំដែលមិនអាចបំភ្លេចបាន។

នាងញញឹមដាក់ប្រជាជននៅតាមដងផ្លូវ ដោយមិនហត់នឿយ ប៉ុន្តែពេលទៅដល់ដំណាក់ ទើបឈឺថ្ពាល់។

"បីចូលដំណាក់ផង" នាងប្រាប់ ពេលត្រូវគេលើកចុងពីរទេះសេះ។

"ខ្លួនក៏ធ្ងន់ ឈុតក៏ធ្ងន់"

"ធ្ងន់ក៏ត្រូវតែបី អូនបញ្ជា" ការ៉ិន យកចង្អុលដៃចាក់ថ្ពាល់គ្រើម។

ទោះអ៊ូ តែ រ៉េមសៀ ក៏បីកូនក្រមុំរបស់ខ្លួនចូលទៅក្នុងដំណាក់ ដោយដំណើរស្វាហាប់ និងមិនភ្លេចខិនថើបបបូរមាត់ប៉ិនបញ្ជា ហើយពេលចូលផុតទ្វារដំណាក់ ទើបនាងថើបគេវិញ។ នេះជាការថើបស្វាគមន៍គ្នា បន្ទាប់ពីរៀបការស្របតាមប្រពៃណី។

អ្នកកំលោះរឹតរង្វង់ដៃឱបភរិយាកាន់តែណែន នាងក៏ឱបរឹតគេវិញដែរ ដោយនៅតែថើបគ្នា ថើបដោយភាពក្តៅគគុក។ វាជាការថើបរបស់ស្វាមីភរិយា ទោះមុននេះមានអារម្មណ៍បែបនេះស្រាប់ហើយក៏ដោយ តែសម្រាប់ថ្ងៃនេះ វាជាថ្ងៃពិសេស។

រ៉េមសៀ បពោសអង្អែលភរិយាកំពូលសម្រស់លើសាឡុង ដោយគ្មានអ្នកបម្រើចូលមករំខាន។

"នៅមានពិធីជប់លៀងទៀត ថ្ងៃនេះប្រហែលអបអរដល់ព្រឹក" ការ៉ិន ប្រាប់ ពេលស្វាមីវាសអាវផាយទៅចំហៀង។



"អូនត្រៀមខ្លួន សម្រាប់រាំវែកហើយនៅ?"

"អូនពូកែរាំណាស់"

"មានន័យថាបងនឹងមិនត្រូវអូនជាន់ជើងទេ មែនទេ?"

"បើអូនជាន់ជើងបង បញ្ជាក់ថាអូនមានចេតនាជាន់ អ៊ុយ!"

នាងប្រញាប់លើកដៃបិទមាត់ ពេលនិយាយចប់។

"ភ្ញាក់ស្លី?"

"អូនមិនគួរណាប្រាប់បងទេ បែបនេះអូនញ៉ោះបងលែងបានហើយ"

"បើអូនជាន់ជើងបង អូននឹងត្រូវដាក់ទោស ខ្លាំហ្វា"

"បងត្រូវអភ័យឲ្យអ្នកមិនចេះរាំ"

"អូនទើបតែប្រាប់បងថាអូនពូកែរាំ"

"អីចឹងអូនសន្យាក៏បាន ថាមិនជាន់ជើងបង"

នាងក្រមុំសើចញឹមៗ។ ថ្ងៃនេះនាងមានសេចក្តីសុខណាស់ ដូច្នេះហើយនឹងធ្វើខ្លួនជាក្មេងល្អដាក់ រ៉េមសៀ។

"ជប់លៀង ម៉ោងប៉ុន្មាន?"

"បងហាមគិតអីផ្តេសផ្តាស"

"អូនគិតថាបងនឹងធ្វើអី?"

"មិនដឹងទេ អូនត្រូវបង្ការទុកមុន មួយម៉ោងទៀតពិធីជប់លៀងចាប់ផ្តើមហើយ អូនត្រូវផ្លាស់ខោអាវ ប្តូរម៉ូតសក់ដែរ" នាងចាក់ដើមទ្រូងរបស់ស្វាមី។

រ៉េមសៀ មិនទាន់មានផែនការលួកលាន់ភរិយានៅពេលនេះ ព្រោះចង់



ចំណាយពេលនៅជាមួយនាងតាមសម្រួល ជាជាងរហេករហាន់ ដែលវាធ្វើឲ្យទទួលបានអារម្មណ៍តបស្នងមិនពេញទី។

"អូនជួយដោះខោអាវឲ្យ"

អ្នកកំលោះងក់ក្បាល ព្រោះពេលភរិយាបញ្ជាឲ្យដោះ គេក៏ត្រូវតែដោះ ហើយការជួយនាងដោះសម្លៀកបំពាក់មិនមែនជារឿងដែលត្រូវបដិសេធ ផ្ទុយទៅវិញ គេមានតែពេញចិត្តធ្វើ។

ការ៉ុន គ្រងឈុតភាគ្រិពណ៌សដូចឈុតមង្គលការ ដើរទៅឱប ចាស្មីន ព្រោះឈុតដែលមិត្តភក្តិកាត់ដេរឲ្យ ធ្វើឲ្យនាងស្អាតគ្មានអ្វីឲ្យទាស់។

"អបអរសាទរ ជូនពរឯងមានសុភមង្គល"

"អរគុណ" កូនក្រមុំទទួលយកការជូនពរពីមិត្តសម្លាញ់។

កូនកំលោះកំពុងនិយាយជាមួយ ខាឡូម៉ាន់ និង ស៊ីតីរ៉ាស ក្រៅពីនេះនៅមានមន្ត្រីជាន់ខ្ពស់ក្នុងជួររដ្ឋាភិបាលដែរ ទើបនាងចាប់ដៃ ចាស្មីន នាំគ្នាមកនិយាយនៅរានហាលជាប់នឹងសាលរៀបចំពិធី។

"ខាននិយាយគ្នាយូរណាស់"

ការ៉ុន ដាក់បង្អួយមុន ទើបមិត្តភក្តិដាក់បង្អួយក្បែរ ដោយពួកនាងនៅតែចាប់ដៃគ្នា ញញឹមដាក់គ្នា។

"ឈុតដែលឯងចេញម៉ូត និងកាត់ឲ្យខ្ញុំ ស្អាតគ្រប់ឈុត"

"ព្រោះឯងស្អាតទៅវិញទេ"



"ឈុតរបស់ឯង ធ្វើឲ្យខ្ញុំកាន់តែមានទំនុកចិត្តចំពោះខ្លួនឯង"

"ព្រោះវាជាឈុតរបស់ឯង"

"អរគុណច្រើន ចាស្មីន"

"ម៉េចក៏អរគុណញឹកម្ល៉េះ"

"មិនដឹងទេ ថ្ងៃនេះជាថ្ងៃនៃការអរគុណទេដឹង"

ចាស្មីន សើចតិចៗ ពេលបានឮបែបនេះ។

"ប្លែកដែរណា៎"

"ប្លែកអី ?"

"ពេលនេះឯងរៀបការហើយ ខ្ញុំមានអារម្មណ៍ដូចកាលពីមិនប៉ុន្មានថ្ងៃមុន យើងនៅក្មេងសោះ"

"មែនហ្នឹង ខ្ញុំក៏គិតអីចឹងដែរ"

ការ៉ុន ច្របាច់ដៃមិត្តសម្លាញ់។ ពេលនាងរៀបការហើយ ពួកនាងមានឱកាសបានជួបគ្នាតិចណាស់ ព្រោះនាងត្រូវទៅរស់នៅឯក្រុងអាឡិចសានដេ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្វាមី។

"ចាប់ពីពេលនេះ អាចមិនសូវបានជួបគ្នា"

"ឯងរង់ចាំអី ព្រះនាង"

"មិនចង់ឯងរង់ចាំទេ តែវាអត់ពុកក្តួលមិនបានដែលត្រូវទៅរស់នៅឯក្រុងអាឡិចសានដេ ទីនោះគ្មានបងប្រុស គ្មានឯង គ្មាន យ៉ោត និង គ្រីស្ទី"

នាងជួប ចាស្មីន ក្នុងមួយសប្តាហ៍បីបួនដង ណាត់ជួបប្អូនស្រីទាំងពីរ





Scanned by CamScanner

ញ៉ាំកញ្ចាប់ តែបើទៅនៅក្រុងអាឡិចសានដេ ការជួបគ្នានឹងរយាល។

"កុំបបួលតើបានទេ"

"ខ្ញុំធ្វើបែបនោះឬ?"

"មែន ថ្ងៃនេះជាថ្ងៃដែលខ្ញុំត្រូវញញឹមឲ្យឯង ញញឹមឲ្យពេលក្រោយបំផុត ដើម្បីសេចក្ដីសុខរបស់ឯង"

"អរគុណ ចាស្ទីន"

ពួកនាងឱបគ្នាម្ដងទៀតជាការបង្ហាញពីចំណងមិត្តភាពយូរឆ្នាំ។

"អរគុណម្ដងទៀត"

"ប្រហែលមកពីយើងឆ្លងកាត់រឿងរ៉ាវជាមួយគ្នាច្រើន ឯងតែងតែនៅក្បែរខ្ញុំ មិនថាខ្ញុំជួបហេតុការណ៍អីក៏ដោយ"

"ឯងក៏ធ្វើបែបហ្នឹងដាក់ខ្ញុំដែរ ការ៉ុន ឯងតែងតែនៅក្បែរខ្ញុំជានិច្ច ជួយជាកម្លាំងចិត្តឲ្យខ្ញុំ នៅថ្ងៃដែលខ្ញុំគ្មានអ្នកណា"

"បែបនេះឬអត់ ដែលគេហៅថាអាការៈរបស់កូនក្រមុំ ខ្ញុំមានអារម្មណ៍ហេងហាងក្នុងទ្រូង ទាំងដែលខ្ញុំមានសេចក្ដីសុខណាស់ដែលបានរៀបការនឹងរ៉េមសៀ"

"ខ្ញុំសប្បាយចិត្តដែលឯងមានអារម្មណ៍បែបហ្នឹង"

"ឯងចង់ឲ្យខ្ញុំមានអារម្មណ៍ល្អចំពោះគេឬ?"

"បើឯងមានអារម្មណ៍ចំពោះលោកឧត្ដមសេនីយ រ៉េមសៀ ឯងនឹងមានសេចក្ដីសុខដែលបាននៅជិតគេ ខ្ញុំចង់ឲ្យឯងមានសេចក្ដីសុខ"



"មិនដឹងទេ ខ្ញុំគិតថាខ្ញុំស្អប់គេ ព្រោះគេប្រមាថកិត្តិយសខ្ញុំ តែដល់ទៅមែនទែនទៅ ខ្ញុំមិនបានស្អប់គេ ខ្ញុំគ្រាន់តែខឹងដែលគេកាត់ក្ដីខ្ញុំ ទាំងដែលមិនទាន់ស្គាល់ខ្ញុំច្បាស់"

"ហើយឯងត្រូវធ្វើឲ្យគេដឹងឲ្យបាន ថាឯងជាពេជ្រសុទ្ធ ដែលគេត្រូវតែថ្នាក់ថ្នមរក្សា"

"មិនដឹងថាគេរក្សា ឬចាប់ខ្ញុំគប់ចោល"

"ឯងព្រមឲ្យគេធ្វើបែបហ្នឹងឬ?"

"គ្មានផ្លូវទេ ខ្ញុំមិនព្រមធ្វើជាមនុស្សស្រីហានប្ដីច្រើន ទោះគេពុញទ្រាន់ខ្ញុំចង់ក្អួតក៏ដោយ គេត្រូវតែទ្រាំរស់នៅជាមួយខ្ញុំ ទាល់តែខ្ញុំនិងគេស្លាប់រៀងខ្លួន"

ការ៉ុន និយាយពីការតាំងចិត្តរបស់ខ្លួនដោយទឹកមុខមាំ។ ការផ្ដល់ប្រឹក្សារបស់ សានេនេ ធ្វើឲ្យនាងរកឃើញអារម្មណ៍មួយនៅក្នុងបេះដូង ទោះមិនទាន់ស៊ាំនឹងវា តែនាងព្យាយាមចាប់វាឲ្យបាន ហើយពិចារណាឲ្យម៉ត់ចត់ ថាវាជាអ្វីឲ្យប្រាកដទៅ។

"ខ្ញុំជឿថា ឯងត្រូវតែធ្វើឲ្យបានសម្រេច"

"ធ្វើអីបានសម្រេច?"

"ធ្វើឲ្យលោកឧត្ដមសេនីយ រ៉េមសៀ ស្រឡាញ់ឯង"

"ខ្ញុំប្រាប់ឬ ថាខ្ញុំចង់ឲ្យតាប៉ិគ្លូតនោះស្រឡាញ់ខ្ញុំ"

ព្រះនាងឆ្មាសនៅតែមាត់រឹង តែពេលគិតដល់ក្ដីស្រឡាញ់ដែលនឹងបានពី រ៉េមសៀ ក៏គិតថាបើបានមែន ប្រហែលជាល្អមិនតិចទេ។





Scanned by CamScanner

"ឬឯងព្រមឲ្យស្វាមីទៅស្រឡាញ់ស្រីផ្សេង"

"គ្មានថ្ងៃទេ"

"អ៊ីចឹងត្រូវធ្វើឲ្យបានសម្រេច"

"ឯងក្លាយជាបក្សពួកគេហើយឬ"

"ខ្ញុំជាមនុស្សដែលចង់ឲ្យឯងមានសេចក្ដីសុខ និងទទួលបានអ្វីដែលឯងគួរបានទៅវិញទេ"

ចាស៊ីន ញញឹមដាក់មិត្តភក្ដិ។ នាងត្រូវអនុញ្ញាតឲ្យមកចូលរួមកម្មវិធីនេះជាពិសេស ព្រោះជាមិត្តជិតស្និទ្ធរបស់កូនក្រមុំ មិនអ៊ីចឹង ដោយតំណែងតួនាទីនាងគ្មានសិទ្ធិបានមកចូលរួមទេ។

"សប្បាយចិត្តដល់ហើយដែលបាននិយាយជាមួយឯង ប្រហែលមកពីខ្ញុំត្រូវទៅរស់នៅក្រុងអាឡិចសានដេទេដឹង ទោះត្រឡប់មកដំណាក់នៅពេលខ្លះប៉ុន្តែមកតែពេលត្រូវមកកាជជានីប៉ុណ្ណោះ ខ្ញុំប្រហែលអផ្សុកខ្លាំង ដែលខានជួបឯងញឹកញាប់"

"ឯងហៅខ្ញុំទៅកាត់ឈុតឲ្យទៅ"

"អ៊ី មែន! ហើយខ្ញុំនឹងទារលុយពី រ៉េមសៀ ទៅបង់ឲ្យបងប្រុស"

ការ៉ិន ទឹកដល់ផែនការរបស់ខ្លួន ហើយញញឹមពព្រាយ បន្ទាប់មកក៏ចាប់ដៃ ចាស៊ីន ឆើបឈរ។ នាងគ្រាន់តែត្រូវការពេលវេលាបន្តិចបន្តួចសម្រាប់និយាយជាមួយមិត្តសម្លាញ់ មុនពេលនាងត្រូវចាប់ផ្ដើមជីវិតគូជាមួយ រ៉េមសៀ ឲ្យប្រាកដប្រជាក្នុងឋានៈជាលោកជំទាវរបស់ត្រកូល ដាវ៉េហឺណេស។



"យប់នេះខ្ញុំមានណាត់ជាតធីជាមួយ យែត និង គ្រីស្ទី ឯងទៅដែរទេ ពួកយើងណាត់គ្នានិយាយលេងមួយម៉ោង"

"បានតើ តែពេលនេះឯងត្រូវទៅទទួលយកការជូនពររបស់ឯងសិន"

ចាស៊ីន បើកទ្វារសាលពិធីឲ្យ ហើយពេល ការ៉ិន ដើរចូលទៅ រ៉េមសៀ ក៏ដើរមករកល្មម ចំណែកខ្លួនឯងក៏ដើរទៅរក យែតទ្រីណា និង គ្រីស្ទីណា ដែលកំពុងឈរនិយាយគ្នានៅមិនឆ្ងាយប៉ុន្មាន។

"ទើបម៉ោពីណា?"

"ចេញទៅយកខ្យល់អាកាស"

"តោះ ទៅ"

ការ៉ិន ដាក់ដៃលើបាតដៃរបស់ស្វាមី ដើម្បីរាំរែក។ នាងញញឹម ពេលគិតដល់ពាក្យសន្យា ដែលឲ្យគេ ទើបត្រូវប្រុងប្រយ័ត្នមិនឲ្យជាន់ជើងគេ ព្រោះបើថ្លោះធ្លោយ ទោះអចេតនាក៏ដោយ ក៏គេគិតថានាងមានចេតនា។



# ១៣

## រាត្រីក្ដៅគគុក

វែមសៀ មិនហត់នឿយ មិនមែនជារឿងប្លែក ប៉ុន្តែ កាអ៊ិន ហត់នឿយ ដោយសារការត្រៀមខ្លួនជាកូនក្រមុំក្រៅពីនេះនៅមមាញឹកនឹងពិធីមង្គលការរួមទាំងពិធីជប់លៀង ដែលដំណើរការដល់វេលាអធ្រាត្រ ម៉ោងបួនទាបភ្លឺទើបពួកនាងបានងូតទឹកងូតភក់។

នាងគួរតែបានដេកភ្លាមៗពេលក្បាលដល់ខ្នើយ តែបែរជាគ្មានអារម្មណ៍ចាំងងុយ បែរជាមានអារម្មណ៍ស្រៀវស្រើបតាម វែមសៀ ដែលមិនទាន់ងងុយដេកដូចគ្នា ហើយពេលនេះកំពុងអង្គុយនៅលើគ្រែរឹងមាំ ដោយម្ចាស់ភ្នែកក្រសោបមុខរបស់នាង សម្លឹងមើលដោយមិនមាត់មិនក។

គេមើលឃើញភាពគួរឲ្យឈ្លក់វង្វេងនៅក្នុងខ្លួនរបស់នាង បើនាងអាចកាត់បន្ថយភាពឆ្មាសឆ្អើមបានខ្លះ ប៉ុន្តែដល់ទៅមែនទែនទៅ ពេលនេះ វែមសៀ គ្មានអារម្មណ៍ថាធុញទ្រាន់នឹងភាពឆ្មាសឆ្អើមរបស់នាង។ នាងមានពេលវេលាធ្វើខ្លួនងរង៉ក់ ប៉ិនរអ៊ូទាំ ថែបទាំងជាប្រពន្ធដែលចូលចិត្តរអ៊ូ ពេលគេធ្វើរឿងលើគ្រែ តែនាងក៏ទោរទន់តាម និងតបស្នង ធ្វើឲ្យគេមានសេចក្ដីសុខគ្រប់ពេលដែលបាននែបនិត្យជិតនាង។



កាអ៊ិន បង្អើបបបូរមាត់ ពេលស្វាមីឱនមករក លើកដៃឱបករបស់គេបន្ទាប់មកអូសមករកស្នាធំទូលាយ ស្វាបអង្អែល។ នាងមានអារម្មណ៍តក់ក្ដៅក្នុងបេះដូង ពេលបាននៅក្នុងរង្វង់ដៃមួយនេះ ប៉ុន្តែរាងកាយរបស់គេក្ដៅជាងទៅទៀត ហើយវាកាន់តែក្ដៅទៅៗ ពេលត្រូវបបូរមាត់របស់គេបបោសអង្អែល។ ព្រោះគេជាស្វាមី ទោះនាងមានផែនការសងសឹក ប៉ុន្តែច្រើនបំផុត ធ្វើបានត្រឹមឲ្យគេមួម៉ៅចំពោះរឿងខ្លះ ហើយជាពិសេសពេលដែលគេបបោសអង្អែលបែបនេះ នាងក៏គិតអីមិនចេញ ក្រៅពីការប៉ះពាល់របស់គេ។

"ងងុយទេ ?" ចើបនាងឡើងបបូរមាត់ជាំអស់ទៅហើយ រាងកាយក៏ក្ដៅគគុកដោយភ្លើងប្រាថ្នា បែរជាឈប់ថើប ហើយសួរដូចត្រូវការឲ្យនាងជ្រើសរើស តែនាងមិនចង់ប្រាប់គេទេថាគេអាចបន្តក៏បាន នាងអូនខេ និងព្រមទោរទន់តាម ព្រោះការនិយាយបែបនោះ ដូចជាការបើកចំហថានាងចូលចិត្តការប៉ះពាល់របស់គេ រឿងបែបហ្នឹងវាគួរឲ្យខ្មាសមែនទែន។

"មិនងងុយ"

គេសួរបង្ខៀងនាងក៏ឆ្លើយបង្ខៀងបានដូចគ្នាហើយលើកដៃអង្អែលថ្ពាល់គ្រើម ប្រសព្វភ្នែកជាមួយ ដោយខ្សែភ្នែកតឃ្លើន។

"បើងងុយ នឹងឈប់"

បើចង់ឈប់តាំងពីដំបូង តើមកប៉ះពាល់ខ្លួនប្រាណរបស់នាងធ្វើអី គេគួរឲ្យនាងដេកពួន ហើយនេះស្អី សភាពឈុតដេកសស្លៀងរបស់នាង ខ្សែមួយក៏របូតពីស្មាបង្ហាញតល់ទ្រូងហើយបើវាធ្លាក់បន្តិចទៀតដើមទ្រូងនឹងនៅកណ្ដាល



វាលទៅហើយ មកបង្អួតខ្សែភ្នែករបស់គេ។

តេដុតអារម្មណ៍របស់នាងឲ្យក្ដៅ ហើយធ្វើដាក់នាងបែបនេះ ចំជាផ្ដេសផ្ដាសមែន។ នាងប្រសព្វភ្នែកជាមួយគេ គិតថាគេបេះបូយឬអត់ ប៉ុន្តែប្រុសឆ្កួតនេះ ក្រៅពីចូលចិត្តស្ដីឲ្យ គឺមិនគួរណាមានល្បិចកលអីបែបហ្នឹង នាងទៅវិញទេ ដែលចូលចិត្តប្រើល្បិចដាក់គេ គេអាចបារម្ភខ្លាចថានាងងងុយដេកមែនក៏ថាបាន។

"អឺ...មិនទាន់ដេកក៏បាន"

នាងតប ដោយរក្សាបុខមាត់ឲ្យខ្លួនឯងបំផុត ទើប រ៉េមសៀ ត្រវាសដៃអាវឲ្យធ្លាក់បន្តិចទៀត ហើយនាងក៏ទាញវាចេញ ទោះយ៉ាងណា ក៏បានជាអីចឹងទៅហើយ តើទុកឲ្យវានៅទើសទែងលើខ្លួនប្រាណធ្វើអី។

អ្នកកំលោះ សម្លឹងមើលតល់ទ្រូង ដែលនៅកណ្ដាលវាល សាច់អាវដំណេកបិទបាំងតែចុងរបស់វាប៉ុណ្ណោះ នាងមិនបានចង់ផ្ដល់ភាពងាយស្រួលដល់គេ ប៉ុន្តែការដែលវាបិទតែបន្តិចបែបហ្នឹង វាធ្វើឲ្យនាងមិនស្រួលខ្លួន ទើបអ៊ែនដើមទ្រូង ឲ្យវាមានសេរីភាពពីអាវដំណេក ដែលអាវនោះ វាធ្លាក់ទៅទើនឹងត្រគាកមូលភ្លុំ។ នាងមិនបានពាក់អាវក្នុង ទើបពេលអាវដំណេកធ្លាក់ រ៉េមសៀ ក៏អាចសម្លឹង និងដាក់ដៃលើវា បានដោយផ្ទាល់។

"នាងអាចត្រូវការសម្រាក"

បើគេចង់ឲ្យនាងសម្រាក គួរតែឈប់ច្របាច់ដើមទ្រូងរបស់នាងទៅ ប៉ុន្តែនេះមិនត្រឹមតែច្របាច់នោះទេ នៅឱនមុខមករក សង្កត់បបូរមាត់ លើចុងរបស់វា



ទៀត។

"អ៊ឺ..." នាងថ្ងូចថ្ងូរនៅដើមក ពេលត្រូវគេបឺតជញ្ជក់ដើមទ្រូង ដូចទារកដែលត្រូវការចំហាយកក់ក្ដៅពីដើមទ្រូងរបស់ម្ដាយ ប៉ុន្តែ រ៉េមសៀ មិនត្រូវការចំហាយកក់ក្ដៅនោះ គេដង្ហោយរក និងត្រូវការសេចក្ដីសុខដែលមានលើសពីនោះ។ គេដឹងថាត្រូវប៉ះពាល់នាងយ៉ាងណា ទើបនាងមិនអាចទប់ចិត្តខ្លួនឯងបាន ប៉ុន្តែរំពេចនោះ គេបែរជាបញ្ឈប់សកម្មភាព ហើយងើយមកប្រសព្វភ្នែកជាមួយនាង ដែលធ្វើឲ្យ កាអ៊ីន ធ្វើភ្នែកឡេមឡាម មានការងឿងឆ្ងល់។

*កុំប្រាប់ណាំថាឈប់ត្រឹមហ្នឹង មិនព្រមទេ!*

មិនគួរណាចាប់ផ្ដើមតាំងពីដំបូង ហើយពេលចាប់ផ្ដើមគឺត្រូវតែទទួលខុសត្រូវទង្វើរបស់ខ្លួនឯង មិនអាចទុកឲ្យនាងហេងហាងនៅកណ្ដាលផ្លូវបែបនេះទេ។

"ងងុយដេកទេ ខ្លារិហ្សា"

អុំយ! ងាប់ហើយ គេត្រូវការយកចម្លើយពីនាងឲ្យបានមែនទេ នាងចង់តែបំបាំងខ្លួន ទៅឲ្យបាត់ ឲ្យវាចប់រឿងចប់រ៉ាវ!

"មិន...មិនងងុយ"

សំឡេងរបស់នាងញ័រ បន្ទាប់ពីត្រូវគេបឺតជញ្ជក់ដើមទ្រូងឲ្យសើមដោយទឹកមាត់ នាងនៅមានស្មារតី និយាយជាមួយគេទៀតឬ។ នាងក្រមុំ សម្រេចចិត្តក្រសោបមុខរបស់ស្វាមី សង្កត់នឹងដើមទ្រូងខ្លួនឯង ដោយមិនភ្លេច អ៊ែនទៅរកជាការផ្ដល់ភាពងាយស្រួលឲ្យ។





Scanned by CamScanner

"ច្បាស់ហើយថាមិនងងុយ ?"

"មិនងងុយ ស្រឡាញ់អូនទៅ រែមសៀ" នាងអង្វរករឲ្យទាល់តែបាន ទើបត្រូវគេឱបក្រសោប ផ្អួលទៅលើគ្រែ និងតាមទៅទ្រាបពីលើ។ នាងលើកដៃឱបគេ អើនដើមទ្រូងទៅរក ផ្ដល់ភាពងាយស្រួលឲ្យ ដោយគ្មានឱកាសបានឃើញស្នាមញញឹមនៅចុងមាត់របស់អ្នកដែលនាងគិតថា គេជាមនុស្សគ្មានល្បិចកល។

រែមសៀ គ្រាន់តែត្រូវការពិសោធ ថានាងត្រូវការគេដូចគេត្រូវការនាងឬអត់ នេះជាតម្រូវការ ដែលពិបាកនឹងគ្រប់គ្រង ទោះនាងមានសេចក្ដីសុខនៅក្នុងរង្វង់ដៃរបស់គេ តែភាពជ្រួលច្រាល់ផ្នែកអារម្មណ៍ដ៏ខ្លាំងក្លា ធ្វើឲ្យគេមានអារម្មណ៍ថាចាញ់ប្រៀប។

គេបានចម្លើយដែលត្រូវការ និងមិនត្រឹមតែគេទេដែលប្រាថ្នានាងដល់ថ្នាក់ងប់ងល់ នាងក៏មានអារម្មណ៍បែបនោះដែរ។ គេមិនចំណាយពេលឲ្យឥតប្រយោជន៍ទៀត ថើបករិយាក់ពូលសម្រស់ សព្វសាច់ ថើបគ្រប់កន្លែង ដោយការស្រេកឃ្លាន។

"រែម..."

ការិន ពត់ពែនខ្លួនប្រាណ ហៅគេដោយសំឡេងខ្សាវៗ ខ្លួនរបស់នាងដូច ត្រូវរោលដោយភ្លើង គេធ្វើឲ្យនាងរើបម្រះ ដោយគួរឲ្យអាម៉ាស់ ប៉ុន្តែទោះខ្មាស យ៉ាងណា ក៏នាងហាមប្រាមការតបស្នងរបស់ខ្លួនឯងមិនបាន។

"រែម...អ៊ា..."



នាងក្រសោបមុខសង្ហា ទាញមករក ហើយថើបបបូរមាត់របស់គេ។ គេកំពុងតែចូលមកក្នុងខ្លួនរបស់នាងយ៉ាងអង់អាច គេក្លាយជាផ្នែកមួយរបស់នាងដោយភាពជ្រាលជ្រៅ។ ជាច្រើនដង ដែលពួកគេស្ថិតនៅក្នុងរង្វង់ដៃរបស់គ្នា ហើយគ្មានម្ដងណា ដែលពួកគេធុញទ្រាន់គ្នា មានតែការប្រាថ្នា ដែលកើនកម្រិត។

បទពិសោធន៍របស់ រែមសៀ ធ្វើឲ្យនាងមានសេចក្ដីសុខ ហើយគេក៏បង្រៀនឲ្យនាងតបស្នង។ នាងយកមេរៀនដែលគេបង្រៀនមកប្រគល់សេចក្ដីសុខឲ្យគេវិញ ហើយវាក៏ធ្វើឲ្យគេលែងមានចំណង់បែបនោះទៅលើស្រីណាទៀតក្រៅពីប្រពន្ធម្នាក់នេះ។

"ខ្លារីហ្សា ទទួលបងឲ្យអស់"

"ចាំ...ចាំ រែមសៀ លោកប្ដី"

រែមសៀ ជាលោកប្ដីរបស់នាង ត្រឹមត្រូវហើយ ព្រោះពួកគេរៀបការ ចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមប្រពៃណីស្របច្បាប់។ គេខិនថើបថ្ពាល់ក្រអូបក្រហើរ ដោកដោយញើស ឱបរឹតនាងនៅក្នុងរង្វង់ដៃរឹងមាំ ហើយរាត្រីដ៏ក្ដៅគគុកនេះ នៅតែដំណើការជាបន្តបន្ទាប់រហូតដល់ពួកគេលង់លក់ជាមួយគ្នានោះឯង។

ខ្នងរបស់នាងនែបនិត្យនឹងដើមទ្រូងរឹងមាំ ដោយចាតដៃធំក្រាស់ម្ខាងកំពុងតែឱបក្រសោបដើមទ្រូងទាំងពីររបស់នាង ចំណែកដៃម្ខាងទៀតរបស់គេ





Scanned by CamScanner

ឱបក្រសោបចង្កេះរបស់នាង ហើយអែនត្រគាកមករកេ។

រាងកាយរបស់នាង យោលយោកនៅលើភ្លៅរបស់គេ ហើយបើគ្មានដៃរឹងមាំជួយឱបក្រសោប នាងអាចនឹងខ្ទាតធ្លាក់ពីគ្រែទៅហើយ និងមិនដឹងជាប៉ុន្មានលើកប៉ុន្មានសារដែលនាងនិងគេត្រូវភ្លើងប្រាថ្នាដុត។

"រ៉េម រ៉េម!"

នាងហៅឈ្មោះគេម្តងហើយម្តងទៀត នាងជារបស់គេ ចង់ហៅគេយ៉ាងម៉េចក៏បាន នាងនឹកដល់គេដោយអារម្មណ៍ជាម្ចាស់កម្មសិទ្ធិ នាងត្រូវបានធ្វើជាម្ចាស់ព្រោះពេលនេះរាងកាយរបស់ពួកគេ រលាយក្លាយជាសាច់មួយ។

រ៉េមសៀ ខិនថើបថ្ពាល់ក្រអូប មុខមាត់របស់ ការ៉ិន ក្រហមង៉ាំងខ្លួនប្រាណក៏ក្រហម ដោយសារឈាមនៅក្នុងខ្លួនធ្វើការខ្លាំងពេក។ នាងត្រូវគេចាប់រុញទៅខាងមុខ ដោយដឹងថាត្រូវលុតជង្គង់និងពូក ទ្រានដៃ ដើម្បីទប់ជំហរខ្លួន និងអែនត្រគាកទៅរកការវាយលុករបស់ស្វាមី។

"លោកប្តី..."

រ៉េមសៀ ពេញចិត្ត ដែលត្រូវនាងហៅយ៉ាងពីរោះបែបនេះ។ គេឱនទៅឱប មិនទម្លាក់ទម្ងន់ខ្លួនឲ្យនាងពន់រែក ព្រោះមាឌរបស់នាងតូចប៉ុណ្ណឹងម្តេចនឹងអាចទទួលយកទម្ងន់ដ៏ធ្ងន់កណ្តុករបស់រាងកាយគេបានទៅ។

ដៃរបស់គេក្រសោបដើមទ្រូងទាំងសងខាង ដែលទម្លាក់ខ្លួន តាមទំនាញផែនដី ប៉ុន្តែទោះយ៉ាងណាក៏វានៅតែមូលក្លំ និងធំប្រាល់បាតដៃរបស់គេដដែល។ គេក្រសោបវា ប៉ះពាល់ ដោយភាពក្តៅគគុក នាងក៏មិនបាន



ហាមប្រាមដោយ មិនគិតទេថា ធ្វើឲ្យវាខូចទ្រង់ទ្រាយ ឬខូចគុណភាព បើគេចូលចិត្តប៉ះពាល់នាងបែបនេះ នាងក៏ជូនតាមសំណើ។

គេប្រមៀលមុខសង្ហា លើស្មាតូចស្តើង។ ក្រៅពីមានមុខមាត់ស្អាតហើយ ស្បែករបស់នាង ក៏ស្អាត ស ម៉ដ្ឋខៃ សព្វសាច់តែម្តង។

អ្នកកំលោះក្រសោបត្រគាកមូលក្លុំរបស់ភរិយាជាទីស្រឡាញ់ ខណៈនោះក៏ខាំថ្គាមណែន ដោយសារការរឹតរួតរបស់នាង ដែលប្រគល់ឲ្យគេ។ រាងកាយរបស់ការ៉ិនដូចត្រូវបង្កើតឡើងដើម្បីគេតែម្នាក់គេមិនធ្លាប់អស់សង្ឃឹមសូម្បីតែម្តង ពេលនាំខ្លួនឯង ជ្រែកចូលទៅក្នុងរាងកាយមួយនេះ ហើយនាងក៏ប្រគល់សេចក្តីសុខឲ្យគេបានល្អជាងមនុស្សស្រីដែលគេធ្លាប់ដេកជាមួយ ទាំងដែលនាងគ្មានបទពិសោធន៍ និងមានតែគេម្នាក់គត់ដែលមានតួនាទី ជាគ្រូបង្រៀនដល់នាង។

គេមិនត្រូវការឲ្យអ្នកដទៃ មកបង្រៀនប្រពន្ធរបស់គេ ហើយបើអ្នកណាហ៊ាន គេនឹងកាត់វាជាពីរកំណាត់។

ក្រៅពីភាពឈ្លក់វង្វេងនឹងរាងកាយរបស់ ការ៉ិន ធ្វើឲ្យគេគ្មានការសោកស្តាយស្រីកំណាន់ដែលត្រូវបញ្ជូនចេញពីប្រាសាទត្រេវ៉ៃក្រយ គេទើបតែដឹងរឿងមួយទៀតថា គឺគេហួងហែងនាងខ្លាំង។

*ប្រពន្ធអញ!*

គេគិត ដោយបង្ហាញភាពជាម្ចាស់ចំពោះនាងបែបនេះជាញឹកញាប់ និងកម្ចាយការហួងហែងរបស់ខ្លួន តាមរយៈការប៉ះពាល់ដ៏ក្តៅគគុកដោយ





Scanned by CamScanner

ភ្លើងប្រាថ្នា។

ការ៉ិន ត្រូវបញ្ចេញកម្លាំងទ្រានដៃនឹងពូក ព្រោះរាងកាយជ្រមិលទៅតាមកម្លាំងវាយលុករបស់ វែមសៀ។ នាងថ្ងូចថ្ងូរដាក់ការប៉ះពាល់ដ៏រញ្ជួយនោះ រាងកាយស្រៀវស្រើបតាមសកម្មភាពរបស់ស្វាមី។នាងត្រូវការឲ្យបុរសម្នាក់នេះមានក្ដីសុខ ត្រូវការតបស្នងគេដោយរាងកាយរបស់នាង ឲ្យគេឈ្លក់វង្វេង ត្រូវការមានអំណាចលើគេ មិនមែនដើម្បីគ្រប់គ្រងគេ តែមិនត្រូវការឲ្យគេមានអ្នកផ្សេង។ កាន់តែនៅជិត ការពិតដែលលាក់នៅក្នុងបេះដូង ដូចត្រូវគោះសម្បកឲ្យបែក។ នាងស្រែកថ្ងូចថ្ងូរខ្លាំងៗ បន្ទាប់មក ក៏ត្រូវបី ចុះពីគ្រែ ធ្វើឲ្យនាងសោកស្ដាយភាពក្ដៅគគុករបស់ វែមសៀ ប៉ុន្តែអត់នោះទេ គេមិនបានបណ្ដោយឲ្យនាងដង្ហោយរកគេយូរជាងនោះគេគ្រាន់តែលើកនាងចុះមកក្រោម ដើម្បីទាញនាងឲ្យបែរមុខមករក ព្រោះត្រូវការឱបរឹតនាង នៃបនិត្យជិតទ្រូង និងឲ្យរាងកាយទាំងពីរនៃបនិត្យជិតគ្នាកាន់តែខ្លាំង បន្ទាប់មក នាងក៏ឡើងច្រកគៀរលើភ្លៅរឹងមាំម្ដងទៀត និងឱបរឹតគេកាន់តែណែន។

"លោកប្ដី ក្ដៅ..."

នាងម៉ិកម៉ូក់ដាក់គេ។ ការ៉ិន ពេលនៅលើគ្រែ គួរឲ្យស្រឡាញ់ គួរឲ្យភ្ញាក់ពេញបេះដូង វាប៉ះប៉ូវនឹងភាពគួរឲ្យទះកំប៉េះគូទរបស់នាង ពេលដែលត្រូវការញ៉ោះឲ្យគេខឹង។

"បាត់ក្ដៅហើយឬនៅ"

វែមសៀ លើកត្រគាកភរិយា ដើម្បីឲ្យនាងទទួលយកគេ ហើយត្រូវនាង



ថើបស្មា បន្តដោយការថើបតែមមាត់។

"កាន់តែក្ដៅ"

នាងតប ហាក់ដូចមនុស្សមមើ វែមសៀ ក៏គ្រហឹមនៅដើម-ក ចាប់ត្រគាកមូលក្លំរបស់នាងសង្កត់ និងគ្រប់គ្រងដោយភាពព្រៃផ្សៃ។ គេមានកម្លាំងពលាំងច្រើន តែងតែស្រឡាញ់នាងដោយភាពឃោរឃៅ ប៉ុន្តែនាងមិនទទួលបានការឈឺចាប់ពីការប៉ះពាល់នោះ។

វែមសៀ ហាក់ដូចមនុស្សឆ្កួត មុខរបស់គេដូចទមិឡ ប៉ុន្តែនាងដឹងថាគេកំពុងតែមានអារម្មណ៍ប្រាថ្នាដ៏ខ្លាំងក្លា ទើបថើបថ្ពាល់របស់គេ ទទួលយកការប្រាថ្នាពីគេ ដោយមិនរង់រង់ក់។

"វែម...អ្វី..."

នាងបើនខ្លួន វែមសៀ ក៏តាមទៅរក។ ពួកគេតបស្នងគ្នាហាក់ដូចស្រេកឃ្លានខ្លាំង ប៉ុន្តែគឺឃ្លានមែនហ្នឹងព្រោះគេនៅឆ្ងាយពីរាងកាយរបស់ភរិយាដោយភារកិច្ច ហើយពេលមានឱកាសក៏ត្រូវព្រះអង្គម្ចាស់ ខាឡម៉ាន់ ជ្រៀតជ្រែកទៀត។ គេទើបតែបានឱបនាងពេញដៃ គឺនៅថ្ងៃនេះឯង ទើបត្រូវទាមទារទាំងដើមទាំងការ មិនឲ្យមានខ្វះ មានតែលើសកម្រិត។

ការ៉ិន និង វែមសៀ សម្ងំនៅក្នុងបន្ទប់ដេកជាមួយគ្នា ស្ទើរតែមិនចេញទៅណា ទទួលទានអាហារដែលអ្នកបម្រើលើកមកឲ្យដល់បន្ទប់ ពេលរួចរាល់ក៏យកចានឆ្នាំងទៅដាក់នៅមុខបន្ទប់ ដោយមិនហៅអ្នកបម្រើឲ្យចូលបម្រើ



ហើយមានព័ត៌មានលិចឮច្រើនណាស់ ថាលោកឧត្តមសេនីយ៍ វែមសៀ មិនធ្វើការធ្វើងាររយៈពេលបីថ្ងៃបន្ទាប់ពីរៀបការរួច តែគេមិនខ្វល់នឹង ព័ត៌មានលិចឮនោះ ក្រៅពីចាប់ដៃភរិយា បណ្តើរគ្នាទៅក្រុងអាឡិចសានដេ នាំភរិយាទៅផ្ទះរបស់គេ។

"វែមសៀ"

"អ៊ឹម" គេតប។

ស៊ីឡានិងហ្វីវ៉ាត្រូវបានអនុញ្ញាតឲ្យតាមមកបម្រើព្រះនាងដល់ប្រាសាទត្រវីត្រយ ខណៈដែលដំណាក់ចាស់ ព្រះនាងក៏គង់នៅ និងជាដំណាក់សម្រាប់លំហែរបស់ពួកគេ ហើយចាប់ពីពេលនេះទៅ ប្រាសាទត្រវីត្រយជាផ្ទះរបស់នាង។

ការ៉ិន ដាក់ដៃលើស្មារបស់ស្វាមី ព្រោះគេមានមាឌធំជាងនាង ក្រៅពីនេះគេក៏រឹងមាំណាស់ដែរ ហើយគេ ក៏ចូលចិត្តលើកនាងបីដោយមិនសំចៃកម្លាំង ហើយពេលនេះក៏មិនត្រូវការឲ្យនាងដើរឡើងឧម្ពគចក្រដោយខ្លួនឯង ដោយគេប្រើវិធីចាប់ចង្កេះរបស់នាងលើកដាក់ ហើយឡើងមកតាមក្រោយ។

"អូនរំភើប"

នាងប្រាប់ ខណៈពេលដែលត្រូវគេដាក់ខ្សែក្រវាត់ការពារឲ្យ បន្ទាប់មកក៏ចាត់ការខ្លួនឯង ទើបនាងស្រវាចាប់ដៃរបស់គេ។

"នៅក្នុងប្រាសាទត្រវីត្រយមានអ្នកណាកាចជាងបងទេ ?"

វែមសៀ ងាកទៅមើលមុខភរិយា តែនាងធ្វើមុខមិនដឹងមិនឮ ធ្វើខ្លួន



មោយៗដាក់គេ។

"គ្មានទេ"

"បើអ៊ីចឹង ប្រហែលមិនគួរឲ្យខ្លាចប៉ុន្មាន"

"អូនធ្លាប់ខ្លាចបង ?"

វែមសៀ ទើបតែដឹងថា គេទទួលបានកិត្តិយសនោះ។ ការ៉ិន ប្រកែកប្រណាំងធ្វើឲ្យគេនិយាយតាមមិនទាន់ នាងជាស្រីឆ្លាស តែមិនគួរឲ្យធុញទ្រាន់ប៉ុន្មាន គេគិតថានាងជាមនុស្សស្រី ចូលចិត្តបង្កបញ្ហា ឆ្លាសឆ្នើមនៅក្នុងកម្រិតដែលគេអាចទប់ទល់បាន។

"ខ្លាចតើ មាឌបងធំដូចយក្ស"

"បងនឹងចាំទុក"

"តែបងកុំបានចិត្ត ទោះអូនខ្លាចបង តែអូនមានអានេះជាអាវុធ"

នាងលើកចង្អុលដៃសង្កត់បបូរមាត់ វែមសៀ ក៏ឈោទៅរក និងថើបបបូរមាត់នោះខ្លាំងៗ។

"អឺ ! មិនឲ្យថើប"

ក្នុងពេលថើបរួចទៅហើយ ទើបគេថើបម្តងទៀត ហើយពេលគេជយទៅអង្គុយឲ្យស្រួលបួល នាងក៏លួចមើលអ្នកផ្សេងនៅក្នុងឧម្ពគចក្រ បន្តដោយការសម្លក់សម្លឹងគេ។



"យកម្រាមដៃសង្កត់បបូរមាត់ធ្វើអី ?"

"អូនចង់មានន័យថាអូនមានសំឡេងជាអាវុធ បើបងចិត្តអាក្រក់ដាក់អូន



Scanned by CamScanner

អូននឹងស្រែកឲ្យបែកប្រាសាទត្របើត្រយ"

"អូនគំរាមបង ?"

"អូននឹងទូលពិតបងប្រុសដែរ"

"ក្រៅពីឆ្លាសហើយ នៅចូលចិត្តទូលពិតទៀត"

"អូនធ្វើបានគ្រប់យ៉ាងហ្នឹង ធ្វើខ្លួនឲ្យល្អទៅ"

នាងយកចង្អុលដៃចាក់ដើមទ្រូងរបស់ស្វាមី ហើយបញ្ឈប់ការសន្ទនាជាមួយគេបណ្ដោះអាសន្ន ដោយការមើលទៅខាងក្រៅឧម្ភគចក្រ។

"បងចាត់ការរឿងស្រីកំណាន់របស់បងរួចរាល់ហើយមែនទេ"

"អូនចង់ឲ្យបងរើសថ្មីឬ"

"សាកមើលទៅ បើចង់ដាច់ត្រចៀក"

នាងផ្ដិះទងត្រចៀករបស់គេលេង តែត្រូវគេចាប់ដៃនិងធ្វើមុខកាចដាក់ ព្រោះការប៉ះពាល់បែបនេះ វាគ្រោះថ្នាក់ចំពោះអារម្មណ៍របស់គេពេកហើយ ទោះនៅក្នុងបន្ទប់បិយប់បិថ្ងៃជាមួយនាងក៏ដោយ ប៉ុន្តែព្រោះគេនៅឆ្ងាយពីនាងយូរពេកឬអត់ ទើបមានអារម្មណ៍ថារាងកាយមិនចេះស្កប់ស្កល់។

"បងចាត់ការរួចរាល់តាំងពីយូរហើយ"

"អូនត្រូវការបញ្ជាក់ឲ្យដឹងជាមុន ដើម្បីទំនុកចិត្ត តិ...តាមពិតទៅអូនរំភើបណាស់ដែលត្រូវទៅទីនោះ"

"រំភើបធ្វើអី យើងគ្រាន់តែត្រឡប់ទៅផ្ទះ"

"តិ...អូនមិនស៊ាំ"



"អូនត្រូវធ្វើខ្លួនឲ្យស៊ាំ ព្រោះអូនត្រូវនៅទីនោះជាមួយបង"

អ្នកកំលោះនិយាយដោយទឹកមុខមាំ តែនាងវិញ ញញឹមឡើងថ្ពាល់ចោងទៅហើយ មិនចង់បង្ហាញអាការៈណាស់ណាថានាងមានសេចក្ដីសុខមែនទែន តែវាហាមមិនបានហ្នឹងណា។

"ញញឹមអី ?"

"អូនមានអារម្មណ៍ល្អ ញញឹមមិនបានឬ"

"អីចឹងអញ្ជើញតាមសម្រួល"

"សុំផ្អែកទ្រូងបន្តិច អូនងងុយ"

រ៉េមសៀ ស្រវាឱបស្មារបស់ភរិយា ឲ្យនាងផ្អែកក្បាលនឹងដើមទ្រូង ហើយនាងក៏បិទភ្នែក ដេកលក់ស្រួលបន្ទាប់ពីនោះ ព្រោះទុកចិត្តថាស្វាមីមើលថែបានល្អ។

អ្នកបម្រើនៅក្នុងប្រាសាទត្របើត្រយឈររៀងគ្នាជាពីរជួរ ដើម្បីធ្វើការគោរព និងណែនាំខ្លួនឯងឲ្យព្រះនាងស្គាល់។ រ៉េមសៀ ដឹកដៃភរិយាដើរកាត់មុខអ្នកបម្រើយឺតៗ ដោយអ្នកបម្រើស្រីបន្ទន់ជង្គង់ ធ្វើការគោរព និងណែនាំខ្លួនឯង ខណៈដែលអ្នកបម្រើប្រុស ឱនគំនាប់។

"អរគុណច្រើនអ្នកទាំងអស់គ្នា សម្រាប់ការស្វាគមន៍"

នាងប្រាប់អ្នកបម្រើ មេការនៅទីនេះ មានពីរនាក់ ស្រីឈ្មោះ ដេណែត ប្រុសឈ្មោះ ដេវីត ដោយនាងអនុញ្ញាតឲ្យមេការទាំងពីរទទួលខុសត្រូវតួនាទី



របស់ខ្លួនបន្ត នាងមិនជ្រៀតជ្រែក ប៉ុន្តែនឹងសុំការណែនាំ ទៅលើរឿងមើលការខុសត្រូវទៅលើអ្នកបម្រើ។

រ៉េមសៀ បានឮបែបនេះហើយ ក៏មានពេញចិត្តនឹងអាកប្បកិរិយារបស់កាំរីយ៉ា។ នាងមិនមែនជាមនុស្សស្រីល្ងង់ខ្លៅ ពេលដែលមានអំណាចនៅក្នុងដៃក៏ប្រើវាខ្វះខ្វាយ។ នាងដឹងថាត្រូវចងមិត្តនឹងមនុស្សបែបណា និងការចេះប្រើមនុស្សឲ្យមានប្រយោជន៍គឺជារឿងល្អ។

"ខ្ញុំមិនទំនេរពេលធ្វើការទេ អញ្ជើញ"

នាងអនុញ្ញាតអ្នកបម្រើ ហើយឲ្យ រ៉េមសៀ ដឹកដៃដើរចូលប្រាសាទ។

ប្រាសាទត្រជាក់ត្រយមានទំហំធំណាស់ ហើយចំនួនបន្ទប់រាប់រយមុខជាធ្វើឲ្យនាងមានរឿងធ្វើបន្ទាប់ពីនេះពេញមួយសប្តាហ៍ នាងនឹងដើរពិនិត្យប្រាសាទទាំងមូល។

"អ្នកបម្រើស្វាគមន៍អូនហើយ ចុះបង ស្វាគមន៍អូនហើយឬនៅ"

"បងត្រូវធ្វើ ?"

"ត្រូវតែធ្វើ ប្រុសមោឃ"

នាងនាំខ្លួនឯងចេញឲ្យឆ្ងាយ ហើយលើកដៃច្រត់ចង្កេះ រ៉េមសៀ ក៏ចង់ចិញ្ចើមនឹងសព្ទនាមនោះ។

"អូនហៅបងថាម៉េច ?"

"ប្រុសមោឃ"

នាងឆ្លើយប្រាប់ដោយមិនក្រែងអែង ថែមទាំងបញ្ជាក់ឲ្យគេឮច្បាស់



ទៀតផង ថានាងហៅគេថាអ្វី ក្រៅពីនេះ ម្រាមដៃស្រឡូន នៅលើកមកចាក់ដើមទ្រូងរឹងមាំទៀត។

"ប្រុសមោឃ ប្រុសមោឃ ប្រុសមោឃ"

"ឈប់ឈ្លើយដាក់បង ខ្លារីហ្សា"

"មិនបានឈ្លើយអីទេ គឺបងមោឃមែន"

ពេលឃើញគេធ្វើមុខក្រមូវបែបនេះ ទើបនាងធ្វើខ្លួនម៉ឺកម៉្ញក់តាមការណែនាំរបស់ សានេនេ។

"ខឹងឬ ?"

នាងស្ទុះទៅរក អែនខ្លួនទៅនែបនិត្យ ហើយបើត្រូវ រ៉េមសៀ រុញចេញ នាងនឹងស្រែកដាក់មុខគេ ប៉ុន្តែអ្នកកំលោះបែរជាលើកដៃឱបស្នាទៅវិញ។

"អូនចង់បានពាក្យស្វាគមន៍ពីបងហ្នឹងណា៎"

"សូមស្វាគមន៍"

វិធីរបស់ សានេនេ ទទួលបានលទ្ធផលល្អគ្រប់វិធី ដែលនាងសាកល្បងប្រើ។ នាងបានទទួលការណែនាំរឿងតម្រូវការរបស់មនុស្សប្រុសជាច្រើនរឿង ទោះនាងមាត់រឹង ប្រាប់ សានេនេ នាងអាចមិនធ្វើតាមទាំងអស់ តែដល់ទៅមែនទែនទៅ នាងបែរជាធ្វើតាមការណែនាំទាំងនោះ ដោយមិនឲ្យមានខ្វះចន្លោះ។

"ដាក់ឈ្មោះអូនចូលផង"

"សូមស្វាគមន៍ ខ្លារីហ្សា"

"ទីនេះជាផ្ទះរបស់យើងមែនទេ"





Scanned by CamScanner

រ៉ែមសៀ រីងខ្លួន ដែលធ្វើឲ្យនាងចង់ញញឹមចេញ ព្រោះគេគិតយូរពេក ប៉ុន្តែសម្តីដាស់តឿនរបស់ សានេនេ ក៏រត់ចូលមកក្នុងការចងចាំ។

'រឿងទំនាក់ទំនងមិនអាចឆេវឆាវបានទេព្រះនាងត្រូវធ្វើចិត្តឲ្យត្រជាក់និងមានស្មារតីចំពោះវា'

នាងសព្តាំចិត្តខ្លួនឯងឲ្យត្រជាក់ បើគេមិនឆ្លើយ ចាំឡូឡាក៏បានដែរ ឲ្យគេបានគិតបន្តិចក៏មិនអី។

"អឺម! ទីនេះជាផ្ទះរបស់យើង"

ទោះបុននេះមានច្រើនដងណាស់ ដែលគេនិយាយដល់ប្រាសាទត្រើត្រយ ដូចវាជាកន្លែងរបស់នាងនិងគេ តែម្តងនេះ នាងទាមទារឲ្យគេឆ្លើយតបឲ្យច្បាស់លាស់ ហើយពេលបានឮចម្លើយ នាងក៏ញញឹមពព្រាយបាញ់ខ្សែភ្នែកផ្អែកវណាស់។

"ថ្ងៃនេះបងទៅណាទេ ?"

"បងនឹងនៅក្នុងប្រាសាទ តែស្អែកបងមានការងារត្រូវធ្វើ"

"អីចឹងថ្ងៃនេះបងនាំអូនដើរមើលប្រាសាទ"

អ្នកកំលោះងក់ក្បាល និងគិតថា មិនទាន់នាំនាងចូលបន្ទប់ដេកទេ ព្រោះបើចូល គេខ្លាចថាមិនបានចេញមកវិញរហូតដល់អាហារល្ងាច ទើបនាំនាងដើរទៅជាន់ក្រោមរបស់ប្រាសាទ មើលផ្នែកខ្លះៗសិន។

"ចង់កែប្រែអីទេ ?"

"អត់ទេ គ្រប់យ៉ាង មានតម្លៃរបស់វា"



នាងឆ្លើយតបតាមអារម្មណ៍ពិតប្រាកដ។ ទីនេះ មានភាពជា រ៉ែមសៀ ច្បាស់ណាស់ ដូច្នេះហើយទើបនាងមិនត្រូវការកែប្រែវា ដូចនៅដំណាក់របស់នាង ក៏តុបតែងតាមចំណង់ចំណូលចិត្តរបស់នាង តែចំណង់ចំណូលចិត្តចំពោះទីកន្លែង មិនអាចប្រៀបធៀបបាននឹងអារម្មណ៍ដែលមានចំពោះគ្នា។ បើនាងនិង រ៉ែមសៀ អាចរក្សាទំនាក់ទំនងដ៏ល្អចំពោះគ្នាបាន ទោះប្រាសាទតុបតែងបែបណា នោះមិនមែនជារឿងសំខាន់ ហើយការយកពេលវេលាទៅមមាញឹកនឹងការតុបតែងប្រាសាទដែលវាស្អាត មានតម្លៃរបស់វាស្រាប់ទៅហើយ វាឥតប្រយោជន៍នោះទេ នាងសុខចិត្តយកពេលចំណាយលើស្វាមីរបស់នាងល្អជាង ព្រោះទោះក្លាយជាស្វាមីភរិយានឹងគ្នាទៅហើយ ប៉ុន្តែទំនាក់ទំនង នៅតែត្រូវបន្តការអភិវឌ្ឍ។

"នៅទីនេះអូនធ្វើអីបានខ្លះ ?"

"បានគ្រប់យ៉ាង"

"គ្មានបម្រាមទេឬ ?"

"បើមានអីដែលអូនធ្វើហើយមិនត្រឹមត្រូវ បងនឹងប្រាប់"

នាងក្រមុំឈប់ដើរ ហើយងាកទៅមើលផ្កាលំត្រើម ពេលនោះក៏អរគុណស្បែកជើងកែងចោត ដែលធ្វើឲ្យនាងមិនចាំបាច់ជំទើត។

"វង្វាន់សម្រាប់មនុស្សចិត្តទូលាយ"

នាងញញឹមពព្រាយដាក់ ហើយដើរទៅមុខបន្ត។

"វាធំណាស់"





Scanned by CamScanner

"បងមិនទាន់មានផែនការសម្រាប់ដីជុំវិញប្រាសាទទេ"

"បើរូនមានអូននឹងប្រាប់បង"

នាងងាកទៅថើបថ្ពាល់របស់គេ រ៉េមសៀ ក៏ក្រសុលទៅរកនិងឱនថើបកញ្ចឹងករបស់នាង។

"ទៅមើលបន្ទប់ដេកទៅ ខ្លារិហ្សា"

សំឡេងស្អកបែបនេះ គេប្រហែលមិនបបួលនាងទៅមើលតែបន្ទប់នោះទេ តែនាងក៏មិនឫកពា ងក់ក្បាល ហើយលើកដៃឱបករឹងមាំ ពេលដែលត្រូវគេលើកបី ដើរសំដៅបន្ទប់ដេក។



# ១៤

## ចិត្តស្នេហា

"បានហើយ! តាប៉ុផ្លូត!"

ការ៉ិន ក្ដាប់ដៃគក់ស្វាស្វាមី នៅថ្ងៃឈប់សម្រាក ដែលគេនាំជិះសេះមើលទេសភាព។ ស្វាមីចេះចំណាយពេលឲ្យភរិយា គឺជារឿងល្អ ប៉ុន្តែស្វាមីដែលនាំភរិយាជិះសេះគយគន់ទេសភាពដូចជិះសេះប្រណាំង គឺជាស្វាមីឡប់។

"ក្រពេញរ៉ូមែនទិកវារលាយតាមអាយុហើយមែនទេ"

នាងចង់តាំងបេះដូងស្លាប់ ព្រោះខ្លាចធ្លាក់ គក់គេហើយគក់ទៀត គិតថាខ្លួនឯងគិតខុសឬត្រូវ ដែលផ្ញើជីវិតនឹង រ៉េមសៀ ដាវ៉ៃហីណោស។

"បញ្ឈប់សេះភ្លាម អូនបញ្ជាឲ្យឈប់!"

រ៉េមសៀ កន្ត្រាក់បង្ហៀរឲ្យសេះឈប់ដើរ។ តាមពិតគេបន្ថយល្បឿនហើយ ប៉ុន្តែនាងនៅតែខឹង ឡើងក្រហមមុខ ព្រមទាំងរអ៊ូទាំបិនចេះហត់។

"ដាក់អូនចុះ"

រ៉េមសៀ ព្រលែងដៃពីបង្ហៀរ ហើយពេលគេធ្វើបែបនោះ អ្នកដែលអង្គុយពាក់ចៀងនៅលើខ្នងសេះ ក៏ប្រញាប់ស្រវាឱបគេ ព្រោះគ្មានរង្វង់ដៃចាំឱបក្រសោប។

"អាប៉ុផ្លូត! បើអូនធ្លាក់តើធ្វើយ៉ាងម៉េច"





Scanned by CamScanner

នាងទាំងទះទាំងតប់ ទាំងរអ៊ូរទាំ បញ្ជាឲ្យគេឈប់សេះក៏ពិតមែន តើយកកម្លាំងឯណាចុះពីខ្នងសេះទៅ នាងធ្វើមុខខ្មូរ ងើយមុខសម្លក់សម្លឹងស្វាមី។

"លើកអូនចុះពីសេះផង អូនចុះដោយខ្លួនឯងមិនបាន"

ទោះខឹង តែក៏ព្រមកាត់បន្ថយឫកពាតិចតួច រ៉េមសៀ ក៏ងក់ក្បាលលោតចុះពីខ្នងសេះ។

"រ៉ក!" សេះធំដូចដឹងថានាងខ្លាច វាប្រហែលជាស៊ុមត្រលុំនឹងម្ចាស់របស់វា ធ្វើបាបនាងដោយការកញ្ជ្រោលតិចៗ ទើប រ៉េមសៀ ហួច វាក៏ព្រមនៅស្ងៀម ទើបនាងប្រឹងប្រវេប្រវា ស្រវាចាប់ដៃអ្នកដែលហុចមករក។

"បានហើយ! ទាំងសេះទាំងម្ចាស់ ព្រួតគ្នាធ្វើបាបអូន"

នាងសម្លក់សម្លឹងសេះធំ ទោះវាមិនដឹងឮស់អី។

រ៉េមសៀ លើកភរិយាចុះពីខ្នងសេះ ហើយត្រូវនាងតក់ខ្នងដៃ និងតើងទ្រូងដាក់ ងរង៉ក់កាន់តែខ្លាំង។

"លែងអូន"

នាងនឹងមិនសម្ងំក្នុងដើមទ្រូងរបស់គេទៀត ទោះដើមទ្រូងកក់ក្ដៅនោះគួរឲ្យសម្ងំគួរឲ្យបពោសអង្អែលយ៉ាងណាក៏ដោយ។ រ៉េមសៀ ស្ដាប់បង្គាប់ណាស់ គេព្រមដាក់ភរិយាចុះហើយពេលជើងនាងជាន់ដីក៏ទន់ជង្គង់ ផ្រមិលរកកល់ចង់ដួល ទើបងាកទៅស្រវាចាប់ដៃគេជាប់ ហើយបន្ទាប់ពីទប់ជំហរខ្លួនបាន ទើបនាងព្រលែងដៃរបស់គេ និងធ្វើងើយដាក់ រួចដើរចេញ។

មនុស្សឆ្កួត ជិះសេះជាមួយគ្នា គឺត្រូវតែផ្អែមល្ហែម ឲ្យវារត់ត្រឹកៗទៅខាង



មុខ អ្នកនៅលើខ្នងសេះបានគយគន់ទេសភាព តែនេះស្អី ទេសភាពមិនបានគយគន់ ព្រោះត្រូវចំណាយពេលយកដៃទៅក្រសោបសក់ ព្រោះល្បឿន វាធ្វើឲ្យសក់ឃើង ឡើងជំពាក់អស់ទៅហើយ។

"ចង់ទៅណា?"

"ដើរទៅផ្ទះវិញ"

រ៉េមសៀ ដឹកសេះសំណព្វដើរតាមភរិយា ដែលដើរចេញទៅឆ្ងាយទៅហើយ។

"ឆ្ងាយ"

"ល្អជាងត្រូវធ្វើបាប"

"ឡើងសេះល្អជាង"

"មិនឡើង ជិះលឿនដូចនាំទៅស្លាប់"

នាងខំតែងខ្លួនឡើងស្អាតស៊ិចស៊ី ដើម្បីម៉ិកម៉ូក់ស្វាមីជាពិសេស ស្លៀកសំពត់ពណ៌ស្វាយខ្ចី សម្រុងវែងដល់កជើង ពាក់អាវដៃអាវវែងដល់កដៃ មានជរំភាយៗ ជាឈុតស្អាត ពណ៌ស្រស់ ហើយនាងក៏ពាក់វាបានស្អាតទៀតផង។ នាងខំដាក់ផែនការធ្វើខ្លួនជាស្ត្រីទន់ជ្រាយ អង្គុយផ្អែកនឹងដើមទ្រូងស្វាមីគយគន់ទេសភាព តែនេះស្អី ប្រុសចង្រៃ ធ្វើឲ្យខូចផែនការរបស់នាងអស់ អីចឹងមិនចាំបាច់ម៉ិកម៉ូក់ទេ មនុស្សឆ្កួតស្អីបែបនេះក៏មានដែរ។

នាងរវល់តែដើរ ភ្លេចគិតទៅថាមិនបានឮសំឡេង រ៉េមសៀ ដើរតាមពីក្រោយ ហើយពេលដើរបានមួយសន្ទុះ ក៏ឈប់ដើរ ងាកទៅមើលជុំវិញខ្លួន



ឃើញថាគ្មានទាំងមនុស្សគ្មានទាំងសេះដើរតាម កំឈរនៅត្រង់នោះម្នាក់ឯង តន្រ្តំជើងដោយកំហឹង។

"តាប៉ិត្តត វែមសៀ ចាំមើលមិនព្រមឲ្យដេកគ្រែជាមួយមួយខែ មនុស្សអន់ចរិត"

នាងក្តាប់ដៃ តន្រ្តំជើងម្តងទៀត ហើយគិតគូដល់បញ្ហាបន្ទាប់។ នាងមិនទាន់ស្គាល់ប្រាសាទត្រវ៉ែយព្រៃយដ៏ធំល្វឹងល្វើយព្បាស់ ទោះរស់នៅទីនេះ បានមួយខែហើយក៏ដោយ ប៉ុន្តែមិនទាន់បានពិនិត្យឲ្យគ្រប់ជ្រុងជ្រោយ។

"តើមានស្រីណាស៊ិយដូចខ្ញុំទៀតដែរទេ ត្រូវប្តីទុកចោល ថែមទាំងវង្វេងផ្លូវទៀត វាគួរឲ្យបណ្តេញចេញពីតំណែងប្តីមែនទែន តាប៉ិត្តត វែមសៀ!"

នាងទាំងខឹង ទាំងតូចចិត្តឡើងទឹកភ្នែករលីងរលោង។ នាងធ្វើតួនាទីជាភរិយាមានខ្វះចន្លោះត្រង់ណាទៅ ទោះនាងពូកែចាយលុយ ប៉ុន្តែនោះដើម្បីពិសោធន៍ការអត់ធ្មត់របស់គេហើយដែលសំខាន់របស់ល្អៗស្អាតៗរបស់មនុស្សស្រី ទិញយ៉ាងណាក៏មិនចេះគ្រប់ដៃរ ទិញហើយ នៅតែចង់បានទៀត។

ទោះនាងចូលចិត្តរអ៊ូរទាំ បរិហារណរឿងលើគ្រែ ធ្វើឲ្យគេប្រាប់ញឹកញាប់ថាបើនាងឧស្សាហ៍រឿងលើគ្រែដូចសិបភឹងប្រហែលល្អ ប៉ុន្តែនាងមិនរអ៊ូបានឬស្វាមីគេឧស្សាហ៍ធ្វើរឿងបែបហ្នឹងដូចស្វាមីរបស់នាងឬអត់។

ថ្ងៃធ្វើការ គេត្រឡប់មកផ្ទះទៀងវេលា ហើយសម្ងំនៅជាមួយនាង ឡើងចង្កេះរបស់នាងគ្រេចចង់ដាច់។ បើម្តងពីរដង នាងមិនរអ៊ូទេ តែគេធ្វើលើសពីនោះទៅទៀត យប់ខ្លះលើសប្រាំទៅប្រាំមួយដង វាលើសចំនួនធម្មតារបស់



មនុស្សទូទៅហើយ ហើយបើជាថ្ងៃឈប់សម្រាកចុងសប្តាហ៍ គេសម្បូរកម្លាំងណាស់ តាំងពីក្បាលព្រលប់ដល់មេឃភ្លឺថ្ងៃថ្មី ដល់ថ្នាក់នាងអង្វរករសុំជីវិតនៅលើគ្រែច្រើនដង។ គេគួរបន្ទោសខ្លួនឯងឬអត់ ដែលមានតម្រូវការខ្ពស់ពេក ធ្វើឲ្យរាងកាយរបស់នាងទប់ទល់មិនឈ្នះ។

"ចាំមើល បើអូនដើរវង្វេងនៅទីនេះដល់ឃ្លានស្លាប់ អូននឹងធ្វើជាខ្មោចតាមលងបង កុំគិតថារៀបការយកប្រពន្ធថ្មី នាំស្រីផ្សេងចូលផ្ទះ នឹងចាប់កាច់កឲ្យអស់"

ការ៉ុន មើលទៅជុំវិញខ្លួន ទោះទេសភាពស្អាតយ៉ាងណាក៏ដោយ ប៉ុន្តែពេលគ្មាន វែមសៀ នៅជាមួយ សោភណ្ឌភាពទាំងនោះក៏ក្លាយជារឿងគួរឲ្យខ្លាច។

"ដើរបន្តក៏បាន អូនហត់ស្លាប់ពេលណា ចាំឈប់ដើរ"

នាងតន្រ្តំជើង ហើយដើរទៅមុខបន្ត ដោយមិនដឹងទិសតំបន់ មាត់ក៏រអ៊ូរទាំ បញ្ឈឺជីវិត តែដើរមិនបានប៉ុន្មានជំហាន ក៏ហត់ ដើរទៅមុខលែងរួច រួមផ្សំនឹងការងរង៉ក់ តូចចិត្តនឹងស្វាមី ទើបអស់កម្លាំង ដាក់បង្អុយលើដី ហើយពេលនោះឯងនាងក៏បើកភ្នែកធំៗ ស្រែកភ្ញាក់មាត់ ពេលដែលលើកដៃមើល។

"អ៎ក..!"

"ខ្លារខ្លាហ្វា"

វែមសៀ លេចចេញពីណាក៏មិនដឹង តែរង្វង់ដៃរឹងមាំនោះ ធ្វើឲ្យនាងរសាយការភ័យខ្លាចបានខ្លះ ទើបងាកទៅស្រវាឱបគេ ដែលឱបនាងពីក្រោយ។





Scanned by CamScanner

"កើតអី ឈឺត្រង់ណា?"

សំឡេងស្រែករស់សំឡេងនោះ ធ្វើឲ្យគេស្ទុះមករកនាងលឿនដូចព្យុះ លែងហ៊ានលាក់ខ្លួនទៀត ហើយស្ទាបខ្លួនរបស់នាង ដើម្បីត្រួតពិនិត្យ។

"រ៉ែមសៀ...បងសម្លាញ់"

"កើតអី ប្រាប់ម៉ោមើល៍"

ខ្លារីហ្សា យំអណ្ដឺតអណ្ដក លើកដៃយឺតៗ ទើបត្រូវ រ៉ែមសៀ ស្រវាចាប់ពិនិត្យមើលថានាងមានរបួសត្រង់ណាដែរទេ អាចមានសត្វល្អិតទិច ឬខាំនាងក៏ថាបាន។

"ក្រចក...របែក"

"ថាម៉េច?"

"ប្រាប់ថាក្រចករបែក មិនឮទេក៏អី ម៉ុតនេះទើបតែធ្វើថ្មីៗ កាលពីម្សិលអង្គុយធ្វើចុកខ្លួងចុកចង្កេះ ទម្រាំតែរួច មើលចុះ អស់ស្អាតរលីង"

រ៉ែមសៀ ខាំធ្មេញក្រតៗ នឹកចង់ចិញ្ច្រាំក្រចកដែលជាប់នឹងដៃរបស់ភរិយាចោលឲ្យគ្រប់ដប់ម្រាម ព្រោះគ្រាន់តែរឿងក្រចករបែកសោះ នាងធ្វើឲ្យគេភ័យលស់អស់ព្រលឹង។

"ក្រចករបែក មិនមែនប្ដីស្លាប់ទេ ស្រែកឡូឡាធ្វើអី ថ្លង់"

"ប្ដីស្លាប់ យំធ្វើអី គេមានតែសើច"

"ខ្លារីហ្សា!"

រ៉ែមសៀ គ្រហឹមហៅឈ្មោះនាងជាការដាស់តឿន តែនាងមិនខ្លាចគ្រហឹមបានចេះតែប្រឹងគ្រហឹមទៅ តែគ្រហឹមញឹកពេក នឹងប្ដូរពីអាហារមនុស្សទៅអាហារគ្រាប់ឲ្យ។

"មិនបាច់គ្រហឹម ជាពិសេសប្ដីចិត្តអាក្រក់មានឈ្មោះ រ៉ែមសៀ សមតែស្លាប់"

"បើបងស្លាប់ បានអ្នកណារកលុយចិញ្ចឹមអូន"

"ទុកមរតកឲ្យច្រើនៗម៉ោ"

"ទុកឲ្យច្រើន គង់តែបំផ្លាញអស់ក្នុងពេលបីខែទេ"

"ចិញ្ចឹមប្រពន្ធប៉ុណ្ណឹង យំតែអ៊ីៗ ប្រពន្ធម្នាក់ចិញ្ចឹមមិនរស់ អន់!"

ការ៉ុន ចេះតែរករឿងគេ តែទោះច្រែតៗដាក់គេយ៉ាងណា ដៃនៅតែខ្ទាំអាវរបស់គេជាប់ព្រោះខ្លាចត្រូវទុកចោលទៀត។

"ប្រពន្ធអ្នកដទៃគេមិនដែលបានប្រាក់ខែមួយខែរាប់លានដូចអូនទេ"

ក្រៅពីប្រាក់ខែហើយ ប្រាក់សិបភឹង គេត្រូវទទួលខុសត្រូវតាមកិច្ចសន្យានាងទិញបានគ្រប់យ៉ាងដែលនៅចំពោះមុខ វិកយបត្រ ក្រេឌីតកាតដោយមិនកំណត់ចំនួនទឹកប្រាក់ដែលគេធ្វើឲ្យនាងវាច្រើនជាងថ្លៃចាយវាយ ដែលគេត្រូវចំណាយឲ្យស្រីកំណាន់ ដែលធ្លាប់ចិញ្ចឹមក្នុងមួយខែៗទៅទៀត។

"ទើបចង់រកប្រពន្ធថ្មី ដាក់ផែនការនាំអូនមកទុកចោលនៅទីនេះឲ្យដើរទៅផ្ទះវិញម្នាក់ឯង ទាល់តែហត់ស្លាប់មែនទេ"

"អូនចុះដើរដោយខ្លួនឯងទេ"

"គឺបងចង់សម្លាប់អូននៅលើខ្នងសេះ"







Scanned by CamScanner

"បងធ្វើអី ?"

"បងជិះសេះលឿនលើសច្បាប់កំណត់"

"ស្រីឡប់ សាក់ខាវៀ គ្មានច្បាប់គ្រប់គ្រងល្បឿនសេះទេ"

ការ៉ិនពេលដែលត្រូវការយកឈ្នះគឺអាចប្រកែកបានដោយមិនចេះហត់ ហើយក៏មិនព្រមចុះញ៉មគេដែរ។

"អូនគិតដោយខ្លួនឯងក៏បាន"

"សប្បទៅក្រចករហែកមែនទេ"

"គ្រាន់តែក្រចករហែកឯណា វារហែកឡើងគួរឲ្យខ្លាចទៅវិញទេ"

នាងលើកដៃដាក់ជិតមុខ គេក៏ចាប់មើល ហើយថើបខ្នងដៃនោះដោយមិនដឹងថាធ្វើយ៉ាងណាដើម្បីដាក់ទោសនាង។

"មិនបាច់ម៉ោថើបដៃទេ កំពុងងរ ងរខ្លាំង ងរបំផុត"

"ងរធ្វើអី ?"

"ត្រូវប្ដីទុកចោល"

ម៉ែសៀ ឱនមកថើបថ្ពាល់របស់នាង ការ៉ិន ក៏លើកដៃបិទមាត់ ទើបគេចាប់ដៃនោះ ថើបខ្សឹតៗ។ គេហិង្សារាងកាយរបស់នាងមិនបាន ត្រឹមថើបខ្លាំងៗក៏ធ្វើឲ្យស្បែកសផូរផង់ ឡើងស្នាមក្រហមទៅហើយ បើឲ្យប្រើដៃប្រើជើងទៀត គេលើកដៃមិនរួច។

ពេលដែលខឹងនាង ឬមានអារម្មណ៍ថានាងគួរឲ្យដាក់ទោស វិធីនៃការដាក់ទោសសម្រាប់នាង មានមិនប៉ុន្មានចំណុចប៉ុណ្ណោះ នាងនឹងត្រូវគេឱបរឹត



ណែនដៃ ថើបខ្លាំងៗ ថើបយូរ និងវិធីចុងក្រោយ គឺចាប់បោះនាងទៅលើគ្រែឲ្យនាងស្រែកខះក។

"មិនបាច់ម៉ោថើប"

នាងទាញដៃរបស់គេចេញ ដោយនៅតែងរង៉ក់ ហើយបើព្រមឲ្យគេថើបពីរបីដងទៀត នាងច្បាស់ជាបាត់ងរ នាងចំជាចិត្តងាយមែន ប៉ុន្តែឲ្យធ្វើយ៉ាងណា ព្រោះគេជាស្វាមី មិនឲ្យចិត្តទន់ដាក់គេ តើឲ្យនាងទៅចិត្តទន់ដាក់អ្នកណា។

"បងធ្វើពីអង្គាល់"

"នៅមកសួរទៀត គ្រាន់តែរឿងយប់មិញមិនឲ្យគុណ ដល់ថ្នាក់សម្លាប់គ្នាផងឬ"

"អូនគិតថាបងខឹងរឿងហ្នឹង ?"

"មែន បងដឹងខ្លួន បងនេះឆ្ងួតកម្លាំង ចូលចិត្តធ្វើច្រើនដងៗ ប្លុងៗយូរ អូនក៏ចេះហត់"

នាងកម្លាយភាពតានតឹង មិនមែនថានាងមិនចូលចិត្តឲ្យស្វាមីបបោសអង្អែល ប៉ុន្តែក៏មិនត្រូវការរឿងបែបហ្នឹងគ្រប់ពេលវេលា ចង់ឲ្យគេទន់ភ្លន់ផ្អែមល្ហែមដាក់នាងខ្លះ។

"បងអូខេតើ"

"តែដាក់ផែនការសម្លាប់អូន"

"ឈប់និយាយអីឡប់ៗទៅ ខ្លារ៉ហ្វា"

"បងហ្នឹងហើយឡប់"



"បើមិនឈប់តមាត់ នឹងចាត់ការនៅត្រង់នេះ"

គេគ្រហឹមដាក់ជាការគំរាម បើកូនចៅបានឮ នឹងទន់ជង្គង់ តែប្រពន្ធឆ្នាសរបស់គេមានតែពើងទ្រូងដាក់។

"ពាប៉ិន្ទូត! អាងអីក៏ចាប់សង្កត់ៗ"

"ចាយលុយដូចប្តីចេះបោះពុម្ពលុយ ចាប់សង្កត់ប៉ុណ្ណឹងធ្វើឯងអរម៉ូ វាតិចពេកផង ត្រូវតែឲ្យសមាមាត្រ"

"មនុស្សឆ្កួតកាម នេះប្រពន្ធមិនមែនកូនក្រមុំកៅស៊ូ"

"គឺប្រពន្ធហ្នឹងហើយ បងមិនធ្លាប់មានអារម្មណ៍នឹងកូនក្រមុំកៅស៊ូ"

នាងប្រកែកនឹងគេឡើងហត់ ដកដង្ហើមដង្ហក់ ទើបសម្លក់សម្លឹង ហើយពេលគេឱនមករកក៏បិទភ្នែកព្រឹមៗ ប៉ុន្តែពេលត្រូវគេថើបមាត់ បែរជាបើកភ្នែកធំៗ។

*ហាមចុះញ៉មងាច់ខាត ត្រូវតែប្រឆាំង!*

ប៉ុន្តែឲ្យប្រឆាំងយ៉ាងណា មាត់របស់គេម៉ោទៅហើយ អណ្តាតក៏ម៉ោដែរ ហើយពេលនេះ អណ្តាតរបស់នាងនិងគេកំពុងតែប៉ះគ្នា អាំ...ការ៉ិន ប្រឆាំងលែងទាន់ គិតថាចាំល្មើកក្រោយចាំប្រឆាំងទៅចុះ។

"រ៉ែមសៀ..."

ថើបគ្នាឡើងមាត់របស់នាងចង់ជាំទៅហើយ ទើបគេព្រមឈប់ថើប តែបែរជាមកថើបថ្ពាល់ និងទាញនាងទៅអង្គុយលើភ្លៅ។



"បងមិនគិតថាសម្លាប់អូនទេ អូនគិតថាបងធ្វើបែបហ្នឹងមែន?"

"អូនគ្រាន់តែនិយាយព្រោះងរង៉ក់តើ"

នាងក្រមុំក្រសុលទៅរកលង្វែកទ្រូងរបស់ស្វាមី ឲ្យគេឱនថើបសក់ និងរឹតរង្វង់ដៃកាន់តែណែន។

"បងគ្រាន់តែត្រូវការឲ្យអូនដឹង ថានៅក្នុងបរិវេណផ្ទះខ្លួនឯង អូនត្រូវតែដឹងឲ្យបានថាអូននៅទីណា ត្រង់ណា បើគ្មានបងនៅជាមួយ ហើយអូនវង្វេងផ្លូវ តើគិតយ៉ាងម៉េច"

នាងស្តាប់ហេតុផលរបស់គេ។ ការពិត រ៉ែមសៀ ប្រាប់ច្រើនដងហើយឲ្យនាងត្រួតពិនិត្យផ្លូវនៅក្នុងប្រាសាទគ្រេវីត្រយ ប៉ុន្តែនាងចេះតែខ្ជិលរហូត។

"អូនដឹងហើយ"

"ដឹងអី?"

"ដឹងថាបងគ្មានគំនិតសម្លាប់អូន"

"ខ្លារិហ្សា បងត្រូវការឲ្យអូនចាប់អារម្មណ៍រឿងសំខាន់ជាងហ្នឹង"

"អូខេ ក៏បាន អូនធ្វើពុតជាមិនយល់ អូនព្រមទទួលស្គាល់រឿងដែលអូនខ្ជិលពិនិត្យផ្លូវនៅក្នុងប្រាសាទ អូននឹងពិនិត្យឲ្យញឹកញាប់ក៏បាន ឲ្យអូនសុំនឹងផ្លូវ"

"បងជាកងទ័ពរបស់សាក់ខាវៀ ខ្លារិហ្សា អូនជាប្រពន្ធរបស់កងទ័ព អូនត្រូវមើលថែខ្លួនឯងឲ្យបាន ព្រោះបងអាចនឹងភ្លោះធ្លោយនៅថ្ងៃណាមួយ បើបងស្លាប់ តើអូនធ្វើយ៉ាងម៉េច?"





Scanned by CamScanner

"បងហាមស្លាប់"

នាងសង្កត់ចង្អុលដៃនឹងបបូរមាត់ក្រាស់ ប្រសព្វភ្នែកជាមួយគេ ដោយទឹកមុខម៉ាំ ព្រោះមិនចូលចិត្តឲ្យគេនិយាយរឿងបែបនេះ។

"បងហាមម៉េចបាន"

"មិនដឹងទេអូនមិនអនុញ្ញាតឲ្យបងស្លាប់បងស្លាប់បានទាល់តែបងអាយុពីមួយរយឡើងទៅ"

រ៉ែមសៀ ឱបរឹតភរិយា ហើយងើបឈរ លើកនាងបី។

"ហាមនិយាយរឿងស្លាប់ទៀត មិនចូលចិត្ត មិនចង់ឮ"

"អូនមិនចង់ឲ្យបងស្លាប់ឬ?"

"អេ៎! ប្រាប់ថាហាមនិយាយ"

នាងងើយមុខទៅថើបបបូរមាត់របស់គេថ្នមៗហើយសម្ងំក្នុងលង្វែកទ្រូងវិញ រ៉ែមសៀ ក៏ក្អកគ្រហែមតិចៗ ដើម្បីមិនឲ្យស្នាមញញឹមរបស់ខ្លួនរីកធំពេក គេត្រូវបន្លំដោយទឹកមុខព្រងាក់ស្រេង ដើម្បីមិនឲ្យភរិយាក្មេងរបស់គេបានចិត្ត។ គេចូលចិត្តនៅជាមួយនាង ការពិតទៅពេលវេលាត្រឡប់មកផ្ទះវិញម៉ោងប្រាំបីយប់ស្មើរតែគ្មានប្រយោជន៍ ព្រោះពេលចប់ការងារ គេក៏ត្រឡប់មកផ្ទះភ្លាម មកមុនម៉ោងប្រាំបីស្មើរតែរៀងរាល់ថ្ងៃ។

"ហាមនិយាយ មិនអីចឹងនឹងខាំមាត់ឲ្យចេញឈាម"

គេត្រូវតែនៅជាមួយនាង ទោះគេកាច ហើយពេលខ្លះចូលចិត្តញ៉ោះឲ្យខឹង ពេលខ្លះសោះកក្រោះ ប៉ុន្តែពេលនៅជាមួយគេហើយនាងចូលចិត្តណាស់



អារម្មណ៍ដែលគិតថាគ្មានគេនៅជាមួយ វាធ្វើឲ្យនាងគុកក្ងួល។

"កើតអី?"

ព្រោះការស្រវាឱបគេណែនដៃ ដោយមិនមាត់មិនក វាខុសពីចរិតរបស់នាង ទើបគេសួរនាំ។

"អូនមិនចូលចិត្តឲ្យបងស្លាប់"

ក្រៅពីអារម្មណ៍គុកក្ងួលហើយ នាងក៏ឈឺក្នុងទ្រូងទៀតផង។ ជីវិតដែលគ្មាន រ៉ែមសៀ នាងមិនត្រូវការ ទោះពួកនាងឈ្លោះគ្នាញឹកញាប់ ប៉ុន្តែនាងចង់ឲ្យគេនៅឈ្លោះជាមួយនាងឲ្យបានយូរ កាន់តែយូរកាន់តែល្អ។

"ទោះអូនចូលចិត្ត ក៏បងស្លាប់ឲ្យអូនបានតែម្តងប៉ុណ្ណោះ"

"តាប៉ិស្នូតនេះ ប្រាប់ថាមិនចូលចិត្តហើយ!"

"អូខេៗ មិននិយាយរឿងនេះទេ យល់ព្រម"

នាងសម្លក់សម្លឹងគេ កែវភ្នែកមូលក្លំមានតំណក់ទឹកភ្នែក ធ្វើឲ្យគេស្ទើរតែទន់ជង្គង់តែម្តង ជាអារម្មណ៍ ដែលទើបតែទទួលបាន ព្រោះមាន កាអ៊ិន នេះឯង។

គេដឹងខ្លួន គេព្រមធ្វើគ្រប់យ៉ាង សុំត្រឹមកុំឲ្យនាងមានទឹកភ្នែក។

"យល់ព្រម មិននិយាយ"

"បើនិយាយទៀត នឹងយំមែនទែនហើយ"

នាងគំរាម ដោយដឹងថាគេខ្លាចទឹកភ្នែករបស់នាង រ៉ែមសៀ មិនចូលចិត្តឲ្យនាងយំ។ នាងសង្កេតតាមអាការៈរបស់គេ អ្វីដែលនាងមានប្រៀប នាង





Scanned by CamScanner

តែងតែយកមកប្រើឲ្យមានប្រយោជន៍ ប៉ុន្តែរឿងខ្លះនាងព្រមចុះញ៉មគេ ព្រោះចង់ឲ្យគេមានសេចក្តីសុខ។

"ឡើងសេះ"

"ធ្វើបាបអូនទៀតឬអត់"

"មិនធ្វើបាបទេ"

គេឱនថើបថ្ពាស ហើយលើកនាងឲ្យអង្គុយពាក់ឆៀងលើខ្នងសេះ បន្ទាប់មកក៏ហក់ឡើងពីក្រោយ ឲ្យនាងស្រវាឱប។

"ហើយធ្វើបាបធ្វើអី"

"គ្មានហេតុផល"

"មនុស្សឆ្កួត"

នាងរអ៊ូទាំ ប៉ុន្តែ រ៉េមសៀ គ្មានហេតុផលនៅក្នុងការធ្វើបាបនាង គេមិនមែនជាមនុស្សប្រុសដែលចូលចិត្តធ្វើបាបអ្នកដទៃ តែការធ្វើបាបប្រពន្ធខ្លួនឯងឲ្យងរង៉ក់ គឺជារឿងគួរឲ្យសប្បាយ ព្រោះពេលនាងងរង៉ក់ គឺគួរឲ្យស្រឡាញ់ ធ្វើឲ្យគេចង់ស៊ីឲ្យនាងជាំសាច់។

រ៉េមសៀ ត្រូវហៅទៅជួបព្រះអង្គម្ចាស់ ខាឡូម៉ាន់ នៅក្រុងសេនថាម៉ាក់ ដោយនាំភរិយាទៅជាមួយ ប៉ុន្តែជូននាងទៅជំណាក់សិន ទើបធ្វើដំណើរទៅប្រាសាទវ៉ៃដូសា។ គេដឹងហើយថាត្រូវហៅរឿងអ្វី ព្រោះផែនការធ្វើដំណើរ បានរៀបចំទុករួចរាល់ហើយ។ វាជាភារៈកិច្ចសម្ងាត់ ហើយគេក៏ត្រូវតែលាក់ការណ៍



នេះឲ្យជិត សូម្បីតែភរិយាខ្លួនឯង។ គេធ្វើដំណើរទៅជួបព្រះអង្គម្ចាស់ ខាឡូម៉ាន់ ដើម្បីដាក់ផែនការ ដោយឲ្យ ការ៉ឹន រង់ចាំគេនៅជំណាក់។

ប្រាសាទត្រវើយត្រយនៅឆ្ងាយពីរាជធានី ហើយវានឹងធ្វើឲ្យនាងអផ្សុក ខណៈដែលនៅជំណាក់នេះ បើត្រូវការគ្នា នាងអាចជួប ចាស្មីន និងប្អូនស្រីទាំងពីរបានគ្រប់ពេលវេលា ប៉ុន្តែគេមិនទាន់ប្រាប់ឲ្យនាងដឹងនៅពេលនេះ។

ពួកគេនឹងធ្វើដំណើរទៅក្រុងអាឡិចសាន់ដេវិញជាមួយគ្នា ហើយគេនឹងនៅទីនោះបីថ្ងៃ មុនពេលចេញដំណើរ ដោយគេបញ្ជូនភរិយាមកទីនេះ។ ការធ្វើដំណើរទៅមកគឺជារឿងស្មុគស្មាញ តែគេមិនចូលចិត្តឲ្យនាងនៅឆ្ងាយពីខ្លួន ហេតុផលរបស់គេមានតែប៉ុណ្ណឹង ហើយគេក៏មិនព្រមទទួលស្គាល់ដែរថាខ្លួនឯងងប់ងល់នឹងប្រពន្ធប៉ុណ្ណា។ គេមិនបានងប់ងល់នឹងនាង គ្រាន់តែមិនចូលចិត្តឲ្យនាងនៅឆ្ងាយពីខ្លួនប៉ុណ្ណោះ ហើយការបានឃើញនាងនៅក្នុងខ្សែភ្នែកធ្វើឲ្យគេមានអារម្មណ៍ស្ងប់ ពេលណាក៏ដោយដែលនាងនៅឆ្ងាយពីភ្នែក គេតែងតែមួម៉ៅ ដូច្នេះហើយដើម្បីបញ្ចៀសបញ្ហានេះ ការមាននាងនៅក្បែរខ្លួនជារឿងត្រឹមត្រូវ។

"រ៉េមសៀ មកវិញហើយ" ការ៉ឹន ស្ទុះទៅរកគេ។

នាងទូរសព្ទទៅនិយាយជាមួយ សានេនេ នៅពេលខ្លះ ដែល សានេនេ បានផ្តល់ការណែនាំថាភរិយាគួរជូនដំណើរស្វាមីចេញពីផ្ទះ និងស្វាគមន៍ពេលគេត្រឡប់មកវិញ ហើយថែមទាំងផ្តល់ការណែនាំបន្ថែមទៀតថាត្រូវថើបគេមុនទៅធ្វើការ និងត្រូវថើបគេទាំងពេលនៅនិងពេលមក។

'ខ្ញុំធ្វើមិនបានទេ សានេនេ'





Scanned by CamScanner

នាងធ្លាប់ប្រាប់ សានេនេ បែបហ្នឹង ប៉ុន្តែប្រហែលជាភ្លេចបាត់ទៅហើយ ព្រោះពេលឃើញ រ៉ែមសៀ ក៏ស្ទុះទៅរក និងពេលដែលត្រូវគេលើកព នាងក៏ថើប បបូរមាត់របស់គេឮជុប ហើយនេះក៏ជាមូលហេតុដែលធ្វើឲ្យ រ៉ែមសៀ ត្រឡប់មកផ្ទះវិញទៀងពេលវេលាដោយអារម្មណ៍រីករាយ។

បើផ្ទះរបស់គេមានមនុស្សស្រីគួរឲ្យពុញម្នាក់រង់ចាំ នោះការត្រឡប់មកផ្ទះគឺជារឿងគួរឲ្យពុញទ្រាន់ ប៉ុន្តែពេល ការ៉ុន ស្វាគមន៍គេដោយភាពគួរឲ្យស្រឡាញ់ ចេះម៉ិកម៉ូក់ដាក់គេនៅពេលខ្លះ ការនឹករឭកនាង ធ្វើឲ្យគេមានសេចក្ដីសុខជាងមានទុក្ខ។

"កំពុងធ្វើអី ?"

"កំពុងរៀនចាក់អាវឲ្យបង"

"អូនឬ ?"

"មែនហើយ តែអូនធ្វើឲ្យអំបោះខូចអស់ច្រើនដុំទៅហើយ"

នាងធ្វើមុខខ្វល់ ពេលនឹកដល់អំបោះជាច្រើនដុំដែលនាងធ្វើឲ្យខូចខាតសរុបតម្លៃទៅ ការទៅទិញអាវចាក់មួយ មកឲ្យគេ វាអាចថោកជាងនាងចាក់ដោយខ្លួនឯងទៅទៀត។

"មិនធ្វើបន្ត ?"

"ធ្វើ អាវរបស់បងអូននឹងចាក់ឲ្យរួច បងឮសំជាចំហាមាត់ឆ្ងល់ដែលអូនអាចធ្វើវាបានដោយខ្លួនឯង"

"អីចឹងឬ ?"



"បានឮសំឡេងបែបនេះរបស់បងពេលណា ចង់តែខាំត្រចៀកបងទេ"

នាងលើកដៃទាញត្រចៀករបស់គេលេង តែគេមិនខឹង។ នាងតបស្នងភាពគួរឲ្យស្រឡាញ់របស់គេដោយការថើបថ្ពាល់ វាអាចជាការដោះដូរដែលគេពេញចិត្តក៏ថាបាន ទើបគេព្រមទោរទន់ដាក់នាងដល់ថ្នាក់នេះ។

"ងូតទឹកជាមួយគ្នាទេ"

"អូខេ"

គេទទួលយកការបបួល។ បើគេត្រឡប់មកផ្ទះវិញម៉ោងប្រាំបីយប់ គេត្រូវងូតទឹកដោយខ្លួនឯង ព្រោះ ការ៉ុន ងូតរួចរាល់ហើយ ប៉ុន្តែបើម៉ោលឿនជាងនោះ នាងនឹងងូតទឹកជាមួយ ទើបគេមានកម្លាំង នៅក្នុងការធ្វើការឲ្យឆាប់រួចរាល់។

"អូនចេញទៅស៊ីបភីង"

"អូនចាយលុយអស់ប៉ុន្មានលាន"

"ធីស ! អូនទិញរបស់តែបន្តិចហ្នឹង អូនបានសាប៊ូទឹកក្លិនថ្មី បងចូលចិត្តអ៊ីរឿងអូនស៊ីបភីង អូនទិញឲ្យតិចក៏បានដែរ"

"វានឹងធ្វើឲ្យអូនឆ្អួតឬអត់ ?"

"ឆ្អួតរឿងអី ?"

"ទិញរបស់តិច"

"តាប៉ិឆ្អួត អូនមិនបានកើតមកស៊ីបភីងឯណា"



នាងក្រមុំ មិនដឹងថានិយាយអីជាមួយគេទើបល្អ ទើបធ្វើបានត្រឹមតែ

អ៊ុំទាំ។ នាងមិនបានឆ្គួតរឿងសិបភីងដល់ថ្នាក់នោះទេ តែការសិបភីង វាកប់ក្នុងឱអិនអេរបស់មនុស្សស្រី របស់ស្អាតៗសមនឹងស្រីស្អាតដូចនាង នាងមើលថែខ្លួនឯងឲ្យស្អាតទាំងរូបរាង មុខមាត់និងសម្លៀកបំពាក់ គឺដើម្បីតែហ្នឹងឯង។

"អឹម"

ធ្វើសំឡេងបែបនេះមានន័យថាម៉េច ដូចគេមិនជឿសម្តីរបស់នាង ទើបកាអ៊ិន ក្តិចថ្ពាល់របស់គេ ក្តិចហើយថើប ដើម្បីកុំឲ្យគេខឹង ដែលនាងសិក្សាវិធីទប់ទល់នឹងស្វាមីបន្តិចម្តងៗ និងអាចសម្របខ្លួនឲ្យចុះសម្រុងនឹងគេបានងាយជាងការគិតទៅទៀត។

នាងដឹងថាគេក៏សម្របខ្លួនតាមនាងដែរ គេត្រូវផ្អាកការស៊ីផឹក ដែលមានខ្លះដែរ ពេលដែលចៀសមិនបាន នាងក៏អនុញ្ញាតនៅពេលខ្លះ ព្រោះធូរពេកក៏មិនល្អ តឹងពេកក៏មិនល្អ។

"ធ្វើសំឡេងដូចមិនជឿ"

"អូនមិនបានចូលចិត្តសិបភីង គ្រាន់តែឆ្គួតកាតឡើងឈឺបកាតចង់របក"

"ប្រុសមាត់ដាច"

នាងក្តិចថ្ពាល់របស់គេ ហើយធ្វើដូចមុន ក្តិចហើយថើប ទើបមានសុវត្ថិភាពពីអារម្មណ៍ក្តៅរបស់ស្វាមី។

"មោះ អូនជួយដោះ"

វែមសៀ ដាក់នាងឲ្យឈរនៅក្នុងបន្ទប់តែងខ្លួន ហើយឲ្យនាងជួយដោះ



សម្លៀកបំពាក់។

"ខ្លារិហ្សា បងត្រូវទៅធ្វើការ"

"ការងារដេកយប់ មិនបានត្រឡប់មកផ្ទះវិញឬ?"

"មែន ការងារដេកយប់មិនបានត្រឡប់មកផ្ទះ តែម្តងនេះទៅយូរបន្តិច"

គេប្រាប់ខ្លួនឯងថា គេមិនបានខ្លាចប្រពន្ធអីបន្តិចទេ ប៉ុន្តែគេព្យាយាមប្រាប់នាងឲ្យពិស្តារតាមដែលអាចធ្វើបាន ដើម្បីមិនឲ្យនាងខឹងប៉ុណ្ណោះ។

"យូរប៉ុណ្ណា?"

សំឡេងងរង៉ក់នេះ ធ្វើឲ្យគេត្រូវរៀបរៀងពាក្យសម្តីឲ្យបានល្អមុនពេលឆ្លើយ គេត្រូវឆ្លើយប្រាប់នាងឲ្យច្បាស់លាស់ ធ្វើឲ្យនាងសប្បាយចិត្តនិងមិនត្រូវប៉ះពាល់ដល់អាថ៌កំបាំងការងារដែរ។

"មិនលើសពីពីរខែ"

"ពីរខែ!"

"បងទៅធ្វើការមែន អូនទៅសួរអង្គម្ចាស់ក៏បាន"

គេទាញ ខាឡូម៉ាន់ មកធ្វើជាលេស ព្រោះគេត្រូវទៅធ្វើការ នាងគួរតែយល់ ប៉ុន្តែពេលបានឮសំឡេងខ្សាវៗ ជាងសំឡេងស្រែកនោះ គេក៏ប្រញាប់កែទិតីងពាក់។

"ហេតុអីត្រូវទៅធ្វើការអីយូរៗបែបហ្នឹង"

"វាចាំបាច់ ព្រោះត្រូវចុះទូកទៅពិនិត្យទីតាំង"

"អូនមិនចូលចិត្តនៅឆ្ងាយពីបង"



រ៉ែមសៀ ទាញនាងមកឱប។ មិនត្រឹមតែនាងទេដែលមិនចូលចិត្តនៅឆ្ងាយពីគេ គេក៏មិនចូលចិត្តនៅឆ្ងាយពីនាងដូចគ្នា ប៉ុន្តែវាចាំបាច់ ព្រោះភារៈកិច្ចនេះគេត្រូវធ្វើដោយផ្ទាល់ ឲ្យអ្នកផ្សេងធ្វើជំនួសមិនបាន បើមិនមែនគេ ក៏ត្រូវតែ ស៊ិតិរ៉ាស ដែរ ប៉ុន្តែពេលនេះ ស៊ិតិរ៉ាស ជាប់បំពេញភារៈកិច្ចមួយទៀត។

"បងនឹងព្យាយាមធ្វើការឲ្យឆាប់រួចរាល់មុនការកំណត់ល្អទេ"

"ល្អ បើមកវិញបាន រឹតតែឆាប់ហ៊ើ"

រ៉ែមសៀ មិនទាន់ចេញបំពេញភារៈកិច្ចផង សំឡេងម៉ិកម៉ក់របស់ភរិយាក៏ធ្វើឲ្យគេមិនចង់ទៅឆ្ងាយពីនាងទៅហើយ។ បើ ស៊ិតិរ៉ាស ដឹង វាច្បាស់ជាយករឿងនេះមកបង្អាប់គេជាមិនខាន តែគេមិនប្រាប់វាទេ ឬទោះវាដឹងក៏គេមិនខ្វល់ដែរ គេខ្វល់ពីអារម្មណ៍របស់ កាអ៊ិន ច្រើនជាង។



# ១៥

## ទឹកណាស់

កាអ៊ិន ប្រែខ្លួនដេកផ្អៀង ដកដង្ហើមដង្ហក់ដោយការហត់នឿយ បន្ទាប់ពីធ្វើសង្គ្រាមស្នេហាជាមួយស្វាមី តែនៅមានចិត្តលើកដៃទៅអង្អែលថ្ពាល់របស់គេទៀត រ៉ែមសៀ ក៏សម្រួតខ្លួនមកឱបភរិយា ដោយអូសបាតដៃពីពោះរាបស្មើមករកដើមទ្រូងណែនក្បំ។

ពួកគេដកដង្ហើមដង្ហក់ដាក់គ្នា ដោយមិនទាន់មានអ្នកណានិយាយអី តែ រ៉ែមសៀ ឱនថើបចង្អួយស្មាមូលក្លំ ហើយទាញនាងមកកាន់តែជិត ក្រសោបដើមទ្រូង ប្របាច់ដោយអារម្មណ៍ឈ្លក់វង្វេង ដែលមានចំពោះរាងកាយស៊ិចស៊ីដែលមានគេជាម្ចាស់។

កាអ៊ិន ងើយមុខមើលស្វាមី ឲ្យគេថើបថ្ពាស ហើយប្រែខ្លួន បែរមុខទៅរក និងឡើងទ្រាបទៅលើ ឱនទៅថើបបបូរមាត់ក្តៅគគុក ឲ្យស្វាមីឱបក្រសោបស្ទាបអង្អែលត្រគាកមូលក្លំថ្មមៗ ខណៈពេលថើបគ្នាស្អិតល្មួត។

"បន្តទេ ?"

"ក្រេកកាម សុំសម្រាកសិន"

នាងចាក់ថ្ពាល់របស់គេ។ រ៉ែមសៀ ចំណាយពេលនៅជាមួយនាងក្នុង



មួយថ្ងៃៗសមាមាត្រណាស់ ដូចត្រូវសន្សំពេលវេលានៃភាពក្ដៅគគុកទុកឲ្យបានច្រើនបំផុត មុនពេលធ្វើដំណើរ ទើបនាងមិនរអ៊ូទាំពីរឿងតម្រូវការខ្លាំងរបស់គេទៀត ព្រោះនាងក៏ត្រូវសន្សំពេលវេលានៃការចងចាំទុកឲ្យបានច្រើនបំផុតដែរ បែបជាគ្រាន់តែគេកេះ នាងក៏ព្រមហក់ទៅរក។

"ហាមក្បត់ចិត្ត"

ការ៉ុន ជូតញើសចេញពីថ្ងាសរបស់ស្វាមី ទាំងដែលនៅក្នុងបន្ទប់បើកម៉ាស៊ីនត្រជាក់ត្រជាក់ស្រេង។

"បញ្ជារាល់ថ្ងៃ"

"រអ៊ូបាន តែត្រូវឆ្លើយផង"

"មិនក្បត់ចិត្តទេ"

"មិនក្បត់ចិត្តដាច់ខាត"

"បងមិនក្បត់ចិត្តដាច់ខាត"

ពេលស្វាមីឆ្លើយឲ្យសប្បាយចិត្តហើយ នាងក៏ញញឹមពព្រាយ។ នាងជាមនុស្សចូលចិត្តបញ្ជាក់ហើយបញ្ជាក់ទៀតចំពោះរឿងខ្លះ ហើយរឿងខ្លះដែលនាងធ្វើ គឺជារឿងហួសហេតុដែលមានចំពោះគេនោះឯង បើមិនហួសហេតុ នាងមុខជាប្រចណ្ឌ ដែលការទទួលបានអារម្មណ៍បែបនេះ ធ្វើឲ្យគេដឹងថា គេជាមនុស្សសំខាន់របស់ភរិយា។

"ហាមមើលស្រីផ្សេងដែរ"

"បើត្រូវធ្វើការជាមួយគ្នា ?"



"មើលបាន តែហាមមើលបែបភ្នែកស្រទន់ បបួលឡើងគ្រែ"

"បែបណា មើលបបួលឡើងគ្រែ ?"

"គឺមើលដូចដែលបងមើលអូន ពេលបងក្រោកពីរលោកហ្នឹង"

"ហ៊ឺយ! បងមើលស្រីផ្សេងធ្វើអី អូនជាប្រពន្ធបង"

"មិនដឹងទេ ឆ្ងាយភ្នែកឆ្ងាយត្រចៀក ត្រូវតែប្រយ័ត្ន"

រ៉េមសៀ មិនយល់ពីគំនិតរបស់នាងទេ តែក្នុងពេលដែលភរិយាបញ្ជាដើម្បីជាការបញ្ចប់បញ្ហា គេត្រូវតែងក់ក្បាល ដើម្បីការសប្បាយចិត្តរបស់នាង។

"ធានាថាមិនក្បត់ចិត្តទេ ព្រះនាង"

"ល្អណាស់ កុំឲ្យដឹងថាក្បត់ចិត្ត មិនអីចឹងនឹងស្រែកឲ្យបែកត្រចៀក"

អ្នកកំលោះមិនធ្លាប់ខ្វល់ពីស្រីណា ប៉ុន្តែតាំងពីមាន ការ៉ុន គឺដូចបិទទ្វារទំនាក់ទំនងនឹងអ្នកដទៃ។

គេលើកដៃអង្អែលថ្ពាល់រលោង ភរិយារបស់គេស្អាតសិចស៊ី និងកាន់តែស្អាតទៅ។

"បិតហើយណ៎ា ខ្លារិហ្សា"

គេក្រសោបដើមទ្រូងណែនក្បែ ស្ងួរម្ចាស់ដោយសំឡេងគ្រលរ ហើយពេលនាងងក់ក្បាល ទើបសម្រួតខ្លួនទៅរកភ្នំព្រិលទាំងពីរ។

"ហ៊ឺ! ថ្នមៗ"



គេញ៉ោះ ដោយការថើបខ្លាំងៗ ទាំងបឺតជញ្ជក់ ទាំងខាំច្បិច ទាល់តែម្ចាស់តភ័លែងបាន ទើបព្រមបន្ធូរកម្លាំងដៃ តែមាត់បឺតខ្លាំងៗដដែល។

"សាកុំងហេ" នាងខ្សឹបប្រាប់ដោយសំឡេងក្ងូរៗ ជាភាសាដែល រ៉ែមសៀ មិនយល់ តែគេចងចាំប្រយោគនោះទុក ដើម្បីរកន័យរបស់វានៅពេលក្រោយ។

"ម្ដងទៀត ខ្លារីហ្សា"

"ចាំ បងសម្លាញ់"

ការ៉ុន បើកផ្លូវទទួលស្វាមី ហើយឱបរឹតតែណែនដៃ ដោយអារម្មណ៍រញ្ជួយកំពុងជ្រួលច្រាល់នៅក្នុងខ្លួន។ នាងថ្ងូចថ្ងូរ ពេលត្រូវចាប់ដើងទាំងពីរញ្ញឹបនឹងដើមទ្រូង។

"ស្រឡាញ់អូនទៅ បងសម្លាញ់" នាងអង្វរគេ សុំការប៉ះពាល់ដ៏ក្ដៅគគុកពីគេ ហើយលើកដៃឱប.ករឹងមាំ និងថ្ងូរហៅឈ្មោះ បន្ទរនឹងសំឡេងដកដង្ហើមដង្ហក់របស់ រ៉ែមសៀ។

គេឈ្លក់វង្វេងនឹងពេលវេលាដែលមាននាងឱបរឹត នាងក្ដៅគគុក រឹតរួតនិងទទួលយកគេដោយការពេញចិត្តពេញថ្លើម រាងកាយការបស់នាងមិនធ្លាប់កុហកថានាងប្រាថ្នាគេខ្លាំងណាស់។

រ៉ែមសៀ ឱនទៅគេគរិយាកំពូលសម្រស់ រុំក្បែងបង់កឲ្យ។ គេនឹងគ្មានបញ្ហាទេ បើពណ៌របស់វាមិនមែនផ្កាឈូកស្រាល វាសមនឹងបុគ្គលិកលក្ខណៈរបស់គេមែនទែន បុរសមាឧក្រអាញ មុខមាំ និងក្បែងបង់កពណ៌ផ្កាឈូក។

"ត្រូវតែជាពណ៌នេះមែនទេ ?"

"អូនចូលចិត្តពណ៌ផ្កាឈូក ក្បែងបង់កនេះតំណាងឲ្យអូន ជាក្បែង



ដែលអូនចូលចិត្តបំផុត ប្រើញឹកញាប់បំផុត ឬបងមិនចង់ដាក់វាតាមខ្លួន"

ចុងប្រយោគ សម្ដីរបស់នាងស្ដាប់ទៅងរង៉ក់ ទើបគេលើកដៃទាំងពីរព្រមចុះចាញ់ ទោះវាមានពណ៌ឆើតឆាយជាងនេះ ក៏ព្រមបង់វាជាប់កដែរ។

ការ៉ុន រុំក្បែងនឹង.កឲ្យចរាល់ ក៏ចាប់ចុងរបស់វាញាត់នៅក្នុងអាវស៊ើមីរបស់ស្វាមី តែវានៅតែមើលឃើញច្បាស់ថាគេបង់ក្បែងពណ៌ផ្កាឈូក។

"ត្រូវញ៉ាំបាយឲ្យទៀងពេល ដឹងទេ"

"ដឹងហើយ"

"ដឹងហើយ ធ្វើឬអត់ ?"

"ធ្វើ សប្បាយចិត្តចុះ"

ដោយសារធ្វើដំណើរតាមទូក ទើប រ៉ែមសៀ ឲ្យហេតុផលដល់ភរិយាថាការទំនាក់ទំនងអាចមានបញ្ហានៅពេលខ្លះ មិនអាចតេរាយការណ៍ប្រាប់នាងរាល់ថ្ងៃបាន។

"បើគេរកអូនបាន ត្រូវតេរភ្លាម"

"បងមិនភ្លេចទេ"

"សន្យាហើយណា៎"

"សន្យា"

គេបញ្ជាក់ឲ្យភរិយាសប្បាយចិត្ត ហើយលើកនាងព ការ៉ុន ក៏ដាក់ដៃលើស្មារឹងមាំ និងឱនថើបថ្ពាល់របស់គេ។

"ភារកិច្ចគ្រោះថ្នាក់ឬអត់ អូនថាមិនសួរទេ តែអត់មិនបាន"



"បងមើលថែខ្លួនឯងបាន"

"មិនបានសួរថាមើលថែខ្លួនឯងបានទេ សួរថាគ្រោះថ្នាក់ឬអត់ ឆ្លើយឲ្យអូនសប្បាយចិត្តមួយម៉ាត់មិនបានទេអី"

"មិនគ្រោះថ្នាក់ទេ"

ការ៉ុន ដាក់ចង្កាលើស្មារបស់ស្វាមី ឱបគេដោយការហួងហែង។ បើគេជាអ្នកផ្សេង នាងមិនបារម្ភទេ តែនេះគេជាស្វាមីរបស់នាង បើមិនឲ្យបារម្ភ គឺមិនបានទេ។

"អូនជឿបង"

"កុំបារម្ភអី នេះមិនមែនជាភារកិច្ចគ្រោះថ្នាក់ទេ បងគ្រាន់តែធ្វើដំណើរដើម្បីត្រួតពិនិត្យ និងចរចា"

នាងងក់ក្បាលដាក់ប្រឡោះករបស់គេ ទើប រ៉េមសៀ ឱនថើបក្បាលរបស់នាង និងអង្អែលរាងកាយជាការលួងលោម។

"អូនស៊ិបតឹងចាំបងបាន"

"ពេលនេះអូនមិនចង់ស៊ិបតឹងទេ"

"ហើយអូនចង់ធ្វើអី ?"

"អូនចង់ឲ្យបងនៅផ្ទះ តែអូនដឹង ថាបងត្រូវទៅធ្វើការ និងជាការងារដើម្បី សាក់ខារៀ"

អ្នកកំលោះឱនថ្ពាល់របស់ភរិយា ហើយពនាងដើរចេញពីបន្ទប់ដេក។ គេជូននាងទៅដំណាក់ចាស់នៅក្រុងសេនថាម៉ាភ៉ាស៊ិន ទើបចូលទៅបង្ហាញខ្លួន



ដល់ព្រះអង្គម្ចាស់ ខាឡុមាន់ មុនពេលចេញដំណើរនៅពេលសៀលថ្ងៃនេះ។

ស្រីឆ្លាសរបស់គេឱបគេជាប់ ម៉ឺកម៉ូក់ដាក់គេជាពិសេសថ្ងៃនេះ។ នាងដូចកូនក្មេងដែលតោងស្អិតហើយក៏តោងស្អិត បេះមិនចង់ចេញ តែកុំឡើយនាងសូម្បីគេក៏មិនចង់នៅឆ្ងាយពីនាងដែរ។

"ពេលបងត្រឡប់មកវិញ យើងទៅដើរលេងល្អទេ"

"ល្អ អូនរង់ចាំ"

"អូនចង់ទៅណា អូនរើសទៅ ពេលរង់ចាំបង ល្អទេ"

"ល្អ អូនរង់ចាំបង" ការ៉ុន បញ្ជាក់ និងលើកដៃអង្អែលថ្ពាល់របស់ស្វាមីមើលគេដោយខ្សែភ្នែកអាឡោះអាល័យ ហើយឱនថើបថ្ពាល់ត្រឹមនោះ។

"ថើបត្រង់នេះទេ ?"

គេដាក់សំណើបប្តូរមាត់ ហើយពេលនាងឱនមកថើបរួច គេក៏ថើបវិញថើបជញ្ជក់ខ្លាំងៗ ថើបដូចត្រូវការត្រាសិទ្ធិជាម្ចាស់ឲ្យជាប់។

"មើលថែខ្លួនផង"

"អូនក៏អីចឹងដែរ មើលថែព្រះនាងឲ្យបានល្អ"

ពេលបញ្ជានាងហើយ រ៉េមសៀ ក៏ងាកទៅបញ្ជាអ្នកបម្រើរបស់នាង និងដាក់នាងចុះ ហើយទាញមកឱបរឹតណែនដៃ ថើបសក់ក្រអូបយ៉ាងយូរ ទើបរសាយដៃ ដើរឡើងឡាន ដែលតែកុងបញ្ចេះចាំ។



"ខ្ញុំមិនដឹងចាត់ការភាពនឹករឭកដែលកើតឡើងយ៉ាងម៉េចទេ"

កាអ៊ិន អញ្ជើញ ចាស្មីន មកផឹកតែពេលរសៀល ព្រោះព្យាយាមធ្វើឲ្យខ្លួនឯងរវល់។ រ៉ែមសៀ ទៅធ្វើការបានបីថ្ងៃហើយ ជារយៈពេលបីថ្ងៃដែលនាងវេទនាចិត្តណាស់ ព្រោះធ្លាប់សម្ងំក្នុងលង្វែកទ្រូងរបស់គេ ដេកលក់ស្កប់ស្កល់។ ការដេកម្នាក់ឯងនៅលើគ្រែដដែល មានអារម្មណ៍ថាគ្រែនោះធំពេកហើយ។

ចាស្មីន លូកដៃទៅដាក់លើខ្នងដៃរបស់ព្រះនាង មើលមុខរបស់មិត្តភក្តិដែលនៅតែស្អាតមិនប្រែប្រួល ប៉ុន្តែភ្នែកមិនថ្លា គ្មានពន្លឺដូចកាលមាន រ៉ែមសៀ នៅជាមួយ។

"កុំគិតច្រើនពេក ប្រយ័ត្នឈឺ"

"បើខ្ញុំឈឺ រ៉ែមសៀ ច្បាស់ជាខឹង"

"លោកឧត្តមសេនីយបញ្ជាឬ?"

"ហ្នឹង គេបញ្ជាថាហាមឈឺ ចំណែកខ្ញុំក៏បញ្ជាគេថាហាមស្លាប់"

ចាស្មីន ញញឹមពព្រាយ ពេលបានឮដូច្នេះ នេះបញ្ជាក់ថាទំនាក់ទំនងរវាង កាអ៊ិន និង រ៉ែមសៀ រលូនល្អ គ្មានអ្វីឲ្យខ្វល់ខ្វាយ។ ជាច្រើនដងដែលនាងលួចគិតថា ជីវិតគូស្រករបស់ព្រះនាងនឹងយ៉ាងណា និងភាវនាឲ្យ កាអ៊ិន មានសុភមង្គល។

"នឹកគេណាស់"

"តិចទៀតគេម៉ោវិញហើយ"

"ខ្ញុំដឹងថាវាគួរឲ្យខ្មាសដែលនិយាយបែបនេះ តែខ្ញុំនឹកគេមែនទែន គេជាស្វាមីរបស់ខ្ញុំ បើមិនឲ្យនឹកគេ តើឲ្យខ្ញុំនឹកអ្នកណា មែនទេ"



កាអ៊ិន សួរខ្លួនឯង ឆ្លើយខ្លួនឯងរួចរាល់ ទើបមិត្តជិតស្និទ្ធច្របាច់ដៃជាការលួងលោម។

"ខ្ញុំចង់ជួបគេឆាប់ៗ"

"ឯងត្រូវរកអីធ្វើ"

"ខ្ញុំបបួល យែត និង គ្រីស្ទី ទៅដើរលេង យើងនឹងទៅក្រុងស៊ិលវេស្ទ័រ"

កាអ៊ិន បបួលប្អូនស្រីទាំងពីរទៅលម្ហែនៅក្រុងស៊ិលវេស្ទ័រ ដែលជាក្រុងកំពង់ផែធំ និងជាក្រុងទេសចរណ៍ មានតំបន់ទេសចរណ៍ច្រើន។ នាងចង់ទៅដើរលេងតាមឆ្នេរខ្សាច់ ទើបក្រុងស៊ិលវេស្ទ័រជាជម្រើសដ៏ល្អ។

"ព្រះអង្គម្ចាស់អនុញ្ញាតហើយមែនទេ?"

"អនុញ្ញាតហើយ បងប្រុសប្រហែលមិនចង់ឲ្យខ្ញុំក្រៀមស្វិត ទើបព្រមអនុញ្ញាត"

"ឯងនឹកលោកឧត្តមសេនីយក៏ល្អហើយ ការនឹករឭកដែលមានចំពោះគ្នា គឺមានន័យដល់ទំនាក់ទំនងល្អដែលមានចំពោះគ្នា តែកុំនឹកដល់ថ្នាក់ធ្វើឲ្យខ្លួនឯងខូចសុខភាព"

"ខ្ញុំដឹង អរគុណច្រើន ចាស្មីន ខ្ញុំនឹងព្យាយាមញ៉ាំឲ្យឆ្អែត ដេកឲ្យលក់ តែពេលខ្លះនឹកពេក ទើបហាមខ្លួនឯងមិនបាន ទើបខ្ញុំគិតថាត្រូវទៅដើរលេងខ្លះ"

"ហើយថ្ងៃនេះឯងចង់ចេញទៅក្រៅទេ ខ្ញុំក៏ជូន"

ចាស្មីន ដាក់សំណើ តែអ្នកដែលចូលចិត្តស៊ីបភីងបែរជាគ្រវីក្បាល។



"ស៊ីបភីងលេងសប្បាយចិត្ត តាមធម្មតាខ្ញុំទិញអីវ៉ាន់ច្រើន រ៉ែមសៀ ក៏



Scanned by CamScanner

ចូលចិត្តអ៊ី"

"ទើបឯងចូលចិត្តទិញអីវ៉ាន់ច្រើនមែនទេ ?"

"មែន បើគេសង្កេត វ៉ក់យប័ត្រមានខោអាវ និងរបស់ប្រើប្រាស់របស់គេច្រើនជាងខ្ញុំទៅទៀត តែខ្ញុំដឹងថាគេមិនមើលឈ្មោះទេ គេមើលតែចំនួនលុយ"

ការ៉ិន រស់សំណើចពេលនឹកដល់ស្វាមី។ រឿងឆូតកាតខ្វះខ្វាយរបស់នាងជារឿងដែលធ្វើឲ្យនាងនិងគេមានពាក្យមានសម្ដីនឹងគ្នា តែជាការឈ្លោះគ្នាមិនប្រាកដប្រជា ហើយក៏បញ្ចប់នៅលើគ្រែ។ នាងមានចេតនាទិញ ព្រោះចង់មានរឿងនិយាយជាមួយគេខ្លះ មិនអីចឹងគឺមិនដឹងថាចូលទៅរកគេយ៉ាងម៉េចពេលបានឈ្លោះគ្នាញឹកញាប់ ពួកគេក៏បាននៅជិតគ្នាកាន់តែខ្លាំង។

នាងមិនបានចាយវាយផ្ដេសផ្ដាស តែដឹងថាគេអាចចាត់ការបាន ប្រាក់ប៉ុណ្ណឹង មិនធ្វើឲ្យរង្គោះរង្គើឃ្លាំងទ្រព្យរបស់គេទេ ក្រៅពីនេះក៏មានព្រាយខ្សឹបប្រាប់ ព្រាយឈ្មោះ ស៊ីតីរ៉ាស ថា វ៉េមសៀ ជាម្ចាស់ធនាគារមួយ ក្នុងចំណោមធនាគារធំៗទាំងបួនរបស់ប្រទេស សាក់ខារៀ ដោយធនាគារធំបំផុតនោះមានបងប្រុសរបស់នាងជាម្ចាស់ ទើបនាងហ៊ានចាយប្រាក់របស់ វ៉េមសៀ លេង តែក៏មិនបានធ្វើញឹកញាប់។

ពេលពួកគេស្និទ្ធស្នាលគ្នា វ៉ក់យប័ត្រក្រេឌីតកាតរបស់នាងក៏កាត់បន្ថយតាមដែរ តែនាងព្រមទទួលស្គាល់ថាខ្លួនឯងចូលចិត្តស៊ីបភីង។ ជារឿងធម្មតាការស៊ីបភីង និងមនុស្សស្រីជារបស់គូគ្នា តែតាមធម្មតា នាងទិញតែរបស់ដែលចង់បានពិតប្រាកដប៉ុណ្ណោះ។



"ការឈ្លោះគ្នាធ្វើឲ្យយើងកាន់តែស្និទ្ធស្នាលគ្នា ពេលគេចងចិញ្ចើមម្ដងៗគល់វាចងដូចប្ញ"

ការ៉ិន ចាក់ប្រជុំចិញ្ចើមខ្លួនឯង ហើយត្រាប់តាមការចងចិញ្ចើមរបស់ស្វាមី ឲ្យមិត្តភក្ដិមើល។ ពេល វ៉េមសៀ ធ្វើមុខបែបនេះ នាងមានអារម្មណ៍ថាគេគួរឲ្យស្រឡាញ់ណាស់។

"ឯងនេះ ចូលចិត្តញ៉ោះគេមែន"

"មិនបានញ៉ោះទេ ខ្ញុំគ្រាន់តែចង់នៅជិតគេ ខ្ញុំដឹង ថាខ្ញុំធ្វើបានសម្រេច ពេលនេះគេល្អដាក់ខ្ញុំណាស់ និងតាមចិត្តខ្ញុំណាស់ដែរ បើខ្ញុំចង់ឮពាក្យផ្អែមៗពីគេ ជាតិនេះប្រហែលគ្មានឱកាសទេ ខ្ញុំចង់ដឹងអារម្មណ៍របស់គេ ទើបត្រូវផ្ចោចអារម្មណ៍ឲ្យគេបញ្ចេញវាចេញមក ខ្ញុំបានចម្លើយតាមរយៈទង្វើរបស់គេ ទោះដូចគិតដោយខ្លួនឯង ក៏ខ្ញុំមិនខ្វល់ដែរ"

"ត្រឹមឯងមានសេចក្ដីសុខទៅ ល្អហើយ"

ជាស្មីន ញញឹម ចំណែក ការ៉ិន ក៏រីករាយបានមួយកម្រិត ពេលបាននិយាយជាមួយមិត្តភក្ដិ មិនចេះតែត្រាំត្រែងនឹងការនឹករឭក ដែលមានចំពោះវ៉េមសៀ។

បុរសមាឌធំ ស្លៀកខោខូវប៊យ ពាក់អាវយឺត និងអាវជែកយឺតស្បែកកងកញ្ចាស់ អង្គុយនៅក្នុងបន្ទប់ជួល។ គេនឹងឡើងទូក ធ្វើដំណើរទៅ ស៊ី រ៉ូវី ដែលមនុស្សភាគច្រើនស្គាល់ថាជាកោះចោរ។





Scanned by CamScanner

ស៊ី រ៉ូវើ ជាតំបន់ស្ងៀត ខុសពីក្រុង អាឡិចសានដេ ត្រង់វាជាកោះត្រូវហាម បើមិនត្រូវបានអនុញ្ញាត គឺមិនអាចចូលទៅកោះនោះបានជាដាច់ខាត ប៉ុន្តែកោះចោរ រើសកម្មករឲ្យទៅធ្វើការជាកម្មករជាហូរហែ អាចក្នុងមួយឆ្នាំម្តងឬច្រើនជាងនោះ ហើយពេលនេះ ទូកមកពីកោះចោរ មករើសកម្មករនៅកំពង់ផែធំក្នុងក្រុងស៊ីលវស្ទ័រ ទើប រ៉ែមសៀ ដាក់ពាក្យនិងត្រូវបានជ្រើសរើស ហើយគេនឹងឡើងទូកចេញដំណើរទៅកោះចោរនៅថ្ងៃខានស្អែក គេនៅឆ្ងាយពីភរិយាប្រាំថ្ងៃហើយ ក្នុងដៃមានកន្សែងបង់កពណ៌ផ្កាឈូកស្រស់។ គេចាប់វាដោយការថ្នាក់ថ្នម លើកមកថើប ហាក់ដូចវាមានក្លិនរបស់ភរិយា។ គេមានរបៀបដាក់កន្សែងបង់ករបស់នាង ពេលបង់ករួចរាល់ ក៏ដាក់ជាប់ខ្លួន។ គេដាក់វាក្នុងហោប៉ៅខោ ព្រោះបើយកមកបង់ក វានឹងក្លាយជាចំណុចគួរឲ្យចាប់អារម្មណ៍ក្រៅពីនេះ គេនៅខ្លាចថាកន្សែងរបស់នាងប្រឡាក់ទៀត។ វាជារបស់តំណាងចិត្ត តំណាងឲ្យនាង ហើយគេត្រូវការឲ្យវានៅជាមួយគេទាល់តែចប់ភារកិច្ច។

ពេលយប់ គេដាក់ដៃលើហោប៉ៅខោ ដូចចាប់កន្សែងបង់កដែរ គេដង្ហោយរកនាង នឹកស្នាមញញឹម និងសំឡេងក្បួររបស់នាង។ គេទប់ទល់នឹងអារម្មណ៍នឹករឭកនេះមិនបានល្អយប់ដំបូង ទាំងដែលមិនធ្លាប់នឹកស្រីណាពេលត្រូវបំពេញភារកិច្ច។ មុននេះគេនឹក ការ៉ិន ខ្លះដែរ តែពេលនេះគេនឹកនាងមែនទែន និងដង្ហោយរកដល់ថ្នាក់បេះដូងធ្ងន់កណ្តុកទៅហើយ។ គេវិភាគអាការៈខ្លួនឯង និងសរុបបានច្បាស់តែម្តង ថាខ្លួនឯងមិនបានឈឺកើតរោគធ្ងន់ធ្ងរ តែគេនឹក ការ៉ិន ស្ទើរតែឆ្កួតប៉ុណ្ណោះ។



កូនចៅដែលធ្វើដំណើរមកជាមួយ លួចមើលចៅហ្វាយនិងកន្សែងបង់កពណ៌ស្រស់ ដែលមិនសមនឹងបុគ្គលិកលក្ខណៈរបស់លោកឧត្តមសេនីយ៍ ប៉ុន្តែឃើញចៅហ្វាយនៅជាមួយកន្សែងបង់កពណ៌ផ្កាឈូករាល់ថ្ងៃ ទើបវាក្លាយជារូបភាពដែលស៊ាំទៅហើយ ដែលគិតថាកន្សែងបង់ក គួរតែជារបស់ភរិយា។

រ៉ែមសៀ មានភរិយាស្អាតដូចទេពធីតា ការនឹករឭកតែងតែមិនមែនជារឿងប្លែក។

កូនចៅធ្វើបានត្រឹមតែលួចមើលចៅហ្វាយប៉ុណ្ណោះ តែមិនហ៊ានចូលទៅរំខានពេលវេលាផ្ទាល់ខ្លួន។ ព្រោះចៅហ្វាយរបស់ពួកគេអាចអង្គុយនិយាយតាមផ្លូវចិត្ត ជាមួយកន្សែងបង់កពណ៌ផ្កាឈូកនោះបានរាប់ម៉ោង។

"កំពុងធ្វើអី ខ្លារិហ្សា"

គេនិយាយរអ៊ូ បើនាងសប្បាយនឹងការស៊ើបភឹង វាប្រហែលល្អ ប៉ុន្តែគេអត់គិតមិនបានទេថា នាងអាចកំពុងសោកសៅព្រោះនឹកគេ។ នាងម៉ឺកម៉ូក់ជាក់គេគួរឲ្យស្រឡាញ់ណាស់ មុនពេលគេធ្វើដំណើរ ជាពេលវេលាដែលនាងបង្ហាញអារម្មណ៍ខ្លួនឯងថា នាងមិនចង់នៅឆ្ងាយពីគេ គេនៅចាំជាប់ភ្នែកនិងជាប់បេះដូង។

"លោកបង"

កូនចៅត្រូវហៅចៅហ្វាយនាយបែបនេះ ដើម្បីឲ្យសមនឹងស្ថានការណ៍។ រ៉ែមសៀ មិនបានធ្វើដំណើរនៅក្នុងឋានៈ រ៉ែមសៀ ដាវ៉ែហ៊ណេស តែធ្វើដំណើរនៅក្នុងឋានៈជា ត្លីន ណាតុន។



ការធ្វើដំណើរទៅកោះចោរ មិនចាំបាច់មានឯកសារផ្ទាល់ខ្លួន ត្រឹមប្រាប់ឈ្មោះ ដែលពួកគេត្រូវការប្រើប៉ុណ្ណោះ គឺគ្រប់គ្រាន់ ព្រោះបើមានអ្នកណាហ៊ានទៅរំខាននៅលើកោះចោរ ម្ចាស់កោះនឹងចាត់ការ។

វែមសៀ មិនត្រូវការទៅទីនោះដើម្បីរករឿង តែមានភារកិច្ចមួយដែលត្រូវទទួលខុសត្រូវ។ ការប្រាប់ភរិយាថាវាមិនគ្រោះថ្នាក់គឺដើម្បីឲ្យនាងសប្បាយចិត្ត ហើយការពិតទៅគេក៏មិនដឹងដែរថា មានស្ថានការណ៍អីរង់ចាំនៅខាងមុខ។

"សូមបញ្ជាក់ ទូកចេញពីកំពង់នៅថ្ងៃស្អែក"

"ល្អ ឲ្យវាឆាប់ចប់"

គេបត់កន្សែងបង់កពណ៌ផ្កាឈូកស្រស់ដោយការថ្នាក់ថ្នម ញាត់ចូលហោប៉ៅខោ ហើយងើបដើរទៅឈរនៅភនហាលរបស់បន្ទប់ជួល ដែលត្រូវសម្រាកបណ្ដោះអាសន្ន រង់ចាំឡើងទូក។

*ព្រលឹងចិត្ត!*

អ្នកកំលោះគិតដល់ពេលពាក្យនេះ ពេលនឹកដល់ ការ៉ិន នាងជាស្ត្រីខ្ពង់ខ្ពស់ ផុតស្រួយ និងសក្តិសមនឹងភាពស្រណុកសុខស្រួល គ្រប់យ៉ាងដែលគេអាចរកឲ្យនាងបាន។ ខាឡូហ៊ាន់ ប្រគល់អ្វីឲ្យគេ ជាផែនការដែលបានរៀបចំឬអត់។ ការ៉ិន មិនត្រឹមតែជាភរិយាដែលគេបានទទួលមក ដើម្បីធ្វើឲ្យរាជវង្សម៉ាលខៃសេនគេ មានលំនឹង ឬដើម្បីបង្កើតទំនុកចិត្តឲ្យប្រជាជន ប៉ុន្តែគេមានចំណងនឹងនាងពិតប្រាកដ គេហៅនាងនៅក្នុងចិត្តដោយពាក្យពេចន៍ដែលគេមិនគិតថាអាចហៅស្ត្រីណាបាន។ គេចង់ឲ្យនាងនៅចំពោះមុខ ចង់ឱប



ក្រសោបជាប់ដើមទ្រូងហើយខិនទៅហៅនាងដែលនាងមុខជាអៀនក្រហមមុខមិនខាន ហើយពេលនាងអៀន មុខរបស់នាងមិនអាចបិទបាំងអារម្មណ៍បានសម្បុរសព្រលាំផ្កាឈូកនោះ បញ្ជាក់ឲ្យដឹងច្បាស់ថានាងមានអារម្មណ៍យ៉ាងណា។

"ខ្លារីហ្សា"

អ្នកកំលោះដាក់ដៃលើហោប៉ៅខោ ដែលមានកន្សែងបង់កពណ៌ស្រស់របស់ភរិយានៅក្នុងនោះ។ គេនឹកនាង ហើយក៏មានចិត្តដូចអ្នកដែលគេនឹកព្រោះពេលនេះ ការ៉ិន នៅក្នុងក្រុងស៊ីលវេស្ទ័រ មកលំហែជាមួយ យែតទ្រីណា និង គ្រីស្ទីណា ហើយនាងមានអារម្មណ៍ធូរស្រាលមែនទែន ប៉ុន្តែការនឹករឭកស្វាមី នៅតែមិនរសាយ។

"អាកាសធាតុល្អទេ"

"ចាំ អាកាសធាតុល្អណាស់"

ការ៉ិន ងាកទៅឆ្លើយប្រាប់ យែតទ្រីណា។ ក្រមុំទាំងបីមកសម្រាកចំណាយពេលនៅជាមួយគ្នាដូចក្រុមគ្រួសារធម្មតា មានអង្គរក្សតាមការពារ តែជាការការពារពីចម្ងាយ ការពារស្ងាត់ៗមិនបង្ហាញខ្លួន ដើម្បីមិនឲ្យពួកនាងក្លាយជាចំណាប់អារម្មណ៍របស់ប្រជាជនពេក។

**បងប្អូនស្រីទាំងបីមកដើរលេង។ ការមកដើរលេងរបស់ពួកនាង ជាការរស់នៅឲ្យដូចប្រជាជនទូទៅ។ ហើយពេលនេះ ការ៉ិន កំពុងតែចាប់អារម្មណ៍**





Scanned by CamScanner

ស្លាកមួយ ដែលប្រាប់ថាមានកម្មវិធីប្រចាំឆ្នាំរបស់ភូមិនៅជិតកន្លែងដែលពួកនាងស្នាក់នៅ។

ត្រីស្នីណា ចាញ់អាកាសធាតុជារឿងធម្មតារបស់ប្អូនស្រី ដែលតែងតែឈឺញឹកញាប់ ហើយសាមីខ្លួនក៏ដឹងពីអាការៈរបស់ខ្លួនឯងច្បាស់ដែរ។

"ប្អូនស្រីត្រូវសម្រាកឲ្យបានច្រើន"

"ចាំ បងស្រី ខ្ញុំចង់ទៅមែនទែន"

"បើស្អែកនេះធូរស្រាលហើយ យើងនឹងទៅជាមួយគ្នាទៀត"

"សុំដើរលេងឲ្យសប្បាយ"

"បងស្រីនឹងឆាប់ត្រឡប់មកវិញ"

ការ៉ិន សន្យាចំពោះ ត្រីស្នីណា ដែលនាងចូលចិត្តហៅថា ត្រីស្នី ខណៈដែលហៅ យែតទ្រីណា ដោយឈ្មោះពេញ ឬហៅខ្លីៗថា យែត ផ្លាស់គ្នាតាមអារម្មណ៍។

"កុំបារម្ភអី ប្អូននៅបាន"

"ត្រូវតែបារម្ភ ប្អូនស្រីជាប្អូនរបស់យើង មែនទេ យែតទ្រីណា"

"ចាំ មែន យើងនឹងទិញនំមកផ្ញើ ត្រីស្នី"

យែតទ្រីណា សន្យា ហើយពួកនាងក៏ជឿជាក់ចំពោះសុវត្ថិភាពនៅក្រុងនេះ ឬអាចខ្វះការប្រុងប្រយ័ត្នបាន ព្រោះពួកនាងមិនធ្លាប់ជួបនឹងហេតុការណ៍គ្រោះថ្នាក់ ព្រោះត្រូវបងប្រុសការពារនោះឯង។

"ឆាប់ទៅ"



ត្រីស្នីណា ជូនដំណើរបងស្រីទាំងពីរមកដល់មុខផ្ទះ ហើយបិទទ្វារចាក់សោ ព្រោះ ការ៉ិន យកកូនសោមួយទៀតទៅជាមួយ។

"បងស្រីមានអារម្មណ៍ល្អហើយមែនទេ ?"

ពេលបណ្តើរគ្នាមកដល់កម្មវិធីបុណ្យប្រចាំភូមិ យែតទ្រីណា ក៏សួរបងស្រី។

"ល្អណាស់ តាមពិតទៅបងស្រីនៅនឹក រ៉េមសៀ តែបងស្រីអាចចាត់ការអារម្មណ៍របស់ខ្លួនឯងបានល្អ សុំទោសផងដែលធ្វើឲ្យប្អូនស្រីលំបាក រឿងរបស់បងស្រី"

"មិនលំបាកទេ យើងបានមកដើរលេងជាមួយគ្នា វាល្អទៅវិញទេ"

ពួកនាងដើរដឹកដៃគ្នា នៅក្នុងកម្មវិធីដោយអារម្មណ៍រីករាយ។ ការ៉ិនទិញគ្រឿងលម្អតូចៗស្រឡាញ់បានច្រើន ខណៈដែល យែតទ្រីណា បានម្ហូបម៉ូតប្លែកៗច្រើនដែរ។ យែតទ្រីណា ជាស្ត្រីដែលចូលចិត្តម្ហូប សន្សំម្ហូបបានច្រើនណាស់ ទាំងម្ហូបតម្លៃថ្លៃ និងតម្លៃថោក។

"យើងរ៉ៃតែភ្លេចនំរបស់ ត្រីស្នី"

"សំណាងដែលយើងមិនភ្លេច បងស្រី"

ត្រីស្នីណា លើកថង់នំបង្ហាញ បន្ទាប់មកពួកនាងក៏បណ្តើរគ្នាត្រឡប់ទៅផ្ទះវិញ ប៉ុន្តែនៅតាមផ្លូវបែរជាមានរឿងមិនប្រក្រតី ហើយក៏មានអារម្មណ៍ថាមានមនុស្សដើរតាមពួកនាងតាំងពីចេញពីកម្មវិធីបុណ្យភូមិម្ល៉េះ ទើបប្រញាប់ប្រញាល់ដើរឲ្យកាន់តែលឿន តែសម្រិបជើងដើរតាមពីក្រោយ ក៏នៅតែឮ។





Scanned by CamScanner

ពួកនាងទម្លាក់អីវ៉ាន់ចោល ហើយចាប់ដៃគ្នាប្រឹងរត់ មិនខ្វល់ពីទិសតំបន់ ប៉ុន្តែពួកនោះក៏រត់តាម។

"រត់ឲ្យលឿនឡើង យែត"

កាអ៊ិន បញ្ជាប្អូនស្រី ទាំងដែលខ្លួនឯងហត់ឡើយខ្លាំង ប៉ុន្តែត្រូវតែរត់ ខណៈនោះអង្គរក្សដែលបង្កប់ខ្លួន ក៏បង្ហាញខ្លួនមកចាត់ការពួកដែលរត់តាមព្រះនាង។

"ព្រះនាង!"

អង្គរក្សហាមប្រាមមិនទាន់ ព្រះនាងទាំងពីររត់ចូលតំបន់ហាមឃាត់ទៅហើយ ដែលសូម្បីតែព្រះអង្គម្ចាស់ ខាឡូម៉ាន់ ក៏មិនអាចចូលទៅតំបន់នោះបាន ព្រោះអាចធ្វើឲ្យប៉ះទង្គិចដល់សម្ព័ន្ធភាពរវាងរាជវង្ស ម៉ាលខៃសេនតេ និងតំបន់ស្វ៊យត ស៊ី រ៉ូវ៉េ។ វាជាកំពង់ផែពិសេសរបស់កោះចោរ គ្រប់គ្នាស្គាល់កំពង់ផែមួយនេះ ក្នុងនាមរបស់ ជីសាស់ ស៊ី រ៉ូវ៉េ។

អង្គរក្សចាត់ការពួកអន្ធពាលនោះរួចរាល់ ប៉ុន្តែអ្វីដែលពួកគេត្រូវធ្វើបន្ទាប់ពីនេះ គឺរាយការណ៍ទៅព្រះអង្គម្ចាស់ ថាគេបំពេញតួនាទីមិនបានល្អ ចំណែក កាអ៊ិន និង យែតទ្រីណា ផ្ដើលចូលមក្នុងតំបន់ដែលសុទ្ធតែមនុស្សប្រុស ពេលនេះត្រូវពួកវាឡោមព័ទ្ធជុំជិត។

"បងស្រី..." យែតទ្រីណា ត្រសុលទៅរក។

"យែត បងស្រីនឹងបង្វែរចំណាប់អារម្មណ៍របស់ពួកវា យែត ត្រូវរកផ្លូវរត់ចេញពីទីនេះ ហើយបើត្រឡប់ទៅវិញបាន ត្រូវឲ្យដំណឹងដល់បងប្រុស"



"តែ..."

"គ្មានតែ យ៉ាងហោចណាស់ ក្នុងចំណោមយើង ត្រូវតែមានម្នាក់រួច" នាងប្រាប់ប្អូនស្រីដោយទឹកមុខមាំ និងប្រើរាងកាយរបស់ខ្លួនបាំងរាងកាយរបស់ប្អូនស្រី ឲ្យ យែតទ្រីណា រកផ្លូវរត់ ចំណែកខ្លួនឯងបង្វែរចំណាប់អារម្មណ៍ពួកវា ខណៈនោះក៏នឹកដល់ រ៉ែមសៀ តែស្ថានការណ៍បែបនេះ បើនាងត្រូវការទៅរកស្វាមី គឺត្រូវតែយោងអាត្មាឲ្យរស់។

"ខ្ញុំត្រូវការចរចា"

ពួកវាហួច ពេលបានឮបែបនេះ ប៉ុន្តែនាងនៅតែពើងទ្រូងដាក់ មិនមែនជានាងមិនខ្លាច នាងខ្លាចចង់សន្លប់ទៅហើយ ប៉ុន្តែត្រូវតែធ្វើចិត្តឲ្យរឹងមាំ។



# ១៦

## យោងរកញ្ញា

ការ៉ុន ចរចានឹងពួកវា និងអាចធ្វើឲ្យពួកវាព្រមដោះលែង យែតទ្រីណា ពីតំបន់ហាមឃាត់បាន។ នាងមិនយល់ទេថាហេតុអ្វីបានជាពួកវាហៅទីនេះថា តំបន់ហាមឃាត់ ប៉ុន្តែនាងគ្មានពេលស្វែងរកចម្លើយ។ ពួកវាព្រមដោះលែង យែតទ្រីណា ហើយ ទោះមិនធានាពីសុវត្ថិភាព តែយ៉ាងហោចណាស់ក៏ប្អូនស្រី បានចេញពីតំបន់ហាមឃាត់ អង្គរក្សក៏អាចរកឃើញ និងនាំទៅផ្ទះវិញបាន។

នាងត្រូវនាំឡើងទូក ស៊ី រ៉ូវើ 1 និងនាំទៅឲ្យអ្នកដែលពួកវាហៅថា មេ ឈ្មោះ ពីទ័រ ទើបសុំចរចា ហើយបើចរចាមិនបានសម្រេច នាងនឹងធ្វើគ្រប់វិធី ដើម្បីឲ្យខ្លួនឯងមានសេរីភាព។

នាងបានឮសំឡេងរបស់ ពីទ័រ និងគ្នីគ្នាសើចពេលនិយាយពីនាងដោយ មិនផ្ដល់កិត្តិយស។ នាងខ្ពើមរអើម ពេលគិតថាមានប្រុសផ្សេងក្រៅពី រ៉ែមសៀ ប៉ះពាល់ខ្លួនប្រាណ បើពួកវាត្រូវការខ្លួនប្រាណរបស់នាង ក៏អញ្ជើញរំលោភ ពេលដែលនាងដាច់ខ្យល់ទៅ នាងសុខចិត្តស្លាប់។

នាងរកមើលរបស់ដែលអាចយកធ្វើជាអាវុធបាន ប៉ុន្តែទោះគ្មានអីសោះ ក៏នៅតែរកមើល និងរកផ្លូវរត់។ ពេលដែលទ្វារបន្ទប់សម្រាករបស់ ពីទ័រ ត្រូវបើក



ក្លិនស្រាភាយចេញពីខ្លួនរបស់វាឡើងឆួល ធ្វើឲ្យនាងចង់ក្អួត និងឃើញគេកាន់ ដបស្រាចូលមកដែរ។

"ស្អាតដល់ក"

ពីទ័រ មិនធ្លាប់ឃើញស្រីណា ស្អាតយ៉ាងនេះទេ។ ពេលកូនចៅនៅលើ ទូកបញ្ជូនមនុស្សស្រីមកឲ្យគេ ដោះដូរនឹងប្រាក់ចំនួនមួយពាន់ដុល្លារ ដែលគេ ព្រមចំណាយ ពេលឃើញ ការ៉ុន និងកាន់តែកើតចិត្តប្រាថ្នាឡើងរឹងខ្លួនអស់ ទៅហើយ។ នាងស្អាតដល់ថ្នាក់ ធ្វើឲ្យគេចង់ស្ទាងស្រា ប៉ុន្តែមើលទៅស្រីស្អាត ដូចមិនរីករាយទទួលគេ។ នាងពើងទ្រូង ធ្វើខ្លួនក្រអឺតក្រទម ដូចខ្លួនឯងមាន វណ្ណៈខ្ពង់ខ្ពស់ ប៉ុន្តែមិនអីទេ ពេលត្រូវគេចាប់សង្កត់នៅលើគ្រែ នាងនឹងអង្វរករ ឲ្យគេជួយបំពេញបន្ថែមមិនខាន។

ពីទ័រ ជាមនុស្សលង់ខ្លួនឯង គិតថាមនុស្សស្រីត្រូវតែឈ្លក់វង្វេងនឹងគេ។ គេជាមេធំនៅលើទូក តែបោះការងារឲ្យកូនចៅធ្វើ បន្ទាប់ពីមានបញ្ហាឲ្យចេញ ទូក គេក៏ចូលមកក្នុងបន្ទប់ ដើម្បីត្រៀមខ្លួនដួសដងយកសេចក្ដីសុខពីស្រីស្អាត ដែលបានចំណាយប្រាក់ទិញ។

"ខ្ញុំមានសំណើ"

"សំណើអីស្រីស្អាត"

"លោកឲ្យលុយពួកនោះប៉ុន្មាន ?"

"មួយពាន់"



"ខ្ញុំនឹងឲ្យលោកច្រើនជាងហ្នឹង បើលោកដោះលែងខ្ញុំ មួយម៉ឺនដុល្លារ



Scanned by CamScanner

យ៉ាងម៉េចដែរ"

ពីទ័រ ហួចឆ្ងាចពេលឮសំណើ ព្រោះមិនគិតថាមនុស្សស្រីនៅចំពោះមុខមានប្រាក់ដល់ទៅមួយម៉ឺនដុល្លារឲ្យខ្លួន។ មនុស្សស្រីដែលគេស្គាល់ ភាគច្រើនរកចំណូលបានតិចតួច ឬមិនអីចឹងជាស្រីលក់សេវាកម្មផ្លូវភេទ ដែលគេទិញមកដេកជាមួយ ពេលទុកចូលកំពង់ផែ។

"ខ្ញុំមិនត្រូវការលុយ តែខ្ញុំត្រូវការនាង"

ពីទ័រ ដើរមករក ដាក់ដបស្រាលើតុ ទើប ការ៉ិន សម្លក់ថ្លៃ ព្រមទាំងគិតថាយកវាធ្វើជាអាវុធបានឬអត់ តែពេលនេះដកថយសិន ដោយថយជារង្វង់មូលព្រោះបន្ទប់នៅលើទូកមិនធំទូលាយដូចបន្ទប់ដេករបស់នាង។

នាងដើរយឺតៗ ភ្នែកសម្លឹងវា។ សំណាងល្អមួយរបស់នាងគឺ ពីទ័រ ស្រវឹង ពេលស្រវឹង ការធ្វើសកម្មភាពរបស់វាក៏មិនពេញលក្ខណៈដែរ នាងត្រូវតែបោកវា ល្បួងវា ដើម្បីចូលទៅជិតទ្វារនោះ។

"ខ្ញុំមិនបានកុហក"

"តែខ្ញុំមិនជឿទេថានាងមានលុយឲ្យខ្ញុំ ខ្ញុំចំណាយលុយទិញនាងហើយអីចឹងហើយ ខ្ញុំនឹងចាត់ការនាងពេញមួយយប់"

ពីទ័រ ចង្អុលគ្រែនៅជាប់ជញ្ជាំង ធ្វើឲ្យនាងព្រឺសម្បុរដោយការខ្ពើមរអើម ប៉ុន្តែនាងសច្ចាហើយថា នាងជាប្រពន្ធរបស់កងទ័ព ជាប្រពន្ធរបស់អ្នកចម្បាំង គឺត្រូវតែរឹងមាំនិងមើលថែខ្លួនឯងឲ្យបាន ជាងនេះទៅទៀតនាងជាប្អូនស្រីរបស់ព្រះអង្គម្ចាស់ ខាឡូម៉ាន់ នាងមិនអាចឲ្យជនដែលមានវណ្ណៈថោកទាបប្រមាថ



ជាន់ឈ្លីកិត្តិយសរបស់នាងជាដាច់ខាត។

វណ្ណៈថោកទាបនៅក្នុងន័យរបស់នាង គឺពួកដែលខ្វះភ្ជាប់មេត្តា។ បើនាងពេញចិត្តធ្វើរឿងលើគ្រែជាមួយវាគឺជារឿងមួយទៀត ប៉ុន្តែនេះនាងមិនពេញចិត្ត និងបានដាក់សំណើដែរ វាបដិសេធសំណើនោះ ហើយនៅមើលមកនាងដោយខ្សែភ្នែកល្មោភលាន់ គួរឲ្យខ្ពើមរអើមទៀត។

"គ្មានផ្លូវ!"

"ត្រូវតែបាន!"

ពីទ័រ គំហក និងហក់ទៅរក តែនាងងាកចេញ ទោះវាស្រវាចាប់ដៃបាន និងទាញទៅរក ក៏នៅតែប្រឹងក្រាញ ក្រាញជើងថយឲ្យឆ្ងាយ ធ្វើឲ្យវាបង់ជំហរ ទើបស្រវាយកដបស្រាបាន។

"ឈប់!"

នាងស្រែកបញ្ជា តាមទម្លាប់ដែលធ្វើដាក់អ្នកបម្រើ ហើយសម្រេចចិត្តវាយដបស្រានឹងតែមតុឲ្យបែក និងកាន់បំណែកស្រួចរលែមអាចធ្វើជាអាវុធបានគំរាមវា។

"កុំចូលមក!"

"ដាក់វាចុះ!"

ពីទ័រ មិនគិតទេថា នាងស៊ូកម្លាំងរបស់ខ្លួនបាន ទើបមនុស្សស្រវឹងស្ទុះទៅរក ប៉ុន្តែត្រូវនាងចាក់នឹងអំបែងដបចំពោះ ហើយប្រឹងអត់ធ្មេញ បែរខ្លួនរត់សំដៅទ្វារបន្ទប់។



"ចាប់ខ្លួនវា!"

សំឡេងស្រែកចេចចាចរបស់មនុស្សប្រុសបន្លឺឡើងពេញទូក តាមដោយសំឡេងសម្រិបជើងរត់ស្រូស្រាបន្លឺឡើង ទើប ការ៉ុន បិទភ្នែករត់ មិនខ្វល់ទេថារត់ទៅបុកនឹងអ្វីខ្លះ មានម្ដងដែលត្រូវពួកវាស្រវាចាប់ដៃអាវបាន ប៉ុន្តែនាងមិនព្រមឈប់រត់ ទើបពួកវាទាញទាល់តែរហែក។

"ចាប់ខ្លួនបាន ពួកអញនឹងរំលោភឲ្យរាប់"

សំឡេងស្រែករបស់ពួកវា ធ្វើឲ្យនាងព្រឺសម្បុរខ្វាកៗ។ នាងខ្លាច ប៉ុន្តែមិនចំណាយពេលទៅលើការភ័យខ្លាចនេះ ទុកចេញពីកំពង់ហើយ ហើយនាងក៏សច្ចាដែរថា បើរត់មិនរួចពីពួកវាមែន នាងនឹងលោតទឹក។

រាងកាយមួយនេះ បើនៅមានខ្យល់ដង្ហើមគឺមិនព្រមឲ្យប្រឡាក់ប្រឡូសភគៈប្រុសផ្សេងដាច់ខាត តែបើលែងមានខ្យល់ដង្ហើមនោះគឺជារឿងមួយទៀត។ ការ៉ុន ស្រវាយកកំណាត់ឈើដែលឃើញនៅម្ដុំនោះ ទុកការពារខ្លួន ពេលត្រូវឡោមព័ទ្ធពីមនុស្សប្រុសមាឌធំៗ និងកណ្ដាលទីធ្លារបស់ទូក។ នាងមិនចេះវិធីតស៊ូ ប៉ុន្តែចេះតែគ្រវីគ្រវាត់តាមកម្លាំងដែលមាន ជាការតំរាម។ នាងដឹងហើយថាការចរចាមិនបានសម្រេច ប៉ុន្តែក៏សង្ឃឹមថានៅលើទូកនេះមាននរណាម្នាក់អាចជួយនាងបាន ទោះក្តីសង្ឃឹមនោះវាដូចពន្លឺភ្លើងទៀនក៏ដោយ។

នាងត្រៀមការ ទប់ការភ័យខ្លាចទុកនៅខាងក្នុង ព្រោះបើនាងភ័យខ្លាចពួកវាកាន់តែបានចិត្ត ដូច្នេះហើយទោះញ័រខ្លួនទទ្រើត ក៏ត្រូវតែអត់ធ្មត់។

*យ៉ាងច្រើន រាប់តែប៉ុណ្ណោះ!*



នាងប្រាប់ខ្លួនឯងនៅក្នុងចិត្ត ពេលនោះក៏នឹក រ៉េមសៀ អស់ពីបេះដូង ទើបយកគេធ្វើជាកម្លាំងចិត្តកម្លាំងកាយឲ្យខ្លួនឯងនៅពេលនេះ។

"កម្លាំងច្រើនណាស់នាង"

"ពួកឯងមករញ៉េរញ៉ៃនឹងខ្ញុំធ្វើអី"

"ពីទ័រ ចាយលុយហើយ!"

"ពួកឯងគ្មានសិទ្ធិលក់ដូរខ្ញុំ" នាងត្បកទៅវិញ ដោយភាពក្រអឺតក្រទម និងនៅតែគ្រវីឈើក្នុងដៃ ហើយគ្រវែងទៅរក ពេលមានប្រុសម្នាក់ស្ទុះមករក។ លើកទីមួយនាងវាយវាបាន តែលើកទីពីរ ត្រូវវាចាប់កញ្ឆក់យកឈើនោះបាន និងទះកំផ្លៀង ឲ្យនាងដួលខ្ពោក។

"ឈប់! អញប្រាប់ថាឲ្យឈប់!"

សំឡេងស្រែកបញ្ជាបន្លឺឡើង នាងរលីងរលោងទឹកភ្នែក តែមិនព្រមយំ ព្រោះតែការឈឺចាប់ប៉ុណ្ណឹង ទោះមានរសជាតិឈាមជាប់នឹងចង្ក្រមាត់ និងសាច់ទន់ៗដែលជាប់នឹងធ្មេញ ថែមទាំងរាកទៅសម្លឹងមុខអាអ្នកដែលទះគប់នាងទៀត ប៉ុន្តែពេលឃើញមុខមាំរបស់បុរសមាឌក្រអាញ ដែលវែកគេវែកឯងចូលមកឈរបាំងមុខ នាងក៏បើកភ្នែកធំៗ។

"អាមាន់ថ្មី"

"បិទមាត់!" រ៉េមសៀ ស្រែកបញ្ជាខ្លាំងៗ។

ពេលនេះគេខឹងឡើងញ័រខ្លួនទទ្រើតទៅហើយ ដោយជឿថាអាចសម្លាប់មនុស្សបាន តាំងពីឃើញអាម្នាក់នោះទះកំផ្លៀងប្រពន្ធរបស់គេ។



"នេះប្រពន្ធអញ"

"ឯងកុហក"

"បិទមាត់! អញប្រាប់ថាប្រពន្ធអញ!"

រ៉ែមសៀ មិនចាំបាច់អីត្រូវអធិប្បាយ ក្រៅពីឈរចាំទែង បើអ្នកណាហ៊ានចូលមក គេនឹងសម្លាប់។

"អ្នកណាប៉ះពាល់ប្រពន្ធអញ ងាប់!"

"អញនេះអី"

អាអ្នកដែលទះកំផ្លៀង ការ៉ិន ស្ទុះមករក និងទាញកូនកាំបិត ដែលសៀតជាប់ខ្លួន បំណងចាក់ តែ រ៉ែមសៀ មិនញញើត ថែមទាំងញញឹមចុងមាត់ ស្រវាចាប់កាំបិតនោះ ចាក់វាវិញ ចាក់ចំបំពង់ក ដោយមិនញញើត។

"អាអ្នកទះកំផ្លៀងប្រពន្ធអញ អញមិនទុកទេ"

គេធ្វើតាមសម្តី ហើយធាក់វាឲ្យខ្ទាត ដោយមិនស្រណោះដើង។

"មានអាណាចូលទៀតទេ"

រ៉ែមសៀ ឈរចាំទែង មិនព្រមទៅណា។ ពួកវាក៏ធ្វើភ្នែកឡេមឡាមមើលមុខគ្នា មិនហ៊ានធ្វើអីផ្តេសផ្តាស។

"អញលក់នាងនេះឲ្យមេទូកមួយពាន់"

រ៉ែមសៀ យកលុយមួយពាន់ដុល្លារគប់មុខ ទើបពួកវាលែងចាប់អារម្មណ៍ តេ នាំគ្នាប្រញិបប្រញាប់ប្រមូលលុយ ហើយលើកដៃគ្រវី ដូចចង់ប្រាប់ថាចប់រឿង មិនចង់ងាប់កំដរអាអ្នកផ្ទុះបំពង់កអម្បាញ់មិញ តែពេលគេបែរខ្នងក៏មាន



ពីរនាក់រត់មករក ទាស់ត្រង់ថា រ៉ែមសៀ រហ័សរហួនណាស់ ទាញកូនកាំបិតពីក្នុងខ្លួន ចាក់គ្រាប់ភ្នែកពួកវាបានចំល្អ ហាក់ដូចចាប់ដោត ធ្វើឲ្យវាស្រែក ដូចប្រេតសុំបុណ្យកុសល។

រ៉ែមសៀ មិនប្រណី គេតែងតែឈាមត្រជាក់ ដាក់មនុស្សពាល។ គេទាញកាំបិតមកវិញ ដោតចំបេះដូងវា ហើយទាញចេញ មើលវាប្រកាច់ប្រកិនដោយការឈឺចាប់ ដោយខ្សែភ្នែកឃោរឃៅ បន្ទាប់មកយកអាវរបស់វា ជូតឈាមពីកាំបិតរបស់គេ ទុកដាក់នៅកន្លែងដើមវិញ។

"មានអាណាចង់ងាប់ទៀតទេ" គេសួរដោយសំឡេងត្រជាក់ស្រេង ទើបអ្នកដែលនៅសេសសល់ថយក្រោយក្រេស ដឹងហើយថាមិនអាចទប់ទល់បាន ទើបគេដាក់បង្គុយចោងហោង ទល់មុខ ការ៉ិន "ហៅបងថា ភ្លីន"

នាងយល់ភ្លាមនិងស្ទុះឱបស្វាមី ឲ្យគេលើកបីរាងកាយញ័រទទ្រើតនោះ។

"ពួកឯងចាំទុក នេះប្រពន្ធអញ បើឯងនៅតែមករញ៉េរញ៉ៃនឹងប្រពន្ធអញទៀត អញនឹងលេងឲ្យងាប់ ទោះពួកឯងជាសាច់ញាតិម្ចាស់កោះក៏ដោយ ក៏អញមិនញញើតដែរ"

ពេលប្រកាសច្បាស់លាស់ហើយ រ៉ែមសៀ ក៏បីភរិយាទៅបន្ទប់សម្រាករបស់ខ្លួន ដោយបានបង់លុយថ្លៃខ្លួនរបស់គេជាពិសេសឲ្យ ពីទ័រ ទើបអាចបានបន្ទប់សម្រាកពិសេស មិនចាំបាច់ដេកលូកឡំជាមួយអ្នកដទៃ។ ពីទ័រ ជាមេការនៅលើទូក ដែលនាំកម្មករទៅគប់ចោល តែក៏យកលុយថ្លៃខ្លួនពីកម្មករដែរ។ បើកម្មករមានប្រាក់ជាប់ខ្លួន ត្រូវបង់ឲ្យ ពីទ័រ នឹងបានបន្ទប់សម្រាក មិនចាំបាច់





Scanned by CamScanner

នៅលុកទ្បុំនឹងអ្នកដទៃ តែបើមិនឲ្យលុយ គឺត្រូវដេកបន្ទប់រួម។

មនុស្សរបស់ រ៉ែមសៀ ដែលឡើងមកលើទូកជាមួយ ចាំប្រុងប្រយ័ត្ន ស្រាប់ទៅហើយ បើមានអ្នកចង់លបខាំចៅហ្វាយ ប៉ុន្តែពេលនេះគ្មានអ្នកណាហ៊ានធ្វើទៀតទេ បន្ទាប់ពីឃើញនឹងភ្នែកថាគេសម្លាប់មែនទែន មិនបានគំរាម។

"រ៉ែម..."

នាងខ្សឹបហៅឈ្មោះស្វាមីដោយសំឡេងញ័រ។ នាងមិនយំពេលដែលប្រឈមមុខនឹងពួកវា ប៉ុន្តែពេលចូលមកក្នុងបន្ទប់ជាមួយស្វាមី អង្គុយលើភ្លៅរបស់គេនៅលើគ្រែតូចចង្អៀត នាងបែរជាទ្រហោយំដោយការភ័យខ្លាច។

"រ៉ែម ហ៊ឹក!"

នាងហៅឈ្មោះរបស់គេផង អណ្ដឺតអណ្ដកផង ធ្វើឲ្យបេះដូងរបស់ រ៉ែមសៀ ឈឺខ្លោចៗ ឱបរឹតនាងជាប់ដើមទ្រូង និងត្រួតពិនិត្យមើលរាងកាយត្រួសៗ។

"ពួកវាចង់រំលោភអូន"

"លែងអីហើយ"

"អូនគិតថាអូនស៊ូស្លាប់ ហ៊ឹៗ បើអូននៅមានជីវិតរស់ អូននឹងមិនឲ្យពួកវាជាន់ដានបងដាច់ខាត អូនខ្លាច ខ្លាចខ្លាំងណាស់"

នាងរៀបរាប់បណ្ដើរ យំបណ្ដើរ រ៉ែមសៀ កំឹនថើបក្បាល។ នេះឬអត់ដែលគេហៅថាភាពស្មោះត្រង់ តក្តី ដែល ខាឡូម៉ាន់ ធ្លាប់និយាយប្រាប់ កាអ៊ីនសុខចិត្តស្លាប់ តែមិនព្រមឲ្យអ្នកណាលូកលាន់ រៀតរៀនខ្លួនប្រាណរបស់នាង



ជាន់ដានរបស់គេ។

"រ៉ែម"

"បងការពារអូន កុំខ្លាច"

គេឱបក្រសោបនាង ប្រើវង់ដៃរឹងមាំរបស់គេលួងលោមនាង និងឱបនាងបែបនោះ ទាល់តែនាងឈប់អណ្ដឺតអណ្ដក។

"កុំធ្វើមុខកាច"

រ៉ែមសៀ ជ្រលក់ក្រណាត់នឹងទឹក ជូតមុខមាត់ឲ្យភរិយាថ្នមៗ។ មុខរបស់គេឡើងក្រមូវ ពេលឃើញស្នាមក្រហមជាប់ថ្ពាល់រលោង និងពេលជូតកំណកឈាមចេញពីចង្ខៀកមាត់របស់នាងហើយក៏ដកដង្ហើមធំ ប៉ុន្តែសម្រាប់ កាអ៊ីនត្រូវទះកំផ្លៀង ល្អជាងត្រូវរំលោភបំពានរាងកាយ។ នាងញ័រទទ្រើតពេលគិតដល់រឿងនេះ ទើប រ៉ែមសៀ ស្រវាឱបភ្លាម។

ពេលពិនិត្យរាងកាយរបស់នាង នាងក៏និយាយឲ្យស្ដាប់ ដែលគេក៏ស្ដាប់ដោយមិនមាត់មិនក ដោះសម្លៀកបំពាក់នាងចេញ ព្រោះដៃរវាវហែករហូយហើយយកអាវយឺតមកពាក់ឲ្យបណ្ដោះអាសន្ន។

"អូនបារម្ភពី ឃែត ដល់ហើយ"

"បងនឹងរកវិធីទាក់ទងអង្គម្ចាស់"

"អូនសង្ឃឹមថា ឃែត មិនអី"

នាងបារម្ភពីប្អូនស្រី ប៉ុន្តែត្រូវរង់ចាំ បើ រ៉ែមសៀ ទាក់ទង ខាឡូម៉ាន់ បាន





Scanned by CamScanner

នាងនឹងដឹងថា ឃែតទ្រីណា យ៉ាងម៉េចយ៉ាងម៉ាខ្លះ។ ពេលនេះនាងនៅជាមួយ រ៉ែមសៀ ហើយ គេនឹងចាត់ការគ្រប់យ៉ាង។

"ធូរហើយមែនទេ ?"

"ចាំ អូនភ័យណាស់ អូនគិតថាបើអូនស៊ូមិនរួចមែន អូននឹងលោតទឹក"

នាងស្រវាចាប់ដៃរបស់គេផ្ទឹបនឹងថ្ពាល់ គេក៏ឱនមកថ្ពាល់ថ្នមៗ។ គេលួចមកបំពេញភារកិច្ច ប៉ុន្តែជោគវាសនាក៏បញ្ជូន ការ៉ិន មកឲ្យ។ គេមិនខឹង ព្រោះបើគេមិននៅលើទូកមួយនេះ តើនឹងមានអ្វីខ្លះកើតឡើងចំពោះនាង។

គេឱបក្រសោបនាងដោយការហួងហែង ឲ្យនាងសម្ងំនៅក្នុងលង្វែកទ្រូង ដូចគេឱបនាងកាន់តែចូលចិត្ត។ នាងនៅភ័យមិនទាន់បាត់ ប៉ុន្តែគ្មានអាការៈស្លុត បន្ទាប់ពីប្រឈមមុខនឹងហេតុការណ៍គួរឲ្យខ្លាចនោះ ព្រោះមានស្វាមីនៅជាមួយ។

"សំណាងល្អដែលបងនៅលើទូកនេះដែរ"

គេចាប់ដៃរបស់នាងថើប ទើប ការ៉ិន ដឹងថាដៃរបស់គេញ័រ។

"ដៃរបស់បងញ័រដល់ហើយ"

"ព្រោះអូនហ្នឹងហើយ"

គេមិនចាំបាច់អធិប្បាយ ក៏នាងយល់ថាគេបារម្ភពីនាង ទើបងើបមកថើបថ្ពាល់ និងញញឹមស្រទន់ដាក់។

"សំណាងល្អដែលជួបបង"

នាងនិយាយតែប៉ុណ្ណឹង ក៏អួលដើម.ក។ បើគ្មានគេ ហើយនាងមាន



មន្ទិល នាងមិនព្រមឲ្យខ្លួនឯងមានជីវិតរស់នៅបន្តទេ ឬទោះត្រូវរស់នៅបន្ត ក៏នាងមានអារម្មណ៍ដូចខ្លួនឯងជាមនុស្សស្លាប់ទាំងរស់។

"ទោះមានអីកើតឡើងចំពោះអូន ក៏អូននៅតែជាប្រពន្ធរបស់បង"

"រ៉ែម..."

"បងមិនរើសអើងអូនទេ ព្រោះអូនគ្មានចេតនាឲ្យវាកើតឡើង តែអូនមិនអាចការពារខ្លួនឯងបាន"

នាងអណ្ដឺតអណ្ដក ស្រវាឱបស្វាមី រ៉ែមសៀ ក៏ឱបនាងវិញណែនដៃ សង្កត់ចង្កានឹងស្មារបស់នាង។

"តែចាប់ពីពេលនេះទៅ បងមិនព្រមឲ្យអូននៅឆ្ងាយពីភ្នែកទៀតជាដាច់ខាត"

ការ៉ិន ជ្រប់មុខនឹងដើមទ្រូងរឹងមាំ ដៃអង្អែលខ្នងរបស់គេ មិនចាំបាច់មានពាក្យអធិប្បាយច្រើនជាងនេះ ក៏នាងយល់ ឯ រ៉ែមសៀ ក៏យល់ពីកិរិយាដូចគ្នា។ នាងស្មោះត្រង់ ស្មោះស្ម័គ្រចំពោះគេ ចំណែកគេត្រូវតែតបស្នងអារម្មណ៍របស់នាងវិញឲ្យស្មើគ្នា។

"បងនឹងនាំអូនទៅជាមួយគ្រប់ទីកន្លែងឬ"

"ប្រហែលជាបែបហ្នឹង ឬបើបងមិននៅ អូននឹងមិនត្រូវអនុញ្ញាតឲ្យដើរលេងតែម្នាក់ឯងទៀតជាដាច់ខាត"

"អូនលែងចង់ដើរលេងហើយ បើបងមិនទៅជាមួយ អូនរាង"

នាងព្រមសារភាពតាមត្រង់ នាងគ្រាន់តែមកសម្រាក គ្រាន់តែមកដើរ



លេងនៅក្នុងកម្មវិធីបុណ្យក្នុងភូមិ ប៉ុន្តែពាក្យថាគ្រាន់តែប៉ុណ្ណឹង វ៉ៈតែធ្វើឲ្យនាងយោងរកភ្នាមិនរស់។

"នេះជាសម្តីដែលបងចង់ឮ"

នាងថើបថ្ពាល់របស់គេ អង្អុយលើភ្លៅរបស់គេ រ៉េមសៀ កំមិនរអ៊ូរទាំ គេធ្វើតួនាទីជាស្វាមី ឱបក្រសោបភរិយា ជួយលួងលោម។

"ត្រូវធ្វើដំណើរប៉ុន្មានថ្ងៃ ?"

"ពីរឬបីសប្តាហ៍"

"បងនឹងនៅជាមួយអូនមែនទេ ?"

"នៅ បងទៅណាបាន"

គេអង្អែលថ្ពាល់ក្រហមរបស់នាង។ ប្រពន្ធរបស់គេ ទោះឆ្អាសឆ្អើមដាក់គេយ៉ាងណា ក៏គេមិនធ្លាប់វាយសូម្បីតែមួយដៃ តែអាសត្វជាតុអស់នោះ វាសមតែងាប់ ដែលហ៊ានទះកំផ្លៀងនាងឲ្យបែកឈាម ហើយគេមិនសោកស្តាយអីបន្តិច ដែលកម្ចាត់សំរាមចេញពី សាក់ខារៀ។

"បងស្នាក់នៅក្នុងបន្ទប់នេះម្នាក់ឯងឬ ?"

"អ៊ឺម បងបង់លុយឲ្យ ពីទ័រ ព្រោះបងត្រូវការភាពផ្ទាល់ខ្លួន ក្នុងការធ្វើការ"

"មានបន្ទប់ទឹកដែរមែនទេ ?"

"អ៊ឺម អូនងូតទឹកនៅក្នុងបន្ទប់ទឹកបាន"

គេចាប់ដៃភរិយា នាំដើរមើលបន្ទប់ វាមិនមែនជាបន្ទប់ធំទូលាយ ប៉ុន្តែវា



មានភាពផ្ទាល់ខ្លួន ព្រោះបើជាបន្ទប់រួម គេនឹងមានបញ្ហានឹងមនុស្សប្រុសគ្រប់គ្នា ដែលមើលភរិយារបស់គេ។ គេនៅជាមួយនាងមិនព្រមទៅណាឆ្ងាយ ដើម្បីឲ្យនាងកក់ក្តៅចិត្ត ព្រោះហេតុការណ៍ដែលកើតឡើង ធ្វើឲ្យគេមើលឃើញភាពតស៊ូ និងបេះដូងរឹងមាំរបស់ភរិយា។ ធ្វើឲ្យការរៀបការដែលគេមិនប្រាថ្នាក្លាយជារឿងដែលល្អបំផុតនៅក្នុងជីវិតរបស់គេក៏ថាបាន។

"ភ្លៀងធ្លាក់ហើយ" ការ៉ិន និយាយ ខណៈដែលអង្អុយលើភ្លៅរបស់ស្វាមី នៅជាប់មាត់បង្អួច ដែលលយចេញទៅក្រៅ។

"ភ្លៀងធ្លាក់ទើបអាកាសធាតុត្រជាក់ បើមិនស្រួលខ្លួនត្រូវប្រាប់ភ្លាម"

"ចាំ បើភ្លៀងធ្លាក់បែបនេះ មានព្យុះទេ"

"គ្មានទេ សប្បាយចិត្តចុះ"

នាងពាក់អាវយឺតរបស់គេ គេមានឈុតថ្មីសម្រាប់នាង ដែលទិញពីមនុស្សស្រីនៅលើទូក យកខោអាវមកលក់ វាធំជាងខ្លួនរបស់នាង តែមិនអីទេ ពាក់រលុងៗ វាល្អជាងពាក់រឹបរាង ដែលទាក់ទាញឲ្យប្រុសផ្សេងមើល។

"បងទៅធ្វើអីនៅកោះចោរ ?"

"ធ្វើការ"

"មិនសួរក៏បាន"

នាងមិនចង់ដឹង គ្រាន់តែចង់បបួលគេនិយាយប៉ុណ្ណោះ រ៉េមសៀ ក៏ឱនថើបថ្ពាស ចំណែកអ្នកដែលត្រូវថើប ក៏ស្រុលទៅកេបន្តិចទៀត។



"ខ្លួនបងកក់ក្តៅដល់ហើយ"

គេឱបក្រសោបនាង នៅជាមួយនាងគ្រប់ពេលវេលា ទោះត្រូវរ៉ះគន់ថាទុកការងារចោលមិនចាប់អារម្មណ៍ ព្រោះប្រពន្ធរបស់គេត្រូវការអ្នកលួងលោម គេក៏អីចឹងដែរ ការបានឃើញនាងមានគ្រោះថ្នាក់នៅចំពោះមុខ ធ្វើឲ្យបេះដូងរបស់គេហោងហាង ទើបការឱបក្រសោបនាង គឺជាការបន្ថែមថាមពលឲ្យខ្លួនឯង និងជាការបញ្ជាក់ថា នាងនៅតែមានសុវត្ថិភាពក្នុងរង្វង់ដៃរបស់គេ។

"ម៉ោះ ពាក់ស្រោមជើងឲ្យកក់ក្តៅ"

គេទិញស្រោមជើងបកដែរ និងថែបប្រាក់ពិសេសឲ្យមនុស្សស្រី ដែលយកសម្លៀកបំពាក់មកលក់ឲ្យបន្តិចបន្តួចទៀត។ គេពាក់ស្រោមជើងឲ្យភរិយា នាងក៏លើកដៃឱប.កគេ ថើបថ្ពាល់គេ។

"ប្តីអ្នកណា គួរឲ្យស្រឡាញ់ដល់ហើយ"

"គួរឲ្យស្រឡាញ់ ព្រោះមានអ្នកប្រណិប័តន៍អូនមែនទេ"

"ព្រោះម្នាក់នោះជាបង"

វ៉ែមសៀ ថើបថ្ពាល់នាងខ្សិតៗ ហើយអង្គុយមើលភ្លៀងមួយសន្ទុះទៀត ទើបលើកនាងបីដើរទៅរកគ្រែ។

"ចូលដេក"

នាងប្រសព្វភ្នែកជាមួយគេដោយខ្សែភ្នែកផ្អែមល្ហែម គេក៏ដាក់បង្អុយចុះលើគ្រែ ដោយដាក់នាងឲ្យអង្គុយលើភ្លៅ។

"ថើបបានទេ ?"



វ៉ែមសៀ ត្រូវតែសួរសិន នាងទើបតែជួបរឿងគួរឲ្យភ័យខ្លាច នាងអាចមិនចង់ឲ្យគេនៅជិតបែបនោះ ប៉ុន្តែនាងមិនឆ្លើយ បែរជាងើយមកថើប និងថើបជញ្ជក់ខ្លាំងៗទៀតផង ហើយពេលគេបើកមាត់ទទួល នាងក៏ជ្រែកអណ្តាតចូលមក។ បបូរមាត់របស់នាងនៅតែផ្អែម វ៉ែមសៀ ឲ្យភរិយាជាអ្នកវាយលុកមួយសន្ទុះ ទើបក្រសោបមុខរបស់នាងថើប។ គេថើបនាងដោយភាពផ្អែមល្ហែមបន្ថែមកម្រិតបន្តិចម្តងៗ ឲ្យនាងទន់ខ្លួនល្អកនៅក្នុងលង្វែកទ្រូងធំទូលាយ។

ពួកគេផ្អាកថើបគ្នាមួយភ្លែត ហើយចាប់ផ្តើមសាថ្មី ដែលម្តងនេះ វ៉ែមសៀ អូសបបូរមាត់មករក.កសខ្ចី ដៃទាញអាវយឺតចេញពីខ្លួនរបស់នាង ដាក់នៅក្បែរខ្លួន បន្តដោយការឈ្មុលមុខសង្ហាទៅលើដើមទ្រូងណែនក្បុំ។

បបូរមាត់ក្តៅគគុករបស់ វ៉ែមសៀ នៅតែគ្រប់គ្រងបង្ហាញភាពជាម្ចាស់ចំណែក ការ៉ិន ស្ទាបអង្អែលរាងកាយរបស់គេ និងឈ្ងោកមើលដោយខ្សែភ្នែកស្រទន់ ជ្រាលជ្រៅ។ ប្រុសផ្សេងត្រឹមប្រកាសថានឹងប៉ះពាល់ខ្លួនប្រាណ នាងក៏មានអារម្មណ៍ឆ្អើមចង់ក្អួតទៅហើយ ប៉ុន្តែពេលបុរសម្នាក់នេះ នាងបែរជាមានអារម្មណ៍ផ្សេង អារម្មណ៍ឈ្លក់វង្វេងពេលបាននៅជាមួយគ្នា។

នាងក្រមុំពើងទ្រូងទៅរកបបូរមាត់ក្តៅ ខណៈដែលរាងកាយក៏ក្តៅ ព្រោះការប៉ះពាល់របស់ស្វាមី។ ការបាននៅក្នុងរង្វង់ដៃរបស់គ្នា ប្រៀបដូចការផ្សះផ្សាផ្លូវអារម្មណ៍ បន្ទាប់ពីឆ្លងកាត់ហេតុការណ៍សាហាវនៅក្នុងជីវិត។

ប្រពន្ធកំពូលសម្រស់បើកផ្លូវ ពេលស្វាមីលូនមករក ហើយលើកត្រគាករបស់នាងឲ្យនៅក្រោមមុខសង្ហា ប្រើអណ្តាតប៉ះពាល់ឲ្យនាងស្រើបស្រាល និង



អ៊ិនទៅរកជាការតបត។

"រ៉ែម សម្លាញ់ចិត្ត..."

គេជាសម្លាញ់ចិត្តរបស់នាង ជាស្វាមីរបស់នាង ជាគ្រប់យ៉ាងសម្រាប់នាង នាងនឹកគេដោយអារម្មណ៍ផ្អែមល្ហែម។ កំពុងពេលមានអារម្មណ៍ក្តៅគគុក នាងរកឃើញថា នាងធ្លាក់ក្នុងអន្លង់ស្នេហ៍របស់ស្វាមីខ្លួនឯងរកផ្លូវឡើងមិនរួច មិនដឹងតាំងពីពេលណា។

រ៉ែមសៀ ថើបជញ្ជក់ ទាល់តែនាងក្តៅដូចភ្លើងនោះឯង ទើបងើបចេញថយទៅផ្អែកនឹងជញ្ជាំងក្បាលគ្រែ ដោយទាញនាងឲ្យមកគ្រប់គ្រងភាពមហិមារបស់ខ្លួន។

"បងសម្លាញ់"

"ព្រលឹងចិត្តបង" រ៉ែមសៀ ខ្សឹបដាក់ត្រចៀកសស្អាត។

កាអ៊ិន លើកដៃឱប.ករឹងមាំ ធ្វើសកម្មភាពស្នេហាយឺតៗ ព្រោះមិនចង់ប្រញាប់ប្រញាល់។ នាងក្រមុំត្រូវការធ្វើដំណើរទៅមុខយឺតៗ ដើម្បីផ្តិតយកការរំលាយរាងកាយទាំងពីរក្លាយជាសាច់មួយនឹងស្វាមី។

"អរគុណ"

បន្ទាប់ពីធ្វើសង្គ្រាមស្នេហានៅលើគ្រែ ទាល់តែបែកញើសជោកខ្លួន ទើបរ៉ែមសៀ យកកន្សែងពោះគោជ្រលក់ទឹកមកជូតសម្អាតរាងកាយឲ្យភរិយា។ ទឹកនៅលើទូក ត្រូវប្រើសន្សំសំចៃ មិនអាចងូតខ្ជះខ្ជាយបាន ហើយពេលជូត



ខ្លួនប្រាណរួចរាល់ នាងក៏រងា ទើបគេស្លៀកពាក់ឲ្យ និងពន្លត់ភ្លើង ផ្តួលខ្លួនដេកឲ្យនាងសម្ងំដេកលើរាងកាយ។

"ហត់នឿយទេ"

"មិននឿយទេ អូនចូលចិត្តនៅជាមួយបង"

ការបានធ្វើរឿងអ្វីក៏ដោយជាមួយស្វាមី នាងដឹងហើយថាគ្រប់ពេលវេលានាងត្រូវការរក្សាទុក ព្រោះអាចនឹងមានហេតុការណ៍អាសន្ន ដែលធ្វើឲ្យនាងនិងគេត្រូវព្រាត់គ្នា ចាប់ពីពេលនេះទៅនាងនឹងមិនធ្វើឫកធ្វើពា មិនលេងខ្លួនទៀតទេ នាងនឹងប្រាប់ រ៉ែមសៀ ថា នាងត្រូវការអ្វី និងបបួលគេរក្សាទុកការចងចាំជាមួយគ្នាឲ្យបានច្រើនបំផុត។

"រ៉ែម"

"មានអី ?"

"បើអូនមានរឿងសំខាន់ចង់ប្រាប់បង បងស្តាប់ទេ"

"អូនចង់ប្រាប់អីដល់បង"

នាងងើបខ្លួនបន្តិច នៅក្នុងភាពងងឹត ប៉ុន្តែខ្សែភ្នែកស៊ាំនឹងវា អាចមើលឃើញស្រមោលរបស់គេព្រាលៗបាន។

"អូនចង់ប្រាប់ឲ្យបងដឹង មុនពេលអូនគ្មានឱកាសបានប្រាប់"

"អូនចង់ទៅណា ?"

"អូនមិនបានទៅណាទេ តែអូនត្រូវប្រាប់ ក្រែងលមានហេតុការណ៍អាសន្នកើតឡើងទៀត"



នាងត្រូវការឲ្យគេដឹងពីអារម្មណ៍ល្អៗដែលមានចំពោះគេ រ៉ែមសៀ ក៏ចាប់ដៃភរិយាថើប និងរង់ចាំស្តាប់នាង។

"អូនចង់ប្រាប់អីដល់បង"

"បើអូនប្រាប់ថាស្រឡាញ់បង បងជឿអូនទេ ?"

"អូនប្រើពាក្យថា បើ អីចឹងអូនអាចនឹងប្តូរចិត្តបាន"

"មិនមែនទេ អូនស្រឡាញ់បងមែន"

រ៉ែមសៀ ថើបបាតដៃរបស់នាង ទាញនាងមកឱបរឹតជាប់ នាងក៏ផ្ទប់មុខនឹងដើមទ្រូងរបស់គេ ដោយដៃម្ខាងត្រូវ រ៉ែមសៀ ចាប់ជាប់។

"មានហេតុផលអីដែលបងមិនជឿ ព្រោះបងក៏មានអារម្មណ៍បែបហ្នឹងលើអូនដែរ"

"បងគួរនិយាយវាចេញមក អូននឹងបានដឹងថាអូនមិនបានគិតដោយខ្លួនឯង"

"បងស្រឡាញ់អូន"

គេបញ្ចប់ពាក្យសម្តីរបស់ខ្លួន ដោយការថើបថ្ពាសរបស់នាងថ្នមៗ ការ៉ុនក៏បិទភ្នែកយប់នេះនាងនិងគេដេកលក់ជាមួយគ្នាអមដោយស្នេហារបស់ពួកគេទាំងពីរដែលមានជាមួយគ្នា។



# ១៧

## អំណាចស្នេហា

ការ៉ុន ស្តាប់បង្គាប់ស្វាមី ព្រោះសុវត្ថិភាពជារឿងសំខាន់ ហើយបញ្ហារបស់គេក៏មិនមែនលេងៗដែរ ទើបនាងមិនធ្វើខ្លួនលេចធ្លោ សម្ងំនៅតែក្នុងបន្ទប់ភាគច្រើន ព្រោះសម្រស់របស់នាង អាចធ្វើឲ្យនាងមានគ្រោះ។

រ៉ែមសៀ មិនត្រូវការសម្លាប់អ្នកណាទៀត តែបើពួកវាប្រុសអត់ប្រាកចង់បៀតបៀនភរិយារបស់គេ គេក៏មិនដោះលែងវាដែរ ទើប ការ៉ុន សម្ងំនៅតែក្នុងបន្ទប់ ហើយបើចង់ចេញទៅក្រៅ រ៉ែមសៀ នឹងនាំទៅ តែបើគ្មានគេ នាងក៏មិនធុញទ្រាន់នឹងនៅតែក្នុងបន្ទប់ដែរ។

នាងមានសៀវភៅអានលេងបីក្បាល ដែល រ៉ែមសៀ ទិញឲ្យពេលទូកចូលចត ដើម្បីយកអីវ៉ាន់ដែលកុម្ម៉ង់ និងត្រូវយករបស់នោះទៅកោះចោរ។

ពីទ័រ នៅតែជាមេក្រុមនៅលើទូក តែជាមេក្រុមដែលមិនហ៊ានសូម្បីតែប្រសព្វភ្នែកនឹង រ៉ែមសៀ។ ពីទ័រ មានបួលធ្ងន់ និងជាមេរៀនសំខាន់សម្រាប់គេ។ គខឹង គុំគួន តែមិនអាចធ្វើអ្វីបាន ព្រោះពេលចាន់ប្រមាណស្ថានការណ៍ហើយ រ៉ែមសៀ រឹងមាំជាង។



ការ៉ុន ស្អប់ ពីទ័រ តែងតែចៀស មិនឲ្យជួបមុខ ចំណែក រ៉ែមសៀ វិញ



Scanned by CamScanner

មិនសម្លាប់វា ចាត់ទុកថាល្អហើយ តែបើវាមិនព្រមឈប់រវីរវល់នឹងភរិយារបស់គេ គេនឹងចាត់ការវាដោយផ្ទាល់ ហើយម្តងនេះធានាថាវាត្រូវតែងាប់មែនទែន។

"បងសម្លាញ់..."

ការិន មិនចូលចិត្តហៅគេដោយឈ្មោះក្លែងក្លាយ បើហៅថា រ៉េមសៀ ក៏ត្រូវប្រុងប្រយ័ត្ន ទើបនាងហៅគេថា **បងសម្លាញ់** ប៉ុន្តែហៅបែបនេះក៏នៅតែមានបញ្ហា...បញ្ហាអីមរអៀនោះឯង។

"មានការអី ?"

នាងហាដៃទៅរក រ៉េមសៀ ក៏ដើរបករកអ្នកអង្គុយនៅលើគ្រែ ហើយលើកបីនិងថើបថ្ពាល់ខ្សឹតៗបន្តដោយការថើបមាត់ ទើបនាងល្មុលមុខនឹងប្រឡោះកដោយមិនខ្វល់ទេថាខ្លួនប្រាណរបស់គេប្រឡាក់ស្រមេកស្រមក។

"ចង់ខិប"

"ប្រយ័ត្នប្រឡាក់ ខ្លួនបងគគ្រិច ឃើញទេ"

"ឃើញ តែមិនខ្វល់"

ក្រោយពីចង់ខិបហើយ នាងក៏ថើប.ករបស់គេជាការបញ្ជាក់ ព្រោះមិនបានខ្ពើមរអើម ញើសនៅលើខ្លួនរបស់គេ ផ្ទុយទៅវិញ បើជាបុរសផ្សេង ទោះស្អាតមានអនាម័យយ៉ាងណា តែបើគិតមិនល្អចំពោះរាងកាយរបស់នាង នាងនឹងខ្ពើមរអើម។

"អីចឹងម៉ោះ ថើបមួយខ្សឹត"

"ថើបច្រើនខ្សឹតក៏បាន"



នាងក្រសោបមុខសង្ហា ងើយមកថើបបបូរមាត់ក្តៅ។ រ៉េមសៀ ជាទីពឹងពាក់របស់នាង ជាក្រោះការពារឃុំគ្រងនាង។

រ៉េមសៀ ទាក់ទង ខាឡូម៉ាន់ ពេលទូកចូលផែ និងប្រាប់នាងឲ្យដឹងថាយែតទ្រីណា មានសុវត្ថិភាព ហើយនាងក៏មិនបានដេញដោលអីដែរ។

"បងសម្លាញ់"

"បាទ ព្រលឹងចិត្ត"

ការិន ញញឹមឡើងចង់រហែកថ្ពាល់ ព្រោះនាងផ្អែមល្ហែមដាក់គេ ទើបគេផ្អែមល្ហែមដាក់នាងវិញ ទោះវាមិនសមនឹងរូបរាងមុខមាត់ម៉ាំរបស់គេ តែវាជាសិទ្ធិពិសេសរបស់ភរិយា។

"ដល់កោះចោរហើយនៅ ?"

"ពីរថ្ងៃទៀតប្រហែលដល់"

"ពេលដល់កោះចោរហើយ ធ្វើយ៉ាងម៉េច ?"

"អូនមិនបាច់ធ្វើអីទេ ធ្វើតាមតែបញ្ជារបស់បងទៅបានហើយ"

នាងលើកកូនដៃដាក់ពីមុខ តែពេល រ៉េមសៀ មិនយល់សញ្ញានេះ ទើបបក់ដៃឲ្យគេលើកដៃឲ្យ ហើយចាប់កូនដៃរបស់គេមកផ្គុំនឹងកូនដៃរបស់នាង។

"អូនសន្យាថា អូននឹងស្តាប់បង្គាប់បង"

"នេះជាការធ្វើកិច្ចសន្យា"

"ចាំ ធ្វើកិច្ចសន្យាច្បាប់ព្រះនាង ខ្លារិហ្វា"

"ព្រះនាងឆ្លាសឬ"



នាងសម្លក់សម្លឹង បើគេមិននិយាយឲ្យខឹង នាងក៏មិនឆ្ងាសឆ្អើមដាក់ដែរ ប៉ុន្តែពេលនេះនាងកាត់បន្ថយភាពឆ្ងាសឆ្អើម និងធ្វើខ្លួនគួរឲ្យស្រឡាញ់ដាក់គេហើយតើ។

"ព្រោះបងហ្នឹងហើយ ធ្វើឲ្យអូនខឹង មិនទាន់ស្គាល់គ្នាច្បាស់ផងក៏រិះគន់ទៅហើយ"

"បងសុំទោសដែលល្មើយដាក់អូន កាលនោះវាមួម៉ៅ បងមានភារកិច្ចច្រើនពេក ហើយការមើលថែប្រពន្ធម្នាក់ គឺជារឿងធំ"

"គួរឲ្យស្រឡាញ់ដល់ហើយ ចេះសុំទោសអូនដែរ"

រ៉េមសៀ ចាប់ដៃភរិយាថើប និងសម្លឹងនាង ដោយខ្សែភ្នែកកក់ក្ដៅ ត្រឹមប៉ុណ្ណឹងក៏ធ្វើឲ្យថ្ពាល់របស់នាងក្រហមទៅហើយ។

"រៀនអី ?"

"មិនដឹងទេ នាំទៅអង្គុយត្រង់នោះបន្តិច"

នាងចង្អុលទៅកន្លែងអង្គុយនៅមាត់បង្អួច ទើប រ៉េមសៀ បីទៅអង្គុយដោយឲ្យអង្គុយលើភ្លៅរបស់គេ។

"ឱបបន្តិច"

ការ៉ុន គ្មានហេតុផលអីត្រូវម៉ិកម៉ូក់ដាក់ស្វាមី ពេលចង់ម៉ិកម៉ូក់ក៏ធ្វើដោយគេមិនបានថាអី ពេលប្រពន្ធសុំ គេក៏ផ្ដល់ឲ្យ។

រ៉េមសៀ នាំវ៉ៃហ៊ិណេស ចុះពីទូកតាមគេតាមឯង ដោយចាប់ដៃភរិយា



ដើរតាមផ្លូវរបស់កម្មករ ដែលមានគ្រួសារ ហើយប្រសព្វភ្នែកនឹងអ្នកកាន់បញ្ជីបន្ទាប់មកក៏ត្រូវចាប់បំបែកផ្លូវ ដោយហេតុផលថាត្រូវត្រួតពិនិត្យទិន្នន័យពិសេស។

ពីទ័រ និងបក្សពួកលួចមើល ដោយមិនហ៊ានមើលចំ ព្រោះខ្លាចថាធ្វើឲ្យ រ៉េមសៀ ខឹង តែក៏សប្បាយចិត្ត ព្រោះថាអ្នកដែលត្រូវទាញចេញពីផ្លូវ ដើម្បីយកទៅត្រួតពិនិត្យនោះមិនមែនជារឿងល្អ ហើយតែងតែចាត់ខ្លួន។

"ឯងរាប់មិនខាន"

"រមាស់"

រ៉េមសៀ ដើរកាត់ បានឮការដាក់ទំនាយនេះល្មម ទើបត្បុកទៅវិញ និងងាកមកសម្លឹងមុខ ដែលធ្វើឲ្យ ពីទ័រ ប្រញាប់ថយក្រោយតាមកូនចៅភ្លាម។

"តោះទៅ"

អ្នកកំលោះដឹកដៃភរិយាដើរចេញទៅ ខណៈដែល ការ៉ុន ងឿងឆ្ងល់នឹងហេតុការណ៍ដែលកើតឡើង តែព្រោះមាន រ៉េមសៀ នៅជាមួយ ទើបនាងមានទំនុកចិត្តមិនថាមានអ្វីកើតឡើង ពួកនាងត្រូវតែនៅជាមួយគ្នា។

"មិនថាមានអ្វីកើតឡើង យើងត្រូវតែនៅជាមួយគ្នា"

នាងខ្សឹបប្រាប់ឲ្យឮតែពីរនាក់ ហើយចាប់ដៃរបស់គេជាប់ដោយត្រូវការបញ្ជាក់តាមអ្វីដែលខ្លួននិយាយ។ មិនថាមានអ្វីកើតឡើង បើ រ៉េមសៀ លំបាក នាងនឹងលំបាកជាមួយគេដែរ បើគេត្រូវយកជីវិតមកបោះចោលនៅទីនេះ នាងនឹងស្លាប់តាមគេ។



នាងមិនដឹងទេថាសម្ដីរបស់ខ្លួន ធ្វើឲ្យ រ៉េមសៀ មានអារម្មណ៍ទន់ភ្លន់ផុង

បេះដូងបែបដែលបុរសខែងរែងបានដឹងថា  ការមាននរណាម្នាក់ស្រឡាញ់គេ ហើយគេក៏ស្រឡាញ់នាងម្នាក់នោះ ជាអារម្មណ៍ដែលពិសេសកម្រិតណា។

មុននេះគេធ្លាប់មានគូស្នេហ៍ តែព្រោះជាស្នេហាបែបយុវវ័យ ទើបធ្វើឲ្យគេអស់សង្ឃឹម។ ស្នេហាកាលនោះបញ្ចប់ដោយអតីតគូស្នេហ៍បោះបង់គេដែលធ្វើគ្រប់យ៉ាងដើម្បីនាងដោយហេតុផលថាគេគ្មានពេលឲ្យនាង ទើបគេតាំងចិត្តថានឹងមិនប្រគល់បេះដូងឲ្យស្រីណាទៀត  តែគេបានល្មើសច្បាប់របស់ខ្លួនឯងពេលបាននៅជិត ការ៉ិន ហើយការបានស្រឡាញ់ព្រះនាងឆ្លាស និងត្រូវនាងស្រឡាញ់ ធ្វើឲ្យគេដឹងទៀតថាស្នេហាកាលពីអតីត ទម្ងន់របស់វាស្រាលណាស់ពេលប្រៀបធៀបនឹងអារម្មណ៍ដែលគេនិង ការ៉ិន មានចំពោះគ្នា។

ស្នេហាកាលពីអតីតគ្រាន់តែជាស្នេហាភ្លើងចំបើង  ខណៈដែលស្នេហាដែលគេនិង ការ៉ិន មានចំពោះគ្នា វាមានចំណងនៃពាក្យថាគូជីវិត។

រ៉ែមសៀ ងាកទៅថើបថ្ពាសរបស់នាងថ្មមៗ ហើយដឹកដៃនាងដើរតាមអ្នកដែលនាំចេញពីជួរ ដោយចិត្តគំនិតនឹងន និងមានភាពមោះមុត។

"នៅទីនេះ"

ពួកគេត្រូវនាំមកខ្ទមឈើមួយ ដែលត្រូវមានការតុបតែងសាមញ្ញៗ តែស្អាត មានអនាម័យ និងគួរឲ្យចង់រស់នៅ។ វាមើលទៅដូចផ្ទះលម្ហែ តែ ការ៉ិន គ្មានអារម្មណ៍ចូលចិត្តវា។

"បងសម្លាញ់" នាងក្រមុំហៅគេដោយសំឡេងញ័រ ព្រោះចង់ទៅជាមួយ



គេ មិនចង់នៅទីនេះម្នាក់ឯង តែទោះនាងនិយាយមិនចេញ ក៏ រ៉ែមសៀ យល់។

"បងត្រូវតែម៉ៅវិញ"

គេទាញនាងមកឱប និងថើបថ្ពាស បន្តដោយការថើបបបូរមាត់ក្រពុំដោយក្ដីស្រឡាញ់។

"ជឿបង ព្រលឹងចិត្ត" គេនិយាយផ្អែមល្ហែមដាក់ ទើប ការ៉ិន ចំទើតជើងថើបថ្ពាល់ត្រើម និងឲ្យគេលើកបី។

"កុំបារម្ភអី"

"ត្រូវតែបារម្ភ"

នាងជ្រប់មុខនឹងប្រឡោះកវឹងមាំ ព្រោះមិនត្រូវការនៅឆ្ងាយពីគេ នាងនិងខ្វល់ខ្វាយ បើគ្មានគេនៅជាមួយ។

"បងត្រូវតែត្រឡប់មកវិញ បងសន្យា"

រ៉ែមសៀ ថ្កក់កូនដៃនឹងភរិយា តាមការចងចាំដែលនាងធ្លាប់ធ្វើ ដែលធ្វើឲ្យព្រះនាងញញឹមពព្រាយតែម្ដង ទោះកំពុងមានអារម្មណ៍តានតឹងក៏ដោយ។

"សន្យាហើយ"

"សន្យា ព្រលឹងចិត្តបង"

"បងហៅអូនពីរោះៗបែបនេះទៀតម៉ោ អូនចូលចិត្ត"

ការ៉ិន ក្រសោបមុខសង្ហាដោយដៃទាំងពីរ ហើយថើបថ្ពាល់។

"ចាំបងហៅញឹកញាប់"

រ៉ែមសៀ ថើបថ្ពាល់ភរិយា ហើយពួកគេក៏ថើបគ្នាយ៉ាងយូរ ដោយមិន





Scanned by CamScanner

ចង់នៅឆ្ងាយពីគ្នាសូម្បីមួយវិនាទី។

"ចាំនៅទីនេះ ដេកលក់ក៏បាន"

"អូនប្រហែលដេកមិនលក់ទេ"

មនុស្សរបស់ម្ចាស់កោះចោរ រង់ចាំនៅខាងក្រៅដើម្បីនាំស្វាមីរបស់នាងទៅជួបអ្នកដែលកំពុងរង់ចាំ តើមិនឲ្យបារម្ភម្ដេចបាន ម្យ៉ាងទៀតនាងក៏មិនត្រូវអនុញ្ញាតឲ្យទៅជាមួយដែរ។

"នៅក្នុងផ្ទះនេះមានសុវត្ថិភាពសម្រាប់អូន"

"ទោះមានសុវត្ថិភាព តែប្រហែលដេកមិនលក់ទេ អូនបារម្ភពីបង" នាងលើកដៃអង្អែលថ្ពាល់របស់គេថ្នមៗ។

"ហត់ក៏សម្រាក អូនខេ ?"

"អូននឹងព្យាយាម"

"បើអូនដេកលក់ ពេលភ្ញាក់ឡើង បងមកវិញល្មម"

"សុំឲ្យបែបហ្នឹងទៅចុះ"

គេនិយាយឲ្យភរិយាសប្បាយចិត្ត ហើយពេលថើបគ្នាជាការលួងលោមរួចហើយ ទើបបីនាងទៅរកគ្រែ។

"បងសម្លាញ់ អូនសុំកូនកាំបិតពីបងបានទេ ចែកឲ្យអូនមួយបានទេ ?"

"យកធ្វើអី ?"

"ដាក់ជាប់ខ្លួន បើមានអីកើតឡើងចំពោះបង អូនអាចត្រូវប្រើវា" នាងប្រាប់ដោយទឹកមុខប្រាកដប្រជា ទើប រ៉េមសៀ ដាក់ភរិយាទៅលើគ្រែ ហើយ



ហុចកូនកាំបិតនៅក្នុងស្រោមឲ្យ។

"ដាក់ជាប់ខ្លួនប៉ុណ្ណោះ ហាមប្រើវា ព្រោះបងត្រូវតែត្រឡប់មកវិញ"

"ចាំ អូនគ្រាន់តែចង់បានការសប្បាយចិត្ត បើបងកើតអី អូននឹងមិននៅទីនេះម្នាក់ឯង"

អ្នកកំលោះដាក់បង្អួយនៅលើគ្រែ ចាប់ដៃទាំងពីររបស់ភរិយាថើបថ្នមៗ។ ក្ដីស្រឡាញ់របស់នាង ធ្វើឲ្យគេមានសេចក្ដីសុខខ្លាំងណាស់។

"អូនជាជីវិតរបស់បង ខ្លាវិហ្សា"

"បងក៏ជាជីវិតរបស់អូន រ៉េមសៀ"

ពួកគេក៏ឱបគ្នា ថើបគ្នាទាល់តែជ្រាយបបូរមាត់ ទើបសម្រេចចិត្តលែងដៃពីគ្នា។

"រង់ចាំនៅទីនេះ ត្រូវស្ដាប់បង្គាប់"

"ចាំ អូនស្ដាប់បង្គាប់"

ពេលថ្នក់កូនដៃគ្នាម្ដងទៀតហើយ រ៉េមសៀ ក៏ដើរសំដៅទ្វារ ពេលទាញវាបិទហើយ ឈរមើលមុខអ្នករង់ចាំ។

"មើលថែព្រះនាងឲ្យបានល្អ"

ពេលបញ្ជាមនុស្សរបស់ខ្លួន និងរង់ចាំឲ្យពួកនោះទៅបង្កប់ខ្លួននៅជិតផ្ទះនោះរួចរាល់ ទើបគេដើរតាមអ្នករង់ចាំមួយក្រុមទៀត ដើម្បីទៅជួបអ្នកដែលត្រូវការជួប។





Scanned by CamScanner

"លួងប្រពន្ធរួចហើយ ?"

រ៉េមសៀ ដើរចូលទៅក្នុងបន្ទប់ធ្វើការក្នុងប្រាសាទស្ដើមស្ដែនៅលើកោះចោរ ដោយម្ចាស់បន្ទប់ គឺបុរសមាឌធំ និងមានអំណាចធំជាងគេនៅលើកោះនេះ។

"រ៉ូម !"

រ៉េមសៀ ងក់ក្បាល ពេលដែលម្ចាស់បន្ទប់ដែលជាបុរសសង្ហា រូសរាយ ប៉ប្លែចប៉ប្លុច តែបង្កប់អំណាចគួរឲ្យកោតក្រែង ងាដៃទៅរកកៅអីនៅមុខគុ។

"អញ្ជើញអង្គុយ លោកឧត្តមសេនីយ រ៉េមសៀ"

ឈ្មោះរបស់គេគឺ ជីសាស់ ស៊ី រ៉ូវើ ដែលនាមត្រកូលគ្រាន់តែជារហស្សនាម និងបញ្ជាក់ថាពាក់ព័ន្ធនឹងកោះនេះប៉ុណ្ណោះ មិនមែននាមត្រកូលពិតប្រាកដ។

"លំបាកស្លាប់ហើយ" ជីសាស់ ដើរទៅដាក់បង្អុយលើកៅអីវិលក្រោយតុធ្វើការ ពេលនិយាយចប់។

រ៉េមសៀ ត្រូវធ្វើដំណើរតាមទូក ដើម្បីមិនឲ្យមានការតាមដានឃើញថាមានទំនាក់ទំនងកម្រិតណានឹងម្ចាស់កោះ ស៊ី រ៉ូវើ ព្រោះនឹងធ្វើឲ្យរង្គោះរង្គើដល់ព្រះអង្គម្ចាស់ ខាឡូម៉ាន់ ក្រៅពីនេះការធ្វើដំណើរតាមទូក ក៏ធ្វើឲ្យ រ៉េមសៀ បានត្រួតពិនិត្យផ្លូវទឹកមួយនេះដែរ ថាមានហេតុការណ៍មិនប្រក្រតីអីកើតឡើងឬអត់ ប៉ុន្តែមិនអាចធ្វើដំណើរមកសន្ទនាជាមួយ ជីសាស់ ដោយបើកចំហបាន ព្រោះអត្ថន័យនៃសម្ព័ន្ធភាពដែលបើកចំហនៅទីភ្លឺ គឺជាសម្ព័ន្ធភាពដែលត្រូវកំណត់ដោយកិច្ចសន្យារួមគ្នា ជាសម្ព័ន្ធភាពបែបសោះកក្រោះ ឬហៅថា សម្ព័ន្ធភាពនយោបាយ។



"មិនលំបាកអីទេ"

"ល្បីថាឯងសម្លាប់មនុស្សរបស់ខ្ញុំអស់បីនាក់"

"ពួកវាសមតែងាប់"

"អូខេ ខ្ញុំមិនបន្ទោសឯងរឿងនេះទេ កូនចៅអន់ចរិតត្រូវឯងកម្ចាត់ឲ្យ ខ្ញុំអរគុណឯងទើបត្រូវ" ជីសាស់ និយាយតាមត្រង់។

ការដែល រ៉េមសៀ ធ្វើដំណើរតាមទូកនោះ អាចឲ្យគេឆក់ឱកាសនេះឲ្យ រ៉េមសៀ ជួយធ្វើការដោយរាយការណ៍ពីសកម្មភាពរបស់កម្មករដែលមកធ្វើការនៅលើកោះនេះ។

"ហើយសុំទោសផង ដែលមនុស្សរបស់ខ្ញុំ ប៉ះពាន់ព្រះនាង ខ្លារិហ្សា ផ្ញើសុំទោសព្រះអង្គម្ចាស់ផង សង្ឃឹមថាអាមៀនោះមិនប្រកាន់"

"ឯងសុំទោសនិងសរុបដោយខ្លួនឯងរួចរាល់ទៅហើយ ខ្ញុំអាចនិយាយអីបានទៀត"

"ព្រោះការជួបគ្នារបស់យើងមួយរយៈនេះនៅតែលំបាក ទើបខ្ញុំត្រូវសរុបឲ្យងាយបំផុតហ្នឹងអី"

"ចាំខ្ញុំប្រាប់ឲ្យទៅចុះ"

"អីចឹង ខ្ញុំសប្បាយចិត្តហើយ ម៉ោះ ! ចូលសាច់រឿងល្អជាង ឯងឃើញអីខ្លះនៅតាមផ្លូវ ?" ជីសាស់ សួរនាំសាច់ការ។



គេទាញ រ៉េមសៀ ពីកម្មករក្រុមថ្មី ធ្វើឲ្យកម្មករគិតថា រ៉េមសៀ ត្រូវហៅទៅត្រួតពិនិត្យ ហើយពេលនិយាយរួច គេនឹងបញ្ជូន រ៉េមសៀ និងភរិយា



Scanned by CamScanner

ចេញពីកោះចោរទៅកោះតូចដែលជាកោះផ្ទាល់ខ្លួនមួយទៀតរបស់គេ ដែលជាតំបន់ហាមឃាត់ ដោយទុកលឿន និងធ្វើដោយការប្រុងប្រយ័ត្ន ព្រោះមនុស្សនៅលើកោះចោរ អាចមានមនុស្សរបស់ពួកឧទ្ទាមមកបង្កប់ខ្លួន។

ជីសាស់ មិនទុកចិត្តកម្មករ ព្រោះការទុកចិត្តនឹងនាំមកនូវហាយនៈ តែគេគ្រប់គ្រងកោះដោយភាពម៉ឺងប្រាយ បើមានអ្នកណាធ្វើខុស ត្រូវគេចាប់បានធានាថានឹងត្រូវកម្ចាត់ មិនថាពួកវាកក់ផ្ទះនៅក្រុងវេសលីយ៍ប្រេនទុករួច ឬអត់ក៏ដោយ។

"មានអ្វីម្យ៉ាងមិនប្រក្រតី"

វ៉ែមសៀ សរសេរអ្វីម្យ៉ាងលើក្រដាស ហើយពេលឈ្លោកទៅអានចប់ ជីសាស់ ក៏ខ្ទាំក្រដាសបោះចូលចង្ក្រាននៅកៀនជញ្ជាំង ដើម្បីដុតវាចោល ជាការបំផ្លាញភស្តុតាង។

"ពេលឯងទៅបាត់ ខ្ញុំត្រូវធ្វើរឿងសប្បាយៗហើយ"

វ៉ែមសៀ មិនបញ្ចេញយោបល់ពីរឿងនេះ។ គេនិយាយជាមួយម្ចាស់កោះពីរឿងពួកឧទ្ទាម ហើយប្រមូលយកទិន្នន័យទាំងនោះតាម ជីសាស់ ឲ្យ។

"បានទិន្នន័យប៉ុណ្ណឹង ?"

"ឯងគិតជាម៉េច ?"

"ខ្ញុំកំពុងតាមប្រមាញ់ ឡៃកា"

ជីសាស់ ងក់ក្បាល។ វ៉ែមសៀ ធ្វើដំណើរមកទីនេះ ក្រៅពីត្រួតពិនិត្យផ្លូវទឹកមួយនេះ ថាមានពួកឧទ្ទាមបង្កប់ខ្លួនឬអត់ នៅបានព័ត៌មានសម្ងាត់ថា



ឡៃកា អាល់ម៉ាហ្គេហ្សុី ឡើងមកលាក់ខ្លួននៅលើកោះចោរនេះដែរ។

"ខ្ញុំគ្មានទិន្នន័យរបស់ ឡៃកា ឲ្យឯងទេ វ៉ែមសៀ"

"មួយសំណួរទៀត ឯងនៅតែជាសម្ព័ន្ធមិត្តរបស់ព្រះអង្គម្ចាស់ ខាឡូម៉ាន់ឬអត់ ?"

"ប្រាកដណាស់ ខ្ញុំនៅតែជាសម្ព័ន្ធរបស់ព្រះអង្គម្ចាស់ ខាឡូម៉ាន់"

"ខ្ញុំសង្ឃឹមថានឹងនៅតែបែបនេះ"

"ឯងសង្ស័យខ្ញុំឬអី វ៉ែមសៀ ?"

"បើសំណួររបស់ខ្ញុំ និងចម្លើយរបស់ឯងនៅតែប្រទាក់ក្រឡាគ្នា គឺគួរតែគ្មានបញ្ហាអី"

វ៉ែមសៀ សន្ទនាជាមួយ ជីសាស់ ដោះដូរទិន្នន័យក្នុងរយៈពេលពីរម៉ោងក៏រួចរាល់ធុរៈ ហើយ វ៉ែមសៀ និង ការ៉ុន ក៏ធ្វើដំណើរចាកចេញពីកោះចោរភ្លាម ដោយម្ចាស់កោះបានរៀបចំគ្រប់យ៉ាងរួចរាល់ហើយ។

ខ្ទមបរបាញ់សត្វរបស់ ជីសាស់ ស្ថិតនៅកណ្ដាលព្រៃ លើកោះចោរ នៅកន្លែងអាថ៌កំបាំង និងមានភាពផ្ទាល់ខ្លួនបំផុត។ ពេលជិះសេះទៅដល់ទីនោះ គេក៏បើកទ្វារចូលទៅក្នុងខ្ទម ហើយដើរទៅឈរមើលអ្នកដែលដេកលើគ្រែ ទើបមេឧទ្ទាម ឡៃកា ប្រែខ្លួន ងើបអង្គុយផ្អែកនឹងក្បាលគ្រែ។

ជីសាស់ ផ្ដល់ជំនួយតាមសន្យាកាលពីអតីតជាមួយបុគ្គលសំខាន់ម្នាក់ ប៉ុន្តែគេគ្មានផែនការក្បត់ព្រះអង្គម្ចាស់ ខាឡូម៉ាន់។





Scanned by CamScanner

"របួសយ៉ាងម៉េចដែរ?"

គេដើរទៅឈរនៅមាត់បង្អួច លើកដៃឱបទ្រូង ហើយបែរមកសួរ។

"ពីរថ្ងៃទៀតខ្ញុំអាចចេញពីទីនេះបានហើយ"

"ល្អ"

ជីសាស់ ញញឹម តែភ្នែកមិនញញឹមជាមួយ។ ទោះមានឈ្មោះជាម្ចាស់កោះចោរ តែគេជាមនុស្សរក្សាសន្យា បើមិនរក្សាសន្យា ឡៃកា ត្រូវបញ្ជូនទៅឲ្យ វ៉ែមសៀ ទៅហើយ ព្រោះ វ៉ែមសៀ បានដំណឹងច្បាស់ណាស់ ទើបធ្វើដំណើរមកទីនេះ។

ស្ថានភាពរបស់ ឡៃកា បើពីរថ្ងៃទៀតចាកចេញពីកោះចោរ មើលទៅវេងលំបាកហើយ តែគេបានផ្ដល់ជំនួយតាម ឡៃកា សំណូមពរ ដោយមិនបានឲ្យអ្វីបន្ថែម ហើយចាត់ទុកជាចប់កិច្ចសន្យាពេល ឡៃកា ចេញពីកោះចោរ ដោយសុវត្ថិភាព។

ម្ចាស់កោះមិនបានភូហកមនុស្សជំនិតរបស់ព្រះអង្គម្ចាស់ ខាឡូម៉ាន់ តែមិនអាចឲ្យទិន្នន័យរបស់ ឡៃកា បាន។ ឡៃកា និងកូនចៅរបស់គេ នៅលើទូកត្រូវទាហានសាក់ខាវៀ តាមប្រមាញ់សឹងតែយោងអាត្មាមិនរស់ ទើបលួចឡើងកោះចោរ ដោយអាងកិច្ចសន្យាសម្ងាត់ ដែលម្ចាស់កោះត្រូវបើកកោះទទួល។

"ខ្ញុំត្រៀមការហើយ ពីរថ្ងៃទៀតនឹងបញ្ជូនឯងចេញពីកោះ"

"គ្មានបញ្ហា ខ្ញុំចង់ចេញពីទីនេះដែរ" ឡៃកា តបដោយភាពក្រអឺតក្រទម ប៉ុន្តែដើម្បីរក្សាជីវិតរបស់ខ្លួន មិនដូច្នោះពួកឧទ្ទាមនឹងបែកខ្ញែក ទើបត្រូវខាំមាត់



សង្កត់ព្រមយកជំនួយពី ជីសាស់។

"បើមិនចង់យកជីវិតមកបោះចោលនៅទីនេះ គួរគិតសាថ្មីពីរឿងដែលកំពុងធ្វើ"

ជីសាស់ មិនចង់ជ្រៀតជ្រែករឿងរបស់ ឡៃកា តែការធ្វើខ្លួនជាពួកឧទ្ទាមលួចប្រមូលកម្លាំងច្បាំងនឹងរដ្ឋាភិបាល ធ្វើឲ្យសាក់ខាវៀពិបាកនឹងរីកចម្រើន ហើយគេក៏គិតដល់ប្រជាជនដែលការរស់នៅកំពុងតែមានការរីកចម្រើន។

ខាឡូម៉ាន់ ធ្វើការគ្មានពេលសម្រាក ហត់នឿយស្ទើរស្លាប់ ខូរក្បាលចង់ផ្ទុះម្ដងៗ ព្រោះគិតដល់ប្រជាជនជាធំ តែហេតុអ្វីបានជា ឡៃកា មើលមិនឃើញ មិនជឿជាក់ចំពោះចេតនារម្មណ៍ពិតរបស់ទ្រង់ ទាំងដែលជីវភាព គុណភាពជីវិតរបស់ប្រជាជនសាក់ខាវៀ មានភាពល្អប្រសើរឲ្យឃើញច្បាស់។

"ខ្ញុំគិតច្បាស់ហើយ"

"បែបនេះហៅថាច្បាស់?"

"ខ្ញុំមានចេតនាពិត"

"ខាឡូម៉ាន់ ក៏មាន ឯងមើលមិនឃើញទេអី ថាប្រទេសជាតិ ប្រជាជនមានការរស់នៅយ៉ាងណា"

សម្ដីរបស់ ជីសាស់ ទោះធម្មតា តែបង្កប់ដោយសទ្ធា ការជឿទុកចិត្ត ខណៈដែល ឡៃកា គិតដល់ ខាឡូម៉ាន់ ដោយអារម្មណ៍តានតឹង។



"ជីសាស់ ទោះឯងផ្ដល់ជំនួយដល់ខ្ញុំ តែយើងមានឧត្ដមគតិខុសគ្នា"

"ឯងថ្លឹងថ្លែង និងរកការពិតច្បាស់លាស់ហើយឬនៅ ជាឧត្ដមគតិដែល

ឯងមាន វាត្រឹមត្រូវឬអត់"

ជីសាស់ ត្បកទៅវិញដោយភាពសោះកក្រោះ និងប្រសព្វភ្នែកជាមួយ។ ឡៃកា ជឿជាក់គំនិតខ្លួនឯង គេក៏ជឿជាក់គំនិតរបស់គេដូចគ្នា។

"ខ្ញុំមិនចាំបាច់ឲ្យចម្លើយពីរឿងនេះដល់ឯង"

"ឯងខ្លាចចម្លើយ" ជីសាស់ បាញ់ចំៗ ដោយមិនញញើត។

"ពួកខ្ញុំគ្រប់គ្នាមានឧត្តមគតិរឹងមាំ"

"ពាក់ព័ន្ធនឹងរឿងអី ?"

"ខ្ញុំសុំបញ្ជាក់" ឡៃកា ក្អក ដែលធ្វើឲ្យរញ្ជួយដល់មុខរបួស ទើបលើកដៃខ្ទប់លើបង់ពណ៌ស "ខ្ញុំមិនចាំបាច់ឲ្យចម្លើយពីរឿងនេះដល់ឯង"

ឡៃកា តបដោយសំឡេងត្រជាក់ តែម្ចាស់កោះស្តាប់ដោយទឹកមុខស្មើ។

"ខ្ញុំក៏មិនត្រូវការចម្លើយដែរ តែចាំទុក ឡៃកា ជំនួយពីខ្ញុំម្តងនេះ ចាត់ទុកថាខ្ញុំធ្វើតាមសន្យាហើយ លើកក្រោយយើងជួបគ្នាទៀត បើឯងនៅតែជាសត្រូវរបស់ ខាឡូម៉ាន់ ខ្ញុំនឹងកម្ចាត់ឯង"

"ឯងខ្ចូលវាពេកហើយ"

"ខាឡូម៉ាន់ ធ្វើឲ្យសាក់ខាវៀរីកចម្រើនរុងរឿង"

"វាកុហក!"

"យើងមានឧត្តមគតិខុសគ្នា ឡៃកា ព្យាបាលខ្លួនឲ្យជា ហើយឆាប់ដកក្បាលចេញពីទីនេះទៅ"

គេមកទីនេះដើម្បីប្រាប់ឲ្យ ឡៃកា ដឹងដោយប្រយោលថា រ៉េមសៀ ធ្វើ



ដំណើរចេញពីកោះចោរហើយ។

"សុំទោសផង រ៉េមសៀ ខ្ញុំនៅតែជាសម្ព័ន្ធមិត្តរបស់ឯងជានិច្ច តែខ្ញុំត្រូវរក្សាសន្យាផ្ទាល់ខ្លួនដែរ"

ជីសាស់ និយាយរអ៊ូ ដឹងថា រ៉េមសៀ មិនឮ តែចាត់ទុកថា គេបានផ្តាំតាមខ្យល់ទៅសុំទោសរួចហើយ។

កាអ៊ិន ចំណាយពេលនៅជាមួយស្វាមី ដោយការដឹកដៃគ្នាដើរលេងក្នុងសួនក្នុងប្រាសាទត្រេវីត្រយ ដោយថ្ងៃនេះ រ៉េមសៀ ត្រឡប់មកផ្ទះវិញលឿនជាងសព្វមួយដង។

"បងសម្លាញ់ អូនដាំផ្កាត្រង់នេះដែរ" នាងក្រមុំចង្អុលថ្នាលផ្កាដែលទើបតែដាំថ្មី។

ប្រាសាទត្រេវីត្រយ របស់ រ៉េមសៀ ចាប់ផ្តើមមានពណ៌ចម្រុះរបស់ផ្កាដោយសារភរិយារបស់គេចូលចិត្តពណ៌របស់ផ្កានោះឯង។

"អូនដាំ ?"

"អូនជាអ្នករើសពូជ ហើយឲ្យមនុស្សរបស់យើងដាំក៏បាន"

ព្រះនាងឆ្លាសឆ្មើមសម្លក់សម្លឹងស្វាមីក៏ពិត តែខ្លួនប្រាណត្រសុលទៅបៀត។ គួរឲ្យភ្ញាក់ផ្អើលមែនទែន ព្រោះបើនាងហ៊ានតែដាំដោយខ្លួនឯង មុខជាត្រូវគេស្តីឲ្យមិនខាន។



"បើផ្កាធំ និងរីក សួនត្រង់នេះនឹងស្អាតណាស់"

"អូនចូលចិត្ត ល្អហើយ"

កាលមុនគេធ្លាប់រិះគន់ ខាឡូម៉ាន់ ដែលទំយើ ការ៉ុន ពេក តែឥឡូវនេះ ប្តូរផ្ទាប្តូង តឺ ខាឡូម៉ាន់ រិះគន់តែដែលទំយើ ការ៉ុន ពេក។

"ឥឡូវនេះអូនមិនសបភិងទេអី ?"

"ថីឬ ?"

"វ៉ៃយប៉ីត្រខែនេះ តិចណាស់"

នាងឈប់ដើរ ហើយចំទើតជើងថើបថ្ពាល់គ្រើម ទើបត្រូវគេឱនថើបថ្វាស វិញ បន្ទាប់មកនាងក៏ដឹកដៃគេដើរទៅរកដើមឈើធំ ដាក់បង្អុយចុះ និងទះភ្លៅ ខ្លួនឯង ទើប វែមសៀ ផ្ទួលខ្លួនដេកកើយភ្លៅតាមតម្រូវការរបស់ភរិយា។

"អូនជួយសន្សំសំចៃបង មិនល្អឬ ?"

"អូនគួរធ្វើរឿងដែលអូនធ្វើហើយ មានសេចក្តីសុខ"

វែមសៀ ក្លាយជាមនុស្សដែលគ្មានបញ្ហានឹងការចាយវាយខ្ជះខ្ជាយ ដើម្បី សេចក្តីសុខរបស់ភរិយា។

"អូនមានសេចក្តីសុខហើយ"

ដៃម្ខាងរបស់នាងត្រូវស្វាមីចាប់ថើប ទើបនាងដៃម្ខាងទៀតដែលទំនេរ អង្អែលថ្ពាល់របស់គេថ្នមៗ។

"អូនកំពុងបង្ខំខ្លួនឯងឬអត់ ?"

"អូនមិនបានបង្ខំខ្លួនឯងទេ បងចាត់ទុកអូនជាមនុស្សបែបណានេះ"

ការ៉ុន ជ្រួញច្រមុះដាក់គេ។ នាងមិនមែនជាមនុស្សខ្ជះខ្ជាយគ្រប់ពេល



ឯណា ហើយទោះមិនមែនជាមនុស្សសន្សំសំចៃ តែការសបភិងនាងម្តងម្កាល ប៉ុណ្ណោះ។

"តាមធម្មតា អូនមិនសូវសបភិងទេ"

"អីចឹងឬ ?"

"ធ្វើសំឡេងបែបនេះ មិនជឿអូនឬ ?"

"អូនមានចេតនាសបភិង ដើម្បីឱបងតើ" នាងប្រាប់ការពិត ហើយឱន ថើបមាត់របស់គេ និងញញឹមពព្រាយដាក់។

"ម៉ោពីចូលចិត្តថាឲ្យអូន ទើបអូនមានចេតនាធ្វើគ្រប់យ៉ាងដែលបងថា"

វែមសៀ ងើបអង្គុយ ហើយក៏ទាញភរិយាមកអង្គុយលើភ្លៅ ក្រៀវចង្កា របស់នាង និងថើបថ្ពាល់ខ្សឹតៗ។

"ហ៊ឺ! ថើបខ្លាំងពេកហើយ"

"ស្រីក៏ហួច"

គេច្របាច់ច្រមុះរបស់នាង ព្រោះភ្ញាញ់ ការ៉ុន ក៏ថើបថ្ពាល់គេវិញ។ នាង ចូលចិត្តលូកលាន់ថ្ពាល់គ្រើម មាត់ក្រាស់ក៏ចូលចិត្តថើប ខ្លួនប្រាណហំប៉ូនក៏ ចូលចិត្តអង្អែល សរុបទៅនាងចូលចិត្តនៃបរិត្យនឹងស្វាមី។

"តែពេលនេះអូនធ្វើខ្លួនធម្មតាហើយ"

"ច្បាស់ហើយ មែនទេ ?"

"ច្បាស់ហើយ តិអូនស្រឡាញ់បង បងក៏ស្រឡាញ់អូន អីចឹងហើយ អូន គ្មានហេតុផលអីត្រូវប្រឆាំងនឹងបងទៀតទេ"





Scanned by CamScanner

"ជាសំណាងរបស់បងមែនទេ ?"

"តែអូនក៏រឹងដាក់បងខ្លះតាមឱកាស តែធានាបានថាអូននឹងមិនរឹងទទឹងពេក បើមិនចាំបាច់"

រ៉ៃមសៀ ត្រួសប្បាយចិត្តនឹងពាក្យសន្យារបស់ភរិយាឬអត់។

"បើអូនរឹងពេក បងបានវ៉ៃអូននៅថ្ងៃណាមួយហើយ"

"បងហ៊ានវ៉ៃអូនឬ ?"

"អូនគិតថាបងមិនហ៊ាន ?"

"បើបងវ៉ៃអូន អូននឹងឈឺ"

នាងប្រមៀលថ្ពាល់នឹងដើមទ្រូងរឹងមាំ។ រ៉ៃមសៀ ឬហ៊ានវ៉ៃនាង ដែលនិយាយនេះ គ្រាន់តែគំរាមប៉ុណ្ណោះ បើឲ្យថើបនាង គេធ្វើបាន ដោយមិនចេះធុញទ្រាន់។

"ដឹងខ្លួនថាបងស្រឡាញ់ កុំធ្វើខ្លួនទំនើងពេក"

"បងមិនបានស្រឡាញ់អូនតែម្នាក់ឯងឯណា អូនក៏ស្រឡាញ់បងដែរ"

រ៉ៃមសៀ ក្រសោបមុខរបស់ភរិយា ថើបថ្ពាសរបស់នាងថ្នមៗ ហើយអូសទៅរកបបូរមាត់។ គេឈ្លក់វង្វេងនឹងភាពផ្អែមល្ហែមជាប់បបូរមាត់នេះ ចំណែកនាងក៏ជាប់ចិត្តនឹងភាពក្តៅគគុកជាប់បបូរមាត់របស់ស្វាមីដូចគ្នា។

"យើងទៅផ្ទះវិញទៅ"

មិនរង់ចាំឲ្យគេបបួល ការ៉ិន ក៏បបួលមុន ទើប រ៉ៃមសៀ យល់ព្រមដោយការលើកបីនាង ដើរចូលក្នុងប្រាសាទ។



រាងកាយនននលគករបស់កំលោះក្រមុំហក់ឱបគ្នា តម្រូវការរបស់ពួកគេដែលមានចំពោះគ្នា មិនធ្លាប់ថមថយ យូរៗទៅកាន់តែកើនកម្រិត ហើយក្រៅពីភាពក្តៅគគុក នៅមានភាពកក់ក្តៅ និងចំណងស្និតល្មួតរវាងពួកគេទៀត។

រ៉ៃមសៀ លើកពភរិយាជាទីស្រឡាញ់ ទើបត្រូវនាងលើកជើងកៀវត្រគាកបាវខ្សាច់ និងក្រសោបមុខសង្ហា ថើបបបូរមាត់ក្តៅ ដោយគេពនាង ដើរទៅរកគ្រែ។ ទោះមេឃងងឹត ឬភ្លឺស្វាង មិនមែនជារឿងសំខាន់សម្រាប់គូស្វាមីភរិយាដែលស្រឡាញ់គ្នាក្តៅគគុក។

អ្នកកំលោះមានតម្រូវការចំពោះភរិយា ដោយមិនកំណត់ពេលវេលា ឯនាងវិញ មានសេចក្តីសុខនឹងការផ្គាប់ចិត្តស្វាមី។ នាងបញ្ចុកគេទាល់តែឆ្អែតដើម្បីមិនឲ្យចាប់អារម្មណ៍ស្រីផ្សេង។

ពេលត្រូវស្វាមីដាក់នៅលើគ្រែ នាងក៏អូសតួទថយក្រោយ ផ្តួលខ្លួនដេកដោយកាយវិការសិចស៊ី មានចេតនាទាក់ទាញគេជាពិសេស ហើយសើចកក្អិចពេលគេហក់មករកដោយការស្រេកឃ្លាន ថើបជញ្ជក់ដើមទ្រូង ដែលនាងក៏ជួយសម្រួល ដោយការពើងទ្រូងទៅរក។

គេរវល់នឹងការញាក់ញីដើមទ្រូងទ្រលុកទ្រលន់ ច្រឡាច់ដោយអារម្មណ៍ក្តៅគគុក មាត់ក៏បឺតជញ្ជប់ ដោយ ការ៉ិន មិនខ្លាចស្បែកមានស្នាម ព្រោះវាត្រូវបិទបាំងដោយសម្លៀកបំពាក់ ទោះត្រូវថើបឲ្យមានស្នាមសព្វសាច់ ក៏មិនខ្វល់បើវាធ្វើឲ្យស្វាមីទទួលបានសេចក្តីសុខ។



"បងសម្លាញ់"



Scanned by CamScanner

នាងហៅគេដោយសំឡេងពីរោះ ដើម្បីផ្ញោចអារម្មណ៍របស់គេ ហើយជ្រែកម្រាមដៃ ច្រងសក់ក្រាស់ ពើងទ្រូងឲ្យគេថើបបានស្រួល។

"ព្រលឹងចិត្ត"

សម្ដីផ្អែមល្ហែមបែបនេះ មានតែនាងប៉ុណ្ណោះ ដែលមានសិទ្ធបានឮ។ នាងឈ្ងោកទៅថើបក្បាលរបស់គេ នាងស្រឡាញ់គេខ្លាំងណាស់ នៅជាមួយកាន់តែយូរ ក្ដីស្រឡាញ់កាន់តែកើនឡើង។

"បងសម្លាញ់ ថើបបន្តិចម៉ោ"

រ៉េមសៀ ងើបមករក ថើបបបូរមាត់ក្រពុំ និងឲ្យនាងឱបរឹត ឲ្យរាងកាយកកិតគ្នា ដើម្បីផ្ញោចអារម្មណ៍ស្រៀវស្រើបឲ្យដំណើរការបន្តជារឿយៗ។

នាងកេរអណ្ដាតរបស់ស្វាមី ថើប ដូចនេះជាលើកចុងក្រោយដែលបានថើបគ្នា ដែលពេលបានថើបគ្នា ពួកនាងតែងតែថើបបែបនេះជានិច្ច មិនលាក់ចិត្តស្នេហា ដែលមានចំពោះគ្នា បង្ហាញឲ្យគ្នាបានដឹង បានឃើញពីអារម្មណ៍ស្រេកឃ្លានដែលមានចំពោះគ្នា។

"ថើបផ្អែមដល់ហើយ" នាងថ្ពរដោកបបូរមាត់ក្រាស់ ហើយថើបជញ្ជក់ដោយមិនព្រមឲ្យចាញ់គេ។

"មានតែផ្អែមទេឬ?"

"ក្ដៅដែរ"

ពួកគេប្រសព្វភ្នែកគ្នា កែវភ្នែករបស់នាងឡើងគឃ្លើនដោយក្ដីស្រឡាញ់លម្អដោយការប្រាថ្នាដ៏ក្ដៅគគុកដែលមានចំពោះគេ។



"ថើបអូនឲ្យខ្លាំងៗ"

"នឹងថើបសព្វសាច់"

នាងមិនខ្លាចការគំរាមនេះ ថែមទាំងប្រែខ្លួន ផ្ដល់ភាពងាយស្រួលឲ្យ ហើយពេលគេថើបល្វែងមុខសព្វហើយ ក៏ប្រែខ្លួនឲ្យថើបល្វែងក្រោយទៀត។

"ស្អាតសព្វសាច់ ព្រលឹងចិត្ត"

កាអ៊ិន មានមោទនភាពនឹងការសរសើរដោយសំឡេងស្អកៗរបស់ស្វាមី នាងមើលថែខ្លួនឯង ផ្ដោតសំខាន់គ្រប់យ៉ាងនៅលើរាងកាយ ដើម្បីសេចក្ដីសុខរបស់គេជាពិសេស។

"ល្មៀយសព្វសាច់"

រ៉េមសៀ តាមទៅទ្រាបពីក្រោយនាង និងលូកដៃទាំងពីរទៅក្រសោបដើមទ្រូងណែនក្បុំ។ គេឈ្លក់វង្វេងនឹងវាខ្លាំងណាស់ ជាប់ចិត្តនឹងវា ត្រូវចាប់ ត្រូវថើបវារាល់ថ្ងៃ ដោយនាងក៏បានមិនហាមប្រាម គេចង់ថើបក៏ឲ្យថើប ចង់មើលនាងក៏ពើងទៅរក ជាការតបស្នងដែលគេចិត្តល្អឲ្យនាងសបភិង។

"ព្រលឹងចិត្តបង"

"រ៉េមសៀ...សម្លាញ់ចិត្តអូន"

នាងក្រឡាស់ខ្លួនឡើងទៅទ្រាបលើរាងកាយមាំមួន ថើបជញ្ជក់គេម្ដងឲ្យរាងកាយមាំមួនឡើងរឹងកំព្រឹស តែគេក៏ព្រមឲ្យកិរិយាដុតអារម្មណ៍ឲ្យពុះ។

"សម្លាញ់ចិត្តអូនសង្ហាលើសគេ" នាងថើបថ្ពាល់គ្រើមម្ដងហើយម្ដងទៀត។



"អូនក៏ស្អាតលើសគេ សម្រាប់បង"



Scanned by CamScanner

"អ៎ា..." សំឡេងថ្ងូចថ្ងូរឮតិចៗ។

រ៉ែមសៀ ឱបក្រសោបនាងឲ្យរាងកាយទាំងពីររលាយក្លាយជាសាច់មួយ បបូរមាត់នៃបនិត្យគ្នាដោយអារម្មណ៍ផ្អែមល្ហែម ជ្រាលជ្រៅ។ វាជាក្តីស្រឡាញ់ដែលគ្មានលក្ខខណ្ឌ ក្តីស្រឡាញ់ដែលបេះដូងពីរដួងមានចិត្តដូចគ្នាកំពុងតែរីក និងឱបក្រសោបដោយភាពកក់ក្តៅឲ្យប្រាសាទត្រេវត្រយ ចំណែកក្នុងបន្ទប់ដេករបស់គូស្វាមីភរិយានៅពេលនេះ កំពុងឱបក្រសោបដោយភាពក្តៅគគុក និងសំឡេងថ្ងូចថ្ងូរ ដែលឮរងំពេញមួយរាត្រី។



# សុភមង្គលស្នេហ៍

មុខក្រមួររបស់ រ៉ែមសៀ ធ្វើឲ្យព្រះនាងញញឹមពព្រាយយកចិត្តយកថ្លើមជាពិសេស។ នាងគ្មានចេតនាធ្វើឲ្យគេខឹង ឈុតរាត្រីវែង ពណ៌សំប៉ាញមួយនេះមិនសិចស៊ីពេក តែព្រោះនាងកំពុងមានផ្ទៃពោះ ទើបដើមទ្រូងធំជាងធម្មតាកដែលវៀលរាងជ្រៅ មើលឃើញគល់ទ្រូងច្បាស់។

វាមិនមែនជាឈុតសិចស៊ី មើលទៅគួរឲ្យស្អប់ តែព្រោះ រ៉ែមសៀ មិនចូលចិត្តឲ្យភរិយាបង្ហាញសាច់បង្ហាញឈាមពេកទើបនាងត្រូវញញឹមយកចិត្ត។ ការ៉ីន ផ្លាស់ឈុតមិនទាន់ ព្រោះពិធីជប់លៀងដល់ពេលត្រូវចាប់ផ្តើមហើយ។

នាងដើរមកឱប ធ្វើឲ្យស្វាមីដកដង្ហើមមិនពេញពោះ ពេលឈ្លោកមើលដើមទ្រូងទ្រលុកទ្រលន់ ដែលបៀតនឹងដើមទ្រូងហាប់ណែនដោយសាច់ដុំ។

"បងសម្លាញ់"

"អូនកំពុងពិសោធការអត់ធ្មត់របស់បងមែនទេ"

"អូនគ្មានចេតនាទេ"

នាងបបោសអង្អែលថ្ពាល់នឹងដើមទ្រូងសុទ្ធសាច់ដុំ។ រូបតម្លៃថ្លៃនៅលើដងខ្លួនពេលនេះ ធ្វើឲ្យសម្រស់របស់នាងកាន់តែលេចធ្លោនិងសិចស៊ីទាក់ទាញឲ្យស្វាមីប៉ិនហួងហែង ចង់ទុកនាងនៅតែក្នុងបន្ទប់។



"ច្បាស់ហើយ ?"

"អូនមានផ្ទៃពោះ ខ្លួនអូនដូចដើម តែទ្រូងអូនធំជាងមុន អូនគ្មានចេតនាឲ្យវាសិចស៊ីពិតមែន"

នាងបើបថ្ពាល់ត្រឹម ដើម្បីយកចិត្ត។ ហេតុផលដែលធ្វើឲ្យដើមទ្រូងនាងធំជាងមុន ព្រោះមានគេចូលរួមជួយធ្វើដែរ ហើយម៉េចក៏មកធ្វើមុខក្រមូវដាក់នាងបែបនេះ គឺមិនបានទេ។

"ធ្វើមុខក្រមូវ គិចកូនភ័យ"

វែមសៀ ឱបក្រសោបភរិយាខិនបើបសៀតផ្កា។ គេថ្នាក់ថ្នមនាងយ៉ាងនេះប្រហែលខឹងនាងបានយូរហើយ។ គេស្រឡាញ់ប្រពន្ធងប់ងល់ ធ្លាប់ប្រកែកយកងាប់យករស់ថា វែមសៀ ដាវ៉ៃហ៊ាណេស មិនខ្លាចប្រពន្ធ សូម្បីតែនៅចំពោះមុខ សិតិភ័ស ក៏ប្រកាសឲ្យដឹង។

'មនុស្សដូច វែមសៀ មិនខ្លាចប្រពន្ធវើយ!'

គេទើបតែនិយាយជាមួយ សិតិភ័ស កាលពីសប្តាហ៍មុន ព្រោះអាម្សៀនោះចោទថាគេជាមនុស្សខ្លាចប្រពន្ធ ពេលមករកនិងបបួលគេចេញទៅខាងក្រៅ។

'អី! ជឿក៏បាន ទៅបានហើយនៅ?'

'ទៅណា ត្រូវប្រាប់ព្រះនាងសិន'

នៅចំពោះ សិតិភ័ស គេត្រូវហៅភរិយាឲ្យពីរោះ ជាការផ្តល់កិត្តិយសឲ្យនាងនិងឲ្យតែឃើញស្នាមញញឹមចុងមាត់របស់វាពេលណា គេចង់តែដាល់។

'ភយការណ៍?'



'ភយការណ៍ស្អី គ្រាន់តែបង្ហារមិនឲ្យប្រពន្ធរអ៊ី'

'អូខេ ជឿហើយថាមិនបានខ្លាចប្រពន្ធមែន!'

គេនឹកដល់មិត្តភក្តិ ដែលត្រូវជួបគ្នានៅក្នុងពិធីជប់លៀងយប់នេះ។ សរុបទៅការមករបស់ សិតិភ័ស នៅថ្ងៃនោះដើម្បីមកបបួលគេទៅទទួលទានអាហារ ព្រោះវាធុញទ្រាន់នឹងទទួលទានអាហារម្នាក់ឯង គ្មានអ្នកណារាប់រកអញ្ជើញ ឯកាត្រូវរត់មករកគេ ថែមទាំងរករឿងចំអន់គេទៀត អាចង្រៃ។

"តោះទៅ ដើរឲ្យប្រយ័ត្នផង"

"អូនចាប់ដៃបង"

កាអ៊ិន ចាប់ដៃស្វាមី គេក៏ជួយឱបក្រសោប ទៅគោរពព្រះអង្គម្ចាស់ខាឡូម៉ាន់ ដែលធ្វើដំណើរមកពីក្រុង សេនថាម៉ារ៉ា មកធ្វើជាភ្ញៀវឲ្យពួកគេ នៅក្នុងពិធីជប់លៀងដើម្បីអបអរសាទរការមានផ្ទៃពោះរបស់ កាអ៊ិន។

"សួស្តីបងប្រុស"

នាងចូលទៅឱបបងប្រុស ដែលក្រៅពី ខាឡូម៉ាន់ ហើយ ឃែតទ្រិណាត្រីស៊្ទីណា និង ចាស្មីន ក៏មិនចូលរួមដែរ។

"ប្អូនសុខសប្បាយទេ"

"សុខសប្បាយណាស់"

"ចាញ់ឬអត់?"

"ចាញ់ខ្លះដែរ តែ វែមសៀ មើលថែប្អូនល្អណាស់"

ព្រះអង្គម្ចាស់ ខាឡូម៉ាន់ ឱនថើបថ្ពាសប្អូនស្រី ជូនពរនិងអបអរសាទរ



ហើយសោយរង្វង់។

"សួស្តី ចាស្មីន"

ពេលរាក់ទាក់បងប្រុសរួចរាល់ នាងក៏រាក់ទាក់មិត្តសម្លាញ់ បន្តដោយប្អូនស្រីទាំងពីរ បន្ទាប់មកស្វាមីភរិយាក៏រាក់ទាក់ដាក់ភ្ញៀវពន្លឺផ្សេងទៀត។

"រូបតឹងល្អទេ"

"តឹងល្អណាស់" នាងប្រាប់ស្វាមីឲ្យមានទំនុកចិត្ត ដែល វែមសៀ ក៏តាមមើលគ្រប់ពេល ជាពិសេសពេលនាងរាក់ទាក់ សីគីរ៉ាស ដែលទើបធ្វើដំណើរមកដល់ ដោយប្រុងប្រយ័ត្នមិនឲ្យមិត្តភក្តិឱបភរិយារបស់ខ្លួនយូរពេក។

"នេះប្អូនស្រីខ្ញុំវើយ"

វែមសៀ មិនខ្វល់ពីសម្តីរបស់មិត្តភក្តិ សីគីរ៉ាស ក៏ខ្ជិលមានបញ្ហា ម្យ៉ាងរាពណិតមនុស្សហ្នឹងហែងប្រពន្ធស្ទើរឆ្កួត ទើបដើរទៅរក ខាឡូម៉ាន់។

"ចង់ឲ្យកម្មវិធីឆាប់ចប់ណាស់" វែមសៀ រអ៊ូរទាំពេញកម្មវិធី និងប្រឹងអត់ធ្មត់ ហើយពេលចប់កម្មវិធី ក៏ឱបចង្កេះភរិយាជូនដំណើរភ្ញៀវពន្លឺ ចំណែកក្រុមគ្រួសារសម្រាកនៅទីនេះ ស្អែកទើបចេញដំណើរ។

បរិយាកាសនៅក្នុងប្រាសាទត្រេវើគ្រយ ត្រជាក់ស្រេង រដូវរងាមកដល់ ការ៉ុន ក៏ជិតដល់ពេលសម្រាលដែរ តែនាងនៅតែស្អាត ហើយពេលនេះកំពុងអង្គុយសណ្តូកជើងនៅលើគ្រែ ផ្អែកនឹងដើមទ្រូងមាំមួនដោយ វែមសៀ មានក្ងានាទីអានសៀវភៅឲ្យនាងនិងកូនក្នុងផ្ទៃស្តាប់។



កូនរបស់គេ ចូលចិត្តស្តាប់សំឡេងរបស់គេណាស់ ទើប ការ៉ុន និយាយថាកូនច្បាស់ជាដូចគេ ព្រោះពេលធាក់នាងម្តងៗ កម្លាំងច្រើនណាស់។

"កូនបម្រះទៀតហើយឬ" គេសួរពេលត្រូវនាងចាប់ដៃដាក់លើពោះធំ។

គេចាប់អារម្មណ៍ ភាពប្រែប្រួលរបស់ទារកនៅក្នុងផ្ទៃរបស់ភរិយាគ្រប់រឿង ហើយរំភើបញាប់ញ័រនឹងការបម្រះរបស់កូន។

"មានអារម្មណ៍ទេ"

"កូនធាក់ខ្លាំងបែបនេះ ឈឺអត់ ?"

"តិចតួច តែមានសេចក្តីសុខជាង"

វែមសៀ ឱបក្រសោបរាងកាយរបស់ភរិយា។ ពោះរបស់នាងធំណាស់ តែដៃជើងនៅតែស្រឡៅស្រឡូន និយាយរួមទៅនៅតែដូចដើម ធ្វើឲ្យគេចង់ឱបក្រសោបគ្រប់ពេលវេលា ហើយនាងជាស្ត្រីមានផ្ទៃពោះដែលស្អាតខ្លាំងណាស់ មុខមាត់សម្បុរសម្បុកស្រស់ស្អាត ប្រហែលមកពីសុខភាពរបស់នាងរាបញូនពីខាងក្នុងមកខាងក្រៅ។

គេឱនថើបថ្ពាល់រលោង ដាក់សៀវភៅចុះ ដើម្បីលើកដៃក្រសោបពោះ និងថើបថ្ពាល់ម្តងទៀត។

"ទឹកចិត្តរបស់កូន" នាងញញឹមពព្រាយ ពេលមានអារម្មណ៍ដល់ការបម្រះរបស់កូន។

វែមសៀ ធ្វើដំណើរទៅក្រុងសេនថាម៉ារ៉ា និងត្រូវស្នាក់នៅដំណាក់របស់ព្រះនាងមួយយប់ ទើបតែត្រឡប់មកវិញថ្ងៃនេះ ហើយចំណាយពេលពេញមួយ

ថ្ងៃនៅជាមួយភរិយា និងកូនក្នុងផ្ទៃ។

"ចាំចាំមករកកូនហើយ" នាងនិយាយពីរោះពិសាដាក់កូនក្នុងផ្ទៃ ហើយងាកទៅរកស្វាមី ធ្វើមាត់ស្រួចដាក់រង់ចាំឲ្យគេថើប។

"បងស្រឡាញ់អូន"

"អូនក៏ស្រឡាញ់បង"

ពួកគេប្រាប់គ្នាដោយវាចាផ្អែមល្ហែម។ អាកាសធាតុត្រជាក់ មិនបានធ្វើឲ្យបេះដូងត្រជាក់តាម។ រ៉េមសៀ កក់ក្ដៅបេះដូងណាស់ ក្រុមគ្រួសាររបស់គេកាន់តែមានសុភមង្គលតាំងពីពេលដែល ការ៉ិន មានផ្ទៃពោះ។ ភរិយានិងកូនជាខ្យល់ដង្ហើមរបស់គេ ដូច្នេះហើយសុំថ្នាក់ថ្នម មើលថែឲ្យបានល្អ ទាំងម្ដាយទាំងកូនលុះដង្ហើមចុងក្រោយរបស់ រ៉េមសៀ ជាវីរបុរស។៕

( ចប់ )